វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ
INSTITUTE OF BANKING & FINANCE

# ការផ្តល់ប្រាក់កម្ចី ប្រកបដោយ ទំនួលខុសត្រូវ

CERTIFICATION

RESPONSIBLE LENDING

អត្ថបទសិក្សា

វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជា រក្សាសិទ្ធិ © ឆ្នាំ ២០២២

**រក្សាសិទ្ធិគ្រប់យ៉ាង**។ គ្មានការផលិតឡើងវិញ ផ្ទេរ រក្សាទុក ឬប្រើប្រាស់ក្នុងមធ្យោបាយណាក៏ដោយ ឬតាមវិធីក្រាភិច អេឡិចត្រូនិក ឬមេកានិកផ្នែកណាមួយនៃស្នាដៃនេះ រួមទាំងការថតចម្លង ស្កេន ធ្វើទៅជាឌីជីថល ថតវីដេអូ ចែកចាយតាមគេហទំព័រ បណ្ដាញព័ត៌មាន ឬផ្ទុកព័ត៌មាន និងប្រព័ន្ធទាញយក ដោយពុំមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសំណាក់វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជាឡើយ។

ការបោះពុម្ពលើកទីមួយ

សេចក្ដីបដិសេធ៖ គ្រប់ឈ្មោះទាំងអស់ ទោះឈ្មោះបុគ្គល ឬឈ្មោះស្ថាប័នគឺមិនបានសំដៅលើឈ្មោះពិតរបស់បុគ្គលណាមួយឡើយ ហើយដូច្នេះពុំគួរត្រូវបានគេយកទៅតំណាងឲ្យបុគ្គលពិតប្រាកដណាមួយ ឬកាលៈទេសៈជីវិតរបស់ពួកគាត់ឡើយ។ គ្រប់ឈ្មោះទាំងអស់មាននៅក្នុងសៀវភៅនេះ គឺសុទ្ធតែជាឈ្មោះប្រឌិត និងមានគោលបំណងដើម្បីបង្កើតជាបរិបទ និងសេណារីយ៉ូដើម្បីឲ្យឆាប់យល់តែប៉ុណ្ណោះ។

ISBN-9: 789-9249-2699-3

# សេចក្តីថ្លែងអំណរគុណ

អត្ថបទសិក្សានេះ ត្រូវបានរៀបរៀងឡើងជាពិសេសសម្រាប់វិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះ វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (IBF) កម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកផ្តួចផ្តើមទាំងអស់ដែលបានជួយបង្កើតឯកសារនេះឡើង។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារជាតិនៃកម្ពុជា (NBC) អ្នកនិពន្ធ និងអ្នកត្រួតពិនិត្យដែលមានរាយនាមដូចខាងក្រោម ដែលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងនិងចំណាយពេលវេលាផ្ទាល់ខ្លួនដើម្បីសរសេរនិងពិនិត្យ លើក្របខណ្ឌសមត្ថភាព សំណួរប្រលង និងអត្ថបទសិក្សាសម្រាប់វិញ្ញាបនបត្រនេះ។

**អ្នកនិពន្ធ (តាមលំដាប់លំដោយនៃតួអក្សរភាសាខ្មែរ)**

- **ជូ គឹមហុង** អនុប្រធានផ្នែក នៃអគ្គនាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា
- **ឈ រតនា** អនុប្រធានផ្នែក នៃអគ្គនាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា
- **ដួង ប៉ាស៊ីធីតា** អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា
- **លី ប៊ុនរឹទ្ធិ** នាយកប្រតិបត្តិប្រតិបត្តិការ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន
- **ស៊ូ សុខសង្ហារ** នាយិការងនាយកដ្ឋានសេវាកម្មធនាគារផ្នែកសាជីវកម្ម នៃធនាគារ ជេត្រាស់ រ៉ូយ៉ាល់
- **ឡេង សេងឡុន** នាយកប្រតិបត្តិប្រតិបត្តិការនៃ ធនាគារព្រីនស៍

**អ្នកត្រួតពិនិត្យគោល (តាមលំដាប់លំដោយនៃតួអក្សរភាសាខ្មែរ)**

- **តាន់ នាងសំបូរ** នាយក នាយកដ្ឋានវាយតម្លៃ និង អនុម័តឥណទាន នៃធនាគារស្ថាបនា
- **ប៉ែន វណ្ណដារ៉ុង** នាយកឥណទាន នៃធនាគារហុងលីអុង
- **ម៉ែន ភក្តី** ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា

**អ្នកចូលរួមត្រួតពិនិត្យមកពីវិស័យធនាគារ និងហរិញ្ញវត្ថុ (តាមលំដាប់លំដោយនៃតួអក្សរភាសាខ្មែរ)**

- **ជាង វណ្ណា** នាយកប្រតិបត្តិបណ្តុះបណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ
- **ញ៉ែម ចំរើន** អ្នកឯកទេសជាន់ខ្ពស់អភិវឌ្ឍគោលការណ៍ឥណទាន នៃធនាគារអេស៊ីលីដា
- **ផេនដេ ប៊ីប៊ូ** នាយកឥណទាន នៃធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ (ABA)

- **វ៉ាជេស កុមារបារូ** ប្រធាននាយកប្រតិបត្តិគ្រប់គ្រងហានិភ័យនៃធនាគារប្រៃសណីយ៍កម្ពុជា
- **លុយ ត្រឹន** អ្នកឯកទេសជាន់ខ្ពស់អភិវឌ្ឍគោលការណ៍ឥណទាន នៃធនាគារអេស៊ីលីដា
- **សឹង ភន** នាយកប្រតិបត្តិឥណទាន នៃធនាគារអេស៊ីលីដា
- **សុខ វឿន** ប្រធាននាយកប្រតិបត្តិ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី
- **សួន ពិសី** ប្រធាននាយកប្រតិបត្តិអាជីវកម្ម នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ
- **អ៊ុក កុសល** នាយកប្រតិបត្តិច្បាប់ និងប្រតិបត្តិតាម នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាគមធនាគារនៅកម្ពុជា (ABC) និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) ដែលបន្តគាំទ្រកិច្ចផ្តួចផ្តើមនេះ។ យើងខ្ញុំបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីទទួលស្គាល់ប្រភពព័ត៌មានទាំងអស់ដែលបានដាក់ចូលក្នុងសៀវភៅនេះ។ ប្រសិនបើមានការលើកឡើងអំពីប្រភពព័ត៌មានមិនបានត្រឹមត្រូវ ឬខ្វះខាតត្រង់ចំណុចណាមួយ សូមជូនដំណឹងដល់យើងខ្ញុំ ហើយយើងខ្ញុំនឹងធ្វើការកែតម្រូវភ្លាមៗ។

វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជានឹងទទួលខុសត្រូវលើរាល់កំហុសឆ្គង អសុក្រឹតភាព និងបញ្ហាផ្សេងទៀតដែលអាចកើតឡើងជាយថាហេតុ។ ប្រសិនបើលោកអ្នកមានបំណងផ្តល់ជាមតិត្រឡប់មកយើងខ្ញុំ ឬរាយការណ៍ពីបញ្ហាណាមួយទាក់ទងនឹងឯកសារនេះ សូមផ្ញើអ៊ីមែលមកកាន់ cm@ibfkh.org។ វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជា នឹងចាត់វិធានការសមស្របភ្លាមៗ ដើម្បីកែតម្រូវបញ្ហានោះ។

# អក្សរកាត់

| | |
|---|---|
| ABC | ៖ Association of Banks in Cambodia (សមាគមធនាគារនៅកម្ពុជា) |
| BCBS | ៖ Basel Committee on Banking Supervision (គណៈកម្មាធិការទីក្រុងបាសែលស្តីពីការត្រួតពិនិត្យធនាគារ) |
| BCPs | ៖ Basel Core Principles (គោលការណ៍គ្រឹះបាសែល) |
| BFI | ៖ Banking and Financial Institution (គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ) |
| BU | ៖ Business Unit (ផ្នែកអាជីវកម្ម) |
| CBC | ៖ Credit Bureau Cambodia (ការិយាល័យឥណទានកម្ពុជា) |
| CCMF | ៖ Consumer Complaint Management Framework (ក្របខណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន) |
| CMA | ៖ Cambodian Microfinance Association (សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា) |
| CO | ៖ Credit Officer (មន្ត្រីឥណទាន) |
| CSR | ៖ Corporate Social Responsibilities (កម្មវិធីទំនួលខុសត្រូវសង្គម) |
| ESG | ៖ Environmental, Social, and Governance (បរិស្ថាន សង្គម និងអភិបាលកិច្ច) |
| EMI | ៖ Equal Monthly Installment (ការបង់រំលស់ថេរប្រចាំខែ) |
| EMPR | ៖ Equal Monthly Principal Repayment (ការបង់រំលស់ប្រាក់ដើមថេរប្រចាំខែ) |
| FinTech | ៖ Financial Technology (បច្ចេកវិទ្យាហិរញ្ញវត្ថុ) |
| GDP | ៖ Gross Domestic Product (ផលិតផលក្នុងស្រុកសរុប) |
| GFC | ៖ Global Financial Crisis (វិបត្តិហិរញ្ញវត្ថុសកល) |
| IPO | ៖ Initial Public Offering (ការបោះផ្សាយមូលបត្រលក់ជាលើកដំបូង) |
| KYC | ៖ Know-Your-Customers (ការស្គាល់អតិថិជនរបស់អ្នក) |
| LG | ៖ Lending Guidelines (គោលការណ៍ណែនាំកម្ចី) |
| LPCO | ៖ Liquidity Providing Collateralized Operation (ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា) |
| MDI | ៖ Microfinance Deposit-Taking Institution (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ) |
| MEF | ៖ Ministry of Economy and Finance (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) |
| MFI | ៖ Microfinance Institutions (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) |
| MSMEs | ៖ Micro, Small, and Medium Enterprises (មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម) |

| | |
|---|---|
| NBC | ៖ National Bank of Cambodia (ធនាគារជាតិនៃកម្ពុជា) |
| NBFSA | ៖ Non-Banking Financial Services Authorities (អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ) |
| NFIS | ៖ National Financial Inclusion Strategy (យុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុជាតិ) |
| NGO | ៖ Non-Governmental Organization (អង្គការមិនមែនរដ្ឋាភិបាល) |
| NPL | ៖ Non-Performing Loan (កម្ចីមិនដំណើរការ) |
| RCI | ៖ Rural Credit Institution (គ្រឹះស្ថានឥណទានជនបទ) |
| P2P | ៖ Peer-to-Peer (គំរូប្រាក់កម្ចីរវាងបុគ្គល និងបុគ្គល) |
| SME | ៖ Small and Medium Enterprises (សហគ្រាសធុនតូច និងមធ្យម) |
| UN | ៖ United Nations (អង្គការសហប្រជាជាតិ) |

# សេចក្តីផ្តើម

វិស័យធនាគារ និងហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់កំណើនសេដ្ឋកិច្ច និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។ ដូច្នេះហើយ វាជាទំនួលខុសត្រូវរបស់យើងក្នុងការធានាថាផលប្រយោជន៍អតិថិជនរបស់យើង ជាចំណុចអាទិភាព ដើម្បីការពារពួកគាត់ និងផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុរបស់ពួកគាត់។

ដូច្នេះហើយ ទើបបានជាសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា តាមរយៈការងារស្ម័គ្រចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុ ដោយសហការជាមួយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ បានផ្តួចផ្តើមឱ្យមានកម្មវិធីសិក្សាថ្នាក់ "វិញ្ញាបនបត្រស្តីពីការផ្តល់កម្ចីប្រកបដោយទំនួលខុសត្រូវ" នេះឡើង ដើម្បីឱ្យបុគ្គលិកដែលធ្វើការដោយផ្ទាល់ជាមួយអតិថិជន រួមមាន បុគ្គលិកផ្តល់ព័ត៌មានឥណទាន បុគ្គលិកគ្រប់គ្រងឥណទាន និងបុគ្គលិកអនុម័ត និងពិនិត្យតាមដានឥណទាន បានយល់ច្បាស់ថាតើពួកគេត្រូវធ្វើដូចម្តេចដើម្បីអាចអនុវត្តការងារទៅបានប្រកបដោយក្រមសីលធម៌ចំពោះភាគីពាក់ព័ន្ធសំខាន់ៗ ដែលជាអតិថិជនរបស់ខ្លួន។

ខ្ញុំជឿថាកម្មវិធីសិក្សាថ្នាក់វិញ្ញាបនបត្រនេះ គឺជាកត្តាសំខាន់មួយ ដើម្បីកសាងនិរន្តរភាពរយៈពេលវែងរបស់យើងសម្រាប់ទាំងអតិថិជនផង និងគ្រឹះស្ថានហិរញ្ញវត្ថុផង។ ជាមួយគ្នានេះដែរ យើងនឹងរីកចម្រើនជាមួយគ្នាប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ។

លោក **គា បូរាណ**

ប្រធានគណកម្មាធិការបរិយាបន្នហិរញ្ញវត្ថុ (ឆ្នាំ២០២០ - ២០២១)

# មាតិកា

**ផ្នែក ក៖ ស្វែងយល់ពីប្រវត្តិវិស័យធនាគារ និងតួនាទីរបស់វិស័យនេះនៅក្នុងសង្គម** .. 11

**ក១ ៖ រៀបរាប់អំពីប្រវត្តិវិស័យធនាគារកម្ពុជា និងការវិវត្តរបស់វិស័យនេះ** .......... 11

ក១.១. សម័យអាណានិគមនិយមបារាំង (ឆ្នាំ១៨៦៣-១៩៥៣) .......................................... 11

ក១.២. សម័យសង្គមរាស្ត្រនិយម (ឆ្នាំ១៩៥៣-១៩៧០) .................................................. 11

ក១.៣. សម័យសាធារណរដ្ឋខ្មែរ (ឆ្នាំ១៩៧០-១៩៧៥) ..................................................... 12

ក១.៤. សម័យខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩) ............................................................. 12

ក១.៥. សាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម័យរដ្ឋកម្ពុជា (ឆ្នាំ១៩៧៩-១៩៩៣) .......... 12

ក១.៦. កម្ពុជាសម័យទំនើប (ឆ្នាំ១៩៩៣- បច្ចុប្បន្ន) ......................................................... 13

**ក២. ពន្យល់អំពីគោលបំណងផ្នែកសង្គមរបស់ធនាគារ** ............................................ 15

**ក៣. រៀបរាប់អំពីមូលដ្ឋានគ្រឹះក្នុងការកសាង និងការថែរក្សាទំនុកចិត្តមកលើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** ......................................................................................... 17

**ក៤. វិភាគការប្រព្រឹត្តមិនត្រឹមត្រូវផ្នែកហិរញ្ញវត្ថុបច្ចុប្បន្ន** ............................................ 21

**ផ្នែក ខ៖ វាយតម្លៃលើក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ នៅក្នុងការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ** ....................................................................................................... 25

**ខ១. ពន្យល់អំពីភាពចាំបាច់នៃបទប្បញ្ញត្តិនៅក្នុងប្រព័ន្ធធនាគារ** ................................... 25

ខ១.១. លក្ខណៈផុយស្រួយនៅក្នុងប្រព័ន្ធធនាគារ .......................................................... 26

ខ១.២. ភាពស្មុគស្មាញក្នុងប្រព័ន្ធធនាគារ ................................................................... 28

**ខ២. ពណ៌នាអំពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជា និងនិយ័តករអន្តរជាតិ** ......................... 31

ខ២.១. ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ........................................... 31

ខ២.២. ធនាគារជាតិនៃកម្ពុជា (NBC) ........................................................................... 32

ខ២.៣. គណកម្មាធិការបាសែលសម្រាប់ការត្រួតពិនិត្យធនាគារ ....................................... 34

**ខ៣. ពណ៌នាអំពីច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងការការពារអ្នកប្រើប្រាស់នៅកម្ពុជា** ....................................................................................................... 36

ខ៣.១. ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ................................................................. 36

ខ៣.២. ប្រកាសស្តីពីតម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ....................................................................................................... 37

ខ៣.៣. ប្រកាសស្តីពីការកំណត់ពិតានអត្រាការប្រាក់ ...................................................... 38

ខ៣.៤. ប្រកាសស្តីពីការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ .. 38

**ខ៤. វាយតម្លៃផលប៉ះពាល់របស់បទប្បញ្ញត្តិនានាលើធនាគារិកកំពុងធ្វើប្រតិបត្តិការ** ....................................................................................................... 45

**ផ្នែក គ៖ អនុវត្តគោលការណ៍ក្រមសីលធម៌ និងគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច** ....................................................................................................... 52

**គ១. អនុវត្តក្រមសីលធម៌នៅក្នុងការសម្រេចចិត្តបុគ្គល** ........ 53
គ១.១. អភិវឌ្ឍឥរិយាបថផ្ទាល់ខ្លួនប្រកបដោយក្រមសីលធម៌ ........ 53
គ១.២. ពន្យល់អំពីទ្វេគ្រោះក្រមសីលធម៌ និងទំនាស់ផលប្រយោជន៍ ........ 57
**គ២. អនុវត្តក្រមសីលធម៌ក្នុងអាជីវកម្ម** ........ 62
គ២.១.កំណត់និយមន័យនៃក្រមសីលធម៌និងស្វែងយល់ពីសារៈសំខាន់របស់វានៅក្នុងវិស័យធនាគារ ........ 62
គ២.២. ក្រមសីលធម៌ក្នុងវិស័យធនាគារ និង ការអនុវត្តគោលការណ៍ក្រមសីលធម៌សំខាន់ៗក្នុងវិស័យធនាគារ ........ 67
**គ៣. អនុវត្ត គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ក្នុងអាជីវកម្ម** ........ 69
គ៣.១. និយមន័យនៃ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ........ 69
គ៣.២. ភាពពាក់ព័ន្ធ និងសារៈសំខាន់នៃ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ចក្នុងវិស័យធនាគារ ........ 71
គ៣.៣.ការអនុវត្ត និងការដាក់បញ្ចូល គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ទៅក្នុងយុទ្ធសាស្ត្ររបស់ធនាគារ ........ 74

**ផ្នែក ឃ៖ ការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ** ........ 78

**ឃ១. ផ្តល់ប្រាក់កម្ចីប្រកបដោយក្រមសីលធម៌** ........ 78
ឃ១.១. ផលិតផល និងសេវាកម្មកម្ចីតាមទីផ្សារ ........ 78
ឃ១.២. ណែនាំប្រាប់អតិថិជនអំពីផលិតផលកម្ចីត្រឹមត្រូវ ........ 85
ឃ១.៣. វាយតម្លៃសំណើប្រាក់កម្ចី ........ 94
ឃ១.៤. ការអនុម័តឥណទាន ........ 106
ឃ១.៥. គ្រប់គ្រងឯកសារឥណទាន ........ 107
ឃ១.៦. ការរាយការណ៍ជូនការិយាល័យឥណទានកម្ពុជា (CBC) ........ 110
**ឃ២. តាមដានផលបត្រឥណទាន** ( Credit Portfolio ) **ដោយក្រមសីលធម៌** ........ 112
ឃ២.១. ការតាមដានឥណទាន ........ 115
ឃ២.២. តាមដានឥណទានហួសកាលកំណត់សង ........ 119
ឃ២.៣. កំណត់រកសញ្ញាព្រមានដំបូងនិងឆ្លើយតបចំពោះភាពមិនប្រក្រតីនៃឥណទាន ........ 124
ឃ២.៤. គាំទ្រអតិថិជនដោះស្រាយឥណទានហួសកាលកំណត់សង ........ 129
ឃ២.៥. ទប់ស្កាត់បំណុលវណ្ឌក ........ 139
ឃ២.៦. គោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន (LG) ........ 142
ឃ២.៧. របាយការណ៍របស់ការិយាល័យឥណទានកម្ពុជាអំពីសកម្មភាពអនុលោមតាមគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន ........ 144
**ឃ៣. ស្តារឡើងវិញនូវឥណទានមិនដំណើរការ** ( NPL ) **ប្រកបដោយសីលធម៌** ........ 152
ឃ.៣.១. តើអ្វីទៅគឺជាឥណទានមិនដំណើរការ? ........ 152
ឃ.៣.២. រៀបចំឥណទានមិនដំណើរការឡើងវិញ (NPL) ........ 154

**ចម្លើយសំណួរឆ្លុះបញ្ចាំង ........................................................................................ 157**
ឯកសារយោង ........................................................................................................ 169

# ផ្នែក ក៖ ស្វែងយល់ពីប្រវត្តិវិស័យធនាគារ និងតួនាទីរបស់វិស័យនេះនៅក្នុងសង្គម

## ក១ ៖ រៀបរាប់អំពីប្រវត្តិវិស័យធនាគារកម្ពុជា និងការវិវត្តរបស់វិស័យនេះ[1]

### ក១.១. សម័យអាណានិគមនិយមបារាំង (ឆ្នាំ១៨៦៣-១៩៥៣)

ប្រព័ន្ធធនាគារកម្ពុជាបានឆ្លងកាត់នូវប្រវត្តិដ៏ជូរចត់ផង និងល្អគួរឱ្យកត់សម្គាល់ផង។ ក្នុងសម័យអាណានិគមនិយមបារាំង បារាំងបានធ្វើទំនើបកម្មលើវិស័យដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធ និងកែលម្អលើវិស័យសុខាភិបាល វិស័យអប់រំ ក៏ដូចជាការដាក់ឲ្យប្រើប្រាស់នូវរូបិយវត្ថុនិងប្រព័ន្ធធនាគារនៅកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាពុំមានអធិបតេយ្យភាពក្នុងការបំពេញតួនាទីរបស់ធនាគារកណ្តាល និងគ្រប់គ្រងប្រព័ន្ធធនាគារដោយខ្លួនឯងឡើយ។ ប្រាក់ពីញ៉ាស់ (Piastres) ដែលត្រូវបានបោះពុម្ពដោយវិទ្យាស្ថាន Institute d'Émission បានដើរតួនាទីយ៉ាងសំខាន់សម្រាប់ធ្វើជាមធ្យោបាយនៃការទូទាត់ប្រាក់នៅប្រទេសកម្ពុជា ឡាវ និងវៀតណាម។

### ក១.២. សម័យសង្គមរាស្ត្រនិយម (ឆ្នាំ១៩៥៣-១៩៧០)

ក្នុងឆ្នាំ១៩៥៣ បើទោះបីជាប្រទេសកម្ពុជាបានប្រកាសឯករាជ្យរបស់ខ្លួនពីប្រទេសបារាំងយ៉ាងណាក្តី កម្ពុជានៅតែត្រូវការពេលជាងមួយឆ្នាំទៀត ដើម្បីទទួលបានអធិបតេយ្យភាពពេញលេញលើវិស័យសេដ្ឋកិច្ច និងរូបិយវត្ថុ។ ធនាគារកណ្តាលរបស់កម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ ដោយមានឈ្មោះថា ធនាគារជាតិនៃកម្ពុជា ដើម្បីបំពេញតួនាទីជាអាជ្ញាធររូបិយវត្ថុ។ បន្ទាប់មកនៅក្នុងខែកញ្ញា ឆ្នាំ១៩៥៥ រូបិយវត្ថុជាតិ"ប្រាក់រៀលខ្មែរ (KHR)" ត្រូវបានបោះផ្សាយនិងដាក់ឱ្យចរាចរណ៍ដោយជោគជ័យ ជំនួសឱ្យរូបិយប័ណ្ណ ប្រាក់ពីញ៉ាស់ (Piastres) វិញ។ តាមរយ:ការបង្កើត ធនាគារជាតិនៃកម្ពុជា និងការដាក់ឱ្យចរាចរណ៍ប្រាក់រៀល ធនាគារជាតិនៃកម្ពុជាទទួលបានស្វ័យភាពក្នុងការកំណត់តម្លៃ និងបរិមាណប្រាក់រៀលដែលចរាចរ ព្រមទាំងបានធ្វើអន្តរាគមន៍លើទីផ្សារហិរញ្ញវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃ។ អធិបតេយ្យភាពក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងរូបិយវត្ថុបានធ្វើទំនើបកម្មគ្រប់វិស័យសំខាន់ៗនៅក្នុងសេដ្ឋកិច្ច ដែលរួមចំណែកដល់កំណើនផលិតផលក្នុងស្រុកសរុប (GDP) ក្នុងរង្វង់អត្រា ៧% ក្នុងមួយឆ្នាំចាប់ពីឆ្នាំ១៩៥៣ ដល់ ឆ្នាំ១៩៦៣។

នៅឆ្នាំ១៩៦៣ រដ្ឋាភិបាលបានសម្រេចចិត្តធ្វើជាតូបនីយកម្មពាណិជ្ជកម្មបរទេស និងវិស័យធនាគារ។ នេះគឺជាកំណែទម្រង់ដ៏ធំមួយនៅក្នុងប្រព័ន្ធធនាគារ ខណ:ដែលធនាគារជាតិនៃកម្ពុជា

[1] This section is written based on the archives and displays at Sosoro – Preah Srey Icanavrman Museum.

បានក្លាយជាស្ថាប័នពាក់កណ្តាលស្វយ័ត។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឯកជនក្នុងស្រុក និងបរទេស ត្រូវបានបិទទ្វារ ហើយមានតែគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរបស់រដ្ឋប៉ុណ្ណោះទេ ដែលបន្តមានប្រតិបត្តិការ។ ជាលទ្ធផល ដើមទុនត្រូវបានហូរចេញទៅបរទេសជាបន្តបន្ទាប់ ហើយធ្វើឱ្យហិរញ្ញប្បទានពុំមានគ្រប់គ្រាន់ ជាពិសេសសម្រាប់វិស័យកសិកម្មនោះទេ។ ទន្ទឹមនេះ បញ្ហាវិសមភាពរវាងជនបទនិងទីក្រុងកាន់តែរីកធំឡើងៗ។ បញ្ហាទាំងអស់នេះបានរាំងរាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងបានបង្កនូវផលប៉ះពាល់លើការនាំចេញស្រូវ អង្ករដែលជាប្រភពចំណូលយ៉ាងធំរបស់រដ្ឋាភិបាល។ ដោយសារពុំមានជម្រើសអ្វីផ្សេងទៀតនោះធនាគារជាតិនៃកម្ពុជា បានបង្ខំចិត្តបោះពុម្ពរូបិយវត្ថុបន្ថែមដើម្បីទ្រទ្រង់ដល់ការចំណាយរបស់រដ្ឋ ដែលចេះតែកើនឡើងជាបន្តបន្ទាប់។ ការសម្រេចចិត្តបែបនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងទៅលើតម្លៃប្រាក់រៀល ហើយបានកាត់បន្ថយទំនុកចិត្តរបស់សាធារណជនមកលើរូបិយវត្ថុជាតិ។

### ក១.៣. សម័យសាធារណរដ្ឋខ្មែរ (ឆ្នាំ១៩៧០-១៩៧៥)

ក្នុងឆ្នាំ១៩៧០រដ្ឋាភិបាលសាធារណរដ្ឋខ្មែរគឺជាអ្នកគ្រប់គ្រងប្រទេស។បើទោះបីជារដ្ឋាភិបាលនេះបានសម្រេចចិត្តវិលទៅរកសេដ្ឋកិច្ចទីផ្សារសេរីយ៉ាងណាក្តី ដំណើរការប្រែក្លាយពីការធ្វើជាតូបនីយកម្មទៅជាឯកជនភាវូបនីយកម្ម និងសេរីភាវូបនីយកម្ម មានភាពយឺតយ៉ាវខ្លាំងសម្រាប់កែលម្អ និងសង្គ្រោះសេដ្ឋកិច្ចរបស់ប្រទេស។ គោលនយោបាយរូបិយវត្ថុ ពុំមានប្រសិទ្ធភាពគួបផ្សំនឹងលំហូរចូលដោយផ្ទាល់នៃប្រាក់ដុល្លារអាមេរិកមកក្នុងសង្គមកម្ពុជាផងនោះ ធនាគារជាតិនៃកម្ពុជាលែងអាចគ្រប់គ្រងនូវការធ្លាក់ចុះតម្លៃប្រាក់រៀលបានតទៅទៀតឡើយ។

### ក១.៤. សម័យខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩)

ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានឡើងកាន់អំណាច។ប្រជាជនប្រមាណបីលាននាក់ត្រូវបានសម្លាប់ ឬស្លាប់ដោយសារការអត់ឃ្លានត្រឹមតែរយៈពេលបីឆ្នាំប៉ុណ្ណោះ។ ប្រព័ន្ធធនាគារទាំងមូលនិងរូបិយវត្ថុជាតិត្រូវបានបំផ្លាញ។ ក្នុងរបបនេះ រាល់សកម្មភាពសេដ្ឋកិច្ចទាំងអស់ ត្រូវបានបោះបង់ចោលគ្មានការធ្វើពាណិជ្ជកម្ម គ្មានទីផ្សារ និងគ្មានរូបិយវត្ថុនៅលើទីផ្សារ ហើយធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វារទាំងស្រុងតែម្តងនៅពេលនោះ។

### ក១.៥. សាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម័យរដ្ឋកម្ពុជា (ឆ្នាំ១៩៧៩-១៩៩៣)

ក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំក្នុងឆ្នាំ១៩៧៩ ធនាគារកណ្តាលរបស់កម្ពុជាត្រូវបានបង្កើតឡើងវិញហើយប្តូរឈ្មោះទៅជា "ធនាគារជាតិនៃប្រជាជនកម្ពុជា" នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩។បន្ទាប់មក ក៏ត្រូវបានផ្លាស់ប្តូរឈ្មោះថ្មីទៅជា "ធនាគារជាតិនៃកម្ពុជា" (NBC) វិញ

ក្នុងឆ្នាំ១៩៩២។រូបិយវត្ថុជាតិ "រៀលខ្មែរ" ត្រូវបានបោះផ្សាយដាក់ឱ្យចរាចរណ៍ឡើងវិញនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ដើម្បីសម្រួលដល់ការទូទាត់នៅលើទីផ្សារ និងការបើកប្រាក់បៀវត្សរ៍ជូនដល់មន្ត្រីរាជការសាធារណៈ។ ប្រព័ន្ធធនាគារដែលបានបង្កើតឡើងវិញនេះ ជាប្រព័ន្ធធនាគារមួយថ្នាក់ដែលក្នុងនោះ ធនាគារជាតិនៃកម្ពុជា មានតួនាទីជាធនាគារកណ្តាលផង ធនាគារពាណិជ្ជផង និងជាធនាគារអភិវឌ្ឍផង។ ធនាគារជាតិនៃកម្ពុជា បានដើរតួនាទីជាអាជ្ញាធររូបិយវត្ថុ និងជារតនាគារជាតិក៏ដូចជាផ្តល់ផលិតផល និងសេវាធនាគារផ្សេងៗ ដូចជាផ្តល់ប្រាក់កម្ចី ទទួលប្រាក់បញ្ញើ និងប្រព័ន្ធទូទាត់ផ្សេងៗទៀតផងដែរ។

ទោះបីជាយ៉ាងណា នៅក្នុងដំណាក់កាលដំបូង ការអភិវឌ្ឍប្រព័ន្ធធនាគារពិតជាមានការលំបាកខ្លាំងណាស់ ដោយសារតែកង្វះធនធានបញ្ញវន្ត និងហិរញ្ញវត្ថុ។ ជាងនេះទៅទៀត ដោយសារតែបទពិសោធដ៏ជូរចត់ពីមុនមក ប្រជាជនកម្ពុជាបានបាត់ទំនុកចិត្តមកលើរូបិយវត្ថុជាតិ និងប្រព័ន្ធធនាគាររបស់ខ្លួនទៅហើយ។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ប្រតិបត្តិការក្នុងស្រុកភាគច្រើនបំផុត គឺផ្អែកលើប្រព័ន្ធដោះដូរគ្នា (ដូចជាការដោះដូរជាទំនិញ និងសេវាកម្ម ជាថ្នូរនឹងការទទួលបានទំនិញ និងសេវាកម្មផ្សេងទៀត) ហើយមាសបានក្លាយទៅជាទំនិញមួយសម្រាប់ទូទាត់ប្រតិបត្តិការនិងការរក្សាទុក។[2] លើសពីនេះទៅទៀត លំហូរចូលយ៉ាងច្រើននូវប្រាក់ដុល្លារអាមេរិក មកក្នុងប្រទេសតាមរយៈជំនួយរបស់អង្គការសហប្រជាជាតិ (United Nation, UN) និងអង្គការមិនមែនរដ្ឋាភិបាលបរទេសផ្សេងទៀត នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ និង ការចាប់ផ្តើមកំណែទម្រង់ជាសេដ្ឋកិច្ចទីផ្សារ បានបង្កើតឱ្យមានអតិផរណាលើសលុប (hyperinflation) និងការធ្លាក់ថ្លៃប្រាក់រៀលខ្មែរយ៉ាងគំហុក។[3] ទាំងអស់នេះហើយ ដែលជាមូលហេតុចម្បង ក្នុងការប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដុល្លាររូបនីយកម្ម។

### ក១.៦. កម្ពុជាសម័យទំនើប (ឆ្នាំ១៩៩៣- បច្ចុប្បន្ន)

ការបោះឆ្នោតជាតិលើកដំបូងក្នុងឆ្នាំ១៩៩៣ បានប្រែក្លាយរបបនយោបាយកម្ពុជា ទៅជារបបប្រជាធិបតេយ្យ ហើយសេដ្ឋកិច្ចកម្ពុជាត្រូវបានផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចទីផ្សារ។ បន្ទាប់មកប្រព័ន្ធធនាគារត្រូវបានប្រែក្លាយទៅជាប្រព័ន្ធធនាគារពីរថ្នាក់នៅចុងទសវត្សរ៍ឆ្នាំ១៩៩០ ដែលក្នុងនោះមុខងាររបស់ធនាគារកណ្តាលនិងធនាគារឯកជនត្រូវបានបែងចែកដាច់ពីគ្នា។ ដើម្បីគាំទ្រដល់ការកំណែទម្រង់នេះ ធនាគារជាតិនៃកម្ពុជា បានកែលម្អក្របខណ្ឌច្បាប់របស់ខ្លួនដើម្បីកំណត់ឡើងវិញនូវតួនាទីរបស់ធនាគារកណ្តាល និងលើកកម្ពស់រចនាសម្ព័ន្ធហិរញ្ញវត្ថុដែលមានភាពរឹងមាំ។[4]

[2] (Duma, 2011)
[3] (Tal & Dabadie, 2007)
[4] (Chun, Zhang, Sharma, & Hsu, 2001)

អំឡុងពេលកំណែទម្រង់ដ៏សំខាន់នេះ ប្រព័ន្ធធនាគារទាំងមូលត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ និងត្រូវបានពង្រឹងថែមទៀត ហើយលក្ខខណ្ឌតម្រូវសម្រាប់ដើមទុនអប្បបរមាក៏ត្រូវបានដំឡើងផងដែរ។ ការអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិនានាក៏ត្រូវបានពង្រឹងថែមទៀតផងដែរ។ តាមរយៈសិទ្ធិអំណាចច្បាស់លាស់របស់ធនាគារកណ្តាល រួមជាមួយក្របខណ្ឌត្រួតពិនិត្យ និងបទប្បញ្ញត្តិតឹងរ៉ឹង ប្រព័ន្ធធនាគាររបស់កម្ពុជាបានបង្ហាញឱ្យឃើញពីការលូតលាស់ឆាប់រហ័ស និងស្របតាមដំណាក់កាលនៃការអភិវឌ្ឍយ៉ាងត្រឹមត្រូវ។ ទ្រព្យសកម្ម និងដើមទុនរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានបន្តកើនឡើងជារៀងរាល់ឆ្នាំ។ ជាងនេះទៅទៀត ដោយសារតែស្ថិរភាពនៃម៉ាក្រូសេដ្ឋកិច្ច និងនយោបាយក្នុងស្រុក ក្នុងរយៈកាលជាងពីរទសវត្សរ៍មកនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតបានបង្កើនការផ្តល់ប្រាក់កម្ចី ហើយអតិថិជនក៏បានបង្កើនការដាក់ប្រាក់បញ្ញើផងដែរ។

ព្រមជាមួយនឹងកំណើនដ៏ឆាប់រហ័សនៅក្នុងវិស័យធនាគារនេះ ធនគារជាតិនៃកម្ពុជា បានបន្តពង្រឹង និងធ្វើបច្ចុប្បន្នភាពលើក្របខណ្ឌច្បាប់បទប្បញ្ញត្តិ និងការត្រួតពិនិត្យ ដើម្បីរក្សាស្ថិរភាពក្នុងវិស័យនេះ។ បើប្រៀបធៀបជាមួយនឹងបណ្តាវិស័យផ្សេងៗទៀតនៅក្នុងប្រទេស ក្របខណ្ឌច្បាប់នៅក្នុងវិស័យធនាគារ ត្រូវបានគេទទួលស្គាល់ថាមានសភាពគ្រប់ជ្រុងជ្រោយជាងគេ។[5] ក្របខណ្ឌត្រួតពិនិត្យក៏ត្រូវបានផ្លាស់ប្តូរពីការត្រួតពិនិត្យផ្អែកលើអនុលោមភាព ទៅជាការត្រួតពិនិត្យផ្អែកលើហានិភ័យវិញ ដើម្បីធានាឱ្យបាននូវអភិបាលកិច្ច និងការត្រួតពិនិត្យផ្ទៃក្នុង របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាការការពារដល់អ្នកប្រើប្រាស់ផងដែរ។ ជាងនេះទៅទៀត បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ក៏ត្រូវបានជំរុញយ៉ាងខ្លាំងក្នុងគោលដៅកសាង និងពង្រឹងទំនុកចិត្តរបស់មហាជននៅក្នុងការប្រើប្រាស់ប្រព័ន្ធធនាគារហើយដើម្បីអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចទទួលបានអត្ថប្រយោជន៍ពីផលិតផល និងសេវាហិរញ្ញវត្ថុប្រកបដោយនវានុវត្តន៍ ដែលគេស្គាល់ថាជាបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech)។

**សំណួរឆ្លុះបញ្ចាំង ក១**

**ប្រទេស ក** ព្យាយាមធ្វើជាតូបនីយកម្មវិស័យធនាគាររបស់ខ្លួន ដោយអនុញ្ញាតឱ្យតែធនាគាររបស់រដ្ឋប៉ុណ្ណោះធ្វើប្រតិបត្តិការ។ រាល់ធនាគារឯកជន មិនថាជាធនាគារក្នុងស្រុក ឬអន្តរជាតិនោះទេ គឺមិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការនៅក្នុងប្រទេសនេះឡើយ។ ក្នុងករណីនេះ តើអ្វីខ្លះអាចជាផលប៉ះពាល់នៃការធ្វើជាតូបនីយកម្មលើវិស័យធនាគាររបស់ខ្លួន?

[5] (Bun, 2019)

## ក២. ពន្យល់អំពីគោលបំណងផ្នែកសង្គមរបស់ធនាគារ

គោលបំណងផ្នែកសង្គមរបស់ធនាគារ សំដៅលើរាល់សូចនាករវេរិយាបថនានា ដែលត្រូវបានកំណត់ដើម្បីបម្រើដល់ផលប្រយោជន៍សាធារណៈតាមរយៈការរក្សាតុល្យភាពរវាងវត្ថុបំណងមូលដ្ឋានរបស់ស្ថាប័នជាមួយនឹងវត្ថុបំណងជាប្រយោជន៍របស់មហាជន។[6] គោលបំណងផ្នែកសង្គមគឺ ជាហេតុផលជំរុញទឹកចិត្តនៅក្នុងវិស័យសេវាហិរញ្ញវត្ថុ[7] មិនថាជាប្រទេសអ្វី មានវប្បធម៌អ្វី ផលិតផលធនាគារអ្វី និងភាគហ៊ុនិកប្រភេទណានោះទេ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចាំបាច់ត្រូវទទួលខុសត្រូវផ្នែកសង្គមចំពោះអតិថិជនរបស់ខ្លួន។[8]ជាងនេះទៅទៀត ប្រព័ន្ធធនាគារដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ នៅក្នុងប្រទេសតាមរយៈការបង្កើតផលិតផលសេវាឥណទានដែលមានតម្លៃសមរម្យហើយ ត្រូវបានច្នៃបង្កើតឡើងផ្អែកទៅតាមស្ថានភាពជាក់ស្តែង(ឧទាហរណ៍ វិបត្តិហិរញ្ញវត្ថុ ជំងឺរាតត្បាត)ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន។[9]

### តើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដូចគ្នានឹងក្រុមហ៊ុនសាជីវកម្មផ្សេងទៀតដែរឬទេ?

ខុសពីក្រុមហ៊ុនសាជីវកម្មផ្សេងទៀត គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើរតួនាទីសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ សាកស្រមៃមើល ប្រសិនបើប្រទេសមួយគ្មានធនាគារៈ[10]

- **តើប្រជាជនសន្សំលុយកាក់របស់ខ្លួនតាមរបៀបណា?** ប្រជាជនប្រហែលជាសន្សំលុយកាក់របស់ខ្លួនដោយដាក់នៅតាមផ្ទះសម្បែងដែលមានហានិភ័យជាច្រើន ហើយដោយពុំបានទទួលការប្រាក់សោះឡើយ។
- **តើអាជីវកម្មនានាស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុតាមរបៀបណា?** អាជីវកម្មតូចៗ ប្រហែលជាមានតែអាចស្វែងរកមូលនិធិបានពីរង្វង់មនុស្សដែលជិតស្និទ្ធ (សមាជិកគ្រួសារ និងមិត្តភក្តិ) ឬ ងាកទៅរកក្រុមចងការប្រាក់ក្រៅផ្លូវការ (loan shark) ដែលមានអត្រាការប្រាក់ខ្ពស់ប៉ុណ្ណោះ។
- **តើសេដ្ឋកិច្ចមានដំណើរការដូចម្តេច?** ពុំមានការកៀរគរដើមទុន ពីអ្នកដែលមានប្រាក់ចំណូលសេសសល់ សម្រាប់អ្នកដែលត្រូវការដើមទុននោះ ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន ហើយដូច្នេះ មិនអាចបង្កើតឱកាសការងារបន្ថែម ហើយមិនអាចរួមចំណែកដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចបានឡើយ។

---

[6] (Bessong & Tapang, 2012)
[7] (Scholtens, 2009)
[8] (Yeung, 2011)
[9] (Bessong & Tapang, 2012)
[10] (Federal Reserve Bank of San Francisco, 2001)

ចំណុចនេះ ឆ្លុះបញ្ចាំងឱ្យឃើញអំពីតួនាទីសំខាន់របស់ធនាគារ នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសមួយ តាមរយៈការកៀរគរហិរញ្ញវត្ថុ តាមរយៈការផ្សារភ្ជាប់អ្នកដែលមានប្រាក់ចំណូលនៅសេសសល់ច្រើន ជាមួយនឹងបុគ្គល និងអាជីវកម្មនានា ដែលត្រូវការហិរញ្ញប្បទានដើម្បីអភិវឌ្ឍអាជីវកម្មរបស់ខ្លួន និងដើម្បីបង្កើតឱកាសការងារកាន់តែច្រើនបន្ថែមទៀត។ ទោះបីជាយ៉ាងណាចំណុចអវិជ្ជមានគឺនៅត្រង់ថា ការដួលរលំរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មួយ អាចបង្កផលប៉ះពាល់អវិជ្ជមានទៅលើវិស័យធនាគារទាំងមូលបាន ដូចក្នុងករណី ការសម្រុកដកលុយចេញពីធនាគារ (bank run) ជាដើម។ ការសម្រុកដកលុយចេញពីធនាគារកើតមាននៅពេលដែលអ្នកដាក់ប្រាក់បញ្ញើជាច្រើនសម្រុកដកប្រាក់របស់ខ្លួនចេញពីធនាគារ ក្នុងពេលដំណាលគ្នា ដោយសារតែមានការភ័យខ្លាចថា គ្រឹះស្ថាននោះនឹងឈានទៅរកភាពក្ស័យធន។[11] ការដួលរលំរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ណាមួយអាចនាំទៅរកការខាតបង់ប្រាក់ចំណូលពីការសន្សំរបស់អ្នកដាក់ប្រាក់បញ្ញើ។ ដូច្នេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានទំនួលខុសត្រូវយ៉ាងធំធេងហើយចាំបាច់ត្រូវមានការគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្នជាងវិស័យណាៗទាំងអស់។

## តើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ គួរសម្លឹងឱ្យហួសពីប្រាក់ចំណេញរបស់ខ្លួនដែរឬទេ?

អាជីវកម្មរបស់ធនាគារពឹងផ្អែកខ្លាំងទៅលើកត្តាគន្លឹះមួយគឺ "ការជឿទុកចិត្ត"។ ប្រសិនបើគ្មានការជឿទុកចិត្តទេ នោះពុំមាននរណាម្នាក់ហ៊ានដាក់ប្រាក់បញ្ញើរបស់ខ្លួនឡើយ។ ដើម្បីបង្កើតឱ្យមានការជឿទុកចិត្ត គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចាំបាច់ត្រូវសម្លឹងឱ្យហួសពីប្រាក់ចំណេញរបស់ខ្លួន ហើយយកចិត្តទុកដាក់ដោយចិត្តស្មោះស ចំពោះអតិថិជនរបស់ខ្លួន។ និយាយម្យ៉ាងទៀតអតិថិជនត្រូវតែជឿថា ធនាគារិកកំពុងប្រតិបត្តិដើម្បីឧត្តមប្រយោជន៍របស់អតិថិជននៅគ្រប់កាលៈទេសៈទាំងអស់។ ចូរគិតពិចារណាលើស្ថានភាពមួយ នៅពេលដែលអតិថិជនជួបប្រទះនឹងហេតុការណ៍ជីវិតលំបាកដូចជា ការលែងលះ មរណភាពរបស់សមាជិកគ្រួសារណាម្នាក់ ឬភាពគ្មានការងារធ្វើជាដើម។ តើពួកគេអាចមកជួបគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីសុំការពិគ្រោះយោបល់ និងការគាំទ្រចំពោះការលំបាកផ្នែកហិរញ្ញវត្ថុរបស់ខ្លួនបានដែរទេ? ឬ តើពួកគេអាចត្រឹមតែជ្រើសរើសយកការពឹងផ្អែកលើខ្លួនឯង និងមនុស្សជុំវិញខ្លួនរបស់គេ?[12] នៅពេលនេះ សូមស្រមៃមើលថា ប្រជាជនងាយរងគ្រោះទាំងនេះជាបងប្អូនរបស់អ្នក។ តើក្នុងស្ថានភាពនេះ តើអ្នកនឹងធ្វើដូចម្តេច?

---

[11] (Knufken, 2009)
[12] (ViZolution, 2020)

ដើម្បីបង្កើតទំនុកចិត្ត ហើយទ្រទ្រង់ដល់អាជីវកម្មធនាគារក្នុងរយៈពេលយូរអង្វែង ជាការសំខាន់ ដែលយើងត្រូវធ្វើឱ្យអតិថិជនមានអារម្មណ៍ថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានគោលបំណងផ្នែកសង្គម ហើយធ្វើសកម្មភាពស្របគ្នាជាមួយនឹងតម្រូវការរបស់អតិថិជន។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អាចបំពេញតាមគោលបំណងផ្នែកសង្គមរបស់ខ្លួនតាមរយៈ៖[13]

- សមត្ថភាពក្នុងការស្វែងយល់អំពីតម្រូវការ និងស្ថានភាពរបស់អតិថិជន
- សុចរិតភាពក្នុងការធ្វើរឿងត្រឹមត្រូវ តាមរយៈការប្រកាន់ខ្ជាប់នូវគោលការណ៍ក្រមសីលធម៌ និងសីលធម៌
- ភាពជាមនុស្សដែលបង្ហាញអំពីការយកចិត្តទុកដាក់ពិតៗចំពោះអតិថិជនដែលងាយរងគ្រោះ និងកំពុងជួបការលំបាក

**សំណួរឆ្លុះបញ្ចាំង ក២**

ធីតាបានខ្ចីប្រាក់មួយចំនួនពី**ធនាគារ ថូម៉ាក្ង** ដើម្បីបើកអាជីវកម្មតូចមួយ មុនពេលមានជំងឺរាតត្បាតកើតឡើង។ ទោះជាយ៉ាងណា នៅពេលដែលជំងឺរាតត្បាតបានចាប់ផ្តើមកើតមាន គាត់ក៏ជួបនឹងការលំបាក ហើយមិនបានទទួលប្រាក់ចំណូលច្រើនឡើយ។ នៅចំពោះមុខបញ្ហាប្រឈមនៃការបង់សងប្រាក់កម្ចី គាត់ពុំបានទាក់ទង ឬសុំយោបល់ពី**ធនាគារ ថូម៉ាក្ង** ឡើយ។ ក្នុងករណីនេះ តើ**ធនាគារ ថូម៉ាក្ង** គួរធ្វើបែបណា ដើម្បីដោះស្រាយបញ្ហានេះ ហើយនៅតែប្រកាន់ខ្ជាប់តាមគោលបំណងផ្នែកសង្គមរបស់ខ្លួន?

## ក៣. រៀបរាប់អំពីមូលដ្ឋានគ្រឹះក្នុងការកសាង និងការថែរក្សាទំនុកចិត្តមកលើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ទំនុកចិត្តកើតមាននៅពេលដែលភាគីម្ខាងមានទំនុកចិត្តមកលើសុចរិតភាព និងភាពអាចពឹងពាក់បានរបស់ភាគីម្ខាងទៀត។គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារ ក៏អាចកសាង និងថែរក្សាទំនុកចិត្តតាមរយៈសកម្មភាពសំខាន់ៗបួន ដូចខាងក្រោម[14]៖

### ក) បង្កើតគោលនយោបាយដើម្បីជួយគាំទ្រដល់អតិថិជនងាយរងគ្រោះ

---

[13] (Daniel Knoll, 2020)
[14] (KPMG, 2020b)

ដើម្បីបង្កើតជាលទ្ធផលដែលមានឥទ្ធិពលសម្រាប់មនុស្សជាតិ ជារឿងសំខាន់ដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវរៀបចំគោលនយោបាយគាំទ្រសម្រាប់ភាគីពាក់ព័ន្ធដែលងាយរងគ្រោះបំផុត ដើម្បីការពារពួកគាត់កុំឱ្យធ្លាក់ចូលទៅក្នុងស្ថានភាពធ្ងន់ធ្ងរណាមួយ ឬបរាជ័យក្នុងការសងប្រាក់កម្ចីមកវិញ។ ចំណុចនេះមានន័យថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែវិភាគឱ្យបានត្រឹមត្រូវចំពោះស្ថានភាពហិរញ្ញវត្ថុកន្លងមក សមត្ថភាពសងត្រឡប់របស់អតិថិជនដែលកំពុងស្នើសុំហិរញ្ញប្បទាន ហើយដើម្បីធានាថានឹងមិនមានការបង្កើតបន្ទុកសងបំណុលបន្ថែមដល់អតិថិជនឡើយ។ ការផ្តល់ហិរញ្ញប្បទាននឹងត្រូវអនុវត្តទៅតាមគោលបំណងផលិតភាព ដូច្នេះ វានឹងធ្វើឱ្យមានផលប៉ះពាល់ជាវិជ្ជមាន ចំពោះទ្រព្យសម្បត្តិដុលរបស់អតិថិជន និងសង្គមទាំងមូល។ អតិថិជនអាចនឹងបរាជ័យក្នុងការសងប្រាក់កម្ចី (ប្រែជាងាយរងគ្រោះ) ដោយសារតែឥរិយាបថខ្វះទំនួលខុសត្រូវរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដោយពុំខ្វល់លើបន្ទុកបំណុលលើសលុបរបស់ពួកគេ ពុំធ្វើការវិភាគពីសមិទ្ធលទ្ធភាពនៃផែនការអាជីវកម្មរបស់គេ ហើយហ៊ានប្រថុយខ្លាំង ដោយសារតែចេតនាចង់បានតែប្រាក់ចំណេញ។ ទោះជាយ៉ាងណា អតិថិជនអាចមានភាពងាយរងគ្រោះផងដែរ សូម្បីក្រោយពេលដែលរាល់កត្តាទាំងអស់ត្រូវបាន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ យកមកពិចារណាក្តី ដែលនេះក៏ដោយសារតែកត្តាខាងក្រៅ ហួសពីការគ្រប់គ្រងរបស់អតិថិជន/គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារ។ គោលនយោបាយគាំទ្រគួរមានដូចខាងក្រោម៖

- ធ្វើការវិភាគ ដើម្បីកំណត់ប្រភេទរបស់អតិថិជន ឬសូចនាករណាមួយដែលនាំទៅរកភាពងាយរងគ្រោះ
- បំពាក់បំប៉នបុគ្គលិកឱ្យមានចំណេះដឹងផ្នែកបច្ចេកទេស ជំនាញ ធនធាន និងសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការដោះស្រាយភាពងាយរងគ្រោះរបស់អតិថិជនតាំងពីដំបូង
- ដំណើរការនានាគួរតែមានភាពងាយស្រួលតាមដែលអាចធ្វើបាន ដើម្បីឱ្យអតិថិជនអាចបង្កើនការប្រាស្រ័យទាក់ទងរបស់ខ្លួនជាមួយនឹង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។
- ផ្តល់ដំណោះស្រាយ និងការគាំទ្រដែលអាចជឿទុកចិត្តបានដល់អតិថិជនដែលងាយរងគ្រោះដើម្បីស្តារឡើងវិញក្រោយពីវិបត្តិ។

### ខ) ការអភិវឌ្ឍសមត្ថភាពបុគ្គលិក

ការដោះស្រាយជាមួយអតិថិជនមិនមែនជាកិច្ចការងាយស្រួលនោះទេ ជាពិសេសសម្រាប់បុគ្គលិកជួរមុខដែលធ្វើការងារពាក់ព័ន្ធដោយផ្ទាល់ជាមួយអតិថិជន ដូចជាការឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវរបស់អតិថិជន ការឆ្លើយតបសំណួររបស់ពួកគាត់ និងការតវ៉ាផ្សេងៗជាដើម។ ដើម្បីបង្កើនគុណភាពសេវា ជាការចាំបាច់ដែលយើងត្រូវយកចិត្តទុកដាក់ចំពោះសុខុមាលភាពរបស់

បុគ្គលិក ហើយអ្នកគ្រប់គ្រងគួរតែចាត់វិធានការទាន់ពេលវេលា នៅពេលដែលមានបញ្ហាពិបាកខ្លាំងពេក ដែលមន្ត្រីក្រោមបង្គាប់របស់ខ្លួនមិនអាចដោះស្រាយបាន។ក្នុងករណីនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ គួរគប្បី៖

- ធានាថា បុគ្គលិកទាំងអស់ទទួលបានការបណ្តុះបណ្តាលយ៉ាងល្អពាក់ព័ន្ធនឹងចំណេះដឹងបច្ចេកទេស និងអាកប្បកិរិយាក្នុងការផ្តល់សេវា ដើម្បីចេះទប់ទល់ចំពោះពេលវេលាដ៏លំបាកណាមួយ។
- ធានាថា អ្នកដឹកនាំកំពុងធ្វើការរួមគ្នាជាមួយក្រុមការងាររបស់ខ្លួន ដើម្បីស្វែងយល់អំពីអ្វីដែលខ្លួនកំពុងធ្វើ និងដើម្បីពិនិត្យមើលថាតើពួកគេដើរលើផ្លូវត្រូវ ក៏ដូចជាផ្តល់ការគាំទ្រទៅតាមភាពចាំបាច់ ដែរឬទេ។

## គ) ជួយឱ្យអតិថិជនចេះមានអារម្មណ៍ថាមានសិទ្ធិ

ជារឿងចាំបាច់ដែលត្រូវធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអតិថិជន ដើម្បីពង្រឹងការធ្វើប្រតិបត្តិការរបស់ពួកគេ និងជម្រះរាល់ភាពមន្ទិលនានា។ ដើម្បីកសាងទំនុកចិត្តរបស់អតិថិជន និងពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ពួកគាត់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែ៖

- ធ្វើឱ្យសាមញ្ញនូវជម្រើសសម្រាប់អតិថិជន ដែលធ្វើឱ្យកាន់តែមានប្រសិទ្ធភាព និងងាយស្រួលក្នុងការស្វែងយល់សម្រាប់ទាំងអតិថិជនផងនិងបុគ្គលិកផង។
- ស្តាប់ដើម្បីដឹងពីស្ថានភាពរបស់អតិថិជន ហើយព្យាយាមស្វែងយល់អំពីលក្ខខណ្ឌពិសេសរបស់ពួកគាត់។
- ផ្តល់ការប្រាស្រ័យទាក់ទងទាន់ពេលវេលា ដើម្បីបង្កើនការជឿទុកចិត្ត តាមរយៈការដោះស្រាយភាពមិនច្បាស់លាស់ និងជម្លោះនានា និងការបំពេញតាមការរំពឹងចង់បានរបស់អតិថិជន។
- អនុវត្តកាតព្វកិច្ចក្រមសីលធម៌ដើម្បីរក្សាបាននូវការវាយតម្លៃល្អពីអតិថិជន។ ចំណុចនេះអាចធ្វើទៅបានតាមរយៈការគាំទ្រ ដើម្បីជួយអតិថិជនជម្នះលើការលំបាក ផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ដូចជាការផ្តល់ការប្រឹក្សាដោយឥតគិតថ្លៃនិងដំបូន្មានពីអ្នកជំនាញ ការពន្យារពេលបង់ប្រាក់ដើម ឬការប្រាក់ ការបន្ថយថ្លៃសេវាធនាគារតាមដែលអាចធ្វើទៅបាន។
- ព្យាយាមមានភាពបុរេសកម្មក្នុងការទំនាក់ទំនងជាមួយអតិថិជន ដើម្បីយល់ឲ្យច្បាស់អំពីតម្រូវការ ការរំពឹងចង់បានរបស់ពួកគាត់ និងឆ្លើយតបចំពោះការផ្តល់យោបល់ ព្រមទាំងបណ្តឹងរបស់ពួកគាត់ឱ្យបានត្រឹមត្រូវ ប្រសិនបើមាន។

### ឃ) ប្រព្រឹត្តចំពោះភាគីពាក់ព័ន្ធដោយមានក្រមសីលធម៌

ភាគីពាក់ព័ន្ធនៅក្នុង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ អាចត្រូវបានចាត់ថ្នាក់ជាពីរប្រភេទ[15]៖

- **ភាគីពាក់ព័ន្ធខាងក្នុង** ដែលចូលរួមយ៉ាងសកម្មនៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- **ភាគីពាក់ព័ន្ធខាងក្រៅ** ដែលទទួលរងឥទ្ធិពលពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**ក្រាហ្វិកព័ត៌មាន ១៖** ភាគីពាក់ព័ន្ធខាងក្នុង និងខាងក្រៅរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដកស្រង់ចេញពី (Jeuken, 1998)




គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចាំបាច់ត្រូវតែផ្សព្វផ្សាយ និងបង្ហាញអំពីគោលបំណងបេសកកម្ម ចក្ខុវិស័យ និងយុទ្ធសាស្ត្ររបស់ខ្លួនឱ្យបានច្បាស់លាស់ ដើម្បីឱ្យភាគីពាក់ព័ន្ធរបស់ខ្លួន

[15] (Olander, 2007)

បានដឹង ដើម្បីធានាឲ្យបាននូវតម្លាភាពនៃអាជីវកម្ម និងសុខុមាលភាពរបស់ភាគីពាក់ព័ន្ធ។[16] ព្រមជាមួយនឹងគោលបំណងអាជីវកម្ម សេចក្តីថ្លែងបេសកកម្មទាំងនោះគួរតែរួមបញ្ចូលអំពីប្រភេទផលិតផល/សេវា ទីតាំងអាជីវកម្ម គោលគំនិតចំពោះខ្លួន ទស្សនវិជ្ជា បច្ចេកវិទ្យា ការយកចិត្តទុកដាក់ចំពោះបុគ្គលិក កិត្តិនាមសាធារណៈ ការរស់រាន កំណើន និងប្រាក់ចំណេញ។[17] មិនថាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នោះផ្តល់នូវផលិតផល ឬសេវាអ្វីនោះទេ ពួកគេមានទំនួលខុសត្រូវក្នុងការថែទាំឱ្យបានល្អចំពោះអ្នកដាក់ប្រាក់បញ្ញើ អ្នកជាប់បង់ពន្ធ និងភាគីពាក់ព័ន្ធទាំងអស់ផ្សេងទៀត។[18]

**សំណួរឆ្លុះបញ្ចាំង ក៣**

សូមជ្រើសរើសយកជម្រើសខាងក្រោមណាមួយ ដែលបកស្រាយអំពីវិធីសាស្រ្តដែល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចកសាងទំនុកចិត្តជាមួយនឹងអតិថិជនរបស់ខ្លួនបាន។ (អ្នកអាចជ្រើសរើសយកចម្លើយលើសពីមួយបាន)

**ក-** គ្រឹះស្ថាន គួរតែផ្តល់ឱ្យអតិថិជននូវព័ត៌មានសង្ខេបទាក់ទងនឹងផលិតផលហិរញ្ញវត្ថុ របស់ខ្លួន ហើយអតិថិជនអាចធ្វើការសន្និដ្ឋានដោយខ្លួនឯង។

**ខ-** គ្រឹះស្ថាន គួរផ្តល់ព័ត៌មានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ដល់អតិថិជន។

**គ-** គ្រឹះស្ថាន គួរសិក្សាអំពីការរំពឹងទុក និងតម្រូវការរបស់អតិថិជន។

**ឃ-** គ្រឹះស្ថាន គួរតែកាត់បន្ថយការប្រាស្រ័យទាក់ទង ជាមួយអតិថិជន ដើម្បីបង្អាក់ពួកគាត់ កុំឱ្យទាក់ទងមកខ្លួន និងកុំឱ្យផ្តល់ហេតុផលក្នុងការពន្យារពេលនៃការទូទាត់សងរបស់ពួកគាត់។

**ង-** គ្រឹះស្ថាន គួរតែបង្កើនការប្រាស្រ័យទាក់ទងជាមួយអតិថិជន ដើម្បីជាការលើកទឹកចិត្តពួកគាត់ឱ្យមានភាពបុរេសកម្មក្នុងការទាក់ទងមកខ្លួន ដើម្បីបង្កើនទំនាក់ទំនងរវាងគ្នា ទៅវិញទៅមក។

## ក៤. វិភាគការប្រព្រឹត្តមិនត្រឹមត្រូវផ្នែកហិរញ្ញវត្ថុបច្ចុប្បន្ន

### ❋ ករណីសិក្សាអំពីការប្រព្រឹត្តមិនត្រឹមត្រូវរបស់ធនាគារ "វែលហ្វាហ្គោ (Wells Fargo)"

ឧទាហរណ៍ដ៏ល្បីមួយបង្ហាញអំពីការប្រព្រឹត្តមិនត្រឹមត្រូវ គឺករណីធនាគារវែលហ្វាហ្គោ។ ធនាគារនេះបានបង្កើតគណនីសន្សំប្រាក់ និងគណនីចរន្តក្លែងបន្លំរាប់លានគណនីក្រោមឈ្មោះ

[16] (Ahmed, 2016)
[17] (Ahmed, 2016)
[18] (Jeucken & Bouma, 1999)

អតិថិជនរបស់វែលហ្វាហ្គោ ដោយគ្មានការយល់ព្រមពីពួកគេ ក្នុងបំណងដើម្បីសម្រេចបាននូវគោលដៅដែលកំណត់ដោយអ្នកគ្រប់គ្រង។ គណនីក្លែងបន្លំប្រហែល ៣.៥ លានគណនីត្រូវបានបើកនៅចន្លោះឆ្នាំ ២០១១ ដល់២០១៦ ដែលបានបំពេញដោយមានហត្ថលេខា លេខទូរសព្ទ អាសយដ្ឋានអ៊ីមែល និងលេខ PIN ក្លែងក្លាយ។ គណនីក្លែងបន្លំទាំងអស់នេះ ត្រូវបានបង្កើតឡើងដោយបុគ្គលិក ដែលពួកគាត់ត្រូវបានដាក់សម្ពាធឱ្យធ្វើពីសំណាក់ប្រធានគ្រប់គ្រងរបស់ខ្លួន ដើម្បីអាចសម្រេចបាននូវគោលដៅ បើកគណនីប្រចាំថ្ងៃរបស់ធនាគារនោះ។ បន្ទាប់មក ធនាគារ បានកាត់ថ្លៃសេវាពីអតិថិជនយ៉ាងហោចណាស់ ១.៥លានដុល្លារ តាមរយៈគណនីក្លែងបន្លំទាំងអស់នេះ។ អតិថិជនជាច្រើនរងផលប៉ះពាល់យ៉ាងខ្លាំងទៅលើពិន្ទុឥណទានរបស់ខ្លួន (ពិន្ទុឥណទានមិនល្អ នៅក្នុងមូលដ្ឋានទិន្នន័យការិយាល័យឥណទាន) ដោយមិនបានធ្វើបច្ចុប្បន្នភាពលើគណនីរបស់ខ្លួន ដែលគណនីទាំងនោះពួកគេមិនស្គាល់ឡើយ។ ករណីនេះកើតមានក៏ដោយសារតែវិធីសាស្ត្រចង់បានប្រាក់ចំណេញខ្លាំងពេករហូតមិនបានគិតគូរពីអតិថិជននិងបុគ្គលិក ព្រមទាំងមានការដាក់សម្ពាធជ្រុលហួសហេតុពីថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ក្នុងការបើកគណនីឱ្យបានច្រើនតាមដែលអាចធ្វើបានតាមរយៈការលក់ឆ្លង (cross-selling)។ អត្ថប្រយោជន៍របស់បុគ្គលិកផ្នែកលក់ត្រូវបានទូទាត់ដោយផ្អែកលើប្រាក់ចំណេញនិងការសម្រេចបានគោលដៅនៃការលក់។ វប្បធម៌អនុលោមភាពគឺពុំមានឡើយនៅក្នុងស្ថាប័ននេះ។[19]

### ❋ ផលវិបាកនៃការប្រព្រឹត្តមិនត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ

ធនាគារនេះ បានបណ្តេញបុគ្គលិកប្រហែល៥៣០០នាក់ នៅចន្លោះពីឆ្នាំ២០១១ដល់ឆ្នាំ២០១៦ ដោយសារតែការលក់ក្លែងបន្លំ។ ធនាគារនេះត្រូវបានពិន័យជាប្រាក់ចំនួន១៨៥លានដុល្លារនៅដើមខែកញ្ញា ឆ្នាំ ២០១៦ ហើយត្រូវប្រឈមមុខនឹងបណ្តឹងរដ្ឋប្បវេណី និងព្រហ្មទណ្ឌបន្ថែមទៀត ដែលឈានដល់ការពិន័យជាប្រាក់ប្រមាណ ២.៧ពាន់លានដុល្លារនៅចុងឆ្នាំ២០១៨។ បុគ្គលជាច្រើនក៏ត្រូវបានឱ្យមកទទួលខុសត្រូវនៅក្នុងករណីនេះផងដែរ។ ប្រធាននាយកប្រតិបត្តិ និងជាប្រធានក្រុមប្រឹក្សាភិបាលនៅពេលនោះ គឺ លោក John Stumpf ត្រូវបានព្រឹទ្ធសមាជិក Elizabeth Warren ហៅថា ជាមេដឹកនាំកំសាក ព្រោះតែលោកខ្វះគណនេយ្យភាពដោយបានបណ្តេញតែបុគ្គលិកថ្នាក់ទាប ហើយពុំបណ្តេញបុគ្គលិកប្រតិបត្តិជាន់ខ្ពស់ និងរូបលោកផ្ទាល់។[20] ជាលទ្ធផល រដ្ឋាភិបាលសហរដ្ឋអាមេរិកបានហាមឃាត់លោក Stumpf មិនឱ្យបម្រើការនៅតាមធនាគារណាមួយនោះទេ ហើយលោករងការពិន័យជាទឹកប្រាក់ចំនួន ១៧.៥ លានដុល្លារ កាត់ចេញពីប្រាក់ផ្ទាល់ខ្លួនរបស់លោក នៅក្នុងរឿងអាស្រូវមួយនេះ។[21]

---

[19] (Wattles, Geier, Egan, & Wiener-Bronner, 2018)
[20] (Warren, 2016)
[21] (Franck, 2020)

ដូចបានឃើញនៅក្នុងករណីខាងលើនេះដែរ ការប្រព្រឹត្តមិនត្រឹមត្រូវ និងការពិន័យអាចបង្កើតឱ្យមានភាពមិនប្រាកដប្រជានៅក្នុងគំរូអាជីវកម្ម សាធនភាពនិងលទ្ធភាពចំណេញរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេស ការប្រព្រឹត្តមិនត្រឹមត្រូវនេះ អាចបំផ្លាញទំនុកចិត្តរបស់មហាជនមកលើប្រព័ន្ធហិរញ្ញវត្ថុ ដែលបង្អាក់ទឹកចិត្តរបស់អតិថិជនមិនឱ្យប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុ ឬទិញសេវាណាមួយ។ ក្នុងករណីធ្ងន់ធ្ងរបំផុត គ្រឹះស្ថាន អាចនឹងដកខ្លួនចេញពីទីផ្សារ និងសកម្មភាពហិរញ្ញវត្ថុ ដោយសារការបង្ខំពីអាជ្ញាធរ ឬដោយស្ម័គ្រចិត្ត។ ម្យ៉ាង ករណីមួយទៀតនៃការប្រព្រឹត្តមិនត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ ក៏អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់វិស័យធនាគារទាំងមូល ដោយសារករណីនោះបានបំផ្លាញទំនុកចិត្តសាធារណៈ ព្រោះអតិថិជនមានការពិបាកក្នុងការពិចារណា ឬជឿទុកចិត្តថាតើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ណាមួយដែលប្រព្រឹត្តល្អ ឬអាក្រក់នោះ។ នៅទីបំផុត ការខ្វះទំនុកចិត្តពីអ្នកដាក់ប្រាក់បញ្ញើ អាចនាំឱ្យមានការសម្រុកដកប្រាក់ពីធនាគារបាន។

## ❋ ការទប់ស្កាត់ការប្រព្រឹត្តមិនត្រឹមត្រូវផ្នែកហិរញ្ញវត្ថុនាពេលអនាគត

ការទប់ស្កាត់ការប្រព្រឹត្តមិនត្រឹមត្រូវគឺប្រសើរជាង និងងាយស្រួលជាងការដោះស្រាយបញ្ហានៅពេលដែលវាកើតឡើង។ អភិបាលកិច្ចល្អ និងការត្រួតពិនិត្យផ្ទៃក្នុងនៅក្នុង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺជាធាតុផ្សំដ៏សំខាន់ក្នុងការទប់ស្កាត់ការប្រព្រឹត្តមិនត្រឹមត្រូវ។ បទប្បញ្ញត្តិប្រុងប្រយ័ត្ន អាចពង្រឹងការងារគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចផ្ទៃក្នុង។ ទន្ទឹមនឹងនេះ វត្តមានរបស់ឧបករណ៍វាស់វែងហានិភ័យដែលរឹងមាំ រួមជាមួយនឹងវប្បធម៌ ក្រមសីលធម៌រឹងមាំផងនោះ ប្រាកដជាអាចជួយការពារ គ្រឹះស្ថាន មិនឱ្យប្រព្រឹត្ត ឬពាក់ព័ន្ធនឹងទម្រង់ណាមួយនៃការប្រព្រឹត្តមិនត្រឹមត្រូវនោះឡើយ។ ជាងនេះទៅទៀត អតិថិជនចាំបាច់ក៏ត្រូវទទួលបានការគាំទ្រផងដែរ តាមរយៈការទទួលបានការអប់រំផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់។

### សំណួរឆ្លុះបញ្ចាំង ក៤

ធនាគារ ហ្គោលមែន សាចស៍ (Goldman Sachs) បានយល់ព្រមបង់ប្រាក់ពិន័យចំនួន ២.៩ ពាន់លានជុំវិញរឿងអាស្រូវ 1MDB (1MDB ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ីដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសម៉ាឡេស៊ី តាមរយៈភាពជាដៃគូសកល និងការវិនិយោគផ្ទាល់ពីបរទេស)។ ធនាគារនេះបានយកថ្លៃសេវាចំនួន ៦០០ លានដុល្លារក្នុងការផ្តល់ប្រឹក្សាដល់គម្រោង 1MDB នេះ។ ធនាគារ ហ្គោលមែន សាចស៍ បានជួយរៃអង្គាសប្រាក់ចំនួន ៦.៥ ពាន់លានដុល្លារសម្រាប់គម្រោង 1MDB ដោយលក់មូលបត្របំណុលទៅឱ្យវិនិយោគិនដែលប្រាក់ចំណូលភាគច្រើនត្រូវបានលួចយកទៅបាត់។ រដ្ឋអាជ្ញាបានចោទប្រកាន់ថា ក្រុម

នាយកប្រតិបត្តិជាន់ខ្ពស់របស់ហ្គោលមែន មិនអើពើចំពោះការក្រើនរំលឹកអំពីការគៃបន្លំក្នុងការងាររបស់ខ្លួនជាមួយ 1MDB។ មានទិដ្ឋភាពជាច្រើនទាក់ទងនឹងរឿងអាស្រូវនេះ។ សម្រាប់ការទិញទ្រព្យសកម្ម ធនាគារហ្គោលមែន សាចស៍ បានជួយ 1MDB ជាមួយនឹងការទិញដូចខាងក្រោម[22]៖

- ខែមីនា ឆ្នាំ២០១២៖ ការទិញក្រុមហ៊ុន Tanjong Energy Holdings ក្នុងតម្លៃ ២.២ ពាន់លាន។ រោងចក្រថាមពលអគ្គិសនីមានអាជ្ញាបណ្ណដែលជិតផុតកំណត់។ តម្លៃទិញអាចត្រូវបានកាត់បន្ថយយ៉ាងច្រើន ប្រសិនបើហ្គោលមែន សាចស៍ ណែនាំ 1MDB ឱ្យរង់ចាំឱ្យហួសកាលបរិច្ឆេទផុតកំណត់។
- ខែសីហា ឆ្នាំ២០១២៖ ការទិញក្រុមហ៊ុនផលិតថាមពលក្នុងស្រុករបស់ Genting ក្នុងតម្លៃ ២.៤ពាន់លានរីងហ្គីត ដែលជាតម្លៃបំប៉ោង។

ហ្គោលមែន សាចស៍ គឺជាធនាគារវិនិយោគលំដាប់ពិភពលោកឈានមុខគេ ដែលមានបុគ្គលិកជាបញ្ញវន្តជាន់ខ្ពស់។ តើសកម្មភាពទាំងអស់នេះឆ្លុះបញ្ចាំងដូចម្តេចចំពោះជំហរក្រមសីលធម៌របស់ធនាគារនេះ?

[22] (Zhang, 2016)

# ផ្នែក ខ៖ វាយតម្លៃលើក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ នៅក្នុងការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ

## ខ១. ពន្យល់អំពីភាពចាំបាច់នៃបទប្បញ្ញត្តិនៅក្នុងប្រព័ន្ធធនាគារ

ប្រព័ន្ធធនាគារដើរតួនាទីយ៉ាងសំខាន់ចំពោះកំណើនសេដ្ឋកិច្ចនិងនិរន្តរភាពរបស់ប្រទេស។ មុខងារនៃការកៀរគរប្រាក់សន្សំពីក្រុមគ្រួសារ និងអាជីវកម្មនានា (រួមទាំងការផ្តល់ហិរញ្ញប្បទានសម្រាប់សាជីវកម្ម និងការសម្របសម្រួលការទូទាត់ និងសេវាទូទាត់ប្រាក់ផង) បាននឹងកំពុងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ជាពិសេសសម្រាប់មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម (MSMEs) ដែលត្រូវការចាំបាច់នូវដើមទុនវិនិយោគ និងដើមទុនបង្វិល ដើម្បីដំណើរការអាជីវកម្មថ្មីរបស់ខ្លួន និងទ្រទ្រង់ប្រតិបត្តិការអាជីវកម្មរបស់ពួកគេ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អាជីវកម្មធនាគារកាន់តែមានភាពប្រកួតប្រជែង ហើយការរីកចម្រើនផ្នែកបច្ចេកវិទ្យាត្រូវបានប្រើប្រាស់ដើម្បីពង្រឹងបន្ថែមលើដំណើរការនៃការប្រមូលប្រាក់បញ្ញើ ការផ្តល់ហិរញ្ញប្បទាន និងការពង្រឹងគុណភាព និងវិសាលភាពនៃប្រព័ន្ធទូទាត់។ នវានុវត្តន៍នៅក្នុងវិស័យហិរញ្ញវត្ថុទាំងអស់នេះ បានបង្កឱ្យមានការកើនឡើងនូវហានិភ័យនិងភាពស្មុគស្មាញនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុដែលតម្រូវឱ្យនិយ័តករគ្រប់គ្រងយ៉ាងតឹងរ៉ឹង និងប្រុងប្រយ័ត្នបំផុត ដើម្បីទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានណាមួយ នៅក្នុងទីផ្សារហិរញ្ញវត្ថុ។ វិបត្តិកន្លងមកបានបង្ហាញថាឥរិយាបថខុសឆ្គង របស់តួអង្គក្នុងវិស័យហិរញ្ញវត្ថុ ដោយសារក្នុងបរិបទនៃការធូររលុងផ្នែកបទប្បញ្ញត្តិ ជាមូលហេតុចម្បងមួយនៃភាពបរាជ័យក្នុងវិស័យហិរញ្ញវត្ថុ។

វិបត្តិហិរញ្ញវត្ថុសកល (GFC) ក្នុងឆ្នាំ ២០០៨ គឺជាវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរបំផុតនៅក្នុងសហរដ្ឋអាមេរិក ដោយគិតចាប់តាំងពីមហាវិបត្តិសេដ្ឋកិច្ច (Great Depression) ហើយបន្ទាប់មកបានរីករាលដាលដល់សេដ្ឋកិច្ចរបស់ប្រទេសដទៃទៀត។ ករណីនេះអាចទាញយកមកធ្វើជាឧទាហរណ៍បង្ហាញពីបរាជ័យទីផ្សារដោយសារតែការលុបចោលបទប្បញ្ញត្តិ ឬការបន្ធូរបន្ថយបទប្បញ្ញត្តិក្នុងប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ។ មានទិដ្ឋភាពសំខាន់ៗចំនួនបីដែលត្រូវបានចាត់ទុកថាជាមូលហេតុចម្បងនៃវិបត្តិហិរញ្ញវត្ថុសកលដែលក្នុងនោះរួមមាន ការទទួលយកហានិភ័យជ្រុលហួសកម្រិតក្នុងការផ្តល់កម្ចីអចលនទ្រព្យដល់អតិថិជនដែលមានប្រវត្តិឥណទានមិនល្អ (subprime mortgage) ក្នុងពេលដែលតម្លៃលំនៅឋានកើនឡើងខ្លាំង ការកើនឡើងនូវកម្ចីរយៈពេលខ្លីរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការឆ្វេសប្រហែសក្នុងការដាក់បទប្បញ្ញត្តិចំពោះទីផ្សារកម្ចីអចលនទ្រព្យ ដល់អតិថិជនដែលមានប្រវត្តិឥណទានមិនល្អ (subprime mortgage) និងការប្រើទ្រព្យតម្កល់ច្រើនជាការ

ធានា (securitization)។[23] បរាជ័យនៃទីផ្សារហិរញ្ញវត្ថុ អាចនឹងកើតមាន នៅពេលដែលពុំមានបទប្បញ្ញត្តិគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងអ្នកផ្តល់សេវាហិរញ្ញវត្ថុជា។[24] ហេតុដូច្នេះ និយ័តករគួរគ្រប់គ្រង និងត្រួតពិនិត្យឱ្យបានតឹងរ៉ឹងលើ គ្រឹះស្ថាន ដើម្បីទប់ស្កាត់ផលវិបាកអវិជ្ជមានដែលអាចកើតមានចេញពីភាពផុយស្រួយនិងភាពស្មុគស្មាញនៃប្រព័ន្ធធនាគារ។

**សំណួរឆ្លុះបញ្ចាំង ១១**

ដើម្បីបំពេញតាមតម្រូវការទីផ្សារកម្ចីអចលនវត្ថុ **ធនាគារ ថូម៉ាក្ញ** បានសម្រេចផ្តល់កម្ចីអចលនវត្ថុដល់អតិថិជនមានប្រវត្តិឥណទានមិនល្អ (subprime mortgage) ម្នាក់ឈ្មោះ ឆដា បើទោះបីជាគាត់មានពិន្ទុឥណទានទាបយ៉ាងណាក្តី។ នេះជាកម្ចីរយៈពេល៣០ឆ្នាំ ដែលមានអត្រាការប្រាក់ប្រចាំឆ្នាំ ៥% សម្រាប់បីឆ្នាំដំបូង ហើយ ១៥% សម្រាប់ឆ្នាំដែលនៅសល់។ តើអាចមានផលវិបាកអ្វីខ្លះ ដែលកើតចេញពីកម្ចីនេះ? តើអ្វីខ្លះអាចនឹងកើតមានឡើងចំពោះប្រព័ន្ធធនាគារប្រសិនបើនិយ័តករ មិនយកចិត្តទុកដាក់ និងពិនិត្យតាមដានចំពោះទីផ្សារកម្ចីដល់អតិថិជនមានប្រវត្តិឥណទានមិនល្អបែបនេះ?

## ១១.១. លក្ខណៈផុយស្រួយនៅក្នុងប្រព័ន្ធធនាគារ

### ១១.១.១. សន្ទនីយភាពផុយស្រួយ

តារាងតុល្យការរបស់ធនាគារបានបង្ហាញថាអាជីវកម្មធនាគារមានលក្ខណៈប្លែកពីគេ បើធៀបនឹងអាជីវកម្មផ្សេងទៀត។ នៅខាងទ្រព្យសកម្ម ទ្រព្យសកម្ម បង្កើតប្រាក់ចំណូល (ឥណទាន និងការវិនិយោគផ្សេងទៀត) គ្របដណ្តប់ស្ទើរទាំងអស់នៃទ្រព្យសកម្មសរុបរបស់ខ្លួន ខណៈដែលប្រភពនៃមូលនិធិ ពឹងផ្អែកភាគច្រើនលើផ្នែកបំណុល (ប្រាក់បញ្ញើ និងកម្ចីផ្សេងទៀត) ជំនួសឱ្យដើមទុនស្នូលរបស់ខ្លួន។[25] ក្នុងការអនុវត្តជាក់ស្តែង កម្ចី និងការវិនិយោគរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានឥណប្រតិទានជាក់លាក់ ហើយមិនអាចបម្លែងជាសាច់ប្រាក់បានដោយងាយស្រួលឡើយ។ ទន្ទឹមនឹងនេះ បំណុលភាគច្រើនរបស់ខ្លួន គឺ ប្រាក់បញ្ញើសន្សំ និង ប្រាក់បញ្ញើចរន្ត ដែលពុំមានកាលកំណត់ជាក់លាក់នោះទេ ដូច្នេះ អ្នកដាក់ប្រាក់បញ្ញើអាចចូលទៅប្រើប្រាក់សន្សំរបស់ខ្លួន

[23] (Reserve Bank of Australia, 2018)
[24] (Gertler, 1988)
[25] (Stellinga, Hoog, Riel, & Vries, 2021)

នៅពេលណាក៏បាន។ ជាមួយគ្នានេះផងដែរ គ្រឹះស្ថាន ត្រូវទទួលខុសត្រូវលើការសងប្រាក់ទៅអ្នកដាក់ប្រាក់បញ្ញើវិញ នៅពេលដែលមានតម្រូវការក្នុងការដកប្រាក់។ ភាពមិនត្រូវគ្នានៃកាលកំណត់នេះ ធ្វើឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវប្រឈមនឹងហានិភ័យសន្ទនីយភាព ឬហានិភ័យនៃការមិនត្រូវគ្នានៃបំណុលនិងទ្រព្យសកម្ម ដែលអាចនឹងប៉ះពាល់ដល់ស្ថិរភាព និងប្រតិបត្តិការរបស់ខ្លួន ហើយថែមទាំងគំរាមកំហែងមកលើប្រព័ន្ធធនាគារទាំងមូលផងដែរ។[26]

### ខ១.១.២. ការរំពឹងទុកបែបផុយស្រួយ

ក្នុងស្ថានភាពធម្មតា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានទុនបម្រុងនិងសន្ទនីយភាពគ្រប់គ្រាន់សម្រាប់ការដកប្រាក់របស់អ្នកដាក់ប្រាក់បញ្ញើដែលបានជូនដំណឹង។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមានពាក្យចចាមអារ៉ាមថា គ្រឹះស្ថាន មួយកំពុងប្រឈមមុខនឹងបញ្ហាសន្ទនីយភាព ហើយទំនងជាដួលរលំ នោះអ្នកដាក់ប្រាក់បញ្ញើទាំងអស់នឹងកើតមានការសង្ស័យចំពោះនិរន្តរភាពរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនោះ។ ជាលទ្ធផល ទាំងអ្នកដាក់ប្រាក់បញ្ញើដែលបានជូនដំណឹង (ដែលត្រូវការសន្ទនីយភាព) និងអ្នកដាក់ប្រាក់បញ្ញើដែលមិនបានជូនដំណឹង (ដែលមិនត្រូវការសន្ទនីយភាព) នឹងតម្រង់ជួរដើម្បីដកប្រាក់របស់ពួកគេក្នុងពេលតែមួយ។ អ្នកដាក់ប្រាក់បញ្ញើដែលមិនបានជូនដំណឹងទាំងអស់នេះ ត្រូវបានគេជឿថា គឺជាចលករដ៏សំខាន់ដែលបង្កឱ្យមានការសម្រុកដកប្រាក់ចេញពីធនាគារ។[27] ក្នុងអំឡុងពេលស្ថានការណ៍រឹករវនេះ ឥទ្ធិពលដូមីណូ (Domino effect) ទំនងជានឹងកើតមាន ដោយសារយន្តការនៃ "អ្នកមកមុន ត្រូវបម្រើមុន" និងការដឹងអំពីប្រព័ន្ធធនាគារ។ សម្រាប់ការដកប្រាក់បញ្ញើ ពុំមានលំដាប់លំដោយឡើយ។ នៅពេលដែលតម្លៃទ្រព្យសកម្មរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធ្លាក់ចុះភ្លាមៗ ហើយគ្រឹះស្ថានពុំមានទុនបម្រុងគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចទូទាត់ប្រាក់បញ្ញើត្រឡប់ដល់សាធារណជនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនោះ នឹងសម្រេចផ្អាកការដកប្រាក់របស់អ្នកដាក់ប្រាក់បញ្ញើមួយចំនួន។ ជាលទ្ធផល អ្នកដាក់ប្រាក់បញ្ញើដែលមកមុន អាចដកប្រាក់របស់ខ្លួនបាន ចំណែកអ្នកមកក្រោយៗ អាចបាត់បង់ប្រាក់របស់ខ្លួនទាំងអស់ក្នុងករណីដែលពុំមានយន្តការការពារអ្នកដាក់ប្រាក់បញ្ញើ។[28] ក្នុងករណីធ្ងន់ធ្ងរបំផុត នៅពេលដែលពាក្យចចាមអារ៉ាមបានសាយភាយនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ទាំងមូល សូម្បីតែ អ្នកដាក់ប្រាក់បញ្ញើក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលរឹងមាំ ក៏សង្ស័យចំពោះលទ្ធភាពចំណេញ និងនិរន្តរភាពរបស់គ្រឹះស្ថាន របស់ខ្លួននោះដែរ ហើយក៏នឹងអាចដកប្រាក់បញ្ញើរបស់ខ្លួនទាំងអស់ ដែលនេះអាចនាំទៅរកការសម្រុកដកប្រាក់ចេញពីធនាគារ នៅក្នុងប្រព័ន្ធធនាគារទាំងមូល។

[26] (Yi & Wang, 2021)
[27] (Díaz, 2000)
[28] (Anginer & Demirguc-Kunt, 2018)

**សំណួរឆ្លុះបញ្ចាំង ១១.១.**

មានពាក្យចចាមអារ៉ាមនៅលើបណ្ដាញសង្គមថា **ធនាគារ ថូម៉ាកូ** នឹងបញ្ឈប់ដំណើរការអាជីវកម្ម ដោយសារតែតម្លៃហ៊ុនរបស់ខ្លួនបន្តធ្លាក់ចុះ។ ក្រោយពេលឮដំណឹងចចាមអារ៉ាមនេះ អ្នកដាក់ប្រាក់បញ្ញើនៅធនាគារនេះ មានការព្រួយបារម្ភចំពោះប្រាក់បញ្ញើរបស់ខ្លួន ហើយក្នុងពេលដំណាលគ្នានេះ ក៏ទាមទារបិទគណនី និងដកប្រាក់បញ្ញើរបស់ខ្លួនមកវិញ មិនថានៅតាមសាខារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនេះ ឬតាមមធ្យោបាយអេឡិចត្រូនិចនោះទេ។ តើការដកប្រាក់ក្នុងពេលដំណាលគ្នានេះនឹងបង្កផលវិបាកអ្វីខ្លះដល់ធនាគារថូម៉ាកូ? នៅក្នុងសេណារីយ៉ូដ៏អាក្រក់បំផុត តើនឹងមានអ្វីកើតឡើងចំពោះប្រព័ន្ធធនាគារ ប្រសិនបើធនាគារថូម៉ាកូ ក្ស័យធន ហើយអ្នកដាក់ប្រាក់បញ្ញើមិនទទួលបានប្រាក់របស់ពួកគេមកវិញ?

## ១១.២. ភាពស្មុគស្មាញក្នុងប្រព័ន្ធធនាគារ

### ១១.២.១. ភាពស្មុគស្មាញរបស់ផលិតផល

នៅក្នុងប្រព័ន្ធធនាគារ ផលិតផលហិរញ្ញវត្ថុដែលបានបង្កើតថ្មី ដូចជាសេវាធនាគារឌីជីថល កម្ចីរវាងបុគ្គល និងបុគ្គល (P2P Lending) សេវាទូទាត់ចល័ត និងក្រោដហ្វាន់ឌីង (crowdfunding) ត្រូវបានដាក់ឱ្យដំណើរការជាបន្តបន្ទាប់ដើម្បីបង្កើនការពេញចិត្តពីអ្នកប្រើប្រាស់សេវា និងផលិតផលហិរញ្ញវត្ថុ បង្កើនលទ្ធភាពស្វែងរកប្រាក់ចំណេញ និងពង្រីកចំណែកទីផ្សារ។ ទោះជាយ៉ាងណាក៏ដោយ ផលិតផលហិរញ្ញវត្ថុដែលបង្កើតថ្មីទាំងនេះបង្កើនភាពស្មុគស្មាញ ដែលធ្វើឱ្យ និយ័តករមានការលំបាកក្នុងដាក់បទប្បញ្ញត្តិទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពធានាបាននូវស្ថិរភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុដើម្បីការពារអ្នកប្រើប្រាស់ និងទប់ស្កាត់ឥរិយាបថប្រថុយប្រថានដែលមិនអាចទទួលយកបាននិងមិនអាចគ្រប់គ្រងបានរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ជាក់ស្ដែង ផលិតផលបង្កើតថ្មី ទាក់ទិននឹងកម្ចីអចលនវត្ថុ (កម្ចីដែលមានអត្រាផ្លាស់ប្ដូរ "ARMs") និងឧបករណ៍និស្សន្ទ (មូលបត្រធានាដោយកម្ចីអចលនវត្ថុ "MBS" និងកាតព្វកិច្ចបំណុលមានវត្ថុបញ្ចាំ "CDO") នៅមុនវិបត្តិហិរញ្ញវត្ថុសកលលោក ត្រូវបានប្រើប្រាស់ដោយ ធនាគារ ពាណិជ្ជ និងធនាគារវិនិយោគ ដើម្បីបង្កើនកម្រិតអនុភាព (Leverage Levels) និងពង្រីកការផ្ដល់ប្រាក់កម្ចីអចលនវត្ថុ ដល់អ្នកខ្ចីដែលមានប្រវត្តិឥណទានមិនល្អ ក្នុងគោលបំណងសម្រួលដល់តម្រូវការខ្ពស់នៃទីផ្សារកម្ចីអចលនវត្ថុ។ ឧបករណ៍និស្សន្ទទាំងនោះមានរចនាសម្ព័ន្ធស្មុគស្មាញ តម្លៃនៃឧបករណ៍ទាំងនោះ ពឹងផ្អែកលើតម្លៃជាមូលដ្ឋានរបស់ទ្រព្យសកម្មផ្សេងទៀត (ជាពិសេស កម្ចីអចលនវត្ថុ)។ វិនិយោគិន និងមហាជនពិតជាមានការយល់ដឹងតិចតួចអំពីឧបករណ៍ទាំងនោះ។

ម្យ៉ាងវិញទៀត និយ័តករសហរដ្ឋអាមេរិកបានបរាជ័យ ក្នុងការគ្រប់គ្រងលើទីផ្សារកម្ចីអចលនវត្ថុ នៅពេលនោះ ដែលនេះអនុញ្ញាតឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានឱកាសពង្រីកការវិនិយោគរបស់ខ្លួននៅក្នុងទីផ្សារកម្ចីអចលនវត្ថុ និងបង្កើនវិធីសាស្ត្រប្រថុយប្រថានដែលជាលទ្ធផលនាំទៅរកការដួលរលំនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធំៗ នៅសហរដ្ឋអាមេរិក មានដូចជាធនាគារ Lehman Brother ដែលផ្តល់កម្ចីអចលនវត្ថុហួសកម្រិត ហើយពុំមានសន្ទនីយភាពគ្រប់គ្រាន់ ក៏ដូចជាដើមទុនស្នូល ដើម្បីរ៉ាប់រងចំពោះការខាតបង់ដែលមិនបានរំពឹងទុកនៅពេលដែលទីផ្សារកម្ចីអចលនវត្ថុស្រាប់តែរលំភ្លាមៗ។ លើសពីនេះទៅទៀត ដោយសារតែទំហំដ៏ធំនៃភាពជាប់ទាក់ទងគ្នាទៅវិញទៅមកក្នុងចំណោម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទាំងអស់ ដូច្នេះបរាជ័យក្នុងប្រព័ន្ធធនាគារបាននាំឱ្យមានភាពបរាជ័យនៃប្រព័ន្ធហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ចទាំងមូល ហើយបន្ទាប់មកឥទ្ធិពលនេះបានរីករាលដាលពាសពេញពិភពលោក។ វិបត្តិកន្លងមកនេះបានផ្តល់មេរៀនជាក់ស្តែងដល់និយ័តករទាំងអស់ឱ្យមានការប្រុងប្រយ័ត្នបន្ថែមទៀត ចំពោះផលិតផលដែលទើបបង្កើតថ្មីៗ។

### ខ១.២.២. ភាពស្មុគស្មាញនៃការប្រើប្រាស់បច្ចេកវិទ្យា

សព្វថ្ងៃនេះ នវានុវត្តន៍បច្ចេកវិទ្យានាពេលបច្ចុប្បន្នបានជួយបង្កើនល្បឿននៃការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធធនាគារបន្ថែមទៀត បើធៀបនឹងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ បច្ចេកវិទ្យាទាំងនេះបាន នឹងកំពុងបង្កើនការភ្ជាប់ទំនាក់ទំនង និងការប្រកួតប្រជែងក្នុងចំណោមបណ្តាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបច្ចេកវិទ្យានេះអនុញ្ញាតឱ្យគ្រឹះស្ថានទាំងនោះអាចអភិវឌ្ឍ និងផ្តល់សេវានិងផលិតផលកាន់តែមានប្រសិទ្ធភាព ចំណាយទាប និងកាន់តែមានភាពងាយស្រួលដល់អ្នកប្រើប្រាស់ ហើយក៏បានបង្កើនភាពស្មុគស្មាញនៅក្នុងប្រព័ន្ធ ដែលទាមទារការយកចិត្តទុកដាក់ខ្ពស់ពីនិយ័តករ។ នវានុវត្តន៍បច្ចេកវិទ្យាក្នុងវិស័យហិរញ្ញវត្ថុ គឺជាការរួមចំណែកដ៏សំខាន់មួយក្នុងការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ ក៏ដូចជាកំណើនសេដ្ឋកិច្ចផងដែរ។ ទន្ទឹមនឹងនេះ នវានុវត្តន៍នេះក៏មានទំនាក់ទំនងជាមួយនឹងហានិភ័យមូលដ្ឋានជាច្រើន ដែលអាចនាំឱ្យមានអស្ថិរភាព នៃប្រព័ន្ធធនាគារទាំងមូលនៅពេលដែលពុំមាននិយ័តកម្មគ្រប់គ្រាន់។[29]

### ខ១.២.៣. ការចូលរួមរបស់និយ័តករនៅក្នុងបរិបទនៃភាពស្មុគស្មាញផ្នែកបច្ចេកវិទ្យា និងផលិតផល

ភាពផុយស្រួយ និងភាពស្មុគស្មាញនៅក្នុងប្រព័ន្ធធនាគារនេះ រួមចំណែកឱ្យមានវិបត្តិហិរញ្ញវត្ថុដែលមិនត្រឹមតែមានផលប៉ះពាល់លើប្រព័ន្ធហិរញ្ញវត្ថុប៉ុណ្ណោះទេ ក៏ប៉ុន្តែប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសុខុមាលភាពសង្គមផងដែរ។ ដូច្នេះ និយ័តករត្រូវតែបន្តពង្រឹងក្របខណ្ឌបទប្បញ្ញត្តិរបស់ខ្លួន ដើម្បីដើរឱ្យទាន់នឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងវិស័យធនាគារ។ ការមានបទ

[29] (Xavier, 2011)

ប្បញ្ញត្តិគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាពគឺមានសារៈសំខាន់ណាស់ ដើម្បីធានាសុវត្ថិភាព និងភាពរឹងមាំរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនីមួយៗព្រមថែមទាំងលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុ និងធានាដល់កិច្ចការពារអ្នកប្រើប្រាស់ផងដែរ។ តួយ៉ាង បទប្បញ្ញត្តិស្តីពីដើមទុននិងសន្ទនីយភាពរបស់ គ្រឹះស្ថាន គឺមានសារៈសំខាន់ដើម្បីធានាថា គ្រឹះស្ថាន មានមូលដ្ឋានដើមទុនរឹងមាំ និងមានទ្រព្យសកម្មដែលមានគុណភាពនិងសន្ទនីយភាពខ្ពស់ សម្រាប់រ៉ាប់រងចំពោះការខាតបង់ដែលមិនបានរំពឹងទុក និងបំពេញតម្រូវការសន្ទនីយភាពភ្លាមៗនាពេលអនាគត។

ទន្ទឹមនឹងនេះ ក៏មានវិធីសាស្ត្រស្វែងរក និងទប់ស្កាត់ការប្រព្រឹត្តមិនត្រឹមត្រូវ និងឥរិយាបថដែលប្រថុយប្រថានខ្ពស់ ដែលអាចបង្កើនភាពងាយរងគ្រោះនៅក្នុងប្រព័ន្ធធនាគារផងដែរ។ លើសពីនេះ បទប្បញ្ញត្តិនានានឹងពង្រឹងកិច្ចការពារអ្នកប្រើប្រាស់ និងតម្លាភាពនិងការអនុវត្តទីផ្សារ ផងដែរ។ បទប្បញ្ញត្តិ ក៏ជួយធានាដល់ការបង្ហាញព័ត៌មានជាសាធារណៈនៅក្នុងប្រព័ន្ធធនាគារ ក្នុងគោលបំណងជៀសវាងនូវព័ត៌មានមិនស៊ីមេទ្រី និងផលប៉ះពាល់ខាងក្រៅ ដែលអាចប៉ះពាល់ដល់បរិយាកាសវិស័យធនាគារ។ បន្ថែមពីលើនេះ និយ័តករបន្តទប់ស្កាត់ការឆ្លៀតយកចំណេញពីច្បាប់ណាមួយ (ការទិញ និងលក់ទ្រព្យសម្បត្តិដូចគ្នាក្នុងពេលដំណាលគ្នានៅក្នុងទីផ្សារខុសគ្នា ដើម្បីទទួលបានប្រាក់ចំណេញតិចតួចពីតម្លៃទ្រព្យសកម្ម) និងចំណុចចន្លោះប្រហោងនានា តាមរយៈការដាក់ចេញនូវយន្តការមួយចំនួន ដើម្បីផ្តល់ជាក្របខណ្ឌច្បាប់ដែលអំណោយផល។ ធ្វើដូច្នេះ អាចបង្កើនជំនឿទុកចិត្តរបស់សាធារណជន ទប់ស្កាត់ហានិភ័យជាប្រព័ន្ធ កាត់បន្ថយការរីករាលដាលនៃការភ័យស្លន់ស្លោផ្នែកហិរញ្ញវត្ថុ និងទប់ស្កាត់លទ្ធភាពនៃ ការសម្រុកដកលុយពីធនាគារនៅក្នុងប្រព័ន្ធធនាគារ។

**សំណួរឆ្លុះបញ្ចាំង ១១.២.**

**ធនាគារ ថូម៉ាក្ង** ថ្មីៗនេះបានណែនាំសេវាបើកគណនីតាមអនឡាញ ដើម្បីពង្រីកចំណែកទីផ្សាររបស់ខ្លួន និងសម្រួលដល់ដំណើរការបើកគណនីធនាគារ។ តាមរយៈសេវាប្រកបដោយនវានុវត្តន៍នេះ គ្រប់គ្នាអាចបើកគណនីធនាគារថ្មីនៅ**ធនាគារ ថូម៉ាក្ង** បានតាមប្រព័ន្ធអេឡិចត្រូនិចភ្លាមៗដោយប្រើទូរសព្ទស្មាតហ្វូន ឬឧបករណ៍ចល័តរបស់ខ្លួន។ អតិថិជនមិនត្រូវបានតម្រូវឱ្យធ្វើដំណើរទៅសាខារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីបំពេញលក្ខខណ្ឌ "ស្គាល់អតិថិជនរបស់អ្នក (KYC)" ឡើយ។ អតិថិជនគ្រាន់តែផ្តល់ឯកសារ KYC ទាំងនោះដោយស្កេនអត្តសញ្ញាណប័ណ្ណ ថតរូបផ្ទាល់ខ្លួន បំពេញលេខទូរសព្ទ និងព័ត៌មានផ្ទាល់ខ្លួនមួយចំនួនផ្សេងទៀត ហើយផ្ញើឯកសារទាំងនោះតាមរយៈកម្មវិធីធនាគារចល័ត គឺរួចជាស្រេច។ ហេតុអ្វីបាន

**ជាធនាគារ ថូម៉ាក្** ផ្តល់សេវាបែបនេះដល់អតិថិជន? តើត្រូវធ្វើអ្វីខ្លះដើម្បីទប់ទល់នឹងហានិភ័យហិរញ្ញវត្ថុដែលអាចកើតមានទាក់ទងនឹងនវានុវត្តន៍នេះ?

## ១២. ពណ៌នាអំពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជា និងនិយ័តករអន្តរជាតិ

នៅក្នុងប្រទេសនីមួយៗ និយ័តករហិរញ្ញវត្ថុ ឬអាជ្ញាធរត្រួតពិនិត្យត្រូវបានបង្កើតឡើងក្នុងគោលបំណងត្រួតពិនិត្យ គ្រប់គ្រង និងកំណត់ក្រមប្រតិបត្តិដល់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ក្នុងគោលដៅធានាស្ថិរភាពហិរញ្ញវត្ថុ តម្លាភាពនៃដំណើរការទីផ្សារហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់។[30] សម្រាប់ប្រទេសមួយចំនួន និយ័តករហិរញ្ញវត្ថុ ឬអាជ្ញាធរត្រួតពិនិត្យត្រូវបានញែកឱ្យដាច់ចេញពីធនាគារកណ្តាលរបស់ប្រទេសនោះ។ ជាក់ស្តែង នៅចក្រភពអង់គ្លេស ធនាគារកណ្តាលរបស់ប្រទេសនេះ គឺជាអាជ្ញាធររូបិយវត្ថុរបស់ប្រទេស ខណៈដែលអាជ្ញាធរក្រមប្រតិបត្តិហិរញ្ញវត្ថុគឺជានិយ័តករសេវាហិរញ្ញវត្ថុរបស់ប្រទេស។ ទោះជាយ៉ាងណា នៅកម្ពុជា អាជ្ញាធរត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបំបែកចេញជាអាជ្ញាធរចំនួនពីរផ្សេងគ្នា គឺក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាល និងអាជ្ញាធរត្រួតពិនិត្យធនាគារ។

### ១២.១. ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ។ អង្គភាពនានាដែលស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានតួនាទី ត្រួតពិនិត្យ និងគ្រប់គ្រងអ្នកផ្តល់សេវាហិរញ្ញវត្ថុមិនមែនធនាគារត្រូវបានប្រែក្លាយ ទៅជានិយ័តករហិរញ្ញវត្ថុមិនមែនធនាគារ ដូចជានិយ័តករធានារ៉ាប់រងកម្ពុជា និយ័តករមូលបត្រកម្ពុជា និយ័តករសន្តិសុខសង្គម និយ័តករបរធនបាលកិច្ច (Trust Regulator) និយ័តករគណនេយ្យ និងសវនកម្ម និងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ។ ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ គោលបំណងនៃការបង្កើតអាជ្ញាធរទាំងនេះគឺដើម្បីបង្កើន និងធានាឱ្យបាននូវការអនុវត្ត ប្រកបដោយប្រសិទ្ធភាពនូវបទប្បញ្ញត្តិនានា ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីត្រួតពិនិត្យ និងតាមដានអ្នកផ្តល់សេវាហិរញ្ញវត្ថុមិនមែនធនាគារ និងជំរុញលើកទឹកចិត្តឱ្យមាននវានុវត្តន៍ផ្នែកបច្ចេកវិទ្យានៅក្នុងផលិតផល និងសេវាហិរញ្ញវត្ថុមិនមែនធនាគារនេះ ក្នុងគោលដៅលើកកម្ពស់ និងអភិវឌ្ឍបន្ថែមទៀតដល់ទីផ្សារហិរញ្ញវត្ថុរបស់ពួកគេ។

---

[30] (Kumar, 2014)

ក្រុមប្រឹក្សាអាជ្ញាធរហិរញ្ញវត្ថុមិនមែនធនាគារត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការដោយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ "NBFSA" (២០២១) ដើម្បីអនុវត្តមុខងារ និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងស្នើឡើងនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ដាក់ចេញនូវផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ពិនិត្យ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពទាំងនោះ
- ពិនិត្យ និងសម្រេចលើការរៀបចំប្រកាស សារាចរ និងសេចក្តីណែនាំផ្សេងៗ ដើម្បីគ្រប់គ្រងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ពិនិត្យ និងសម្រេចលើលក្ខខណ្ឌ នីតិវិធី និងវិធានដើម្បីផ្តល់ ព្យួរ និងដកហូតអាជ្ញាបណ្ណសម្រាប់អ្នកផ្តល់សេវាហិរញ្ញវត្ថុមិនមែនធនាគារ
- លើកកម្ពស់ការអនុវត្ត និងជំរុញដល់ការប្រតិបត្តិ និងអនុលោមភាពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ត្រួតពិនិត្យការអនុវត្តតួនាទី និងភារកិច្ចរបស់និយ័តករក្រោមឱវាទ។

### ២២.២. ធនាគារជាតិនៃកម្ពុជា (NBC)

ធនាគារជាតិនៃកម្ពុជា គឺជាធនាគាររបស់ស្ថាប័នរាជរដ្ឋាភិបាល និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឯកជន ដូច្នេះធនាគារជាតិនៃកម្ពុជា មិនផ្តល់សេវាហិរញ្ញវត្ថុណាមួយដល់សាធារណជនឡើយ។ ធនាគារជាតិនៃកម្ពុជា ដើរតួជាអាជ្ញាធររូបិយវត្ថុ និង ត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា។ បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺរក្សាស្ថិរភាពថ្លៃដើម្បីធានាបាននូវលក្ខខណ្ឌទីផ្សារអំណោយផលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ត្រួតពិនិត្យ និងគ្រប់គ្រងយ៉ាងតឹងរ៉ឹងចំពោះរូបិយវត្ថុកំពុងចរាចរណ៍ ដើម្បីរក្សាស្ថិរភាពរូបិយវត្ថុ និងគ្រប់គ្រង និងត្រួតពិនិត្យលើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ការណ៍នេះបានធានាដល់ស្ថិរភាពប្រព័ន្ធធនាគារ ការប្រព្រឹត្តិទៅរបស់ទីផ្សារ និងកិច្ចការពារអ្នកប្រើប្រាស់។

ធនាគារជាតិនៃកម្ពុជា ត្រូវបានកំណត់ដោយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា ដើម្បីបំពេញមុខងារ និងភារកិច្ចដូចខាងក្រោម៖[31]

- កំណត់គោលដៅនយោបាយរូបិយវត្ថុ ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា

[31] (National Bank of Cambodia, 1996)

- ត្រិះរិះរក អនុវត្ត និងត្រួតពិនិត្យនយោបាយរូបិយវត្ថុ និងប្តូរប្រាក់ឱ្យសម្រេចទៅតាមគោលដៅដែលបានកំណត់
- ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតី រួចចេញផ្សាយលទ្ធផល ហើយលើកសំណើ និងវិធានការជូនរាជរដ្ឋាភិបាល
- ផ្តល់ ឬដកហូតអាជ្ញាបណ្ណអាជីវកម្ម ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងគ្រឹះស្ថានឯទៀត ដែលពាក់ព័ន្ធ ដូចជា ស្នងការគណនី គ្រឹះស្ថានជម្រះបញ្ជី ជាដើម ព្រមទាំងចេញបទបញ្ជា និងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ
- ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជា និងកែលម្អប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ
- ទទួលភារកិច្ចផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ទទួលខុសត្រូវ និងអនុវត្ត ក្នុងនាមព្រះរាជាណាចក្រកម្ពុជា នូវកិច្ចការទាំងឡាយណាដែលជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នអន្តរជាតិសាធារណៈក្នុងកិច្ចការធនាគារ ឥណទានរូបិយវត្ថុ
- ដំឡើងតារាងជញ្ជីងទូទាត់
- ផ្តល់ ឬ ដកហូតអាជ្ញាបណ្ណ ចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ សង្ហារិមបណ្ណ ត្បូងថ្ម និងលោហៈធាតុមានតម្លៃ ព្រមទាំងចេញបទបញ្ជា និងត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ
- កំណត់អត្រាការប្រាក់ និង
- ចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យជាមួយប្រទេសក្រៅ។

ដោយទទួលភារកិច្ចជាអាជ្ញាធរត្រួតពិនិត្យធនាគារនៅក្នុងប្រទេស ធនាគារជាតិនៃកម្ពុជាកំពុងអនុវត្តវិធីសាស្ត្រត្រួតពិនិត្យធនាគារផ្អែកលើច្បាប់ និងផ្អែកលើហានិភ័យ ដើម្បីបន្តធ្វើឱ្យប្រព័ន្ធធនាគារមានស្ថិរភាព ដោយធានាបាននូវតម្លាភាពទីផ្សារ និងពង្រឹងទំនុកចិត្តរបស់សាធារណជន។ ក្នុងន័យនេះ ដំណើរការផ្តល់អាជ្ញាបណ្ណតឹងរ៉ឹង និងលក្ខខណ្ឌដើមទុនអប្បបរមាខ្ពស់សម្រាប់អាជីវកម្មធនាគារ បានធ្វើឡើង ដើម្បីធានាថាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកំពុងធ្វើប្រតិបត្តិការ ដោយមានដើមទុន រឹងមាំ និងកម្រិតអនុភាព (Leverage) ដែលអាចគ្រប់គ្រងបាន។ ធនាគារជាតិនៃកម្ពុជាក៏កំពុងពិនិត្យមើលជាប្រចាំនូវបទប្បញ្ញត្តិក្នុងវិស័យនេះនិងបង្កើតបទប្បញ្ញត្តិថ្មីៗ ដើម្បីដើរឱ្យទាន់កំណើនយ៉ាងឆាប់រហ័សនៅក្នុងវិស័យធនាគារ។ ក្រុមជំនាញវិភាគហានិភ័យ ក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីទទួលខុសត្រូវក្នុងការត្រួតពិនិត្យ តាមដាន និងវិភាគហានិភ័យដែលពាក់ព័ន្ធជាមួយនឹងគ្រឹះស្ថាន ក៏ដូចជាប្រព័ន្ធទាំងមូល ក្នុងគោលបំណងធានានូវភាពរឹងមាំនៃប្រព័ន្ធធនាគារ។ សម្រាប់ក្របខណ្ឌត្រួតពិនិត្យធនាគារ អាជ្ញាធរត្រួតពិនិត្យមាន

ទំនួលខុសត្រូវធ្វើការត្រួតពិនិត្យលើឯកសារ និងការពិនិត្យដល់ទីកន្លែង ជាមួយនឹងវិធីសាស្ត្រផ្អែកលើហានិភ័យ និងទស្សនៈពេលអនាគតទៅមុខ ចំពោះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីធានានិរន្តរភាពប្រតិបត្តិការរបស់គ្រឹះស្ថានទាំងនោះ និងដើម្បីអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានា។ លើសពីនេះទៅទៀត ក្នុងនាមជាស្ថាប័នដឹកនាំមួយសម្រាប់អនុវត្តយុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុជាតិឆ្នាំ ២០១៩-២០២៥ (NFIS)[32] ធនាគារជាតិនៃកម្ពុជា មានកាតព្វកិច្ចអនុវត្តផែនការសកម្មភាពដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិ សំដៅលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដើម្បីបង្កើនភាពងាយស្រួល និងការប្រើប្រាស់ជាផ្លូវការនូវសេវាហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជា ត្រូវតែធានាឱ្យមានការប្រកួតប្រជែងទីផ្សារដោយស្មើភាព និងការការពារអ្នកប្រើប្រាស់តាមរយៈការត្រួតពិនិត្យជាប្រចាំលើគ្រឹះស្ថាននិងតាមដានការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ និងសេវាហិរញ្ញវត្ថុដែលមានភាពនវានុវត្តន៍។

## ២២.៣. គណកម្មាធិការបាសែលសម្រាប់ការត្រួតពិនិត្យធនាគារ

សកលភាវូបនីយកម្មហិរញ្ញវត្ថុ គឺជាផ្នែកមួយនៃសកលភាវូបនីយកម្មសេដ្ឋកិច្ច។ សកលភាវូបនីយកម្មហិរញ្ញវត្ថុបានផ្តល់អត្ថប្រយោជន៍សំខាន់ៗ ដល់ទីផ្សារហិរញ្ញវត្ថុនៅក្នុងប្រទេសដែលកំពុងរីកចម្រើន ឬកំពុងអភិវឌ្ឍ។ សកលភាវូបនីយកម្មហិរញ្ញវត្ថុក៏បានពង្រឹងប្រព័ន្ធហិរញ្ញវត្ថុតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ និងការកើនឡើងនៃលំហូរដើមទុនឆ្លងប្រទេស ដើម្បីគាំទ្រដល់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាក៏ដោយ សកលភាវូបនីយកម្មហិរញ្ញវត្ថុក៏បង្កើតភាពងាយរងគ្រោះនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ និងបង្កើនលទ្ធភាពនៃការកើតមានវិបត្តិហិរញ្ញវត្ថុផងដែរ។[33]

ក្នុងគោលដៅធានាបាននូវស្ថិរភាព និងភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុក៏ដូចជារក្សានិងពង្រឹងទំនុកចិត្តពីសាធារណជន និយ័តករត្រូវតែបន្តពង្រឹងក្របខណ្ឌបទប្បញ្ញត្តិនិងត្រួតពិនិត្យរបស់ខ្លួន។ ក្នុងន័យនេះ គណៈកម្មាធិការទីក្រុងបាសែលសម្រាប់ត្រួតពិនិត្យធនាគារ (BCBS) ត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់គុណភាពនៃបទប្បញ្ញត្តិ និងការត្រួតពិនិត្យធនាគារនៅទូទាំងពិភពលោកតាមរយៈការកំណត់បញ្ហាបច្ចុប្បន្ន ដែលកើតចេញពីសកលភាវូបនីយកម្មហិរញ្ញវត្ថុ និងការអភិវឌ្ឍស្តង់ដារជាសកល គោលការណ៍ណែនាំ និងការអនុវត្តត្រឹមត្រូវសម្រាប់ ក្របខណ្ឌបទប្បញ្ញត្តិ និងត្រួតពិនិត្យដោយប្រុងប្រយ័ត្ន។[34] និយ័តករ ឬអាជ្ញាធរត្រួតពិនិត្យអាចប្រើប្រាស់ស្តង់ដារ ឬគោលការណ៍ណែនាំរបស់ BCBS ជាមូលដ្ឋានសម្រាប់ការបង្កើតបទប្បញ្ញត្តិ និងការត្រួតពិនិត្យរបស់ខ្លួន។

---

[32] (The Council of Ministers, 2019)
[33] (Schmukler, 2004)
[34] (Bank for Internation Settlements, 2018)

តួយ៉ាង នៅក្នុងឆ្នាំ១៩៨៨ គណៈកម្មាធិការទីក្រុងបាសែលសម្រាប់ត្រួតពិនិត្យធនាគារ (BCBS) បានដាក់ចេញនូវកិច្ចព្រមព្រៀងបាសែល ដែលកំណត់កម្រិតបទដ្ឋានអប្បបរមា និងរបៀបវាស់វែង អនុបាតភាពគ្រប់គ្រាន់នៃដើមទុន(CAR) របស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីធានាថា គ្រឹះស្ថានទាំង នោះមានមូលធនរឹងមាំសម្រាប់រ៉ាប់រងការខាតបង់ដែលមិនបានរំពឹងទុកនាពេលអនាគត។ កិច្ចព្រមព្រៀងបាសែល ទីមួយត្រូវបានគេហៅថា **បាសែល ១** ដែលក្នុងនោះ កម្រិតនៃហានិភ័យឥណទានគឺជាកត្តាកំណត់តែមួយគត់សម្រាប់លក្ខខណ្ឌដើមទុនអប្បបរមា។ បន្ទាប់មក កិច្ចព្រមព្រៀងនេះត្រូវបានកែប្រែទៅជា **បាសែល ២** ដែលត្រូវបានបែងចែកចេញជា **សសរស្តម្ភចំនួនបី។**

- **សសរស្តម្ភទី ១៖** តម្រូវការដើមទុនអប្បបរមា ត្រូវកំណត់ដោយកម្រិតនៃហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ និងហានិភ័យទីផ្សារ។
- **សសរស្តម្ភទី ២៖** អាជ្ញាធរត្រួតពិនិត្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវវាយតម្លៃយ៉ាងតឹងរ៉ឹងនូវវិធីសាស្ត្រវាស់វែង អនុបាតភាពគ្រប់គ្រាន់នៃមូលធន ( CAR)។
- **សសរស្តម្ភទី ៣៖** វិន័យទីផ្សារ និងតម្លាភាពទីផ្សារត្រូវធានា និងពង្រឹងឱ្យបាន។

បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុពិភពលោកកើតមានមក កិច្ចព្រមព្រៀងទីក្រុងបាសែលត្រូវបានកែទម្រង់ម្តងទៀតទៅជា **បាសែល ៣** ដើម្បីដោះស្រាយហានិភ័យជាប្រព័ន្ធ និងហានិភ័យសន្ទនីយភាព។ សសរស្តម្ភទាំងបីនៅតែមានដដែល ប៉ុន្តែគុណភាព និងភាពគ្រប់គ្រាន់នៃមូលធនត្រូវបានកែលម្អ។ តម្រូវការទ្រនាប់ដើមទុនថ្មី ត្រូវបានណែនាំឱ្យអនុវត្ត ហើយកម្រិតអានុភាព (Leverage)របស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានរឹតត្បឹត ដើម្បីពង្រឹងឧបករណ៍សន្ទនីយភាព ដែលក្នុងនោះរួមមានអនុបាតគ្របខណ្ឌសន្ទនីយភាព (LCR) និង អនុបាតមូលនិធិថេរសុទ្ធ (NSFR)។ អនុបាតគ្របខណ្ឌសន្ទនីយភាព (LCR) ត្រូវបានបង្កើតឡើងដើម្បីជំនួសឱ្យអនុបាតសន្ទនីយភាព ដែលពុំមានប្រសិទ្ធភាពសម្រាប់ឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចបន្តប្រតិបត្តិការបាន អំឡុងពេលមានភាពរង្គោះរង្គើសន្ទនីយភាពរយៈពេលខ្លីភ្លាមៗនៅក្នុងទីផ្សារ។ អនុបាតគ្របខណ្ឌសន្ទនីយភាព (LCR) ខ្ពស់អាចធានាបាននូវសមត្ថភាពសន្ទនីយភាពរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីអាចបន្តប្រតិបត្តិការបានក្នុងអំឡុងពេលមានសម្ពាធសន្ទនីយភាពរយៈពេលខ្លី (រហូតដល់៣០ថ្ងៃ) ដែលកើតចេញពីការរង្គោះរង្គើទីផ្សារ។ ទន្ទឹមនឹងនេះ អនុបាតមូលនិធិថេរសុទ្ធ (NSFR) ត្រូវបានរៀបចំឡើងដើម្បីលើកទឹកចិត្តឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រក្សាបានជាប្រចាំនូវ ស្ថិរភាពនៃប្រភពមូលនិធិធៀបនឹងសកម្មភាពអាជីវកម្មរបស់ខ្លួន ក្នុងគោលបំណងបង្កើនភាពធន់នៃសមត្ថភាពសន្ទនីយភាពរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ណាមួយសម្រាប់រយៈពេលវែង (ច្រើនជាងមួយឆ្នាំ)។ លើសពីនេះទៅទៀត គណៈកម្មាធិការទីក្រុងបាសែលសម្រាប់ត្រួតពិនិត្យធនាគារ (BCBS) មិនត្រឹមតែផ្តោតលើបញ្ហាភាពគ្រប់គ្រាន់នៃដើមទុនប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តោតលើសមត្ថភាពនិយ័តកម្ម និង

ការត្រួតពិនិត្យវិស័យធនាគារទាំងមូលផងដែរ។ គណៈកម្មាធិការនេះក៏បានដាក់ចេញផងដែរនូវគោលការណ៍ស្នូលបាសែល (BCPs) សម្រាប់ការគ្រប់គ្រងធនាគារប្រកបដោយប្រសិទ្ធភាព ដែលកំណត់ស្តង់ដារអប្បបរមាសម្រាប់អាជ្ញាធរត្រួតពិនិត្យធនាគារ ដើម្បីធានាបាននូវក្របខណ្ឌបទប្បញ្ញត្តិ និងការត្រួតពិនិត្យរឹងមាំលើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងឆ្នាំ១៩៩៧។ បន្ទាប់មកគោលការណ៍ស្នូលបាសែល (BCPs) ត្រូវបានធ្វើបច្ចុប្បន្នភាពពីរលើក គឺនៅក្នុងឆ្នាំ២០០៦មុនពេលមានវិបត្តិហិរញ្ញវត្ថុសកលលោក និងនៅឆ្នាំ២០១២ក្រោយពេលមានវិបត្តិហិរញ្ញវត្ថុសកលលោក។ បច្ចុប្បន្ន គោលការណ៍ស្នូលបាសែល (BCPs) មានគោលការណ៍ស្នូលចំនួន២៩ដើម្បីពង្រឹងបទប្បញ្ញត្តិ និងការត្រួតពិនិត្យរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងទិសដៅចំនួនពីរ។ ទីមួយគឺការធ្វើឱ្យប្រសើរឡើងនូវអំណាចត្រួតពិនិត្យ ការទទួលខុសត្រូវ និងមុខងាររបស់ប្រទេស និង ទីពីរគឺពង្រឹងលក្ខខណ្ឌ និងបទប្បញ្ញត្តិ ដោយមានការប្រុងប្រយ័ត្ន។

**សំណួរផ្ទុះបញ្ចាំង ខ២**

តើអ្នកផ្តល់សេវាហិរញ្ញវត្ថុប្រភេទណាខ្លះដែលត្រូវបានត្រួតពិនិត្យ និងគ្រប់គ្រងដោយក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ? តើអ្នកផ្តល់សេវាហិរញ្ញវត្ថុប្រភេទណាខ្លះដែលត្រូវបានត្រួតពិនិត្យ និងគ្រប់គ្រងដោយ ធនាគារជាតិនៃកម្ពុជា?

## ខ៣. ពណ៌នាអំពីច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងការការពារអ្នកប្រើប្រាស់នៅកម្ពុជា

### ខ៣.១. ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

ការរីកចម្រើននៃសកម្មភាពអាជីវកម្មបាននិងកំពុងរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងនាំមកនូវផលិតផល និងសេវាប្រកបដោយភាពនវានុវត្តន៍ក្នុងទីផ្សារ។ ទោះជាយ៉ាងណាក៏ដោយ ការពង្រីកខ្លួនយ៉ាងឆាប់រហ័ស និងនវានុវត្តន៍ក្នុងដំណើរការអាជីវកម្មបានបង្កឱ្យនិយ័តករមានការព្រួយបារម្ភទាក់ទងនឹងហានិភ័យនានាដល់អ្នកប្រើប្រាស់។ ជាក់ស្តែង ហានិភ័យទាក់ទងនឹងការប្រព្រឹត្តិមិនត្រឹមត្រូវលើកិច្ច ព្រមព្រៀងតែងកើតឡើងជាញឹកញាប់។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ត្រូវបានអនុម័តនៅថ្ងៃទី០២ខែវិច្ឆិកា ឆ្នាំ២០១៩។ ច្បាប់ថ្មីនេះគឺជាក្តីសង្ឃឹមថ្មីសម្រាប់អ្នកប្រើប្រាស់ ដែលផលប្រយោជន៍របស់ពួកគាត់គួរតែត្រូវបានការពារ ហើយត្រូវប្រកាន់ខ្ជាប់នូវការប្រកួតប្រជែងដោយយុត្តិធម៌នៅលើទីផ្សារ។ គោលបំណងនៃច្បាប់ថ្មីនេះ គឺដើម្បីកំណត់វិធាន និងយន្តការសម្រាប់រួមចំណែកដល់ការបង្កើតបរិបទនៃការជួញដូរដែលក្នុងនោះ៖

- សិទ្ធិ និងផលប្រយោជន៍របស់អ្នកប្រើប្រាស់ត្រូវបានការពារ
- ការធ្វើពាណិជ្ជកម្មមានការប្រកួតប្រជែងដោយសុចរិត និង
- ទាំងអ្នកប្រើប្រាស់ និងពាណិជ្ជករ ធ្វើសកម្មភាពអាជីវកម្មព្រមគ្នាដោយការជឿទុកចិត្ត។[35]

ដើម្បីអនុវត្តច្បាប់នេះការបង្កើតគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ដែលដឹកនាំដោយក្រសួងពាណិជ្ជកម្ម ដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យលើកិច្ចការពារអ្នកប្រើប្រាស់ស្របទៅតាមច្បាប់។[36] ច្បាប់នេះត្រូវប្រើជាឆត្រសម្រាប់ក្រសួង និងស្ថាប័ននានាក្នុងប្រទេសកម្ពុជាក្នុងការបង្កើតវិធាន និងបទប្បញ្ញត្តិផ្សេងៗ។ ទោះបីជាយ៉ាងណា ចាប់តាំងពីច្បាប់នេះត្រូវបានប្រកាសនៅចុងឆ្នាំ២០១៩មក គណៈកម្មាធិការនៅថ្នាក់ជាតិ និងក្រុមការងារពាក់ព័ន្ធបាន និងកំពុងធ្វើការលើការរៀបចំក្របខណ្ឌទ្រទ្រង់ផ្សេងៗ ដើម្បីអាចអនុវត្តច្បាប់ច្បាប់នេះបានគ្រប់ជ្រុងជ្រោយក៏ដូចជាធ្វើឱ្យសាធារណជនបានយល់ដឹងបានទូលំទូលាយ។

## ខ៣.២. ប្រកាសស្តីពីតម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ទោះបីជាច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ត្រូវបានអនុម័តជាផ្លូវការក្នុងឆ្នាំ២០១៩ក៏ដោយធនាគារជាតិនៃកម្ពុជា មានក្របខណ្ឌច្បាប់របស់ខ្លួន ទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់សម្រាប់ប្រព័ន្ធធនាគារចាប់តាំងពីឆ្នាំ២០១១មកម្ល៉េះ។ ប្រកាសស្តីពីតម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានគោលបំណងលើកកម្ពស់ការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានទាំងនោះ ប្រកបដោយតម្លាភាព យុត្តិធម៌ សមហេតុផល និងទំនួលខុសត្រូវ។[37] យោងតាមប្រកាសនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវបានតម្រូវឱ្យប្រព្រឹត្តចំពោះអតិថិជនរបស់ខ្លួនតាមលក្ខណៈដូចខាងក្រោមនេះ៖[38]

- គ្រប់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថាការផ្សព្វផ្សាយពាណិជ្ជកម្ម និងពាក្យពេចន៍ក្នុងការផ្សព្វផ្សាយមានលក្ខណៈយុត្តិធម៌ ច្បាស់លាស់ មិនធ្វើឱ្យភាន់ច្រឡំ។
- អតិថិជនត្រូវទទួលបានព័ត៌មានច្បាស់លាស់ អំពីផលិតផល និងសេវាកម្មទាំងឡាយនៅមុនពេល ឬក្នុងពេល ឬបន្ទាប់ពីពេលទទួលសេវាឥណទាន ដោយរួមមានបែបបទដំណើរការនៃឥណទាន លក្ខខណ្ឌអត្រាការប្រាក់ និងកម្រៃដែលជាបន្ទុករបស់អតិថិជន។
- អតិថិជនត្រូវទទួលបានព័ត៌មានជាមុនអំពីការប្រែប្រួលអត្រាការប្រាក់ កម្រៃ និងលក្ខខណ្ឌផ្សេងៗ។

[35] (Royal Government of Cambodia, 2019) Article 2
[36] (Royal Government of Cambodia, 2019), Article 3
[37] (National Bank of Cambodia, 2011), Article 1
[38] (National Bank of Cambodia, 2011), Article 2 to Article 5

- ព័ត៌មានរបស់អតិថិជនត្រូវបានរក្សាទុកជាការសម្ងាត់។ គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវផ្តល់ជូនអតិថិជននូវប្រព័ន្ធធនាគារស្នូល និងប្រព័ន្ធទូទាត់ដែលមានសុវត្ថិភាព និងអាចជឿទុកចិត្តបាន។

## ២៣.៣. ប្រកាសស្តីពីការកំណត់ពិតានអត្រាការប្រាក់

ដើម្បីការពារអ្នកប្រើប្រាស់ ទាក់ទងនឹងអត្រាការប្រាក់ខ្ពស់ហួសហេតុពីសំណាក់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងដើម្បីមានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់កម្ចីដែលមានតម្លៃសមរម្យ ធនាគារជាតិនៃកម្ពុជា បានអនុម័តប្រកាសស្តីពីការកំណត់ពិតានអត្រាការប្រាក់ឥណទាន នៅថ្ងៃទី១៣ខែមីនា ឆ្នាំ២០១៧ដែលអាចអនុវត្តចំពោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ (RCIs) ដែលគ្រឹះស្ថាននីមួយៗមិនត្រូវកំណត់អត្រាការប្រាក់លើសពី ១៨% ក្នុងមួយឆ្នាំ សម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។[39] ពិដានអត្រាការប្រាក់មានសុពលភាពសម្រាប់តែកិច្ចសន្យាកម្ចីថ្មី រួមទាំងប្រាក់កម្ចីដែលបានរៀបចំឡើងវិញ និងការផ្តល់ហិរញ្ញប្បទានឡើងវិញដែលធ្វើឡើងចាប់ពីថ្ងៃទី០១ខែមេសា ឆ្នាំ២០១៧ តទៅ។[40] បន្ទាប់ពីដាក់ឱ្យប្រើប្រាស់ប្រកាសនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានគោរពតាមការកំណត់ពិដានអត្រាការប្រាក់ដោយកាត់បន្ថយចំណាយប្រតិបត្តិការ និងអត្រាការប្រាក់លើប្រាក់បញ្ញើរបស់អតិថិជន ហើយជាលទ្ធផល អត្រាការប្រាក់ប្រចាំឆ្នាំជាមធ្យមលើកម្ចីមីក្រូហិរញ្ញវត្ថុបានថយចុះពី២០.៨% ក្នុងឆ្នាំ២០១៦មកប្រហែល ១៦% ក្នុងឆ្នាំ២០១៩។[41]

## ២៣.៤. ប្រកាសស្តីពីការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ជាទូទៅ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាជីវកម្មធនាគារមិនអាចធ្វើឡើងទៅបានដោយគ្មានការជឿទុកចិត្តពីសាធារណជននោះទេ។ ដូចគ្នានេះដែរ គោលការណ៍សំខាន់មួយក្នុងការកសាងទំនុកចិត្ត គឺត្រូវបង្កើតក្របខណ្ឌការពារអតិថិជន។ អាស្រ័យហេតុនេះ ប្រកាសស្តីពីការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានដាក់ឱ្យអនុវត្ត នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ដើម្បីរៀបចំយន្តការដោះស្រាយបណ្តឹងតវ៉ារបស់អតិថិជនរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ យោងតាមប្រកាសនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តម្រូវឱ្យបង្កើតក្របខណ្ឌគ្រប់គ្រងពាក្យបណ្តឹងអតិថិជន (CCMF) ដែលត្រូវរួមបញ្ចូលចំណុចអប្បបរមាដូចខាងក្រោមៈ[42]

---

39 (National Bank of Cambodia, 2017), Article 2 to Article 4

40 (National Bank of Cambodia, 2017), Article 5

41 (Heng, Chea, & Heng, 2021), p. 18

42 (National Bank of Cambodia, 2017), Article 6

- តួនាទីរបស់មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជនទទួលបន្ទុក អនុវត្តក្របខណ្ឌគ្រប់គ្រងបណ្តឹងអតិថិជនរបស់គ្រឹះស្ថាន។
- គោលនយោបាយ និងនីតិវិធីជាលាយលក្ខណ៍អក្សរច្បាស់លាស់ ពេញលេញ និងមានការផ្សព្វផ្សាយទូលំទូលាយដល់បុគ្គលិករបស់គ្រឹះស្ថាន។ គោលនយោបាយ និងនីតិវិធីត្រូវបានបង្កើតឡើងសម្រាប់៖
  - ➢ កំណត់ដំណើរការបណ្តឹងអតិថិជនរបស់គ្រឹះស្ថាន
  - ➢ រក្សាការសម្ងាត់ព័ត៌មានទាក់ទងនឹងបណ្តឹងអតិថិជន
  - ➢ រក្សាទុកឯកសារបណ្តឹងអតិថិជនដោយសុវត្ថិភាពយ៉ាងតិច៣ឆ្នាំ
  - ➢ បណ្តុះបណ្តាលគណៈគ្រប់គ្រង និងបុគ្គលិកដែលពាក់ព័ន្ធនឹងការអនុវត្តក្របខណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន។
- ធ្វើមជ្ឈការក្នុងការតាមដាន និងត្រួតពិនិត្យក្របខណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន
- របៀបរាយការណ៍ជាប្រចាំដល់គណៈគ្រប់គ្រងជាន់ខ្ពស់អំពីការគ្រប់គ្រង និងដោះស្រាយបណ្តឹង
- ក្រមប្រតិបត្តិនៃការរាយការណ៍ ការចៀសវាង និងការគ្រប់គ្រងការដោះស្រាយបណ្តឹងដែលពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍
- ការកំណត់ច្បាស់លាស់អំពីតួនាទី ការទទួលខុសត្រូវ និងការផ្តល់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិក ក្នុងក្របខណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន និងនីតិវិធី សម្រាប់ធ្វើការពិនិត្យ និងរាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សាភិបាលអំពីលទ្ធផលនៃការអនុវត្តក្របខណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន រួមទាំងរយៈពេលនៃដំណើរការដោះស្រាយកម្រិតនៃការពេញចិត្តរបស់អតិថិជន និងលទ្ធផលនៃបណ្តឹងអតិថិជន ដែលធនាគារជាតិនៃកម្ពុជាបានបញ្ជូនទៅ។

លើសពីនេះទៅទៀត ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានត្រូវបានតម្រូវឱ្យត្រួតពិនិត្យ និងធានាថា ក្របខណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន (CCMF) ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពដោយអនុវត្តការទទួលខុសត្រូវយ៉ាងតិចដូចខាងក្រោម[43]៖

- អនុម័ត និងធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវក្របខណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន (CCMF)
- កំណត់តួនាទី ការទទួលខុសត្រូវ និងផ្តល់សិទ្ធិអំណាចដល់មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន

[43] (National Bank of Cambodia, 2017), Article 7

- ផ្តល់ការបណ្តុះបណ្តាលសមស្របជាប្រចាំ និងទៀងទាត់ដល់ថ្នាក់គ្រប់គ្រង និងបុគ្គលិក ដែលពាក់ព័ន្ធនឹងក្របខណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន
- ធ្វើការពិនិត្យឡើងវិញប្រចាំឆ្នាំ អំពីប្រសិទ្ធភាព និងលទ្ធផលនៃការអនុវត្តក្របខណ្ឌ គ្រប់គ្រងបណ្តឹងអតិថិជន។

បន្ថែមលើនេះ គ្រឹះស្ថានត្រូវបង្កើតផ្នែកគ្រប់គ្រងបណ្តឹង ដែលទទួលបន្ទុកដោយមន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន ដើម្បីទទួល និងដោះស្រាយបណ្តឹងរបស់អតិថិជន ហើយត្រូវទទួលខុសត្រូវភារកិច្ចយ៉ាងតិចដូចខាងក្រោម៖[44]

- ទទួល និងដោះស្រាយបណ្តឹងស្របតាមគោលនយោបាយ និងនីតិវិធីរបស់គ្រឹះស្ថាន
- តាមដាន និងត្រួតពិនិត្យលទ្ធផលនៃការអនុវត្តក្របខណ្ឌគ្រប់គ្រងបណ្តឹងអតិថិជន
- ធានាថា គ្រឹះស្ថានប្រតិបត្តិតាមប្រកាសនេះ និងមានកាតព្វកិច្ចរាយការណ៍មក ធនាគារជាតិនៃកម្ពុជា
- រាយការណ៍ជាប្រចាំអំពីបណ្តឹងទៅគណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល។

**គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តម្រូវឱ្យដោះស្រាយបណ្តឹងអតិថិជន ដូចខាងក្រោមនេះ[45]៖**

**ក. បណ្តឹងផ្ទាល់មាត់**

បណ្តឹងផ្ទាល់មាត់ត្រូវដោះស្រាយក្នុងអំឡុងពេល ពីរថ្ងៃ នៃថ្ងៃធ្វើការ។ ក្នុងករណីបណ្តឹងផ្ទាល់មាត់មិនអាចដោះស្រាយបានតាមពេលកំណត់ គ្រឹះស្ថានត្រូវណែនាំដល់អតិថិជន និង/ឬ បុគ្គលតំណាងអតិថិជនឱ្យដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ។ ក្នុងករណីអតិថិជនមិនមានបំណងចង់បន្តបណ្តឹងជាលាយលក្ខណ៍អក្សរ គ្រឹះស្ថានត្រូវធ្វើកំណត់ត្រានូវការមិនពេញចិត្តរបស់អតិថិជន។ ក្នុងករណីដែលអតិថិជនមានបំណងដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ប៉ុន្តែមិនអាចធ្វើបានក្នុងហេតុផលណាមួយ គ្រឹះស្ថានត្រូវរៀបចំឯកសារបណ្តឹងនេះ ជំនួសឱ្យអតិថិជន ហើយទុកដាក់បណ្តឹងនេះតាមរយៈដំណើរការគ្រប់គ្រងបណ្តឹងអតិថិជនរបស់ខ្លួន។ គ្រឹះស្ថានត្រូវផ្តល់ច្បាប់ចម្លងនៃពាក្យបណ្តឹងមួយច្បាប់ដល់អតិថិជន។

[44] (National Bank of Cambodia, 2017), Article 8
[45] (National Bank of Cambodia, 2017), Article 9

## ខ. បណ្តឹងជាលាយលក្ខណ៍អក្សរ

សម្រាប់បណ្តឹងជាលាយលក្ខណ៍អក្សរ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានកាតព្វកិច្ចក្នុងការអនុវត្តនូវជំហានខាងក្រោមនេះ៖

- គ្រឹះស្ថានត្រូវចេញលិខិតទទួលស្គាល់បណ្តឹងជាលាយលក្ខណ៍អក្សរទៅអតិថិជន និង/ឬបុគ្គលតំណាងអតិថិជន បន្ទាប់ពីទទួលបានបណ្តឹងពីអតិថិជន។ លិខិតទទួលស្គាល់បណ្តឹងត្រូវមានបញ្ជាក់យ៉ាងតិចនូវចំណុចដូចជា លេខចុះបញ្ជី កាលបរិច្ឆេទទទួលបណ្តឹង ឈ្មោះអតិថិជន និង/ឬបុគ្គលតំណាងអតិថិជន ឈ្មោះ និងលេខទូរសព្ទបុគ្គលិករបស់គ្រឹះស្ថានដែលទទួលបណ្តឹង និង សេចក្តីសង្ខេបនៃបណ្តឹង។
- គ្រឹះស្ថានត្រូវស្វែងរកអង្គហេតុ និងដោះស្រាយបណ្តឹងមិនឱ្យលើសពី៣០ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យបណ្តឹង។ គ្រឹះស្ថានត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃដំណោះស្រាយបណ្តឹង ដោយមានបញ្ជាក់អំពីមូលហេតុច្បាស់លាស់។
- ក្នុងករណីបណ្តឹងពាក់ព័ន្ធនឹងបញ្ហាធ្ងន់ធ្ងរផ្នែកហិរញ្ញវត្ថុ បញ្ហាជាប្រព័ន្ធ ឬបញ្ហាផ្នែកច្បាប់ គ្រឹះស្ថានត្រូវបញ្ជូនបន្តទៅអ្នកជំនាញ ដើម្បីផ្តល់យោបល់ដល់គណៈគ្រប់គ្រងជាន់ខ្ពស់ ឬក្រុមប្រឹក្សាភិបាលធ្វើសេចក្តីសម្រេចចុងក្រោយ។
- គ្រឹះស្ថានត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជា ក្នុងរបាយការណ៍ត្រីមាសបន្ទាប់ នូវរាល់ការសម្រេច និងមូលហេតុនៃបណ្តឹងដែលមិនអាចដោះស្រាយបានក្នុងអំឡុងពេល៣០ថ្ងៃ។ របាយការណ៍នេះ ត្រូវពន្យល់អំពីមូលហេតុនៃការពន្យារពេល និងកំណត់កាលបរិច្ឆេទដែលត្រូវដោះស្រាយបញ្ចប់បណ្តឹង។ ក្នុងករណីនេះ គ្រឹះស្ថានត្រូវជូនដំណឹងទៅអតិថិជនអំពីការពន្យារពេល នៃដំណើរការដោះស្រាយបណ្តឹង ដោយបញ្ជាក់ អំពីមូលហេតុច្បាស់លាស់។

## គ. កាតព្វកិច្ចរាយការណ៍

ក្រៅពីការដោះស្រាយបណ្តឹងអតិថិជន គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍គ្រប់គ្រង និងដោះស្រាយបណ្តឹងមកធនាគារជាតិកម្ពុជារៀងរាល់ត្រីមាស យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥នៃខែទីមួយ នៃត្រីមាសបន្ទាប់។ របាយការណ៍នេះ ត្រូវបង្ហាញនូវព័ត៌មានយ៉ាងតិចដូចខាងក្រោម៖[46]

- ចំនួនបណ្តឹងដែលទទួលបានក្នុងគ្រារាយការណ៍

---

[46] (National Bank of Cambodia, 2017), Article 10

- បណ្តឹងដែលបានដោះស្រាយបញ្ចប់ក្នុងគ្រាវាយការណ៍
- ផលិតផល និងសេវាពាក់ព័ន្ធនឹងបណ្តឹង
- បញ្ហាជាប្រព័ន្ធក្នុងគ្រឹះស្ថាន
- រយៈពេលជាមធ្យមសម្រាប់ការដោះស្រាយបណ្តឹង
- វិធានការកែតម្រូវ ដើម្បីកាត់បន្ថយចំនួនបណ្តឹង ដែលកើតឡើងញឹកញាប់ និងមានសារៈសំខាន់ជាប្រព័ន្ធ និង
- បណ្តឹងកំពុងដំណើរការដោះស្រាយក្នុងគ្រាវាយការណ៍។

### ឃ. ការបង្ហាញនីតិវិធីបណ្តឹងអតិថិជន

ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន ដែលមានបំណងដាក់ពាក្យបណ្តឹង គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវដាក់បង្ហាញជាសាធារណៈនូវឯកសារនានាដូចខាងក្រោមៈ

- **ដំណើរការគ្រប់គ្រង និងដោះស្រាយបណ្តឹង** ដែលមានលក្ខណៈងាយយល់ ដោយមានបញ្ជាក់អំពី ពេលវេលាដោះស្រាយច្បាស់លាស់
- **ដំណើរការគ្រប់គ្រង និងដោះស្រាយបណ្តឹង នៅក្នុងគេហទំព័រ** ដោយបង្ហាញឱ្យឃើញច្បាស់នូវ ICON/LINK សម្រាប់អតិថិជនទាញយកបាន និង
- **បណ្ណព័ត៌មាន សម្រាប់ទំនាក់ទំនង** ដែលត្រូវបង្ហាញឱ្យច្បាស់លាស់អំពីលេខទូរសព្ទទាន់ហេតុការណ៍ អ៊ីមែល និងអាសយដ្ឋានសម្រាប់ទទួលបណ្តឹង។

**ក្រាហ្វិកព័ត៌មាន ២៖** គំនូសបង្ហាញពីដំណើរការគ្រប់គ្រងនិងដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ




បន្ថែមពីលើនេះទៀត ដើម្បីពង្រឹងការអនុវត្តប្រកាសស្តីពីការដោះស្រាយបណ្តឹងអតិថិជន ធនាគារជាតិនៃកម្ពុជា បាននិងកំពុងដើរតួជាផ្នែកមួយក្នុងការដោះស្រាយបណ្តឹងអតិថិជន តាមរយៈយន្តការទូរសព្ទទាន់ហេតុការណ៍ (hotline) របស់ខ្លួន ដែលមានលេខទូរសព្ទទាន់ហេតុការណ៍ចំនួន៥ខ្សែ នៅទីស្នាក់ការកណ្តាល និងបណ្តាញទូរសព្ទទាន់ហេតុការណ៍ ចំនួន២១ខ្សែ នៅតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី និងខេត្ត។ លេខទូរសព្ទទាន់ហេតុការណ៍របស់ធនាគារជាតិនៃកម្ពុជា

មិនត្រឹមតែប្រើដើម្បីទទួលពាក្យបណ្ដឹង និងចម្ងល់ផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបានប្រើប្រាស់ដើម្បីផ្ដល់សារអប់រំទាក់ទងនឹងការប្រើប្រាស់ផលិតផល និងសេវាហិរញ្ញវត្ថុដល់អ្នកហៅចូលផងដែរ។ ក្នុងឆ្នាំ២០២០ ក្រុមការងារខ្សែទូរសព្ទទាន់ហេតុការណ៍របស់ធនាគារជាតិនៃកម្ពុជា បានទទួលពាក្យបណ្ដឹង និងការសាកសួរចំនួន១០៧៣ លើក ដែលភាគច្រើនទាក់ទងនឹងផលិតផល និងសេវា ដូចជាការបង់ផ្ដាច់ប្រាក់កម្ចីមុនកាលកំណត់ ការដកទ្រព្យធានា ការគណនាការប្រាក់ ការពិន័យផ្សេងៗ បញ្ហាទាក់ទងនឹងម៉ាស៊ីនអេធីអឹម បញ្ហាទាក់ទងនឹងប្រាក់បញ្ញើ បញ្ហាទាក់ទងនឹងការិយាល័យឥណទានកម្ពុជា (CBC) ការសាកសួរផ្សេងទៀតទាក់ទងនឹងការប្រើប្រាស់ផលិតផល/សេវារបស់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ល។[47]

**សំណួរឆ្លុះបញ្ចាំង ខ៣**

សុភា ជាអតិថិជនកម្ចីរបស់**ធនាគារថ្ងៃម៉ាក្ង**។ ថ្មីៗនេះ នាងបានលក់ដីរបស់ខ្លួន ហើយមានបំណងចង់បង់ផ្ដាច់ប្រាក់កម្ចី។ កិច្ចសន្យាប្រាក់កម្ចីបានចែងថា ប្រសិនបើនាងចង់បង់ផ្ដាច់ប្រាក់កម្ចីមុនកាលកំណត់នោះ នាងត្រូវជូនដំណឹងទៅធនាគារមួយខែមុនថ្ងៃបង់ផ្ដាច់។ គាត់បានផ្ញើទម្រង់បង់ផ្ដាច់ទៅធនាគារនៅថ្ងៃទី២ខែមករា ឆ្នាំ២០២១ហើយមន្ត្រីឥណទានបានទទួលឯកសារនោះ។ នៅថ្ងៃទី២ខែកុម្ភៈ ឆ្នាំ២០២១ មន្ត្រីឥណទានបានជូនដំណឹងដល់គាត់ថា សំណើទូទាត់មិនទាន់ត្រូវបានអនុម័តនៅឡើយ ហើយបានស្នើសុំឱ្យគាត់រង់ចាំមួយសប្ដាហ៍ទៀត។ សុភាមិនសប្បាយចិត្តក៏បានទូរសព្ទទៅលេខទូរសព្ទទាន់ហេតុការណ៍របស់ធនាគារនេះនៅថ្ងៃដដែល។ តើធនាគារដោះស្រាយបណ្ដឹងរបស់នាងដោយរបៀបណា?

**ក.** ធនាគារស្នើឱ្យគាត់ដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរជាផ្លូវការ។

**ខ.** ធនាគារស្នើឱ្យគាត់ដាក់ពាក្យបណ្ដឹង តាមរយៈ ធនាគារជាតិនៃកម្ពុជា ឬសមាគមធនាគារនៅកម្ពុជា ។

**គ.** ធនាគារមិនចាត់វិធានការណាមួយលើពាក្យបណ្ដឹងរបស់គាត់ឡើយ ហើយប្រាប់ឱ្យគាត់រង់ចាំ។

**ឃ.** ធនាគារដោះស្រាយបណ្ដឹងភ្លាមៗ។ ប្រសិនបើមិនអាចដោះស្រាយបានក្នុងរយៈពេល ២ថ្ងៃនៃថ្ងៃធ្វើការ ធនាគារណែនាំឱ្យគាត់ដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរដែលនឹងត្រូវដោះស្រាយក្នុងរយៈពេល៣០ថ្ងៃ។

[47] (National Bank of Cambodia, 2021), p. 18-19

## ២៤. វាយតម្លៃផលប៉ះពាល់របស់បទប្បញ្ញត្តិនានាលើធនាគារិកកំពុងធ្វើប្រតិបត្តិការ

### តើបទប្បញ្ញត្តិនានា ជួយ ឬរាំងស្ទះដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកម្រិតណា?

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជាត្រូវបានតម្រូវឱ្យគោរពតាមច្បាប់ វិធាន បទបញ្ញាសារាចរ ជាដើមដែលកំណត់ដោយនិយ័តករ ជាពិសេស ធនាគារជាតិនៃកម្ពុជា ។ ការស្ថិតក្រោមការគ្រប់គ្រងត្រឹមត្រូវ មានផលប៉ះពាល់ជាវិជ្ជមានដោយមិនត្រឹមតែរក្សាបាននូវនិរន្តរភាពនៃប្រព័ន្ធធនាគារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹង និងរួមចំណែកដល់ការរីកចម្រើននៃគ្រឹះស្ថាននីមួយៗផងដែរ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បាននិងកំពុងប្រើប្រាស់បទប្បញ្ញត្តិនានា ដើម្បីបង្កើតផែនការអាជីវកម្មវាស់ស្ទង់ភាពប្រុងប្រយ័ត្នកាត់បន្ថយហានិភ័យនិងបង្កើតផលិតផលនិងសេវាថ្មីៗផងដែរ។ ទោះបីជាការអនុវត្តបទប្បញ្ញត្តិទាំងនោះមានអត្ថប្រយោជន៍ជាច្រើនក៏ដោយ ប៉ុន្តែ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក៏ជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនផងដែរដែលតម្រូវឱ្យពួកគេមានយុទ្ធសាស្រ្តប្រកបដោយប្រសិទ្ធភាពដើម្បីប្រែក្លាយបញ្ហាទាំងនោះទៅជាឱកាស។

បទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ទាក់ទងនឹងលក្ខខណ្ឌសម្រាប់ការផ្តល់អាជ្ញាបណ្ណដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ គឺជាបុរេលក្ខខណ្ឌមូលដ្ឋានមួយសម្រាប់អ្នកដែលមានបំណងចង់បង្កើតគ្រឹះស្ថានមួយនៅក្នុងវិស័យហិរញ្ញវត្ថុធនាគារ។ បទប្បញ្ញត្តិទាំងនោះរួមមានលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់គ្រឹះស្ថាន ដែលត្រូវបានបង្កើតឡើង ក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។ គេអាចកំណត់ពីផលប៉ះពាល់នៃបទប្បញ្ញត្តិទាំងនោះបានតាមរយៈថាតើគ្រឹះស្ថាននោះ ត្រូវបានបង្កើតឡើងតាមរបៀបណា ហើយជ្រៀតចូលក្នុងទីផ្សារដូចម្តេច។ ឧទាហរណ៍ ដើម្បីបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ លក្ខខណ្ឌតម្រូវមួយគឺត្រូវមានដើមទុនចុះបញ្ជីអប្បបរមាចំនួន៦,០០០,០០០,០០០ រៀល។[48] ទន្ទឹមនេះយោងតាមប្រការ ៥ នៃប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពាក្យសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្នើដោយបុគ្គលដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ ត្រូវមានព័ត៌មានដូចខាងក្រោម។[49]

- **អត្តសញ្ញាណរបស់គ្រឹះស្ថាន៖** នាម ឬនាមករណ៍អាជីវកម្ម អាសយដ្ឋាន ចុះបញ្ជី រូបភាពគតិយុត្តិ លក្ខន្តិក ឬឯកសារបង្កើតផ្សេងៗទៀត។
- **ដើមទុន និងការបែងចែកភាគហ៊ុន៖** ចំនួនដើមទុនដែលបានបង់ ប្រភេទភាគហ៊ុន និងសិទ្ធិបោះឆ្នោត ប្រវត្តិរូបលម្អិតរបស់ភាគទុនិកដែលកាន់កាប់ ៥% ឬលើសពីនេះ នៃសិទ្ធិបោះឆ្នោត។

[48] (National Bank of Cambodia, 2016), Article 7
[49] (National Bank of Cambodia, 2000), Article 5

- **អត្តសញ្ញាណរបស់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់៖** ក្រុមប្រឹក្សាភិបាល និងប្រធានប្រតិបត្តិពីររូប ឬច្រើនជាងនេះ។ ប្រសិនបើអ្នកស្នើសុំគឺជានីតិបុគ្គល ត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីសកម្មភាពអាជីវកម្មរបស់ខ្លួន ព្រមទាំងតារាងតុល្យការដែលមានការបញ្ជាក់ពីស្នងការគណនីសម្រាប់ប្រតិបត្តិការរយៈពេល ៣ ឆ្នាំចុងក្រោយ។
- **ផែនការសកម្មភាពអាជីវកម្មរយៈពេល ៣ ឆ្នាំទៅមុខ** មានព័ត៌មានដូចខាងក្រោម៖
  - ➢ ព័ត៌មានពិស្តារអំពីការព្យាករណ៍ស្តីពីប្រាក់កម្ចី រាប់បញ្ចូលទាំងលក្ខខណ្ឌ ចំនួន ប្រភេទ និងកម្រៃសេវា។ល។
  - ➢ អតិថិជនគោលដៅ
  - ➢ ការព្យាករណ៍ពីប្រភពមូលនិធិពីភាគទុនិក ប្រាក់ឧបត្ថម្ភ បំណុលបន្ទាប់បន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចីជាដើម។ល។ ប្រភពច្បាស់លាស់នៃមូលនិធិទាំងនេះត្រូវបញ្ជាក់ឱ្យច្បាស់ក្នុងករណីចាំបាច់។
  - ➢ ការព្យាករណ៍ពីចំនួនបុគ្គលិក និងប្រាក់បៀវត្សរ៍សម្រាប់ ៣ ឆ្នាំទៅមុខ
  - ➢ ទីតាំងសាខាដែលមានស្រាប់ និងការព្យាករណ៍ពីការពង្រីកសាខា
  - ➢ ការព្យាករណ៍ ពីធនធានដែលត្រូវការចាំបាច់ ជាពិសេសចំពោះទម្រង់ការគណនេយ្យ និងឧបករណ៍កុំព្យូទ័រ
  - ➢ ការព្យាករណ៍ពីនីតិវិធីសវនកម្ម រាប់បញ្ចូលទាំងការធ្វើផែនការរបស់អង្គភាពសវនកម្មផ្ទៃក្នុង អត្តសញ្ញាណស្នងការគណនីឯករាជ្យនិងប្រភេទនៃមុខងារដែលត្រូវប្រគល់ឱ្យស្នងការគណនីឯករាជ្យនោះ។

លក្ខខណ្ឌតម្រូវ ដែលមានចែងក្នុងប្រកាសនេះអាចមានឥទ្ធិពលជាប្រយោជន៍ សម្រាប់ការត្រៀមលក្ខណៈរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទើបបង្កើតថ្មី នៅពេលដែលរូបភាពគតិយុត្តិរបស់គ្រឹះស្ថាននេះត្រូវបានបង្កើតឡើង។ លើសពីនេះ គ្រឹះស្ថានអាចប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលចាំបាច់ ធ្វើជាផ្នែកមួយនៃផែនការមេរបស់ខ្លួន សម្រាប់បង្កើតយុទ្ធសាស្ត្រអាជីវកម្ម ដើម្បីទទួលបានចំណែកទីផ្សារក្នុងវិស័យនេះ។ បទប្បញ្ញត្តិប្រុងប្រយ័ត្នដែលដាក់ចេញដោយ ធនាគារជាតិនៃកម្ពុជា មិនត្រឹមតែមានអត្ថប្រយោជន៍ សម្រាប់ការការពារប្រព័ន្ធធនាគារប៉ុណ្ណោះទេ ប៉ុន្តែក៏មានអត្ថប្រយោជន៍សម្រាប់គ្រឹះស្ថាននីមួយៗដែលកំពុងធ្វើប្រតិបត្តិការ ក្នុងការកាត់បន្ថយហានិភ័យ ជាពិសេសក្នុងអំឡុងពេលមានវិបត្តិ។ ឧទាហរណ៍ប្រកាសស្តីពីអនុបាតគ្របខណ្ឌសន្ទនីយភាព (LCR) ដែលអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs) មានគោលបំណង៖[50]

- បង្កើនភាពធន់រយៈពេលខ្លីចំពោះហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថាន

[50] (National Bank of Cambodia, 2015), Article 1 and Article 2

- ធានាថា គ្រឹះស្ថានមានបរិមាណទ្រព្យសកម្មសន្ទនីយគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការសន្ទនីយភាព ក្នុងស្រ្តេសសេណារីយ៉ូ (stress test scenario) សម្រាប់រយៈពេល៣០ថ្ងៃ និង
- ធានាថា នៅពេលដែលអនុបាតក្របខណ្ឌសន្ទនីយភាពនេះមិនគ្រប់គ្រាន់ គណៈគ្រប់គ្រងគ្រឹះស្ថានត្រូវចាត់វិធានការកែតម្រូវបន្ទាន់។

ការអនុវត្តពេញលេញតាមប្រកាសនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចបង្ការហានិភ័យសន្ទនីយភាព ដែលជាហានិភ័យមួយក្នុងចំណោមហានិភ័យធំៗបំផុតសម្រាប់អាជីវកម្មធនាគារ។ ស្រដៀងគ្នានេះដែរ ដើម្បីបង្កើនគុណភាពទ្រព្យសកម្មរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យឥណទាន ធនាគារជាតិនៃកម្ពុជា បានចេញប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន (Impairment Provisioning) ក្នុងគោលបំណងធានានូវភាពត្រឹមត្រូវនៃការទទួលស្គាល់ ការវាស់វែង ការធ្វើសំវិធានធន និងការរាយការណ៍ចំពោះហ្វាស៊ីលីធី (Facilities) ដែលមានអ៊ីមភែរមិនរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។[51] ខណៈដែលចំណាត់ថ្នាក់ហានិភ័យឥណទាន និង សំវិធានធនលើអ៊ីមភែរមិន គឺជាផ្នែកមួយនៃក្របខណ្ឌហានិភ័យឥណទានដែលគេទទួលយក ដូច្នេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានតម្រូវឱ្យមានៈ[52]

- ប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន ដែលមានលក្ខណៈសមស្របទៅនឹងចរិតលក្ខណៈភាពស្មុគស្មាញ និងទំហំនៃសកម្មភាពអាជីវកម្ម
- ការពិនិត្យឡើងវិញជាប្រចាំទៅលើប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន ដោយផ្អែកលើការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច សកម្មភាពអតិថិជន និងហានិភ័យនានា
- ប្រព័ន្ធគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពសម្រាប់ការកំណត់ជាមុន ការតាមដាន និងការវាស់វែងហានិភ័យឥណទានឱ្យបានត្រឹមត្រូវ រួមទាំងការកំណត់ឱ្យបានពេញលេញ និងការរាយការណ៍អំពីហ្វាស៊ីលីធី ដែលមានអ៊ីមភែរមិន និងការព្យាករណ៍ការខាតបង់នៃសម្ពាធឥណទាន
- សំវិធានធនគ្រប់គ្រាន់ (Sufficient provisioning) សម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន (impaired facilities) ស្របតាមស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា និង
- គោលនយោបាយ នីតិវិធី និងដំណើរការអនុវត្តអនុលោមតាមលក្ខខណ្ឌតម្រូវទាំងអស់នៃប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន។

ជាងនេះទៅទៀត ចំណាត់ថ្នាក់ហានិភ័យឥណទាន ត្រូវមានការចាត់ថ្នាក់ឱ្យបានទូលំទូលាយដោយផ្អែកលើកម្រិតហានិភ័យឥណទានរបស់គ្រឹះស្ថាន ហើយហ្វាស៊ីលីធីត្រូវតែចាត់ថ្នាក់ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃលើសមត្ថភាពទូទាត់សងរបស់សមភាគី តាមរយៈប្រភព

---

[51] (National Bank of Cambodia, 2017), Article 2
[52] (National Bank of Cambodia, 2017), Article 5

ចំណូលជាក់ស្តែង។ ការវាយតម្លៃសមត្ថភាពទូទាត់សងរបស់សមភាគីត្រូវមានលក្ខណៈវិនិច្ឆ័យអប្បបរមា ដោយរាប់បញ្ចូលទាំងប្រវត្តិនៃការទូទាត់សងពីអតីតកាល ស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន និងទៅថ្ងៃអនាគតរបស់សមភាគី ការព្យាករណ៍ពីអនាគតអាជីវកម្ម និងលំហូរសាច់ប្រាក់ផ្អែកលើការសន្មតជាក់ស្តែង និងដោយប្រុងប្រយ័ត្ន និងឆន្ទៈ ព្រមទាំងលទ្ធភាពនៃការទូទាត់សង និងគុណភាពនៃសំណុំឯកសារ។[53]

ក្រៅពីការដាក់ចេញ និងធ្វើបច្ចុប្បន្នភាពលើប្រកាស និងបទប្បញ្ញត្តិនានា ស្របតាមកំណើនសេដ្ឋកិច្ច និងភាពស្មុគស្មាញនៃអាជីវកម្ម ធនាគារជាតិនៃកម្ពុជា ក៏យកចិត្តទុកដាក់យ៉ាងខ្លាំងលើក្របខណ្ឌ/យន្តការគាំទ្រនានាដែលមានភាពចាំបាច់ និងបន្ទាន់ ដើម្បីពង្រឹង និងការពារគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងអតិថិជនរបស់ខ្លួនក្នុងអំឡុងពេលមានវិបត្តិ។ គេអាចមើលឃើញឧទាហរណ៍ជាក់ស្តែង នៅពេលដែល ធនាគារជាតិនៃកម្ពុជា (សហាការជាមួយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ) បានដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារប្រព័ន្ធធនាគារ និងរក្សាទំនុកចិត្តសាធារណជនក្នុងអំឡុងពេលជំងឺរាតត្បាតនៃជំងឺកូវីដ-១៩។ ដើម្បីជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីប្រកាសមួយក្នុងគោលបំណងបង្កើនសន្ទនីយភាពសម្រាប់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយមានវិធានការគាំទ្រចំនួនប្រាំដូចខាងក្រោម៖[54]

- ពន្យារពេលឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រក្សាកម្រិតទ្រនាប់ដើមទុនខនសឺវេសិន (Capital Conservation Buffer, CCB) ត្រឹម ៥0% ដែលស្មើនឹង១.២៥% នៃទ្រព្យសកម្មមានទម្ងន់ហានិភ័យ។
- កាត់បន្ថយអត្រាការប្រាក់អប្បបរមានៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (Liquidity Providing Collateralized Operation, LPCO) ចំនួន ០.៥% ចំពោះគ្រប់ឥណប្រតិទាន
- កាត់បន្ថយអត្រាការប្រាក់លើមូលបត្រអាចជួញដូរបាន (Negotiable Certificate of Deposit, NCD) ជារៀល និងជាដុល្លារអាមេរិកក្នុងកម្រិតមួយសមស្រប
- កាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ច (RRR) ពី ៨% ចំពោះប្រាក់រៀល និង ១២.៥% ចំពោះរូបិយប័ណ្ណដុល្លារអាមេរិក មកត្រឹម ៧% ទាំងចំពោះប្រាក់រៀល និងរូបិយប័ណ្ណដុល្លារអាមេរិក ក្នុងរយៈពេល ៦ ខែចាប់ពីខែមេសា២០២០។
- កាត់បន្ថយកម្រិតអនុបាតក្របខណ្ឌសន្ទនីយភាព (Liquidity Coverage Ratio, LCR) ក្នុងកម្រិតសមស្របតាមការចាំបាច់។

[53] (National Bank of Cambodia, 2017), Article 16
[54] (National Bank of Cambodia, 2020)

ទោះបីជាបទប្បញ្ញត្តិនានាជួយផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្តី ប៉ុន្តែបទប្បញ្ញត្តិទាំងនោះមិនមែនតែងតែងាយស្រួលក្នុងការអនុវត្តនោះទេ។ បទប្បញ្ញត្តិមួយចំនួនតម្រូវឱ្យគ្រឹះស្ថានមានធនធាន និងបុគ្គលិកគ្រប់គ្រាន់។ បទប្បញ្ញត្តិមួយចំនួនផ្សេងទៀតតម្រូវឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្របសម្រួលដោយភាពបត់បែន ផ្អែកលើស្ថានភាពជាក់ស្តែង ក្នុងគោលបំណងសម្រេចបាននូវនិរន្តរភាពរយៈពេលវែង។ ឧទាហរណ៍ យោងតាមសារាចរណែនាំស្តីពីឥណទានរៀបចំឡើងវិញ ក្នុងអំឡុងពេលរងផលប៉ះពាល់ពីការរីករាលដាលរបស់វីរុសកូវីដ-១៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ តម្រូវឱ្យ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ យកចិត្តទុកដាក់បន្ថែមទៀតចំពោះអតិថិជនរបស់ខ្លួន ដែលអាជីពរបស់ពួកគាត់ស្ថិតនៅក្នុងវិស័យអាទិភាព និងបានរងផលប៉ះពាល់ដោយជំងឺរាតត្បាត កូវីដ-១៩។ អតិថិជនទាំងនោះគួរតែត្រូវបានផ្តល់ជូននូវជម្រើសឥណទានរៀបចំឡើងវិញ ដូចខាងក្រោម៖[55]

- ការកាត់បន្ថយចំនួនប្រាក់ដើមឥណទាន ឬចំនួនដែលត្រូវសងនៅឥណប្រតិទាន
- ការបន្ថយអត្រាការប្រាក់
- ការពន្យារពេលទូទាត់សងប្រាក់ដើម ឬការប្រាក់ ឬការធ្វើមូលធនកម្មការប្រាក់
- ការពន្យារពេលឥណប្រតិទាន
- ការបន្ថែម និង/ឬ ការផ្លាស់ប្តូរអ្នករួមខ្ចី និង/ឬ អ្នកធានាប្រសិនបើមាន
- ការផ្លាស់ប្តូរពីឥណទានមានការទូទាត់សង តាមការបង់រំលស់ទៅជាការទូទាត់តែការប្រាក់ ហើយទូទាត់សងប្រាក់ដើមទាំងអស់នៅឥណប្រតិទាន
- ការលើកលែង ឬបន្ថយទ្រព្យធានា
- ការបន្ថយលក្ខខណ្ឌ កិច្ចសន្យា និង/ឬ
- ការផ្តល់រយៈពេលអនុគ្រោះដោយគ្មានការទូទាត់សង (Grace period) ដែលអាចមានរយៈពេលពេលរហូតដល់ ៦ ខែ គិតចាប់ពីថ្ងៃប្រសិទ្ធភាពនៃកិច្ចសន្យាថ្មី។

សម្រាប់រយៈពេលខ្លី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចមានការលំបាកក្នុងការអនុវត្តសារាចរនេះ ដោយសារខ្លួនត្រូវពិចារណាលើប្រាក់ចំណេញ ខណៈពេលដែលត្រូវអនុវត្តជាពិសេសចំពោះអតិថិជនដែលងាយរងគ្រោះរបស់ខ្លួន។ ទោះជាយ៉ាងណា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅតែទទួលបានអត្ថប្រយោជន៍ពីទស្សនវិស័យរយៈពេលវែង ពីព្រោះផលប្រយោជន៍ទៅវិញទៅមករវាង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាមួយនឹងអតិថិជនរបស់ខ្លួន គឺជាគន្លឹះនៃភាពជោគជ័យនៅក្នុងអាជីវកម្មធនាគារ និងជាគន្លឹះក្នុងការរក្សាការជឿទុកចិត្តពីសាធារណជន។

[55] (National Bank of Cambodia, 2020)

សរុបមក អនុលោមភាព និងបទប្បញ្ញត្តិផ្អែកលើហានិភ័យទាំងអស់ មានឥទ្ធិពលជាវិជ្ជមានយ៉ាងច្រើនលើប្រព័ន្ធធនាគារ។ ទន្ទឹមនឹងនេះ បទប្បញ្ញត្តិបន្ទាន់នានាដែលឆ្លើយតបទៅនឹងវិបត្តិក៏មានតួនាទីសំខាន់ក្នុងការជួយ និងអាចឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុសម្របខ្លួនដោយប្រុងប្រយ័ត្ន ដើម្បីទប់ទល់ និងរីកលូតលាស់បានក្នុងអំឡុងពេលមានវិបត្តិ។ ជាក់ស្តែងការដាក់ចេញនូវ បទប្បញ្ញត្តិ និងគោលនយោបាយគាំទ្រចាំបាច់ និងបន្ទាន់ពី ធនាគារជាតិនៃកម្ពុជាគឺជាគន្លឹះដែលជំរុញឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចរក្សាភាពធន់ និងរក្សាទំនុកចិត្តសាធារណជន សូម្បីតែក្នុងអំឡុងពេលមានជំងឺរាតត្បាត កូវីដ-១៩ ក៏ដោយ។[56] ក្នុងឆ្នាំ ២០២០វិស័យធនាគារនៅតែរក្សាបាននូវភាពរឹងមាំ ហើយទ្រព្យសកម្មសរុប បន្តកើនឡើង១៩.៧%, កម្ចីដុលកើនឡើង ១៦.១% និងប្រាក់បញ្ញើពីសាធារណជនបន្តកើនឡើង ១៤.៥%។[57] ដូចគ្នានេះដែរ វិស័យមីក្រូហិរញ្ញវត្ថុនៅតែរឹងមាំជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំ (Y-o-Y) ចំនួន ១៨.៨%, ១៧.៥% និង១៨.៨% សម្រាប់ទ្រព្យសកម្មសរុប ប្រាក់កម្ចី និងប្រាក់បញ្ញើរបស់អតិថិជនរៀងគ្នា។

**សំណួរឆ្លុះបញ្ចាំង ខ៩**

យោងតាមប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន (Credit Risk Grading and Impairment Provisioning) គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបែងចែកចំណាត់ថ្នាក់ហានិភ័យឥណទាននៃហ្វាស៊ីលីធី (credit facility) ដោយផ្អែកលើការរួមបញ្ចូលនូវចំណុចដូចខាងក្រោមនេះ៖

១) ប្រវត្តិនៃការទូទាត់សង ស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន និងព្យាករណ៍ទៅថ្ងៃក្រោយរបស់សមភាគី សមត្ថភាព និងឆន្ទៈនៃការទូទាត់សង និងស្ថានភាពសេដ្ឋកិច្ច។

២) ប្រវត្តិនៃការទូទាត់សង ស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន និងព្យាករណ៍ទៅថ្ងៃក្រោយរបស់សមភាគី តម្លៃទ្រព្យធានា និងស្ថានភាពកម្រិតវប្បធម៌របស់អតិថិជន។

៣) អនាគតអាជីវកម្ម និងការព្យាករពីលំហូរសាច់ប្រាក់ផ្អែកលើការសន្និដ្ឋានជាក់ស្តែង និងគុណភាពសំណុំឯកសារ តម្លៃទ្រព្យធានា និងស្ថានភាពកម្រិតវប្បធម៌របស់អតិថិជន

៤) អនាគតអាជីវកម្ម និងការព្យាករពីលំហូរសាច់ប្រាក់ផ្អែកលើការសន្និដ្ឋានជាក់ស្តែង និងគុណភាពសំណុំឯកសារ។

[56] (National Bank of Cambodia, 2021), p. 1
[57] (National Bank of Cambodia, 2021), p. 3

ជម្រើស៖

**ក)** ១ & ២

**ខ)** ២ & ៣

**គ)** ១ & ៤

**ឃ)** ទាំងអស់

# ផ្នែក គ៖ អនុវត្តគោលការណ៍ក្រមសីលធម៌ និងគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច

ផ្នែកនេះនឹងពិភាក្សាអំពីអត្ថន័យក្រមសីលធម៌ បញ្ហាទ្វេគ្រោះផ្នែកក្រមសីលធម៌ (Ethical Dilemma) និងរបៀបរកដំណោះស្រាយចំពោះស្ថានភាពទ្វេគ្រោះផ្នែកក្រមសីលធម៌។

## អ្វីជាក្រមសីលធម៌ ហើយហេតុអ្វីបានជាក្រមសីលធម៌មានសារៈសំខាន់?

**ក្រមសីលធម៌** គឺជាសំណុំនៃគោលការណ៍សីលធម៌ ឬជំនឿរបស់បុគ្គល អង្គភាព ឬសង្គមមួយ ទាក់ទងនឹងអ្វីដែលត្រូវ និងអ្វីដែលខុស ជុំវិញការប្រព្រឹត្ត និងឥរិយាបថរបស់គេ។ ជំនឿនោះមានតួនាទីជាក្បួនមូលដ្ឋាន ដែលជួយណែនាំដល់ការសម្រេចចិត្ត ជុំវិញអ្វីដែលគេគួរធ្វើ និងអ្វីដែលមិនគួរធ្វើ។ ឥរិយាបថ ឬការសម្រេចចិត្តប្រកបដោយក្រមសីលធម៌ គឺសំដៅទៅលើរាល់ទង្វើដែលផ្តល់នូវគុណតម្លៃទៅកាន់បុគ្គលណាម្នាក់ ឬសង្គមណាមួយ ដូចជាសុខុមាលភាព ភាពស្មោះត្រង់ ភាពយុត្តិធម៌ ការគោរព សេចក្តីថ្លៃថ្នូរ ការរក្សាការសន្យា ឬការជួយគ្នាទៅវិញទៅមក។ ការប្រព្រឹត្តដែលផ្ទុយនឹងគុណតម្លៃទាំងនោះ អាចនឹងត្រូវបានថ្កោលទោស ឬដាក់ទោសទណ្ឌដោយច្បាប់ ឬសង្គម។

- **ការរស់រានមានជីវិតរបស់សង្គម៖** មនុស្សគ្រប់រូបនៅក្នុងសង្គមខិតខំរស់នៅឱ្យមានសេចក្តីសុខ និងសុភមង្គល។ នៅក្នុងពិភពលោកដែលមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នានេះ ការសម្រេចចិត្ត ឬការប្រព្រឹត្តិរបស់បុគ្គល ឬស្ថាប័នណាមួយ មិនថាតូច ឬធំនោះឡើយ កំពុងជះឥទ្ធិពលលើគ្នាទៅវិញទៅមក។ ការប្រកាន់ភ្ជាប់នូវក្រមសីលធម៌ ធានាបានថា ផលប៉ះពាល់មានភាពវិជ្ជមានដល់សង្គម ហើយធ្វើឱ្យសង្គមជាកន្លែងដ៏ល្អប្រសើរសម្រាប់ការរស់នៅ ដែលនាំឱ្យជីវិតរស់នៅរបស់យើងកាន់តែប្រសើរ និងកាន់តែសប្បាយរីករាយ។
- **ជោគជ័យក្នុងអាជីវកម្ម៖** ក្រមសីលធម៌អាចលើកកម្ពស់លទ្ធភាពចំណេញរបស់អាជីវកម្មតាមពីររបៀប។
    - ➢ ក្រមសីលធម៌បណ្តុះឱ្យមានការជឿទុកចិត្តលើការគ្រប់គ្រង និងអាជីវកម្ម និងពង្រឹងកេរ្តិ៍ឈ្មោះអាជីវកម្ម។ ក្រមសីលធម៌អាចបង្កើនភាពស្មោះត្រង់របស់អតិថិជន និងបុគ្គលិក ព្រមទាំងទាក់ទាញអតិថិជនសក្តានុពល អ្នកពាក់ព័ន្ធសំខាន់ៗ (រួមទាំងបុគ្គលិក ភាគទុនិក។ល។) ឬវិនិយោគិននាពេលអនាគត ដើម្បីគាំទ្រដល់កំណើនអាជីវកម្ម។

➢ ការអនុវត្តនូវក្រមសីលធម៌អាជីវកម្ម ជួយជំរុញទឹកចិត្តបុគ្គលិក ឱ្យបំពេញតួនាទីប្រកបដោយសុចរិតភាព និងការទទួលខុសត្រូវ ដែលអាចរួមចំណែកដល់ការលូតលាស់របស់អាជីវកម្ម និង/ឬកាត់បន្ថយកំហាតសក្តានុពល។

- **សុខុមាលភាពបុគ្គល និងការអភិវឌ្ឍអាជីព៖** ក្រមសីលធម៌វិជ្ជាជីវៈ និងក្រមសីលធម៌ផ្ទាល់របស់បុគ្គល អាចជាកត្តាដែលជួយឱ្យបុគ្គលម្នាក់ៗទទួលបានភាពជោគជ័យ និងជំរុញឱ្យមានការជឿទុកចិត្តក្នុងវិជ្ជាជីវៈនិង លក្ខណសម្បត្តិក្រមសីលធម៌របស់ខ្លួន ត្រង់នេះអាចជួយពួកគេទាក់ទាញបាននូវការគាំទ្រពីមិត្តភក្តិ សហការី ក្រុមការងារ ឬនិយោជករបស់ខ្លួនដើម្បីធ្វើឱ្យអាជីពរបស់ខ្លួនកាន់តែមានវឌ្ឍនភាពថែមទៀត។ មនុស្សដែលមានក្រមសីលធម៌ក៏អាចដឹកនាំជីវិតរបស់ខ្លួនឱ្យមានភាពសប្បាយរីករាយផងដែរដោយសារតែពួកគេមានគោលការណ៍ក្នុងការវិនិច្ឆ័យ ដែលធ្វើឱ្យជីវិតរស់នៅកាន់តែងាយស្រួល មិនស្ទាក់ស្ទើរ ឬមិនខ្វល់ខ្វាយអំពីផលវិបាកនៃការគ្មានក្រមសីលធម៌។

## គ១. អនុវត្តក្រមសីលធម៌នៅក្នុងការសម្រេចចិត្តបុគ្គល

### គ១.១. អភិវឌ្ឍឥរិយាបថផ្ទាល់ខ្លួនប្រកបដោយក្រមសីលធម៌

#### តើត្រូវប្រព្រឹត្តទង្វើតាមក្រមសីលធម៌របៀបណា?

និយមន័យនៃគុណតម្លៃក្រមសីលធម៌គឺអាចខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ដូចគ្នាទៅនឹងជំនឿលើអ្វីដែលល្អ ឬអាក្រក់ ហើយអាចរងឥទ្ធិពលពីកត្តាជាច្រើនរួមមានសាសនា វប្បធម៌ក្បួនច្បាប់សង្គម អំណាចនយោបាយ អំណាចពីអ្នកដែលមានឋានៈខ្ពស់ជាង ទំនាស់ផលប្រយោជន៍ ឬកត្តាផ្ទាល់ខ្លួន ដូចជាការអប់រំ អាយុ និងគ្រួសារជាដើម។ គុណតម្លៃក្រមសីលធម៌អាចប្រែប្រួលទៅតាមពេលវេលា ហើយខុសគ្នាពីវប្បធម៌មួយ ទៅវប្បធម៌មួយ ឬពីសង្គមមួយ ទៅសង្គមមួយទៀត។ ដូច្នេះហើយ ពេលខ្លះ វាអាចមានការពិបាកក្នុងការវិនិច្ឆ័យថាតើការប្រព្រឹត្តិមួយត្រូវ ឬខុសទាំងស្រុង ព្រោះថា វាអាស្រ័យទៅលើបរិបទ និងវប្បធម៌ ដែលករណីនោះបានកើតឡើង។ទ្រឹស្តីអំពីក្រមសីលធម៌ក៏ផ្តល់នូវវិធីសាស្ត្រនានា ដែលព្យាយាមដោះស្រាយសំណួរ ដែលសួរថា "តើទង្វើអ្វីខ្លះដែលមនុស្សម្នាក់ៗគួរធ្វើ?" និងសំណួរ "តើមនុស្សយល់ថាសកម្មភាពមួយ ល្អឬអាក្រក់ ដោយផ្អែកលើអំណះអំណាងអ្វីខ្លះ?" ការយល់ពីទ្រឹស្តីអំពីក្រមសីលធម៌នឹងជួយបុគ្គលនានាមានគោលការណ៍ក្នុងការវាយតម្លៃសកម្មភាពរបស់ខ្លួន និងយល់ពីរឿងត្រឹមត្រូវដែលត្រូវធ្វើ។ ដើម្បីស្រាយសំណួរខាងលើ ទាក់ទងនឹងក្រមសីលធម៌បុគ្គល យើងពិនិត្យមើលលើទ្រឹស្តីនៃ "ក្រមសីលធម៌បទដ្ឋាន"។

**ក្រមសីលធម៌បទដ្ឋាន** ជាផ្នែកមួយនៃទ្រឹស្តីសីលធម៌ ហើយទាក់ទងនឹងអ្វីដែលបុគ្គលម្នាក់ៗគួរ ឬមិនគួរធ្វើ។ ក្រមសីលធម៌បទដ្ឋានក៏មានការពាក់ព័ន្ធ ជាមួយហេតុផលនៃក្រមសីលធម៌ ផ្សារភ្ជាប់ទៅនឹងទង្វើរបស់បុគ្គល។ វិធីសាស្រ្តនៃក្រមសីលធម៌បទដ្ឋានមានបីយ៉ាងសំខាន់ៗដូចជា៖ **ក្រមសីលធម៌ផ្អែកលើគុណធម៌** (virtue ethics) **ក្រមសីលធម៌ផ្អែកលើកាតព្វកិច្ច** (deontological ethics) និង **ក្រមសីលធម៌ផ្អែកលើលទ្ធផល** (teleological ethics)។




- **ក្រមសីលធម៌ផ្អែកលើគុណធម៌** (virtue ethics)៖ ក្រមសីលធម៌នោះឆ្លើយតបទៅនឹងសំណួរ៖ "តើទង្វើអ្វីខ្លះដែលមនុស្សម្នាក់ៗគួរធ្វើ?" បុគ្គលដែលមានគុណធម៌ត្រូវចាត់ទុកថាប្រព្រឹត្តទង្វើប្រកបដោយក្រមសីលធម៌។ មនុស្សអាចសម្រេចចិត្តថាសកម្មភាពមួយគឺត្រឹមត្រូវឬយ៉ាងណា ដោយសម្លឹងមើលបុគ្គលដែលពួកគេជឿថាមានលក្ខណសម្បត្តិល្អ។ លក្ខណសម្បត្តិល្អទាំងនេះអាចមានការផ្លាស់ប្តូរ តែទោះបីជាយ៉ាងណាក៏ដោយ គុណធម៌រួមដែលមនុស្សភាគច្រើនយល់ស្របតាម នៅតែមាន ហើយគុណធម៌រួមទាំងនោះមានដូចជា៖[58]
    - ➢ ភាពស្មោះត្រង់
    - ➢ ចិត្តសប្បុរស
    - ➢ សុជីវធម៌
    - ➢ សុចរិតភាព
    - ➢ សេចក្តីក្លាហាន
    - ➢ ការតាំងចិត្ត

[58] (The Asian Institute of Chartered Bankers, 2015)

**ឧទាហរណ៍៖** លោកមហាត្មៈ គន្ធី និង លោក នែលសុន ម៉ាន់ដេឡា ត្រូវបានចាត់ទុកថាជាបុគ្គលមានគុណធម៌។ ដូច្នេះ វិធីសាស្រ្តនៃចលនាមិនសហការរបស់ពួកគាត់ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងការជិះជាន់ ត្រូវបានចាត់ទុកថាមានសីលធម៌។

- **ក្រមសីលធម៌ផ្អែកលើកាតព្វកិច្ច** (Deontological Ethics)៖ ក្រមសីលធម៌នេះ ផ្តោតលើចំណុច "ធ្វើរឿងត្រឹមត្រូវ"។ ទង្វើមួយអាចត្រូវបានចាត់ទុកថាត្រឹមត្រូវ ដោយមិនគិតពីលទ្ធផលដែលកើតចេញពីទង្វើនោះ ដរាបណាទង្វើនោះគោរពតាមក្បួនច្បាប់ ឬកាតព្វកិច្ចផ្អែកសីលធម៌។ ក្រមសីលធម៌ផ្អែកលើកាតព្វកិច្ចត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ការអនុវត្តច្បាប់ ក្រមសីលធម៌វិជ្ជាជីវៈ ដែលក្នុងនោះមានវិធាន និងបញ្ញត្តិជាក់លាក់ដែលត្រូវបានអនុវត្តតាម។

  **ឧទាហរណ៍៖** ក្នុងនាមជានិយោជិត យើងមានភារកិច្ចគោរពតាមក្បួនច្បាប់របស់ក្រុមហ៊ុន។ ដូច្នេះ ការរាយការណ៍ពីការប្រព្រឹត្តមិនត្រឹមត្រូវរបស់សហការី មិនមែនជារឿងខុសក្រមសីលធម៌ទេ បើទោះបីជាការធ្វើបែបនេះអាចបណ្តាលឱ្យមានទំនាក់ទំនងអវិជ្ជមានជាមួយសហការីទាំងនោះក្តី។

  ដូច្នេះ តើគួរធ្វើដូចម្តេចដើម្បីកំណត់ក្រមសីលធម៌ផ្អែកលើកាតព្វកិច្ចនៅក្នុងស្ថានភាពមួយបាន? គេអាចកំណត់បាន តាមរយៈកត្តាចំនួន ៣៖ (i) ភាពជាសកល (universalizability) (ii) ភាពអាចត្រឡប់វិញបាន (reversibility) និង (iii) ការគោរព។[59]

  (i) **ភាពជាសកល** (universalizability)៖ តើគ្រប់គ្នានឹងប្រព្រឹត្តទង្វើដូចខ្ញុំដែរទេ ប្រសិនបើស្ថិតនៅក្នុងកាលៈទេសៈដូចគ្នា?

  (ii) **ភាពអាចត្រឡប់វិញបាន** (reversibility)៖ តើនោះជាអ្វីដែលខ្ញុំចង់ឱ្យអ្នកដទៃប្រព្រឹត្តមកលើខ្ញុំមែនទេ ផ្អែកលើហេតុផលស្រដៀងគ្នា?

  (iii) **ការគោរព**៖ រាល់ទង្វើណាក៏ដោយមិនគួររំលោភលើស្វ័យភាពរបស់បុគ្គលណាម្នាក់ឡើយ។

- **ក្រមសីលធម៌ផ្អែកលើលទ្ធផល** (Teleological ethics)៖ បុគ្គលដែលមានក្រមសីលធម៌ផ្អែកលើលទ្ធផល តែងតែគិតពីលទ្ធផលដែលកើតចេញពីសកម្មភាព ដើម្បីវិនិច្ឆ័យថាតើសកម្មភាពមួយនោះមានសីលធម៌ ឬ ត្រឹមត្រូវ។ សកម្មភាពណាដែលបង្កើតបាននូវលទ្ធផលល្អ ត្រូវបានចាត់ទុកថាជាសកម្មភាពត្រឹមត្រូវ។

[59] (Schwartz, 2017)

មានវិធីសាស្ត្រសំខាន់ៗចំនួនពីរនៅក្នុងក្រមសីលធម៌ផ្អែកលើលទ្ធផល៖

- **អត្តទត្ថភាព** (Egoism)៖ ផ្តោតលើការលើកកម្ពស់ផលប្រយោជន៍ខ្លួនឯងនៃបុគ្គលណាម្នាក់។ ក្នុងន័យនេះ សកម្មភាពមួយជាសកម្មភាពមានសីលធម៌ ប្រសិនបើសកម្មភាពនោះ បង្កើតបាននូវលទ្ធផលល្អបំផុតសម្រាប់បុគ្គលនោះខ្លួនឯង។
- **ប្រយោជន៍និយម** (Utilitariansim)៖ គិតគូរពីផលប្រយោជន៍របស់អ្នកដទៃ។ សកម្មភាពមួយ ជាសកម្មភាពមានសីលធម៌ នៅពេលដែលសកម្មភាពនោះ បង្កើតឱ្យមានអត្ថប្រយោជន៍ក្នុងកម្រិតអតិបរមាសម្រាប់មនុស្សជាច្រើន។

**ឧទាហរណ៍៖** លោក ច័ន្ទ មានសណ្ឋាគារ និងភោជនីយដ្ឋានមួយកន្លែងក្នុងខេត្តសៀមរាប។ សណ្ឋាគារ និងភោជនីយដ្ឋាននោះ មានបុគ្គលិកប្រហែល១០០នាក់។ ក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩ អាជីវកម្មបានរងផលប៉ះពាល់យ៉ាងខ្លាំង ហើយការលក់បានធ្លាក់ចុះ ៥០ %។ ដើម្បីឱ្យអាជីវកម្មនៅរស់រានបាន លោក សុធី ដែលជាអ្នកគ្រប់គ្រងទូទៅរបស់ក្រុមហ៊ុន ពិចារណាលើការបញ្ឈប់បុគ្គលិកដើម្បីកាត់បន្ថយការចំណាយ។ ជាមួយនឹងការសម្រេចចិត្តនេះ ក្រុមហ៊ុននឹងនៅមានជីវិត ប៉ុន្តែការធ្វើដូច្នេះ នឹងបង្កឱ្យមនុស្សគ្មានការងារធ្វើ និងប៉ះពាល់ដល់សុខុមាលភាពរបស់បុគ្គលិក។ ដូច្នេះ តើការសម្រេចចិត្តមួយនេះត្រូវបានចាត់ទុកថាជាការសម្រេចចិត្តប្រកបដោយសីលធម៌ឬទេ?

ផ្អែកលើអត្តទត្ថភាព (Egoism) ការសម្រេចចិត្តបែបនេះ អាចត្រូវបានចាត់ទុកថាជាទង្វើមានសីលធម៌ ពីព្រោះថា ការសម្រេចចិត្តនេះ គឺដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន ដើម្បីអាចរស់រានបានអំឡុងគ្រាលំបាក។

ប៉ុន្តែ ផ្អែកលើប្រយោជន៍និយម (Utilitarianism) បញ្ហានេះអាចត្រូវបានដោះស្រាយបាន ប្រសិនបើក្រុមហ៊ុនថ្លឹងថ្លែងពីផលប៉ះពាល់ដែលកើតចេញពីការសម្រេចចិត្តនេះ ទៅនឹងផលប្រយោជន៍ដែលអ្នកដទៃនឹងទទួលបាន។ តើមានដំណោះស្រាយផ្សេងទៀតណាដែលក្រុមហ៊ុនអាចធ្វើឡើង ដើម្បីផ្តល់ផលប្រយោជន៍ឱ្យបានច្រើនបំផុតដល់ភាគីពាក់ព័ន្ធរបស់ខ្លួនដែរ ឬទេ? ជំនួសឱ្យការកាត់បន្ថយបុគ្គលិក ៥០% ក្រុមហ៊ុនអាចពិចារណាកាត់បន្ថយថ្ងៃធ្វើការរបស់បុគ្គលិក។ ធ្វើដូច្នេះអាចមានប្រយោជន៍ដល់ភាគីទាំងសងខាង ទាំងក្រុមហ៊ុន និងបុគ្គលិក៖ (១) បុគ្គលិកនៅតែរក្សាការងាររបស់ខ្លួន ហើយរកប្រាក់ចំណូលបានខ្លះ ដើម្បីទ្រទ្រង់ដល់ក្រុមគ្រួសាររបស់ខ្លួន បើទោះបីជាប្រាក់បៀវត្សរ៍ ត្រូវបានកាត់បន្ថយតាមរយៈការកាត់បន្ថយចំនួនថ្ងៃធ្វើការក្តីហើយក្រុមហ៊ុននៅតែអាចសម្រេចបាននូវវត្ថុ បំណងរបស់ខ្លួនក្នុងការកាត់បន្ថយការចំណាយប្រតិបត្តិការដើម្បីអាចនៅរស់រានបន្តបាន។ (២) វាងាយស្រួលក្នុងទាញយកធនធានមកវិញ នៅពេលដែលសេដ្ឋកិច្ចបានប្រសើរឡើង។ ធ្វើដូច្នេះ

នឹងចំណេញពេលវេលា និងការចំណាយរបស់ក្រុមហ៊ុនក្នុងការជ្រើសរើសបុគ្គលិកថ្មី។ (៣) ការលើកកម្ពស់ការជឿទុកចិត្តពីបុគ្គលិកមកលើថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន នឹងធ្វើឱ្យមានឥទ្ធិពលល្អទៅលើកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន។

**សំណួរឆ្លុះបញ្ចាំង គ១.១.**

ដារ៉ា ជានាយកគ្រប់គ្រងនាយកដ្ឋានផ្នែកលក់។ គាត់ត្រូវការជ្រើសរើសប្រធានផ្នែកលក់ ដែលត្រូវទៅខេត្តញឹកញាប់។ មានបេក្ខជនចុងក្រោយចំនួនពីររូប ១) សុធី ភេទស្រី ទើបតែរៀបការ មានបទពិសោធន៍ ៣ឆ្នាំក្នុងវិស័យនេះ ហើយមានប្រវត្តិការងារល្អ។ ២) កុសល ភេទប្រុស មានបទពិសោធក្នុងវិស័យនេះរយៈពេល ១ ឆ្នាំ និងមានទំនាក់ទំនងជាសាច់ញាតិជាមួយនឹងថ្នាក់គ្រប់គ្រងជាន់ខ្ពស់មួយរូបរបស់ក្រុមហ៊ុន។ ថ្វីត្បិតតែ សុធី ស័ក្តិសមបំផុតសម្រាប់តួនាទីនេះ យោងតាម បទពិសោធន៍វិជ្ជាជីវៈ និងប្រវត្តិសិក្សាក៏ដោយ ប៉ុន្តែ ដារ៉ាសម្រេចចិត្តផ្តល់ការងារនេះឱ្យកុសលដោយឈរលើមូលដ្ឋានថា ១) កុសល ជាមនុស្សប្រុស ងាយស្រួល ធ្វើដំណើរជាង ២) សុធី ទើបតែរៀបការរួច ដូច្នេះ មិនយូរមិនឆាប់ គាត់អាចមានផ្ទៃពោះ ដែលអាចប៉ះពាល់ដល់ដំណើរការរបស់ក្រុមហ៊ុន។ តើដារ៉ាសម្រេចចិត្តប្រកបដោយក្រមសីលធម៌ទេ? សូមបញ្ជាក់ហេតុផលរបស់អ្នកដោយផ្អែកលើទ្រឹស្តីក្រមសីលធម៌ខាងលើ។

## គ១.២. ពន្យល់អំពីទ្វេគ្រោះក្រមសីលធម៌ និងទំនាស់ផលប្រយោជន៍

### គ១.២.១. តើបញ្ហាទ្វេគ្រោះផ្នែកក្រមសីលធម៌ (Ethical Dilemma) ជាអ្វី?

បញ្ហាទ្វេគ្រោះផ្នែកក្រមសីលធម៌ កើតឡើងនៅពេលដែលមានចំណុចខ្ទាស់គ្នារវាងគោលការណ៍ក្រមសីលធម៌ពីរ ឬច្រើនក្នុងចំណោមជម្រើសទាំងអស់ដែលបុគ្គល ឬស្ថាប័នអាចយកមកអនុវត្ត។ នៅក្នុងស្ថានភាពនេះ បុគ្គល ឬស្ថាប័នយល់ឃើញថាមានការលំបាកក្នុងការសម្រេចចិត្តឱ្យបានត្រឹមត្រូវណាស់ ព្រោះគ្មានជម្រើសវិធានការណាមួយអាចត្រឹមត្រូវស្របតាមក្រមសីលធម៌ពេញលេញនោះទេ ពោលគឺ យោងតាមទស្សនៈក្រមសីលធម៌។ ការអនុវត្តវិធានណាមួយក្នុងចំណោមនោះ អាចនឹងត្រឹមត្រូវ និងខុសផ្នែកក្រមសីលធម៌ណាមួយផងដែរ។

**ឧទាហរណ៍៖** ធីតានិងសុភក្ត្រ ជាមិត្តភក្តិជិតស្និទ្ធដែលបានធ្វើការជាមួយគ្នានៅក្រុមហ៊ុនតែមួយ។ សុភក្ត្រជាប្រធានផ្នែកលទ្ធកម្ម។ សុភក្ត្រ ប្រាប់រឿងអាថ៌កំបាំងដល់ធីតា ថា គាត់បានទទួលកម្រៃជើងសារពីអ្នកផ្គត់ផ្គង់រាល់ពេលដែលចុះកិច្ចសន្យាទិញ ដោយជោគជ័យ។ គាត់សុំឱ្យធីតា

រក្សារឿងនេះជាការសម្ងាត់ប៉ុន្តែ ធីតា យល់ឃើញថា ទង្វើនេះមិនស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។ តើ ធីតា ត្រូវរាយការណ៍អំពីរឿងរបស់សុភក្រ្តជូនអ្នកគ្រប់គ្រងជាន់ខ្ពស់ឱ្យចាត់វិធានការដែរឬទេ? ការសម្រេចចិត្តបែបនេះគឺជារឿងដ៏លំបាកមួយ ពីព្រោះអាចមានទំនាស់រវាងគោលការណ៍គុណធម៌ "ភាពស្មោះត្រង់" របស់គាត់ចំពោះមិត្តភក្តិ និងក្រមសីលធម៌វិជ្ជាជីវៈក្នុងការបំពេញតួនាទីនៅក្នុងក្រុមហ៊ុន ដែលតម្រូវឱ្យគាត់ធ្វើចំណាត់ការដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន។

### គ១.២.២. ដំណោះស្រាយចំពោះទ្វេគ្រោះក្រមសីលធម៌

នៅពេលប្រឈមនឹងទ្វេគ្រោះក្រមសីលធម៌ បុគ្គល ឬស្ថាប័នអាចមានចំណាត់ការមួយចំនួនដូចខាងក្រោម ៖ [60]

- ប្រមូលព័ត៌មានពិត និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតអំពីស្ថានភាព/ករណីនោះ
- កំណត់អត្តសញ្ញាណភាគីសំខាន់ៗដែលពាក់ព័ន្ធ៖ តើនរណាអាចមានឥទ្ធិពលទៅលើ ឬនឹងរងឥទ្ធិពលពីការសម្រេចចិត្តរបស់អ្នក និងដោយវិធីណា?
- ពិចារណាលើគោលការណ៍ក្រមសីលធម៌ដែលពាក់ព័ន្ធ និងបញ្ហាពាក់ព័ន្ធ
- ពិនិត្យពីនីតិវិធីផ្ទៃក្នុង ប្រសិនបើមាន
- ពិចារណារកជម្រើសនៃវិធានការផ្សេងទៀត
- ពិចារណាទៅលើផលវិបាកសម្រាប់វិធានការនីមួយៗ
- ធ្វើការសម្រេចចិត្តដើម្បីដោះស្រាយទំនាស់នោះ

### ឧទាហរណ៍៖

ការលើកឧទាហរណ៍ទាក់ទងចំណុច គ១.២.១ អំពីទ្វេគ្រោះក្រមសីលធម៌ខាងលើ៖ **តើធីតា គួរធ្វើអ្វី?** អនុវត្តជំហាននៅក្នុងចំណុច គ១.២.២ សម្រាប់ការដោះស្រាយទ្វេគ្រោះក្រមសីលធម៌។

| | |
|---|---|
| ប្រមូលអង្គហេតុ និងបញ្ហា | ការណ៍ដែលសុភក្រ្តទទួលកម្រៃជើងសារពីអ្នកផ្គត់ផ្គង់ គឺជាការមិនគោរពបទបញ្ជាផ្ទៃក្នុង |
| ភាគីសំខាន់ៗដែលពាក់ព័ន្ធ | • សុភក្រ្ត<br>• ធីតា<br>• ក្រុមហ៊ុន |

[60] (The Asian Institute of Chartered Bankers, 2015)

| | |
|---|---|
| គោលការណ៍ក្រមសីលធម៌ដែលពាក់ព័ន្ធ | • ក្រមសីលធម៌ផ្អែកលើកាតព្វកិច្ច (deontological ethics)៖ សុភក្ត្រ និងធីតា ធ្វើការឱ្យក្រុមហ៊ុន ហើយពួកគេទាំងពីរនាក់មានកាតព្វកិច្ចបម្រើផលប្រយោជន៍របស់ក្រុមហ៊ុន ដូច្នេះត្រូវអនុវត្ត តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។<br>• ក្រមសីលធម៌ផ្អែកលើលទ្ធផល (Teleological Ethics)៖ ការទទួលបានកម្រៃជើងសារពីអ្នកផ្គត់ផ្គង់ អាចនាំឱ្យមានលទ្ធផលអវិជ្ជមានសម្រាប់មនុស្សមួយចំនួនធំ ដោយសារតែអ្នកផ្គត់ផ្គង់ការងារក្រោមស្តង់ដារ ដែលអាចធ្វើឱ្យលទ្ធផលការងាររបស់ក្រុមហ៊ុនមានការធ្លាក់ចុះ ដែលអាចប៉ះពាល់ដល់ប្រាក់ខែបុគ្គលិក ប្រាក់ចំណេញសម្រាប់ម្ចាស់ក្រុមហ៊ុន និងការទុកចិត្តរបស់អតិថិជន។<br>• ក្រមសីលធម៌ផ្អែកលើគុណធម៌ (Virtue Ethics)៖ ភាពស្មោះត្រង់ និងភាពគួរឱ្យទុកចិត្តរបស់ធីតា ចំពោះក្រុមហ៊ុន ប្រៀបធៀបនឹង ភាពស្មោះត្រង់ និងភាពគួរឱ្យទុកចិត្តរបស់នាងចំពោះមិត្តភក្តិរបស់នាង (សុភក្ត្រ)។ |
| យោងតាមនីតិវិធីផ្ទៃក្នុង | រាល់នីតិវិធីដែលបានចងក្រងជាឯកសារអំពីការចាត់វិធានការនៅពេលរកឃើញការរំលោភបំពាន |
| ពិចារណារកជម្រើសនៃវិធានការផ្សេងទៀត | • មិនធ្វើអ្វីសោះ - គ្មាននរណាម្នាក់ដឹង<br>• រាយការណ៍ជូនអ្នកគ្រប់គ្រងតាមនីតិវិធី<br>• វីស្សេលប្លូវីង (Whistleblowing)<br>• បញ្ចុះបញ្ចូលសុភក្ត្រ ឱ្យឈប់ប្រព្រឹត្តខុស និងពន្យល់អំពីការប្រឈមនឹងការចាត់វិធានការ |
| ពិចារណាទៅលើផលវិបាកសម្រាប់វិធានការនីមួយៗ | • មិនធ្វើអ្វីសោះគឺជាសញ្ញាមួយដែលបង្ហាញថា គាត់យល់ស្របចំពោះសកម្មភាពដែលសុភក្ត្រ បានធ្វើ ហើយលើកទឹកចិត្តឱ្យសកម្មភាពនេះកើតមានជាបន្តទៀត<br>• តាមរយៈការរាយការណ៍ទៅអ្នកគ្រប់គ្រង ឬការរាយការណ៍អំពីសកម្មភាពមិនត្រឹមត្រូវសុភក្ត្រ អាចនឹងត្រូវទទួលទោសតាមវិធានច្បាប់ ហើយវានឹងប៉ះពាល់ដល់ការអភិវឌ្ឍអាជីពរបស់នាង។ ម្យ៉ាងទៀត បញ្ហានេះនឹងប៉ះពាល់ដល់ចំណងមិត្តភាពរវាងធីតា និងសុភក្ត្រ<br>• បញ្ចុះបញ្ចូលសុភក្ត្រ ឱ្យបញ្ឈប់ការប្រព្រឹត្តកំហុសអាច ឬមិនអាចមានប្រសិទ្ធភាព ប្រសិនបើវាមានប្រសិទ្ធភាព នោះជាលទ្ធផលដែលយើងចង់បាន។ បើ |

| | |
|---|---|
| | មិនដូច្នេះទេ ការប្រព្រឹត្តកំហុសនៅតែបន្ត ហើយបញ្ហាដើមមិនត្រូវបានដោះស្រាយ |
| ធ្វើការសម្រេចចិត្ត | ធីតា អាច បញ្ចុះបញ្ចូលឱ្យសុភក្ត្រ ឈប់ប្រព្រឹត្តខុសទៀត ដែលអាចបំពេញតាមគោលការណ៍ "ភាពស្មោះត្រង់" របស់គាត់ ហើយទន្ទឹមនេះដែរ ធីតា អាចបញ្ជាក់ប្រាប់ សុភក្ត្រ ឱ្យបានច្បាស់ថា គាត់មិនគាំទ្រអាកប្បកិរិយាបែបនោះឡើយ។<br><br>ធីតា ក៏អាចប្រើប្រាស់យន្តការវីស្សលប្លូវីង ផងដែរ ប្រសិនបើការប្រព្រឹត្តបែបនេះនៅតែបន្តទៀតនោះ។ ភាពខ្វះចន្លោះដែលបានកត់សម្គាល់ឃើញស្តីពីដំណើរការដែលទាក់ទងនឹងលទ្ធកម្ម គួរលើកឡើងទៅកាន់អ្នកគ្រប់គ្រងជាន់ខ្ពស់ដើម្បីធានាបាននូវភាពត្រឹមត្រូវនៃដំណើរការនាពេលអនាគត។ |

**គ១.២.៣. ទំនាស់ផលប្រយោជន៍**

"ទំនាស់ផលប្រយោជន៍" កើតឡើងនៅពេលដែលបុគ្គល ឬស្ថាប័ន ពាក់ព័ន្ធនឹងកត្តាផលប្រយោជន៍ច្រើន ហើយការបម្រើផលប្រយោជន៍នេះអាចបង្កការខូចខាតដល់ផលប្រយោជន៍ផ្សេងទៀតផងដែរ។ផលប្រយោជន៍ នេះរួមមានទាំងផលប្រយោជន៍ហិរញ្ញវត្ថុ (ដូចជា ប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ចំណូល/ ប្រាក់ចំណេញ) និងផលប្រយោជន៍មិនមែនហិរញ្ញវត្ថុ (ដូចជា ទំនាក់ទំនងរវាងបុគ្គល កេរ្តិ៍ឈ្មោះ ការរីកចម្រើនមុខរបរវិជ្ជាជីវៈ ការគាំទ្រចំពោះគ្រួសារ/មិត្តភក្តិ) ជាដើម។

ទំនាស់ផលប្រយោជន៍អាចកើតឡើងក្នុងកាលៈទេសៈពីរគឺក្នុងករណីដែល៖

- មានទំនាស់រវាងផលប្រយោជន៍ផ្ទាល់ខ្លួន និងផលប្រយោជន៍របស់ភាគីទីបី ឧទាហរណ៍ កាតព្វកិច្ចរបស់ក្រុមហ៊ុន និង
- បុគ្គល ឬអង្គភាពមានកាតព្វកិច្ចបម្រើភាគីផ្សេងៗគ្នា ដែលអាចមានផលប្រយោជន៍ប្រកួតប្រជែងគ្នា។

**ឧទាហរណ៍៖** សាច់ញាតិធ្វើការជាមួយគ្នានៅក្រុមហ៊ុនតែមួយជាអ្នកគ្រប់គ្រង និងអ្នកក្រោមបង្គាប់។ ស្ថានភាព នេះអាចបង្កើតភាពអនុគ្រោះនិយម ដែលអាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់អ្នកគ្រប់គ្រង ការបែងចែកប្រាក់រង្វាន់ ឬការដំឡើងប្រាក់ខែ ឬជួនកាលមានការគប់គិតគ្នា (ការសហការខុសច្បាប់) រវាងគូភាគី ជាដើម។

បញ្ហាសំខាន់នៃទំនាស់ផលប្រយោជន៍គឺ "**សុចរិតភាព**" សំដៅទៅដល់ថាតើសកម្មភាពរបស់បុគ្គល ឬស្ថាប័នមួយមានភាពត្រឹមត្រូវ និងស្មើភាព ហើយបម្រើផលប្រយោជន៍ចម្បងនៃវិជ្ជាជីវៈដែរឬទេ។ បញ្ហាទាំងអស់នេះបានចោទជាសំណួរអំពីការសម្រេចចិត្ត និងសកម្មភាពប្រកបដោយក្រមសីលធម៌ហេតុដូច្នេះហើយហានិភ័យត្រូវតែទទួលបានការគ្រប់គ្រង និងត្រួតពិនិត្យជាចាំបាច់។

## ការកាត់បន្ថយទំនាស់ផលប្រយោជន៍

ហានិភ័យនៃទំនាស់ផលប្រយោជន៍អាចកាត់បន្ថយ ដោយការចាត់វិធានការដូចខាងក្រោម៖

- **ការកំណត់រក៖** កំណត់រក ឃើញពីទំនាស់ផលប្រយោជន៍ដែលគួរឱ្យកត់សម្គាល់។ ការកំណត់រកនេះអាចធ្វើឡើងតាមរយៈការពិនិត្យមើលគោលនយោបាយផ្ទៃក្នុងដែលមានស្រាប់ ក្រមប្រតិបត្តិក្នុងវិស័យទាំងមូល និងផ្អែកលើសុភនិច្ឆ័យ។
- **ការទប់ស្កាត់៖** ទប់ស្កាត់ទំនាស់ផលប្រយោជន៍តាមរយៈការដកខ្លួនចេញពីស្ថានភាពដែលអាចបង្កើតឱ្យមានទំនាស់ផលប្រយោជន៍ ប្រសិនបើអាចធ្វើទៅបាន។ ពេលខ្លះ ការទប់ស្កាត់មិនអាចធ្វើទៅបានទេ ដូច្នេះហើយក្នុងករណីនោះ ត្រូវប្រើការកាត់បន្ថយវិញ ដូចជា តាមរយៈការបង្ហាញព័ត៌មានជាដើម។
- **ការកាត់បន្ថយតាមរយៈការបង្ហាញព័ត៌មាន៖** លាតត្រដាងពីទំនាស់ផលប្រយោជន៍ដែលអាចកើតមានដល់ភាគីពាក់ព័ន្ធទាំងអស់។ ការធ្វើដូចនេះដើម្បីធានាថា ភាគីពាក់ព័ន្ធទាំងអស់នឹងបានដឹង ហើយធ្វើការវាយតម្លៃ។ ដូច្នេះ ប្រសិនបើរកឃើញមានទំនាស់ផលប្រយោជន៍ បញ្ហានេះគួរ លើកឡើង និងដោះស្រាយ ឱ្យបានត្រឹមត្រូវ។
- **ការអនុវត្តដំណោះស្រាយ៖** អនុវត្តដំណោះស្រាយដែលឆ្លើយតបទៅ នឹងទំនាស់ផលប្រយោជន៍ដែល ភាគីពាក់ព័ន្ធបានឯកភាពគ្នា បន្ទាប់ពីការលាតត្រដាងពីបញ្ហា ដើម្បីឱ្យប្រាកដថា ទំនាស់ផលប្រយោជន៍នោះត្រូវបានគ្រប់គ្រង និងដោះស្រាយ។

**ឧទាហរណ៍៖** ចាន់ គឺជាប្រធានផ្នែកគ្រប់គ្រងហានិភ័យទទួលបន្ទុកពិនិត្យ និងអនុម័តការស្នើសុំឥណទាន។ គាត់ទទួលបានការស្នើសុំឥណទានពីសាខាមួយ ហើយបានកត់សម្គាល់ឃើញថា មានជាប់ពាក់ព័ន្ធជាមួយក្រុមហ៊ុនអចលនទ្រព្យ ដែលគ្រប់គ្រងដោយបងថ្លៃស្រីរបស់គាត់។ ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍ ចាន់ បានស្នើឱ្យសហការីរបស់គាត់ដោះស្រាយការងារស្នើសុំឥណទាននេះជំនួសគាត់ដោយប្រកាសថា ករណីនេះមានជាប់ពាក់ព័ន្ធជាមួយសាច់ញាតិរបស់គាត់។ គាត់ក៏បានជូនដំណឹងដល់អ្នកគ្រប់គ្រងរបស់គាត់អំពីករណីនេះ។

**សំណួរផ្ទះបញ្ចាំង គ១.២**

រិទ្ធី ជាប្រធាននាយកដ្ឋានធនាគារសាជីវកម្ម។ ថ្មីៗនេះ គាត់សម្រេចលើសំណើប្រាក់កម្ចីរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ អចលនទ្រព្យដ៏ធំមួយ ដែលពាក់ព័ន្ធនឹងការសាងសង់លំនៅឋាន។ សូមធ្វើការវាយតម្លៃទៅលើទំនាស់ផលប្រយោជន៍ និងផ្តល់ដំណោះស្រាយតាមដែលអាចទៅរួចផ្អែកតាមករណីខាងក្រោម៖

បច្ចុប្បន្ន រិទ្ធី កំពុងស្វែងរកផ្ទះថ្មីមួយកន្លែង ហើយគាត់មានការចាប់អារម្មណ៍លើគម្រោងរបស់ក្រុមហ៊ុននេះ។ ម្ចាស់ក្រុមហ៊ុនបានផ្តល់ការបញ្ចុះតម្លៃខ្ពស់ដល់គាត់សម្រាប់ការទិញនេះ។ តើការបញ្ចុះតម្លៃនេះជាទំនាស់ផលប្រយោជន៍ដែរឬទេ?

## គ២. អនុវត្តក្រមសីលធម៌ក្នុងអាជីវកម្ម

### គ២.១.កំណត់និយមន័យនៃក្រមសីលធម៌និងស្វែងយល់ពីសារៈសំខាន់របស់វានៅក្នុងវិស័យធនាគារ

ក្រមសីលធម៌អាជីវកម្មគឺជាបណ្តុំនៃស្តង់ដារ ឬបទដ្ឋាននៃភាពត្រឹមត្រូវ និងភាពខុសឆ្គងណាមួយដែលតម្រង់ទិសដៅនៃអាកប្បកិរិយារបស់បុគ្គលិក។ ក្រមសីលធម៌នេះមានសារៈសំខាន់ចំពោះនិរន្តរភាព និងការរីកចម្រើនរបស់អាជីវកម្មពីព្រោះវាលើកកម្ពស់សុចរិតភាព និងការទទួលខុសត្រូវរបស់បុគ្គលិក បណ្តុះទំនុកចិត្តចំពោះភាគីពាក់ព័ន្ធ បង្កើតកេរ្តិ៍ឈ្មោះអាជីវកម្មជាវិជ្ជមានព្រមទាំងបង្កើនភាពស្មោះត្រង់របស់អតិថិជន និងបុគ្គលិកផងដែរ។ ដូច្នេះ តើធ្វើដូចម្តេចដើម្បីអភិវឌ្ឍនិងរក្សាវប្បធម៌សាជីវកម្ម ប្រកបដោយក្រមសីលធម៌នៅក្នុងអាជីវកម្មមួយបាន?

វប្បធម៌សាជីវកម្មប្រកបដោយក្រមសីលធម៌មានសសរស្តម្ភចំនួនបី៖[61]

- គុណតម្លៃក្រមសីលធម៌ស្នូល
- កម្មវិធីក្រមសីលធម៌
- ភាពជាអ្នកដឹកនាំប្រកបដោយក្រមសីលធម៌

[61] (Schwartz, 2017)

## គ២.១.១. គុណតម្លៃក្រមសីលធម៌ស្នូល

ជំហានសំខាន់ទីមួយក្នុងការអភិវឌ្ឍវប្បធម៌នៃក្រមសីលធម៌នៅក្នុងស្ថាប័ន គឺត្រូវកំណត់ "គុណតម្លៃក្រមសីលធម៌ស្នូល" ដែលស្ថាប័នចង់លើកតម្កើងក្នុងការធ្វើអាជីវកម្ម។ គុណតម្លៃនេះចាំបាច់ត្រូវរួមបញ្ចូលទៅក្នុងការប្រតិបត្តិតាមរបស់បុគ្គលិក គ្រប់ជាន់ថ្នាក់នៅក្នុងក្រុមហ៊ុន រួមមានក្រុមប្រឹក្សាភិបាលក្នុងការគ្រប់គ្រងសកម្មភាពអាជីវកម្ម ជាមួយភាគីពាក់ព័ន្ធទាំងខាងក្នុង និងខាងក្រៅអាជីវកម្ម។ គណៈគ្រប់គ្រងកម្រិតខ្ពស់បំផុតគឺ "ក្រុមប្រឹក្សាភិបាល" ដែលជាអ្នកទទួលខុសត្រូវក្នុងការអនុម័តគុណតម្លៃនៃក្រមសីលធម៌របស់ស្ថាប័ន។

ក្នុងការជ្រើសរើសគុណតម្លៃ ស្ថាប័នត្រូវធ្វើការពិចារណាទៅលើចំណុចដូចខាងក្រោម៖

- **ការបន្ស៊ីជាមួយអ្នកពាក់ព័ន្ធគោលដៅ៖** ស្ថាប័នគប្បីមានគុណតម្លៃស្នូលដែលស្របគ្នាជាមួយនឹងភាគីពាក់ព័ន្ធរបស់ខ្លួនដែលរួមមាន បុគ្គលិក អតិថិជន អ្នកផ្គត់ផ្គង់ អ្នកវិនិយោគ ជាដើម។ ស្ថាប័នមួយចំនួននឹងជំរុញឱ្យបុគ្គលិកចូលរួមក្នុងការជ្រើសរើសគុណតម្លៃរបស់ស្ថាប័ន។
- **សកលភាព៖** គុណតម្លៃដែលបានជ្រើសរើសត្រូវមានលក្ខណៈជាសកលគ្រប់គ្រាន់ មានន័យថា សារៈសំខាន់របស់វាគឺមិនអាស្រ័យទៅលើវប្បធម៌ សាសនា ពេលវេលា និងកាលៈទេសៈនោះទេ។
- **ការអនុលោមតាមបទប្បញ្ញត្តិ៖** គុណតម្លៃមិនត្រូវផ្ទុយនឹងបទប្បញ្ញត្តិ ឬស្ថាប័នពាណិជ្ជកម្មដែលមានស្រាប់ដែលអាចមានឥទ្ធិពលលើជម្រើសនៃគុណតម្លៃឡើយ។ គុណតម្លៃត្រូវបានបញ្ជាក់ឱ្យបានច្បាស់នៅក្នុងគោលនយោបាយរបស់ស្ថាប័ន ដែលបានដាក់បញ្ចូលទៅក្នុងដំណើរការ និងមុខងារទាំងអស់ ហើយបានប្រាស្រ័យទាក់ទងយ៉ាងទូលំទូលាយទៅកាន់ថ្នាក់ដឹកនាំ និងបុគ្គលិកគ្រប់រូបនៅក្នុងស្ថាប័ន ដែលជាសសរស្តម្ភទី២ នៃវប្បធម៌សាជីវកម្មប្រកបដោយក្រមសិលធម៌(**កម្មវិធីក្រមសីលធម៌**)។

**ឧទាហរណ៍៖** "Bank of America" មានអាយុកាលជា២៤០ ឆ្នាំមកហើយ ដែលមានគុណតម្លៃស្នូល "កំណើនប្រកបដោយទំនួលខុសត្រូវ" ដែលក្នុងនោះរួមមានគោលការណ៍ចំនួនបួនគឺ៖ ១) ការផ្តោតលើកំណើន ២) ការផ្តោតលើអតិថិជន ៣) កំណើនក្នុងក្របខណ្ឌហានិភ័យ ៤)កំណើនប្រកបដោយនិរន្តរភាព តាមរយៈភាពល្អឥតខ្ចោះផ្នែកប្រតិបត្តិការ ជាកន្លែងធ្វើការដ៏អស្ចារ្យសម្រាប់ក្រុមការងារ និងការចែករំលែកភាពជោគជ័យជាមួយសហគមន៍។ តាមរយៈកំណើនប្រកបដោយទំនួល

ខុសត្រូវធនាគារចង់ផ្តល់ផលតបស្នងដល់អតិថិជន និងម្ចាស់ភាគហ៊ុន និងដោះស្រាយបញ្ហាដែលកើតមានក្នុងសង្គម។[62]

### គ២.១.២. កម្មវិធីក្រមសីលធម៌

កម្មវិធីក្រមសីលធម៌គឺជាក្របខណ្ឌមួយដែលរៀបរាងឡើងដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តគុណតម្លៃប្រកបដោយក្រមសីលធម៌ក្នុងការប្រព្រឹត្តក៏ដូចជាការធ្វើសេចក្តីសម្រេចរបស់ស្ថាប័ន។ កម្មវិធីនេះរួមមានការចងក្រងជាឯកសារនូវក្រមសីលធម៌ ឬក្រមប្រតិបត្តិ កម្មវិធីបណ្តុះបណ្តាលក្រមសីលធម៌ និងការត្រួតពិនិត្យ កម្មវិធីក្រមសីលធម៌។

- **ក្រមប្រតិបត្តិ**

  ក្រមប្រតិបត្តិនេះត្រូវបានបង្កើតឡើងដោយផ្អែកលើគុណតម្លៃស្នូលរបស់ស្ថាប័នដែលជាកម្រងវិធានឬគោលនយោបាយ ដែលមានចែងគោលការណ៍ណែនាំសម្រាប់ការប្រតិបត្តិរបស់បុគ្គលិក (អ្វីដែលគួរធ្វើ និងអ្វីដែលមិនគួរធ្វើ) ក៏ដូចជាការវិនិច្ឆ័យទាក់ទងនឹងបញ្ហាក្រមសីលធម៌ជាដើម។ ខ្លឹមសារអាចគ្របដណ្តប់លើប្រធានបទដូចខាងក្រោម។[63]

  - ការសម្ងាត់នៃព័ត៌មាន
  - ទំនាស់ផលប្រយោជន៍
  - ការងារស្មើភាព ការរើសអើង
  - អំណោយ និងការកម្សាន្ត
  - ការបៀតបៀនផ្លូវភេទ
  - សុខភាព បរិស្ថាន និងសុវត្ថិភាព
  - នីតិវិធីនៃការទិញ។ល។

- **ការបណ្តុះបណ្តាល និងពង្រឹងក្រមសីលធម៌៖**

  ដើម្បីធានាថាបុគ្គលិករក្សាបាននូវគុណតម្លៃរបស់ស្ថាប័ន ពួកគេត្រូវស្វែងយល់ពីខ្លឹមសារក្រមគោលនយោបាយ និងសំខាន់បំផុតនោះគឺយល់ដឹងពីមូលហេតុដែលធ្វើឱ្យគុណតម្លៃមានសារៈសំខាន់ចំពោះពួកគេ និងចំពោះស្ថាប័ន។ ទាំងនេះអាចសម្រេចបានតាមរយៈ

---
[62] (Bank of America Corporation, n.d.)
[63] (Schwartz, 2017)

- **ការបណ្តុះបណ្តាលទៀងទាត់ / ការណែនាំដល់បុគ្គលិក៖** ការបណ្តុះបណ្តាលបុគ្គលិកអំពីគុណតម្លៃស្នូល និងបញ្ហាក្រមសីលធម៌ត្រូវធ្វើឡើងឱ្យបានទៀងទាត់។ វាមិនត្រឹមតែធានាដល់ការយល់ដឹងរបស់បុគ្គលិកអំពីគោលការណ៍ក្រមសីលធម៌ និងគោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងសមត្ថភាពសីលធម៌របស់ពួកគេទៀតផង ដែលអាចឱ្យពួកគេទទួលស្គាល់ពីបញ្ហាក្រមសីលធម៌ ហេតុផល និងធ្វើការសម្រេចចិត្តបានត្រឹមត្រូវប្រកបដោយក្រមសីលធម៌។
- **ការពង្រឹងការអនុវត្ត៖** ការអនុលោមតាមក្រមប្រតិបត្តិចាំបាច់ត្រូវពង្រឹងជាប់ជានិច្ចតាមរយៈកិច្ចប្រជុំ អ៊ីមែល ការលើកឡើងរបស់ថ្នាក់ដឹកនាំ ឬបណ្តាញទំនាក់ទំនងផ្សេងទៀត។ ការធ្វើដូចនេះគឺដើម្បីធានាថា បុគ្គលិកទាំងអស់ យល់ដឹងពីការតាំងចិត្តនិងការប្តេជ្ញាចិត្តទាក់ទងនឹងគុណតម្លៃប្រកបដោយក្រមសីលធម៌របស់ស្ថាប័ន។ ការទទួលស្គាល់ឥរិយាបថល្អរបស់បុគ្គលិកនៅទីសាធារណៈគឺជាវិធីសាស្ត្រមួយដើម្បីបង្កើនការប្តេជ្ញាចិត្តរបស់បុគ្គលិក និងជំរុញឱ្យមានទង្វើប្រកបដោយក្រមសីលធម៌កាន់តែច្រើនផងដែរ។
- **ការវាយតម្លៃ និងប្រាក់ឈ្នួល៖** អាកប្បកិរិយារបស់បុគ្គលិកគឺជាផ្នែកនៃដំណើរការនៃវាយតម្លៃប្រសិទ្ធភាពការងារ។ បញ្ហាស្តីពីក្រមសីលធម៌ នឹងត្រូវចងក្រងទុកជាឯកសារ និងធ្វើការពិភាក្សាជាមួយបុគ្គលិក។ រចនាសម្ព័ន្ធនៃការផ្តល់រង្វាន់គួរត្រូវផ្សារភ្ជាប់ទៅនឹងឥរិយាបថក្រមសីលធម៌របស់បុគ្គលិក មិនមែនផ្អែកទៅលើតែចំណូលដែលពួកគេរកបានឱ្យក្រុមហ៊ុននោះទេ។ ការធ្វើដូចនេះលើកទឹកចិត្តបុគ្គលិកឱ្យពិចារណាពីលទ្ធផល នៃសកម្មភាពប្រកបដោយក្រមសិលធម៌របស់ពួកគេ។

- **កម្មវិធីត្រួតពិនិត្យក្រមសីលធម៌៖**

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តក្រមសីលធម៌ ស្ថាប័នអាចដាក់ចេញនូវយន្តការតាមដាន និងត្រួតពិនិត្យកម្មវិធីក្រមសីលធម៌ ដែលរួមមានដូចខាងក្រោម៖

- **ការតែងតាំងមន្ត្រីទទួលបន្ទុកផ្នែកក្រមសីលធម៌៖** បុគ្គលនេះទទួលបន្ទុកមើលការខុសត្រូវលើបញ្ហាក្រមសីលធម៌និងកម្មវិធីក្រមសីលធម៌។ មន្ត្រីក្រមសីលធម៌គឺជាអ្នកដែលបុគ្គលិកអាចប្រឹក្សាសុំយោបល់ស្តីពីបញ្ហាទាក់ទងនឹងក្រមសីលធម៌ រួមទាំងការអនុវត្តក្រមប្រតិបត្តិ ឬការធ្វើសេចក្តីសម្រេច។
- **យន្តការរាយការណ៍៖** ត្រូវដាក់ចេញនូវយន្តការនេះដើម្បីធានាថា ការប្រព្រឹត្តិខុសត្រូវមានការរាយការណ៍ឱ្យបានត្រឹមត្រូវ ឧទាហរណ៍ តាមរយៈបណ្តាញវិស្សលប្លូវីង

(whistle blowing) ជាដើម។ យន្តការនេះអនុញ្ញាតឱ្យស្ថាប័នស៊ើបអង្កេត និងស្វែងរកដំណោះស្រាយបានទាន់ពេលវេលា។

- **កម្មវិធីសវនកម្ម និងត្រួតពិនិត្យក្រមសីលធម៌៖** កម្មវិធីនេះនឹងរួមបញ្ចូលការធ្វើតេស្តជាប្រចាំលើការអនុលោមតាមក្រមសីលធម៌ និងការស្ទង់មតិបុគ្គលិកដើម្បីកំណត់ផ្នែកដែលត្រូវកែលម្អនៃកម្មវិធីក្រមសីលធម៌។ ក្រមនេះគួរត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់ដើម្បីឆ្លុះបញ្ចាំងពីកង្វល់ថ្មីៗដែលកើតឡើង ប្រសិនបើមាន។

### គ២.១.៣. ភាពជាអ្នកដឹកនាំប្រកបដោយក្រមសីលធម៌

ភាពជាអ្នកដឹកនាំប្រកបដោយក្រមសីលធម៌ គឺជាធាតុផ្សំដ៏សំខាន់ក្នុងការលើកកម្ពស់វប្បធម៌ក្រមសីលធម៌នៅក្នុងស្ថាប័ន។ ថ្នាក់ដឹកនាំគឺជាអ្នកដែល "បង្ហាញការប្តេជ្ញាចិត្ត និងកំណត់ទិសដៅពីថ្នាក់លើ" (set tone from the top) នូវគោលជំហរក្រមសីលធម៌របស់ស្ថាប័ន ហើយ "ធ្វើការអនុវត្ត (walk the talk)" មានន័យថា ថ្នាក់ដឹកនាំត្រូវកំណត់ការរំពឹងទុកឱ្យបានច្បាស់លាស់ទាក់ទងនឹងគុណតម្លៃក្រមសីលធម៌សម្រាប់បុគ្គលិកគ្រប់រូប ដោយឱ្យមនុស្សគ្រប់រូប (រួមទាំងខ្លួនឯងផង) ប្រកាន់ខ្ជាប់តាមស្តង់ដារនៃគុណតម្លៃតែមួយ និងអនុវត្តឱ្យបានខ្ជាប់ខ្ជួនដើម្បីជាគំរូល្អដល់បុគ្គលិក។ គុណតម្លៃប្រកបដោយក្រមសីលធម៌ចាំបាច់ត្រូវឆ្លុះបញ្ចាំងលើរាល់សកម្មភាព និងការសម្រេចចិត្តរបស់អ្នកដឹកនាំដើម្បីជំរុញឱ្យមាននូវទង្វើប្រកបដោយក្រមសីលធម៌របស់បុគ្គលិក និងអ្នកពាក់ព័ន្ធ។ ក្រមសីលធម៌ផ្ទាល់ខ្លួន និងក្រមសីលធម៌វិជ្ជាជីវៈមិនត្រូវញែកដាច់ពីគ្នាទាំងស្រុងនោះទេ ដែលមានន័យថា អ្នកដឹកនាំប្រកបដោយក្រមសីលធម៌ត្រូវរស់នៅក្នុងជីវិតប្រកបដោយសីលធម៌ផ្ទាល់ខ្លួនដើម្បីក្លាយជាគំរូដ៏ល្អ។

បន្ថែមពីលើនេះ អ្នកដឹកនាំត្រូវបង្កើនវប្បធម៌ដែលប្រកបដោយក្រមសីលធម៌ តាមរយៈបរិយាកាស និងសកម្មភាពជាក់ស្តែង ដែលអ្នកដទៃអាចធ្វើការសម្រេចចិត្តបានផងដែរ។ នេះធ្វើឡើងតាមរយៈការបង្កើតផលិតផលនិងសេវាកម្មថ្មីៗដែលបង្កើតគុណតម្លៃសម្រាប់សង្គម។[64]

**ឧទាហរណ៍៖** ក្រុមហ៊ុន វ៉ុលវ៉ូ (Volvo) ដែលជាក្រុមហ៊ុនផលិតរថយន្ត បានផលិតខ្សែក្រវាត់សុវត្ថិភាពរថយន្តប្រភេទ V បីចំណុច (V type three-piont safety car seatbelt) ក្នុងឆ្នាំ១៩៥៩ដោយវិស្វកររបស់ខ្លួនឈ្មោះ Nils Bohlin ដោយបានចំណាយប្រាក់រាប់លានដុល្លារលើការស្រាវជ្រាវ និងការអភិវឌ្ឍព្រមទាំងការធ្វើទីផ្សារផ្សព្វផ្សាយពីផលិតផលនេះ។ ខ្សែក្រវាត់សុវត្ថិភាពដែលបានបង្កើតឡើងនេះគឺមានភាពងាយស្រួលក្នុងការប្រើប្រាស់ និងមានសុវត្ថិភាពជាងមុន ហើយបច្ចុប្បន្ន

[64] (Bazerman, 2020)

ជាខ្សែក្រវាត់សុវត្ថិភាពស្តង់ដារសម្រាប់រថយន្ត។ ទោះបីជាបានចំណាយប្រាក់រាប់លានដុល្លារលើការស្រាវជ្រាវ និងការអភិវឌ្ឍរួមទាំងការធ្វើទីផ្សារផ្សព្វផ្សាយពីផលិតផលនេះក៏ដោយ ក៏ក្រុមហ៊ុន វ៉លវ៉ូ បានអនុញ្ញាតឲ្យ ពិភពលោកប្រើប្រាស់តក្កកម្មនោះ ដោយឥតគិតថ្លៃដើម្បីជំរុញឱ្យមានការអនុវត្តបានយ៉ាងទូលំទូលាយនិងជួយសង្គ្រោះអាយុជីវិត ពីគ្រោះថ្នាក់។[65] នេះបង្ហាញពីភាពជាអ្នកដឹកនាំប្រកបដោយសីលធម៌របស់ក្រុមហ៊ុន វ៉លវ៉ូ នៅក្នុងឧស្សាហកម្មផលិតរថយន្ត។

**សំណួរឆ្លុះបញ្ចាំង គ២.១.**

អតិថិជនម្នាក់ដែលមានទ្រព្យសម្បត្តិច្រើនបានមកកាន់ធនាគារដើម្បីដាក់ប្រាក់បញ្ញើមួយចំនួនធំទៅក្នុងគណនីរបស់ខ្លួន។ ដោយយោងតាមនីតិវិធីធនាគារ បុគ្គលិកធនាគារឈ្មោះ ធារី បានតម្រូវឱ្យអតិថិជនរូបនេះផ្តល់ឯកសារគាំទ្រដើម្បីដំណើរការប្រតិបត្តិការ។ ប៉ុន្តែ អតិថិជនរូបនេះបានបដិសេធ។ ទោះបីជាមិនមានឯកសារយោងក៏ដោយ ក៏អតិថិជនរូបនេះបានទាមទារឱ្យបុគ្គលិកធនាគារដំធ្វើណើរការប្រតិបត្តិការនេះជាបន្ទាន់។ ធារី បានបដិសេធតាមលក្ខណៈវិជ្ជាជីវៈ ដោយមិនឱ្យមានដំណើរការបន្តទៀតឡើយ។ អតិថិជនរូបនេះមានការខឹងសម្បារយ៉ាងខ្លាំងដោយបានស្រែកដាក់នាង និងគំរាមបិទគណនីទាំងអស់ជាមួយធនាគារនេះ។ ធារី បានព្យាយាមធ្វើឱ្យអតិថិជនរូបនេះស្ងប់ចិត្ត ហើយពន្យល់ប្រាប់ពីមូលហេតុ។ ប៉ុន្តែ អតិថិជនរូបនេះនៅតែបន្តភាពឆេវឆាវរបស់ខ្លួនដដែល។ អតិថិជនរូបនេះគឺជាអ្នកជំនួញដ៏មានឥទ្ធិពលម្នាក់នៅក្នុងវិស័យនេះ ហើយក៏ជាអតិថិជនសំខាន់របស់ធនាគារ ផងដែរដែលគាត់មានធនធានច្រើនដែលបានជួយបង្កើតប្រាក់ចំណូលសមរម្យសម្រាប់ធនាគារនេះក្នុងរយៈពេលបីឆ្នាំចុងក្រោយ។ ប្រធានសាខា លោក រិទ្ធី បានចូលមកជួយអន្តរាគមន៍ក្នុងស្ថានការណ៍នោះ។ តើរិទ្ធីគួរធ្វើអ្វីក្នុងកាលៈទេសៈបែបនេះ?

## គ២.២. ក្រមសីលធម៌ក្នុងវិស័យធនាគារ និង ការអនុវត្តគោលការណ៍ក្រមសីលធម៌សំខាន់ៗក្នុងវិស័យធនាគារ

ការប្រព្រឹត្តិកំហុសក្នុងវិស័យធនាគារអាចកើតឡើង ហើយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ថិរភាពទាំងមូលនៃប្រព័ន្ធនេះដូចជា “វិបត្តិហិរញ្ញវត្ថុក្នុងឆ្នាំ២០០៨” ។ រឿងអាស្រូវហិរញ្ញវត្ថុ

[65] (Bell, 2019)

ទាំងនេះអាចពាក់ព័ន្ធនឹងការលក់ផលិតផលមិនត្រឹមត្រូវ អំពើពុករលួយ និងការមិនគោរពតាមបទដ្ឋានគតិយុត្តិដែលបង្កឱ្យមានការសង្ស័យកើនឡើងពាក់ព័ន្ធនឹងក្រមសីលធម៌ និងទំនុកចិត្តក្នុងវិស័យធនាគារ។

ជាទូទៅ មូលហេតុនៃការមិនអនុលោមតាមច្បាប់អាចបណ្តាលមកពីៈ[66]

- ទំនាស់ផលប្រយោជន៍ ដែលបុគ្គល ឬស្ថាប័នផ្តល់អាទិភាពដល់ផលប្រយោជន៍ផ្ទាល់ខ្លួន លើទំនួលខុសត្រូវ និងភារកិច្ចរបស់ពួកគេ និង
- បុគ្គល ឬស្ថាប័នដែលមិនអាចអនុវត្តតាមកម្រិតចាំបាច់នៃសមត្ថភាព ឬការយកចិត្តទុកដាក់ដើម្បីបំពេញនូវទំនួលខុសត្រូវផ្នែកក្រមសីលធម៌ និងបទប្បញ្ញត្តិរបស់ខ្លួន។

ផ្អែកលើលក្ខណៈអាជីវកម្មនេះ សកម្មភាពដែលប្រព្រឹត្តខុសនៅក្នុងគ្រឹះស្ថានណាមួយអាចប៉ះពាល់យ៉ាងខ្លាំងដល់ប្រព័ន្ធធនាគារ និងសេដ្ឋកិច្ចទាំងមូល។ ដូច្នេះហើយ បទប្បញ្ញត្តិ និងការពិន័យតែមួយមុខមិនទាន់គ្រប់គ្រាន់នោះទេ។ វិស័យធនាគារទាមទារឱ្យមានស្តង់ដារក្រមសីលធម៌ខ្ពស់ដែលស្ថាប័ននិងបុគ្គលិកម្នាក់ៗត្រូវអនុវត្តលើសពី "ការអនុលោមតាមបទប្បញ្ញត្តិ/ច្បាប់" ក្នុងដោយធ្វើរឿងដែលត្រឹមត្រូវដើម្បីពង្រឹងទំនុកចិត្តសាធារណជន និងស្ថិរភាពនៃវិស័យទាំងមូល។

**គោលការណ៍ក្រមសីលធម៌ ដែលបានចងក្រងដោយសមាគមធនាគារនៅកម្ពុជា សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អនុវត្តមានដូចខាងក្រោមៈ**[67]

- អនុវត្តដោយយុត្តិធម៌ និងសមហេតុផលទៅលើអ្នកប្រើប្រាស់ប្រកបដោយ សង្គតិភាព (consistent) និង សីលធម៌ (ethical)
- អនុលោមតាមច្បាប់ វិធាន និងបទប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជាគ្រប់ពេលវេលាទាំងអស់។ មិនត្រូវចូលរួម ឬគាំទ្រសកម្មភាពពុករលួយនោះទេ ហើយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនឹងទទួលខុសត្រូវផ្នែកសង្គម សហគមន៍ វប្បធម៌ និងបរិស្ថាននៃប្រទេសកម្ពុជា
- លើកកម្ពស់ និងពង្រឹងការអនុវត្ត ចំពោះអ្នកប្រើប្រាស់ដោយស្មើភាពគ្នា និងដោយការគោរព
- ចៀសវាងការរើសអើង ប្រឆាំងនឹងប្រភេទ ឬក្រុមភាគតិច (protected groups or minorities) ដែលត្រូវបានការពារ នៅក្នុងការជ្រើសរើសអ្នកប្រើប្រាស់ និងកំណត់លក្ខខណ្ឌ
- ធ្វើការប្រមូលឥណទានដោយ បុគ្គលិក ឬភ្នាក់ងារដែលបានផ្តល់ការអនុញ្ញាត (authorized staff or agents)។

[66] (The Asian Institute of Chartered Bankers, 2015)
[67] (The Association of Banks in Cambodia, 2022)

លើសពីនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលប្រកបដោយក្រមសីលធម៌ត្រូវធ្វើអាជីវកម្មដែលមានបទដ្ឋានក្រមសីលធម៌ច្បាស់លាស់ ហើយមិនត្រឹមតែផ្តោតលើការបង្កើនប្រាក់ចំណេញរបស់គ្រឹះស្ថានប៉ុណ្ណោះទេ រួមបញ្ចូលទាំងផលប្រយោជន៍ខាងសេដ្ឋកិច្ចសង្គមផងដែរ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវពិចារណាពីផលប៉ះពាល់នៃការវិនិយោគ និងប្រាក់កម្ចីរបស់ពួកគេ ទៅកាន់សង្គមនិងបរិស្ថាន។ ដូចនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នឹងមានគោលនយោបាយកំណត់ថាតើពួកគេគួរធ្វើអាជីវកម្មជាមួយនរណា ជាមួយឧស្សាហកម្ម ឬ វិស័យណា ឬ ជំនួយមូលនិធិគួរត្រូវបានផ្តល់ជូននរណា ក៏ដូចជាការគិតគូរពីសកម្មភាពសង្គមនិងមនុស្សធម៌ (CSR) ផងដែរ។ ជាពិសេស នៅប្រទេសកម្ពុជា ក្រមប្រតិបត្តិសម្រាប់បុគ្គលិករបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយសមាគមធនាគារនៅកម្ពុជា ហើយវាជាកាតព្វកិច្ចចាំបាច់ដែលស្ថាប័នត្រូវប្រកាន់ខ្ជាប់នូវក្រមប្រតិបត្តិនេះ។[68]

**សំណួរឆ្លុះបញ្ចាំង គ២.២.**

ធារី ជាប្រធានផ្នែកទំនាក់ទំនងប្រាក់កម្ចី។ លទ្ធផលប្រចាំត្រីមាសរបស់គាត់គឺនៅទាបជាងគោលដៅដែលបានកំណត់។ ថ្មីៗនេះ សាខាបានណែនាំឱ្យនាងនូវអតិថិជនថ្មីមួយដែលស្នើសុំខ្ចីប្រាក់ចំនួន២លានដុល្លារ។ ប្រសិនបើការងារនេះ សម្រេចបានដោយជោគជ័យធារី អាចសម្រេចតាមគោលដៅប្រចាំត្រីមាសរបស់ខ្លួន។ បន្ទាប់ពីជួបសំណេះសំណាលជាមួយអតិថិជន ធារី បានដឹងថា អាជីវកម្មនេះត្រូវបានចាត់ថ្នាក់ជាសហគ្រាសធុនតូច និងមធ្យម (SME) និងជាអាជីវកម្មលក្ខណៈគ្រួសារ ដែលមិនមានកំណត់ត្រារបាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវ។ អតិថិជនស្នើសុំឱ្យ ធារី បង្កើតរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ពួកគេ និងស្វែងរកវិធីយ៉ាងណាជួយពួកគេឱ្យទទួលបានប្រាក់កម្ចីនេះ។ ជាការតបស្នង ពួកគេនឹងផ្តល់កម្រៃជើងសារមួយចំនួនជាការដឹងគុណ។ តើធារី គួរធ្វើយ៉ាងណា?

## គ៣. អនុវត្ត គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ក្នុងអាជីវកម្ម

### គ៣.១. និយមន័យនៃ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច

គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច គឺជាបណ្តុំនៃកត្តាទាំងឡាយដែលទាក់ទងនឹងផលប៉ះពាល់បរិស្ថាន សង្គម ព្រមទាំងអភិបាលកិច្ចនៃអាជីវកម្ម និងប្រតិបត្តិការអាជីវកម្ម។[69] ដោយមើលឃើញពីកង្វល់បច្ចុប្បន្នស្តីពីការប្រែប្រួលអាកាសធាតុ និងការខូចខាតនៃបរិស្ថានរួមជាមួយ

[68] (The Association of Banks in Cambodia, 2021)
[69] (IFC, 2021)

នឹងកត្តាជំរុញដើម្បីកាត់បន្ថយបញ្ហាសង្គម និងកង្វះអភិបាលកិច្ច អ្នកវិនិយោគ និងអ្នកផ្តល់ប្រាក់កម្ចី ត្រូវមានការយកចិត្តទុកដាក់ឱ្យបានច្រើនជាងមុន និងធ្វើការងារផ្សេងៗទៀតបន្ថែមពីលើការស្វែងរកប្រាក់ចំណេញពីការ វិនិយោគ និង ផ្តល់ប្រាក់កម្ចី។[70] ជាពិសេស ធនាគារត្រូវកំណត់ការវាយតម្លៃ និងកាត់បន្ថយហានិភ័យទាំងនេះ រួមមានហានិភ័យកេរ្តិ៍ឈ្មោះ ហានិភ័យសន្ទនីយភាពនិងហានិភ័យឥណទាន ដែលបន្សល់ទុកពីសកម្មភាពផ្តល់ប្រាក់កម្ចីរបស់ពួកគេដល់អាជីវកម្មដែលអាចមានបញ្ហាទាក់ទងនឹង គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច។[71] គោលការណ៍នេះ មានវិសាលភាព ទូលំទូលាយ ប៉ុន្តែខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនតាមប្រភេទនីមួយៗ៖

- **បញ្ហាបរិស្ថាន៖**[72]

  - សកម្មភាពដែលប៉ះពាល់ដល់គុណភាព និងបរិមាណទឹក ជាពិសេសសកម្មភាពដែលមានតម្រូវការទឹកខ្ពស់ហើយនៅក្នុងតំបន់កំពុងខ្វះខាតទឹក
  - សកម្មភាពដែលបញ្ចេញឧស្ម័នគ្រោះថ្នាក់ រួមមាន កាបូនឌីអុកស៊ីត កាបូនម៉ូណូអុកស៊ីត មេតាន ស្ពាន់ធ័រឌីអុកស៊ីត និងឧស្ម័នពុលផ្សេងៗទៀត
  - សកម្មភាពដែលបង្កើតកាកសំណល់រឹង និងកាកសំណល់គីមី រួមទាំងលោហធាតុគ្រោះថ្នាក់ (រួមទាំងសារធាតុអាសេនិក បារត សំណ ។ល។) កាកសំណល់ជីវសាស្ត្រ និងវត្ថុធាតុបង្កគ្រោះថ្នាក់ផ្សេងទៀត
  - សកម្មភាពដែលប៉ះពាល់ដល់ការផ្លាស់ប្តូរការប្រើប្រាស់ដី រួមមានកសិកម្មតាមរយៈការកាប់ព្រៃនិងដុតព្រៃ ការអភិវឌ្ឍអចលនទ្រព្យ ការកាប់បំផ្លាញព្រៃឈើ។ល។ ដែលឈានទៅរកការបាត់បង់ជីវចម្រុះ ជម្រកធម្មជាតិរបស់សត្វព្រៃ និងប្រភេទសត្វជិតផុតពូជជាដើម
  - ការប្រើប្រាស់ធនធានគ្មានប្រសិទ្ធភាព
  - ការគ្រប់គ្រងកាកសំណល់ និងការកែច្នៃឡើងវិញ

- **បញ្ហាសង្គម៖**[73]

  - សិទ្ធិការងារ និងសិទ្ធិកម្មករ រួមទាំងលក្ខខណ្ឌសុខភាព និងសុវត្ថិភាព
  - សុខភាពនិងសុវត្ថិភាពសហគមន៍ ពោលគឺការគ្រប់គ្រងហានិភ័យចំពោះសហគមន៍មូលដ្ឋានបង្កើតឡើងដោយប្រតិបត្តិការអាជីវកម្មរបស់អតិថិជនដែលអាចរាប់បញ្ចូលទាំងការ

[70] (Stampe, 2014) & (IFC, 2021)
[71] (KPMG, 2020a)
[72] (Stampe, 2014) & (IFC, 2021)
[73] (Stampe, 2014)

ផ្ទះ ការប៉ះទង្គិច ផលប៉ះពាល់លើយានយន្ត និងការដឹកជញ្ជូន ឬបញ្ហាផ្នែកហេដ្ឋារចនាសម្ព័ន្ធជាដើម ។

- ដំណើរការប្រឹក្សាយោបល់មិនត្រឹមត្រូវ (ការខកខានមិនបានជូនដំណឹងដល់សហគមន៍មូលដ្ឋាន ឬកម្មករអំពីផលប៉ះពាល់ដល់ពួកគាត់ជាដើម)
- ការតាំងទីលំនៅថ្មី ឬការបណ្តេញចេញដោយបង្ខំ (រូបវន្ត ឬសេដ្ឋកិច្ច)
- ផលប៉ះពាល់លើសហគមន៍មូលដ្ឋាន មនុស្សចាស់ ជនជាតិភាគតិច ស្ត្រី ជនជាតិដើមភាគតិច និងបុគ្គលដែលងាយរងគ្រោះផ្សេងទៀត ដែលអាចទទួលរងដោយផ្ទាល់ឬដោយប្រយោលពីប្រតិបត្តិការអាជីវកម្មរបស់អ្នកខ្ចីប្រាក់
- ផលប៉ះពាល់លើបេតិកភណ្ឌ/បទដ្ឋានវប្បធម៌ និងសាសនា (ទាំងរូបី និងអរូបី)
- ពលកម្មកុមារ និងពលកម្មដោយបង្ខំ
- ល្បែងស៊ីសង និងអាជីវកម្មពាក់ព័ន្ធផ្សេងទៀត
- ពេស្យាចារ និងការជួញដូរមនុស្ស
- រូបអាសអាភាស និងអំពើអាសអាភាសផ្សេងៗទៀត
- ការផលិត ជួញដូរ ឬរក្សាទុកគ្រឿងញៀន និងសារធាតុញៀន

- **បញ្ហាអភិបាលកិច្ច៖**[74]

    - អំពើពុករលួយ និងការស៊ីសំណូក
    - បញ្ហាកេរ្តិ៍ឈ្មោះ
    - ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការអនុវត្ត /ប្រាសចាក ក្រមសីលធម៌
    - រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល និង ភាពចម្រុះជាតិសាសន៍
    - ការគ្រប់គ្រងហានិភ័យ
    - ការបង្ហាញព័ត៌មាននិងតម្លាភាព

## គ៣.២. ភាពពាក់ព័ន្ធ និងសារៈសំខាន់នៃ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ក្នុងវិស័យធនាគារ

ដើម្បីធានាបាននូវការអភិវឌ្ឍសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវការការអនុវត្តអាជីវកម្មប្រកបដោយការទទួលខុសត្រូវ និងនិរន្តរភាពបន្ថែមទៀតតាមទិសដៅយុទ្ធសាស្ត្រនិងប្រតិបត្តិការអាជីវកម្ម ប្រចាំថ្ងៃរបស់ខ្លួន។ ក្រុមហ៊ុនពហុជាតិជាច្រើន ដូចជា អង្គការសហប្រជាជាតិ (UN) អង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD)

[74]This is based on (IFC, 2021) & (Stampe, 2014)

ក្រុមប្រទេសសេដ្ឋកិច្ចនាំមុខG20 វិនិយោគិនដែលមានទំនួលខុសត្រូវ និងនិយ័តករមួយចំនួនបាន សង្កត់ធ្ងន់លើសារៈសំខាន់នៃបញ្ហាបរិស្ថាន និងសង្គម ដែលចាំបាច់ត្រូវលើកយកមកពិចារណា និង ដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រផ្តល់មូលនិធិ (ការវិនិយោគ ឬផ្តល់ប្រាក់កម្ចី) របស់ខ្លួន និងដំណើរ ការធ្វើការសម្រេចចិត្ត បន្ថែមពីលើរង្វាស់ហិរញ្ញវត្ថុសំខាន់ៗ។[75] បញ្ហាប្រឈមរបស់ គោលការណ៍ប រិស្ថាន សង្គម និងអភិបាលកិច្ច ដូចជា ការប្រែប្រួលអាកាសធាតុ កំណើនប្រជាជន និងកង្វះធនធាន មានផលប៉ះពាល់យ៉ាងខ្លាំងចំពោះអាជីវកម្មនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សេដ្ឋកិច្ច និងសង្គម ទាំងមូល។ នេះបង្ហាញពីហានិភ័យ និងឱកាសដែលត្រូវកំណត់រក និងដោះស្រាយ ដើម្បីរក្សាបាននូវ កំណើនសេដ្ឋកិច្ចរយៈពេលវែង ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងស្ថិរភាពសង្គម។[76]

បញ្ហាប្រឈមនៃ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ទាំងនេះពាក់ព័ន្ធនឹង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយសារតែ គ្រឹះស្ថានមានតួនាទីជាភ្នាក់ងារគៀរគរដើមទុន និង ជាអន្តរការីផ្នែកហិរញ្ញវត្ថុ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺជាកាតាលីករក្នុងការជំរុញការអភិវឌ្ឍ សេដ្ឋកិច្ចដោយការប្រមូលមូលនិធិពីអ្នកដែលមាន អតិរេក (surplus) ហើយផ្តល់ទៅឱ្យអ្នកដែល កំពុងត្រូវការជំនួយ។ ដូច្នេះហើយ ការលើកកម្ពស់ និងការប្រកាន់ខ្ជាប់នូវការអនុវត្តធុរកិច្ច ប្រកបដោយនិរន្តរភាពគឺជារឿងចាំបាច់ បើមិនដូច្នោះទេគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នឹងត្រូវ បញ្ចប់ការផ្តល់ហិរញ្ញប្បទាន និងការសម្របសម្រួលដល់អាជីវកម្មដែលមានផលប៉ះពាល់អវិជ្ជមាន ដល់បរិស្ថាន និងសង្គម ហើយដែលនឹងធ្វើឱ្យកេរ្តិ៍ឈ្មោះ ព្រមទាំងទិដ្ឋភាពហិរញ្ញវត្ថុផ្សេងទៀត ប្រឈមនឹងហានិភ័យ។ ហានិភ័យទាំងនេះ រួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមតែ៖

- ការកើនឡើងនៃឥណទានមិនដំណើរការ (non-performing loans) ដោយសារតែអាជីវកម្ម របស់អតិថិជនដំណើរការមិនល្អ ដែលបណ្តាលមកពីការប្រឈមនឹងការពិន័យតាមបទ ប្បញ្ញត្តិ ឬការរើសអើងផលិតផល ឬសេវាកម្មពីសំណាក់អ្នកទិញ
- វិវាទ(បណ្តឹង)ដែលអាចកើតមានដោយសារកង្វះការវាយតម្លៃដែលត្រឹមត្រូវនិង/ ឬការបង្ហាញ អោយឃើញពីហានិភ័យ ទាក់ទងនឹងគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ក្នុង សកម្មភាពផ្តល់ប្រាក់កម្ចីរបស់ខ្លួន
- ហានិភ័យសន្ទនីយភាពដោយសារតែការដកប្រាក់បញ្ញើ និងប្រាក់កម្ចី
- ការកើនឡើងនូវថ្លៃដើមទុនដោយសារ៖
    - ម្ចាស់ភាគហ៊ុន និងអ្នកផ្តល់កម្ចី (equity and debt holders) ទាមទារប្រាក់ចំណេញខ្ពស់ ដើម្បីទប់ស្កាត់ហានិភ័យខ្ពស់ ការគ្រប់គ្រងហានិភ័យមិនបានល្អ និងគុណភាពនៃផលបត្រ ប្រាក់កម្ចី

[75] (Stampe, 2014)
[76] (Stampe, 2014)

➢ ការបាត់បង់ប្រាក់បញ្ញើដែលមានតម្លៃទាប និងបំពេញតម្រូវដែលជំនួសដោយបំណុល និង

- ហានិភ័យកេរ្តិ៍ឈ្មោះ ការប៉ះពាល់ដល់ម៉ាកយីហោ និងការផ្សព្វផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយពីលក្ខណៈអវិជ្ជមានដែលអាចកើតមានជាដើម។

គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច គ្របដណ្តប់លើប្រធានបទ និងបញ្ហាជាច្រើន។ កត្តាទាំងនោះមានដូចជា ការប្រែប្រួលអាកាសធាតុ អាចប៉ះពាល់ដល់ក្រុមហ៊ុន វិស័យ ឬប្រទេសទាំងមូល និងអាចប៉ះពាល់ដល់ស្ថិរភាព សេដ្ឋកិច្ចផងដែរ។ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច បានក្លាយជាឧបករណ៍ដ៏ល្អសម្រាប់វាយតម្លៃពីរបៀបដែលក្រុមហ៊ុនកំណត់ហានិភ័យនិងឱកាស ដែលមិនទាក់ទងនឹងហិរញ្ញវត្ថុ និងថាតើក្រុមហ៊ុននឹងបង្កើតយុទ្ធសាស្ត្រសមស្របដើម្បីគ្រប់គ្រង ឬកាត់បន្ថយហានិភ័យ ទាំងនោះដែរឬទេ។[77] គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច គឺជាកត្តាដ៏សំខាន់ ដោយសារតែបរិស្ថាន និងសង្គមអាចនាំឱ្យមានការប្រែប្រួលយ៉ាងខ្លាំង និងការផ្លាស់ប្តូរនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សាកល សេដ្ឋកិច្ច វិស័យ និងក្រុមហ៊ុននិមួយៗ។ នៅក្នុងឧទាហរណ៍កាលពីពេលថ្មីៗនេះ កូវីដ-១៩ បានផ្លាស់ប្តូរសក្តានុពលនៃសេដ្ឋកិច្ចពិភពលោកក្នុងរយៈពេលតែប៉ុន្មានសប្តាហ៍ប៉ុណ្ណោះ។ នៅពេលវិបត្តិនេះកើតឡើង អាជីវកម្ម និងអ្នកវិនិយោគជាច្រើនបានផ្លាស់ប្តូរការផ្តោតការយកចិត្តទុកដាក់របស់ខ្លួនពីប្រាក់ចំណេញទៅផ្តោតលើមនុស្សវិញ។ ផលប៉ះពាល់លើមនុស្សមានវិសាលភាពធំជាងផលប៉ះពាល់លើសេដ្ឋកិច្ច។ បញ្ហាទាំងនោះទាក់ទងនឹងសមភាពមនុស្ស លទ្ធភាពទទួលបានសេវាសុខភាព និងសុខុមាលភាពសង្គម បានក្លាយជារបៀបវារៈដ៏សំខាន់។ អាស្រ័យហេតុនេះ វាបង្ហាញច្បាស់ណាស់ថា បញ្ហាបរិស្ថាន និងសង្គមក៏មានឥទ្ធិពលយ៉ាងស៊ីជម្រៅ និងដោយផ្ទាល់ទៅលើស្ថិរភាពសេដ្ឋកិច្ច និងប្រតិបត្តិការអាជីវកម្ម ឬ សេដ្ឋកិច្ចផងដែរ។[78]

ចំណុចសំខាន់ៗបំផុតសម្រាប់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺថានិយ័តករប្រព័ន្ធហិរញ្ញវត្ថុ និងអាជ្ញាធរកំពុងធ្វើដំណើរក្នុងទិសដៅតែមួយនៅលើរបៀបវារៈនៃគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច។[79] លើសពីនេះទៀត អតិថិជនរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាច្រើន មិនត្រឹមតែនៅក្នុងឧស្សាហកម្មនិស្សារណកម្ម (extractive industry) និងក្រុមហ៊ុនកម្មន្តសាល (manufacturing businesses) សំខាន់ៗមួយចំនួនប៉ុណ្ណោះទេ នឹងត្រូវអនុវត្តតាមលកខណ្ឌនៃគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ឱ្យកាន់តែតឹងរ៉ឹងផងដែរនៅពេលឆាប់ៗនេះ។ ដោយមើលឃើញថានេះជានិន្នាការដែលកំពុងទទួលបានការយកចិត្តទុកដាក់ខ្ពស់ សមាគមធនាគារនៅកម្ពុជា

[77] (IFC, 2021)
[78] (KPMG, 2020a)
[79] (KPMG, 2020a)

និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានព្រមព្រៀងគ្នាបង្កើត "គោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា" ដែលមានគោលការណ៍សំខាន់ៗចំនួនបីគឺ៖[80]

១. ការពារបរិស្ថាន ប្រជាជន និងបេតិកភណ្ឌវប្បធម៌កម្ពុជា

២. ផ្តល់ហិរញ្ញប្បទានដល់អនាគតកម្ពុជា

៣. ដឹកនាំបង្ហាញផ្លូវ

គោលការណ៍ទាំងបីនេះមានគោលបំណងដោះស្រាយបញ្ហាប្រឈមរបស់ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (សម្រាប់ព័ត៌មានលម្អិត សូមស្វែករកក្នុងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជារបស់ សមាគមធនាគារនៅកម្ពុជា និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា)។[81] ផ្នែកនេះមានគោលបំណងផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតអំពីបញ្ហាប្រឈម និងហានិភ័យ ជាពិសេស ប្រភេទបញ្ហា ខាងលើ។ យុទ្ធសាស្ត្រ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ចនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗត្រូវផ្តោតលើបញ្ហាប្រឈម និងហានិភ័យទាំងនេះ។

## គ៣.៣.ការអនុវត្ត និងការដាក់បញ្ចូល គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ទៅក្នុងយុទ្ធសាស្ត្ររបស់ធនាគារ

- **អត្ថប្រយោជន៍នៃការដាក់បញ្ចូល គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច**

ការដាក់បញ្ចូល គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច នៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានអត្ថប្រយោជន៍សំខាន់ពីរគឺ (១) គ្រប់គ្រងហានិភ័យ និង (២) ទាញយកប្រយោជន៍ពីឱកាស។[82] ការមានយុទ្ធសាស្ត្រ និងការអនុវត្ត គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ល្អៗអាចជួយឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កាត់បន្ថយហានិភ័យដែលពាក់ព័ន្ធ ដែលនេះនឹងជួយកាត់បន្ថយការចំណាយលើការពិន័យ និងបង្កើនប្រាក់ចំណូល និងលទ្ធភាពចំណេញ។ លើសពីនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចប្រើប្រាស់យុទ្ធសាស្ត្រ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ជាឱកាសក្នុងការបង្កើតផលិតផលត្រឹមត្រូវ ឬកែតម្រូវផលិតផលដែលមានស្រាប់ ដើម្បីបំពេញតាមតម្រូវការនៃ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ។ យុទ្ធសាស្ត្រ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ដែលមានប្រសិទ្ធភាពក៏ជួយលើកកម្ពស់សកម្មភាពសង្គមនិងមនុស្សធម៌ កេរ្តិ៍ឈ្មោះម៉ាកយីហោ និងកេរ្តិ៍ឈ្មោះរបស់ គ្រឹះស្ថាន ផងដែ

[80] (The Association of Banks in Cambodia, 2022)
[81]Ibid.
[82] (Stampe, 2014)

រ។[83] សរុបសេចក្តីមក អត្ថប្រយោជន៍ធំៗទាំងពីរនេះជួយពង្រឹងគោលជំហររបស់ គ្រឹះស្ថាន នៅលើទីផ្សារ ក៏ដូចជាទស្សនៈរបស់អាជីវកម្ម ។

- **យុទ្ធសាស្ត្រនៃការដាក់បញ្ចូល គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច**

ការដាក់បញ្ចូលយុទ្ធសាស្ត្រ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច គឺជាដំណើរការដែលកំពុងបន្ត និងកំពុងវិវត្តទៅមុខ។ សម្រាប់ការចាប់ផ្តើមថ្មី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនត្រូវមានមហិច្ឆតាខ្លាំងពេកក្នុងការកំណត់គោលដៅនៃ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ពីព្រោះគោលដៅ ភាគច្រើនស្ទើរតែមិនអាចសម្រេចបាននោះឡើយ។ ផ្ទុយទៅវិញ គ្រឹះស្ថានត្រូវកំណត់គោលដៅ មួយចំនួនដែលពាក់ព័ន្ធបំផុតដើម្បីចាប់ផ្តើមការងារនេះ ក៏ព្រោះតែកត្តាសំខាន់បំផុតគឺត្រូវចាប់ផ្តើមដំណើរការដាក់បញ្ចូល គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ចនេះជាមុនសិន។ កម្រិតមហិច្ឆតា និងល្បឿននៃការដាក់បញ្ចូលគោលការណ៍នេះ របស់ គ្រឹះស្ថាននីមួយៗ គឺមិនដូចគ្នានោះទេ។[84] គ្រឹះស្ថាន ទាំងអស់ត្រូវកំណត់គោលដៅជាបណ្តើរៗស្តីពីការដាក់បញ្ចូលពេញលេញ។ ខាងក្រោមនេះគឺជាជំហានទូទៅនៃយុទ្ធសាស្ត្រ បរិស្ថាន សង្គម និងអភិបាលកិច្ច ដែលបានបង្កើតឡើង និងដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្ររួមរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ៖

- ការបង្កើតកម្រិតមហិច្ឆតា
- ការឈ្វេងយល់ពីការប្រឈមទៅនឹងហានិភ័យព្រមទាំងកម្រិតនៃការដាក់បញ្ចូលគោលការណ៍ ក្នុងពេលបច្ចុប្បន្ន និងបានស្នើឡើង
- ការកំណត់ពីហានិភ័យរបស់គោលការណ៍
- ការឆ្លើយតបទៅនឹងហានិភ័យ
- ការរៀបចំក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រ
- ការអនុវត្ត និងការពិនិត្យមើលក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រ

- **ការអនុវត្តស្តីពីការដាក់បញ្ចូល គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច**
  - **ក្រុមប្រឹក្សាភិបាល**

បន្ថែមពីលើជំហានខាងលើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយមានការយកចិត្តទុកដាក់ខ្ពស់ និងពិនិត្យមើលលើតួនាទីរបស់ថ្នាក់ដឹកនាំផ្សេងៗ (ឧទាហរណ៍ ក្រុម

[83] (KPMG, 2020a)
[84] (KPMG, 2020a)

ប្រឹក្សាភិបាល និងគណៈគ្រប់គ្រង) និងបុគ្គលិកជួរមុខ។[85] ក្រុមប្រឹក្សាភិបាលត្រូវធានាថា ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវស្របតាមយុទ្ធសាស្ត្រ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ហើយបញ្ហាទាំងនេះត្រូវបញ្ជូនទៅគណៈគ្រប់គ្រង និងបុគ្គលិកដែលពាក់ព័ន្ធ។ លើសពីនេះ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការវាយតម្លៃហានិភ័យ និងឱកាស ដើម្បីធ្វើឱ្យមានតុល្យភាពរវាងទិសដៅអាជីវកម្ម និងយុទ្ធសាស្ត្រនៃ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ដើម្បីរក្សាកម្រិតនៃការដាក់បញ្ចូលគោលការណ៍នេះឱ្យបានល្អ។

- **គណៈគ្រប់គ្រង**

គណៈគ្រប់គ្រងត្រូវទទួលយកការណែនាំពីក្រុមប្រឹក្សាភិបាល និងអនុវត្តការដាក់បញ្ចូលគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ទៅក្នុងគំរូអាជីវកម្ម គោលនយោបាយ នីតិវិធីប្រតិបត្តិការស្តង់ដារ និងការសម្រេចចិត្ត ឬប្រតិបត្តិការរបស់អាជីវកម្មប្រចាំថ្ងៃ។ គណៈគ្រប់គ្រងក៏ត្រូវទទួលបន្ទុកក្នុងការបកស្រាយយុទ្ធសាស្ត្រ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ទៅជាសូចនាករដែលអាចវាស់ស្ទង់បាន ដូចជាការដាក់បញ្ចូលទៅក្នុង សូចនាករប្រតិបត្តិការសំខាន់ៗ (KPIs & KRIs) ត្រួតពិនិត្យ និង ចាត់វិធានការកែតម្រូវ ប្រសិនបើចាំបាច់ និងរាយការណ៍ទៅភាគីពាក់ព័ន្ធ។

- **ក្រុមប្រតិបត្តិការ**

នៅកម្រិតប្រតិបត្តិការ វាសំខាន់ណាស់ដែលត្រូវមានការបណ្តុះបណ្តាលស្តីពី គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ចំពោះបុគ្គលិកជួរមុខទាំងអស់ ដែលនឹងធ្វើការពិនិត្យស្ថានភាពរបស់អតិថិជន។ បន្ថែមពីលើការបណ្តុះបណ្តាលនេះ វាជាការចាំបាច់ដែលត្រូវបង្កើតឯកសារគំរូដែលពាក់ព័ន្ធ និងត្រូវបំពេញ ក្នុងអំឡុងពេលដំណើរការបង្កើតឥណទាន។ មុខងារត្រួតពិនិត្យ និងអនុម័តឥណទាន ឬ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ចដែលបានកំណត់របស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាបានថា ឯកសារគំរូនេះត្រូវបានបំពេញនូវរាល់ព័ត៌មានត្រឹមត្រូវ និង/ឬ អាចទុកចិត្តបាន ហើយវាយតម្លៃហានិភ័យ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ស្របតាមកម្រិតនៃការទទួលយកហានិភ័យរបស់ គ្រឹះស្ថាន ។ អ្នកខ្ចីបណាដែលពាក់ព័ន្ធនឹងហានិភ័យនេះ មិនគួរត្រូវបានបដិសេធនៅដំណាក់កាលដំបូងឡើយ ប៉ុន្តែត្រូវផ្តល់ពេលវេលាកំណត់ដើម្បីកែតម្រូវបញ្ហាទាំងនោះ និងកាត់បន្ថយហានិភ័

[85] (IFC, 2021)

យ។ ក្នុងករណីដែលមិនមានភាពប្រសើរឡើង នោះ គ្រឹះស្ថាន ត្រូវពិចារណាពីយុទ្ធសាស្ត្របញ្ចប់ទំនាក់ទំនង (exit strategy) ជាមួយអតិថិជន។ សរុបមក ការរៀបចំ និងការដាក់បញ្ចូលយុទ្ធសាស្ត្រ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ទៅក្នុងយុទ្ធសាស្ត្រគោលរបស់គ្រឹះស្ថាន ទាមទារឱ្យមានបញ្ជាពីថ្នាក់លើ ក៏ដូចជាការអនុវត្តយុទ្ធសាស្ត្រ នេះឱ្យបានល្អខ្ជាប់ខ្ជួន។

# ផ្នែក ឃ៖ ការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ

## ឃ១. ផ្តល់ប្រាក់កម្ចីប្រកបដោយក្រមសីលធម៌

### ឃ១.១. ផលិតផល និងសេវាកម្មកម្ចីតាមទីផ្សារ

ជំហានដំបូងឆ្ពោះទៅរកការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ ឬប្រកបដោយក្រមសីលធម៌ ចាប់ផ្តើមពីការធ្វើទីផ្សារលក់ផលិតផល ឬសេវាកម្មប្រាក់កម្ចី។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានគោលការណ៍ណែនាំផ្ទៃក្នុងសមស្របសម្រាប់កំណត់សារតាដល់អតិថិជនរបស់ខ្លួនដោយផ្អែកលើផលិតផល ឬសេវាកម្មប្រាក់កម្ចី ដើម្បីធានាបាននូវលទ្ធផលជាវិជ្ជមានតាមការរំពឹងទុកបន្ទាប់ពីការផ្តល់ប្រាក់កម្ចីដល់អតិថិជន។ ផ្នែកនេះគ្របដណ្តប់ (១) ការរៀបចំផលិតផលឥណទានសមស្រប (២) រៀបចំការផ្សាយពាណិជ្ជកម្ម និងព័ត៌មានផ្សព្វផ្សាយប្រកបដោយតម្លាភាព និង (៣) ការណែនាំដល់អតិថិជនអំពីផលិតផលប្រាក់កម្ចីត្រឹមត្រូវ។

#### ឃ១.១.១. ការរៀបចំផលិតផលឥណទានសមស្រប

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានវិធីសាស្ត្រប្រកបដោយក្រមសីលធម៌ក្នុងការរៀបចំផលិតផលកម្ចីជាក់លាក់សម្រាប់អតិថិជនគោលដៅ ហើយត្រូវអនុវត្តគោលគំនិតស្តីពីការវាយតម្លៃពី "ភាពសមស្របរបស់ផលិតផល" ដើម្បីកំណត់ថា តើអតិថិជន៖

- មានចំណេះដឹងផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីស្វែងយល់ពីផលិតផលហិរញ្ញវត្ថុហើយឬនៅ
- មានសមត្ថភាពហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការទូទាត់សងហើយឬនៅ និង
- មានកម្រិតហានិភ័យ ទាបជាង កម្រិតនៃការទទួលយកហានិភ័យ (Risk Appetite) របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែរឬយ៉ាងណា

បែបបទក្នុងការកំណត់សារតារបស់ អតិថិជនមានភាពស្មុគស្មាញ ដោយសារ កម្ចីមួយចំនួនជាប់ពាក់ព័ន្ធជាមួយនឹងអ្នកបង្កើតកាតព្វកិច្ចច្រើន។

តាមទស្សនៈនៃការរៀបចំផលិតផលកម្ចី ក៏មានបញ្ហាប្រឈមផងដែរក្នុងការរៀបចំបែងចែកផ្នែកឱ្យបានច្បាស់លាស់សម្រាប់ផលិតផលកម្ចី ដែលអាចខុសគ្នាពីអតិថិជនមួយទៅអតិថិជនមួយ។ ឧទាហរណ៍ ការផ្តល់ហិរញ្ញប្បទានលើការទិញផ្ទះអាចត្រូវបានកំណត់លក្ខណៈដូចជា៖

- ប្រាក់កម្ចីផ្ទាល់ខ្លួន ឬ ប្រាក់កម្ចីទិញផ្ទះសម្រាប់អ្នកខ្ចីដែលនឹងប្រើប្រាស់ផ្ទះនេះសម្រាប់គោលបំណងធ្វើជាលំនៅឋានស្នាក់នៅ *ឬ*

- ប្រាក់កម្ចីអាជីវកម្មសម្រាប់អ្នកខ្ចី ដែលនឹងប្រើប្រាស់ផ្ទះនេះសម្រាប់ធ្វើជាកន្លែងប្រកបអាជីវកម្ម។

### i. ការកំណត់សាវតាអតិថិជន

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗមានវិធីផ្សេងគ្នាក្នុងការកំណត់ សាវតាអតិថិជនរបស់ខ្លួន ដោយផ្អែកលើកត្តាជាច្រើន ឬការរួមបញ្ចូលគ្នា។ កត្តាសំខាន់ពីរគឺប្រភពចំណូល និងមុខរបរ អាចត្រូវបានចាត់យកមកពិចារណាដើម្បីចាត់ថ្នាក់អតិថិជននីមួយៗដូចជា សិស្ស និស្សិត និវត្តជន មន្ត្រីរាជការ អ្នកនយោបាយ អ្នកជំនួញ ឬវិនិយោគិន។ ប៉ុន្តែការកំណត់សាវតាដោយប្រើប្រាស់កត្តាផ្សេងទៀតក៏ត្រូវគិតគូរដែរ ដោយផ្អែកលើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ។

### ii. ការសម្រេចបាននូវភាពសមស្របនៃសាវតាព័ត៌មានអតិថិជន និងការរៀបចំផលិតផល

ការរៀបចំផលិតផល និងសេវាកម្មត្រូវស្របតាមបទប្បញ្ញត្តិស្តីពីការការពារអ្នកប្រើប្រាស់ដែលមានជាធរមានហើយកំណត់ដោយ សមាគមធនាគារនៅកម្ពុជា និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និង ធនាគារជាតិនៃកម្ពុជា។ លក្ខណៈពិសេសរបស់ផលិតផល និងសេវាកម្មត្រូវស្របគ្នានឹងតម្រូវការរបស់អតិថិជនដូចខាងក្រោម៖ [86]

- **ទំហំប្រាក់កម្ចី៖** ទំហំប្រាក់កម្ចីអតិបរមា និងអប្បបរមា និងលក្ខខណ្ឌប្រាក់សន្សំដែលសក្តិសមគ្នានឹងប្រាក់ចំណូលរបស់អតិថិជន ប្រភេទអាជីវកម្ម ទម្លាប់សន្សំប្រាក់។ល។
- **ប្រភេទឥណទាន៖** ប្រភេទឥណទានសម្រាប់ទុនបង្វិល និងមិនសម្រាប់ជាទុនបង្វិល (Revolving and non-revolving facility) ត្រូវស៊ីគ្នានឹងលំហូរសាច់ប្រាក់របស់អតិថិជន
- **រយៈពេលកម្ចី៖** រយៈពេលនៃការប្រើប្រាស់ប្រាក់កម្ចីត្រូវស្របតាមគោលបំណងប្រាក់កម្ចី
- **តម្លៃ៖** តម្លៃគួរតែសមរម្យ សម្រាប់អតិថិជន
- **លក្ខខណ្ឌតម្រូវឱ្យមានការធានា/ទ្រព្យធានា**(guarantee/collateral)៖ លក្ខខណ្ឌតម្រូវឱ្យមានទ្រព្យធានាគួរតែត្រូវគ្នានឹងលទ្ធភាពរបស់អតិថិជនចំពោះវត្ថុបញ្ចាំ និងអ្នកធានាជាក់ស្តែង
- **កាលវិភាគបង់ប្រាក់កម្ចី៖** កាលវិភាគបង់ប្រាក់សក្តិសមគ្នានឹងលំហូរសាច់ប្រាក់របស់អតិថិជន
- **បណ្តាញផ្តល់សេវា** (Delivery channels)៖ បណ្តាញផ្តល់សេវាគួរតែគិតតម្លៃសមរម្យងាយស្រួល និងអាចទុកចិត្តបានសម្រាប់អតិថិជន

[86] (The Association of Banks in Cambodia & Cambodian Microfinance Assoication, 2022)

- **សមត្ថភាពហិរញ្ញវត្ថុ៖** ផលិតផល និងសេវាកម្មសក្តិសមគ្នានឹងសមត្ថភាពហិរញ្ញវត្ថុរបស់អតិថិជន ដែលសំដៅដល់៖
  - សមត្ថភាពរបស់អតិថិជនក្នុងការធ្វើសកម្មភាពដើម្បីផលប្រយោជន៍ហិរញ្ញវត្ថុរបស់ខ្លួនផ្ទាល់ ព្រមទាំងជ្រើសរើស និងទទួលបានសេវាកម្មហិរញ្ញវត្ថុដែលឆ្លើយតបទៅនឹងតម្រូវការរបស់ខ្លួន និង
  - ចំណេះដឹង ឥរិយាបថ ជំនាញ និងអាកប្បកិរិយារបស់អតិថិជន

**ឧទាហរណ៍៖** ពាណិជ្ជករដែលបើកដំណើរការអាជីវកម្មពាណិជ្ជកម្មធម្មតារកប្រាក់ចំណូលបាន១៥០០០ ដុល្លារក្នុងមួយខែមិនគួរត្រូវបានណែនាំឱ្យទទួលយកប្រាក់កម្ចីអភិវឌ្ឍន៍អចលនទ្រព្យចំនួន ១០០០០០០ ដុល្លារក្នុងអត្រាប្រចាំឆ្នាំ ៩% ជាមួយនឹងការបង់រំលស់ប្រចាំខែចំនួន ១២៧៤០ ដុល្លារនោះទេ។ ជាមួយនឹងបទពិសោធតិចតួចក្នុងការវិនិយោគអចលនទ្រព្យ និងការប្រើប្រាស់ទ្រព្យសម្បត្តិអាជីវកម្មស្ទួលជាទ្រព្យធានា ពាណិជ្ជកររូបនេះកំពុងតែប្រថុយប្រថានខ្លាំងលើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ក្នុងករណីការវិនិយោគបរាជ័យ ដែលគាត់នឹងត្រូវប្រើប្រាស់ទ្រព្យសម្បត្តិអាជីវកម្មរបស់គាត់ដើម្បីទូទាត់សងបំណុល ខណៈដែលការវិនិយោគអចលនទ្រព្យរបស់គាត់នឹងជាប់គាំង។ ប្រសិនបើធនាគារចង់បន្តដំណើរការនេះ នោះលក្ខខណ្ឌឥណទានពិសេសត្រូវរៀបចំដោយប្រយ័ត្នប្រយែងបំផុត។

**សំណួរផ្ទុះបញ្ចាំង ឃ១.១.**

បន្ទាប់ពីសិក្សាអំពីទីផ្សាររួចមក ធនាគារថូម៉ាកូ បានស្វែងយល់បន្ថែមអំពីសាវតារបស់អតិថិជន ប្រវត្តិឥណទាន តម្រូវការឥណទាន កម្រិតនៃការទទួលបានឥណទាន (credit penetration levels) និងកំណើនសក្តានុពល។ បន្ទាប់មក ធនាគារថូម៉ាកូ ពង្រីកប្រតិបត្តិការទៅកាន់តំបន់ជនបទក្នុងខេត្តបាត់ដំបង ដែលធនាគារមានគោលបំណងបម្រើសេវាកម្មទៅដល់កសិករដែលធ្វើស្រែចម្ការ និងដាំដំណាំផ្សេងៗទៀត។ ក្នុងចំណោមលក្ខណៈពិសេសផលិតផលកម្ចីដូចជាចំនួនប្រាក់កម្ចី រយៈពេល អត្រាការប្រាក់ សោហ៊ុយទម្រង់ការនិងរយៈពេលឡក់អ៊ីន(lock-in period)។ តើវិធីសាស្ត្រសងប្រាក់កម្ចីមួយណាដែលសមស្របបំផុតសម្រាប់ អតិថិជនប្រភេទនេះ? ហេតុអ្វី?

**ក.** បង់ប្រាក់ប្រចាំខែទាំងការប្រាក់ និងប្រាក់ដើម

**ខ.** បង់ការប្រាក់ប្រចាំខែ និងការបង់ប្រាក់ដើមនៅចុងបញ្ចប់នៃរយៈពេលកម្ចី

**គ.** បង់ប្រាក់ប្រចាំខែដើម្បីឱ្យត្រូវនឹងលំហូរសាច់ប្រាក់តាមរដូវសម្រាប់អតិថិជន

### ឃ១.១.២. ការរៀបចំការផ្សាយពាណិជ្ជកម្មនិងព័ត៌មានផ្សព្វផ្សាយប្រកបដោយតម្លាភាព[87]

ការផ្សាយពាណិជ្ជកម្ម និងព័ត៌មានផ្សព្វផ្សាយត្រូវបានរៀបចំឡើងអនុលោមទៅតាមតាមបទប្បញ្ញត្តិពាក់ព័ន្ធ មានតម្លាភាព និងមានព័ត៌មានសំខាន់ៗគ្រប់គ្រាន់។ ព័ត៌មានផ្សព្វផ្សាយនេះនឹងអាចឱ្យអ្នកខ្ចីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។ ដើម្បីសម្រេចបាននូវចំណុចនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវពិចារណាលើការប្រើប្រាស់ភាសា បណ្តាញផ្តល់សេវា និងការបង្ហាញព័ត៌មានដែលជាកត្តាសំខាន់ក្នុងការរៀបចំការផ្សាយពាណិជ្ជកម្ម និងព័ត៌មានផ្សព្វផ្សាយផ្សេងទៀត។

### I. ការប្រើប្រាស់ភាសា

**ភាសា៖** ព័ត៌មានផ្សព្វផ្សាយគួរមានយ៉ាងហោចណាស់មួយភាសាដែលត្រូវគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងតំបន់ជាក់លាក់នោះ។ ដូច្នេះហើយ នៅក្នុងប្រទេសកម្ពុជា រាល់ព័ត៌មានសម្រាប់ការផ្សព្វផ្សាយត្រូវមានយ៉ាងហោចណាស់ជាភាសាខ្មែរដែរ។

- **ការសរសេរភាសា៖**
  - ➢ **ការកំណត់ភាសា៖** ត្រូវសរសេរក្នុងភាសាដោយផ្អែកលើអតិថិជនគោលដៅដើម្បីឱ្យត្រូវគ្នានឹងចំណេះដឹងរបស់ពួកគាត់ ជាពិសេសសម្រាប់អតិថិជនដែលមានការអប់រំទាប និងបទពិសោធឥណទានតិចតួចបំផុត។
  - ➢ **របៀបសរសេរ៖** ជាការអនុវត្តល្អ របៀបនៃការសរសេរត្រូវអនុវត្តតាម KISS៖ សរសេរឱ្យខ្លី ហើយងាយយល់ (Keep It Short and Simple)។
    - i. **ពាក្យបច្ចេកទេស៖** បើជៀសមិនរួច ត្រូវធ្វើការពន្យល់បន្ថែមក្នុងលក្ខណៈដែលងាយយល់។ ដូច្នេះ ត្រូវបង្កើតសទ្ទានុក្រមពីការប្រើប្រាស់វាក្យសព្ទ ហើយដាក់បញ្ចូលជាផ្នែកសំខាន់នៃកិច្ចសន្យាកម្ចី។ **ឧទាហរណ៍៖** "ថ្លៃសេវាមិនប្រើប្រាស់ឥណទាន" សំដៅលើថ្លៃសេវាដែលបានកំណត់ជាភាគរយ (%) លើឥណទានសម្រាប់ទុនបង្វិលដែលមិនបានប្រើប្រាស់ (ឧ. ឥណទានវិបារូបន៍ (overdraft))។
    - ii. **ខ្លឹមសារ**
      - ¤ **ភាពជាក់ស្តែង៖** ជៀសវាងការធ្វើកំណត់ចំណាំតូចៗនៃព័ត៌មាន ដែលវាមានសារៈសំខាន់ចំពោះការសម្រេចចិត្តរបស់អតិថិជន។ **ឧទាហរណ៍៖** ព័ត៌មានទាក់ទងនឹងលក្ខខណ្ឌសម្រាប់ការដកទ្រព្យធានាត្រូវបានដាក់ជាកំណត់ចំណាំតូចមួយនៅខាង

---

[87] (The Association of Banks in Cambodia & Cambodian Microfinance Assoication, 2022) (World Bank, 2017)

ក្រោមជើងទំព័រដែលមានសញ្ញាផ្កាយតូច (*) ដាក់តំណភ្ជាប់ ឬទំហំអក្សរតូច ដែលនាំឱ្យពិបាកអាន ឬកត់សម្គាល់។

- **ការនាំឱ្យយល់ច្រឡំ៖** ខ្លឹមសារមិនគួរមានព័ត៌មានដែលអាចនាំឱ្យយល់ច្រឡំឬព័ត៌មានមិនពិតនោះឡើយ។ **ឧទាហរណ៍៖** សារនៃការរំលេចច្បាស់ថា "**អត្រាការប្រាក់ ៣%**" ធ្វើឱ្យអតិថិជនយល់ច្រឡំថាប្រាក់កម្ចីនឹងមានទទួលការប្រាក់ក្នុងចំនួននេះសម្រាប់រយៈពេលកម្ចីទាំងមូល។ ជំនួសមកវិញ "៣%" ត្រូវបានអនុវត្តសម្រាប់តែ "ឆ្នាំដំបូង" ប៉ុណ្ណោះ។ ដូចនេះ ត្រូវផ្សព្វផ្សាយថា "**អត្រាការប្រាក់ ៣%សម្រាប់ឆ្នាំដំបូង**"។
- **ការលុប៖** មិនមានការលុបព័ត៌មានដែលធ្វើឱ្យប៉ះពាល់ដល់ការសម្រេចចិត្តរបស់អតិថិជន។ **ឧទាហរណ៍៖** សារដែលសរសេរថា "**គ្មានទ្រព្យធានា១០០%**" អាចត្រូវបានបកស្រាយថា កម្ចីអាចត្រូវបានផ្តល់ ដោយមិនចាំបាច់មានទ្រព្យធានាជាអចលនទ្រព្យ។ ប៉ុន្តែ មានការតម្រូវឱ្យបង់ថ្លៃសេវាធានាសំខាន់ៗ ហើយថ្លៃសេវាធានា នឹងត្រូវគិតថ្លៃចំពោះអតិថិជនដែលមិនបានជូនដំណឹងជាមុនអំពីបញ្ហានេះ។ អ្នកផ្តល់កម្ចីមិនបានប្រាប់ដល់អតិថិជនឱ្យបានដឹងទេ។ តាមពិតទៅ វាគឺជាប្រាក់កម្ចីដែលមិនមានទ្រព្យធានាជាមួយនឹងថ្លៃសេវាបន្ថែមភ្ជាប់មកជាមួយ បើប្រៀបធៀបទៅនឹងប្រាក់កម្ចីដែលមានទ្រព្យធានាធម្មតា។

## II. ធ្វើការផ្សព្វផ្សាយប្រកបដោយក្រមសីលធម៌

ដើម្បីធ្វើការផ្សព្វផ្សាយប្រកបដោយក្រមសីលធម៌សម្រាប់អតិថិជនសក្តានុពល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវពិចារណាលើកត្តាបីក្នុងការអនុវត្តសកម្មភាពផ្សព្វផ្សាយរបស់ខ្លួន រួមមាន៖ ១) របៀបទំនាក់ទំនង ២) ពិធីការសម្រាប់ការលក់ និង ៣) បណ្តាញទំនាក់ទំនង។

### i. របៀបទំនាក់ទំនង

- **ទាន់ពេលវេលា៖** ត្រូវផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់អតិថិជនឱ្យបានទាន់ពេលវេលាដែលអាចឱ្យពួកគាត់ធ្វើការសម្រេចចិត្តបានច្បាស់លាស់។ **ឧទាហរណ៍៖** ធនាគារផ្តល់ការប្រូម៉ូសិនដោយមិនគិតការប្រាក់ក្នុងខែដំបូង។ ប៉ុន្តែថ្ងៃនេះគឺជាថ្ងៃទី៣០ហើយ ដូច្នេះហើយការប្រូម៉ូសិនគឺមានតែមួយថ្ងៃទៀតប៉ុណ្ណោះ។
- **ភាពពាក់ព័ន្ធ៖** ផ្តល់ព័ត៌មានពាក់ព័ន្ធដែលអាចឱ្យអតិថិជនធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ជាពិសេសថ្លៃសេវា និងសោហ៊ុយចំណាយផ្សេងទៀតដែលអាចអនុវត្តចំពោះការប្រូម៉ូសិនជាក់លាក់ណាមួយ។ **ឧទាហរណ៍៖** អតិថិជនមិនបានដឹងថាការផ្លាស់ប្តូរ

ទ្រង់ទ្រាយនៃទ្រព្យធានាត្រូវមានការយល់ព្រមជាមុនពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះទេ បើមិនដូច្នេះទេ វានឹងចាត់ទុកថាជាការរំលោភបំពានកិច្ចសន្យា។

- **ការបង្ហាញព័ត៌មានពីទំនាស់ផលប្រយោជន៍៖**[88] មន្ត្រីឥណទានត្រូវបានតម្រូវឱ្យបង្ហាញព័ត៌មានពីទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬសក្តានុពលណាមួយដល់អតិថិជន មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀង ឬនៅពេលដែលករណីបែបនេះកើតឡើង។ **ឧទាហរណ៍៖** អាជីវករផលិតទឹកកកម្នាក់ស្នើសុំកម្ចីពង្រីកឃ្លាំងដោយយកទៅទិញដីទំនេរនៅជាប់នឹងរោងចក្រផលិតទឹកកកបច្ចុប្បន្ន។ មន្ត្រីឥណទានដែលទទួលខុសត្រូវគឺជាកូនរបស់ម្ចាស់ដីទំនេរនោះ។ ដូច្នេះ ព័ត៌មាននេះត្រូវបង្ហាញឱ្យដឹងទាំងអ្នកខ្ចី និងអ្នកគ្រប់គ្រង។

### ii. ពិធីការសម្រាប់ការលក់

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបង្កើតស្តង់ដារពិធីការ សម្រាប់ការលក់ដែលផ្តល់ព័ត៌មានសំខាន់ៗដើម្បីជួយអតិថិជនក្នុងការធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ។ នេះអាចជាបញ្ជីត្រួតពិនិត្យសាមញ្ញមួយរៀបរាប់ពីអ្វីដែលត្រូវលើកឡើង និងព័ត៌មានដែលត្រូវផ្តល់ជូន។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកផ្នែកលក់អំពីរបៀបលក់ផលិតផល និងសេវាកម្មដោយមិនមានការដាក់សម្ពាធលើអតិថិជន។ បុគ្គលិកផ្នែកលក់ត្រូវ **ជៀសវាងបច្ចេកទេសលក់បែបបង្ខំដូចខាងក្រោម**។[89]

- ការប្រាប់អតិថិជនថា មានពេលវេលាកំណត់សម្រាប់ការបញ្ចុះតម្លៃពិសេស (*"អ្នកត្រូវចុះហត្ថលេខាថ្ងៃនេះ ព្រោះតម្លៃនឹងឡើងនៅថ្ងៃស្អែក"*)
- ការបន្តទាក់ទងអតិថិជនដែលបានបដិសេធយ៉ាងច្បាស់ថាមិនប្រើប្រាស់ផលិតផល
- ការបំបាក់ទឹកចិត្ត ឬរារាំងអតិថិជនមិនឱ្យប្រឹក្សាយោបល់ជាមួយបុគ្គលដែលគួរឱ្យទុកចិត្ត
- ការបំបាក់ទឹកចិត្ត ឬរារាំងអតិថិជនមិនឱ្យអានព័ត៌មានអំពីផលិតផល កិច្ចសន្យា។ល។
- ការឈ្លោះប្រកែក ការបង្កអរិភាព ឬការធ្វើជាដាក់ខ្លួនចំពោះអតិថិជន
- ការបំភិតបំភ័យ ឬគំរាមកំហែងអតិថិជន *("ប្រសិនបើអ្នកមិនទិញធានារ៉ាប់រងអាយុជីវិតទេ អ្នកហាក់ដូចជាមិនខ្វល់ពីគ្រួសាររបស់អ្នកអញ្ចឹង")*
- ការប្រើប្រាស់បច្ចេកទេសទីផ្សារដែលធ្វើឱ្យមានការយល់ច្រឡំ / បែបបំភាន់

[88] (World Bank, 2017)
[89] (The Association of Banks in Cambodia & Cambodian Microfinance Assoication, 2022)

- ការបញ្ចុះបញ្ចូលអតិថិជនដើម្បីលក់ដាច់តាមមធ្យោបាយផ្សេងៗគ្នា និងញឹកញាប់បំផុតនោះ (ឧទាហរណ៍ SMS អ្នកនាំសារ សារជាសំឡេង ការហៅទូរសព្ទ) ដែលបង្កការរំខាន

**ឧទាហរណ៍៖** អតិថិជនម្នាក់បានជូនដំណឹងដល់មន្ត្រីឥណទានដែលមកពីគ្រឹះស្ថានរុក្ខាហ្វាយណាន់ (Rukha Finance) រួចហើយថា គាត់មិនចាប់អារម្មណ៍លើប្រាក់កម្ចីសម្រាប់ការពង្រីកអាជីវកម្មនោះទេ ហើយបានសុំកុំឱ្យមន្ត្រីឥណទាននេះទំនាក់ទំនងមកទៀតអី។ ប៉ុន្តែ មន្ត្រីឥណទាននេះផ្ញើលេខទំនាក់ទំនងនេះទៅសហសេវិកម្នាក់ទៀតឱ្យបន្តការសាកសួរ។ ប្រសិនបើអតិថិជនបានស្នើសុំឱ្យបញ្ឈប់ការទំនាក់ទំនងទាំងតាមទូរសព្ទ អ៊ីមែល ឬទំនាក់ទំនងផ្ទាល់នោះ សំណើរបស់ពួកគាត់គួរត្រូវគោរព។

### III- បណ្តាញទំនាក់ទំនង

- គួរមានបណ្តាញទំនាក់ទំនងដែលងាយស្រួលសម្រាប់អតិថិជនក្នុងការទំនាក់ទំនងមកគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចជាសាខា បណ្តាញសង្គម ឬទូរសព្ទដែលអាចឱ្យអតិថិជននៅក្នុងតំបន់ជាក់លាក់ណាមួយ ស្នើសុំការបកស្រាយរាល់កង្វល់ ឬសាកសួរព័ត៌មានបន្ថែមមុននឹងធ្វើការសម្រេចចិត្ត។
- គួរបណ្តុះបណ្តាលបុគ្គលិកគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យបានល្អដើម្បីឱ្យពួកគេអាចឆ្លើយតបទៅនឹងកង្វល់ណាមួយ និងផ្តល់ព័ត៌មានបន្ថែម ប្រសិនបើពាក់ព័ន្ធ។

**ឧទាហរណ៍៖** មន្ត្រីឥណទានដែលបានជួបអតិថិជនគួរផ្តល់លេខទូរសព្ទផ្ទាល់ខ្លួនដល់គាត់ជាជាងលេខទូរសព្ទរបស់សាខា ដូច្នេះអតិថិជនអាចទាក់ទងទៅកាន់មន្ត្រីឥណទាននោះដោយផ្ទាល់ ដោយមិនចាំបាច់ទូរសព្ទទៅសាខា និយាយជាមួយមនុស្សផ្សេង ហើយអាចចាប់ផ្តើមការសន្ទនាជាថ្មីម្តងទៀតនោះឡើយ។

**សំណួរឆ្លុះបញ្ចាំង ឃ១.១.២**

ចាន់ ចាប់អារម្មណ៍លើប្រាក់កម្ចីពីធនាគារ ថូម៉ាកូ។ មុនពេលធ្វើការសម្រេចចិត្ត គាត់ចង់អានដើម្បីស្វែងយល់ពីលក្ខខណ្ឌទាំងអស់ដែលមានចែងក្នុងកិច្ចសន្យាប្រាក់កម្ចី។ ប៉ុន្តែ មន្ត្រីឥណទានបានប្រាប់ ចាន់ ថា គាត់អាចអានកិច្ចសន្យាបាន លុះត្រាតែគាត់ចុះហត្ថលេខាលើពាក្យស្នើសុំប្រាក់កម្ចីជាមុនសិន។ មន្ត្រីឥណទានរូបនេះបានហុចពាក្យស្នើសុំកម្ចីមួយដល់ ចាន់ ដោយមិនទាន់បានបំពេញព័ត៌មានណាមួយនោះឡើយ ហើយសុំឱ្យ ចាន់ ចុះហត្ថលេខាជាមុនសិន ហើយបន្ទាប់មកគាត់នឹងបង្ហាញ ចាន់ នូវគំរូកិច្ចសន្យាកម្ចី។ តើអ្វីជាកំហុសឆ្គងក្នុងការអនុវត្តនេះ?

## ឃ១.២. ណែនាំប្រាប់អតិថិជនអំពីផលិតផលកម្ចីត្រឹមត្រូវ

### ឃ១.២.១. ការបង្ហាញអំពីលក្ខខណ្ឌឥណទានសំខាន់ៗ

ក្នុងន័យនេះ មន្ត្រីឥណទានត្រូវប្រាកដថា អ្នកខ្ចីទទួលបានព័ត៌មានច្បាស់លាស់អំពីលក្ខខណ្ឌឥណទានសំខាន់ៗ ជាពិសេសទាក់ទងទៅនឹង៖[90]

- ស្ថានភាពបទប្បញ្ញត្តិរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ពោលគឺ MDI ធនាគារ ឬប្រតិបត្តិករឥណទានជនបទ និងអាជ្ញាបណ្ណ
- លក្ខខណ្ឌស្តីពីសិទ្ធិទទួលបានកម្ចី
- អត្រាការប្រាក់ ការចំណាយ ថ្លៃសេវា និងសោហ៊ុយផ្សេងៗទាំងអស់ (រួមទាំងពីភាគីទីបី) ដែលកើតឡើង ឬអាចកើតឡើងពីកិច្ចព្រមព្រៀង នៅពេលដែលអាចយកទៅអនុវត្ត និងរបៀបគណនា។ ថ្លៃសេវា និងសោហ៊ុយទាំងនេះអាចរួមបញ្ចូល៖

  - ចំនួនទឹកប្រាក់បង់ប្រចាំខែ ឬតាមកាលកំណត់
  - ថ្លៃសេវា/សោហ៊ុយដែលត្រូវបង់ជាមុនដល់ធនាគារ ដូចជាសោហ៊ុយទម្រង់ការជាដើម
  - ថ្លៃសេវា/សោហ៊ុយ លក្ខណៈវិជ្ជាជីវៈ ដូចជាថ្លៃសេវារបស់ការិយាល័យឥណទានកម្ពុជា ថ្លៃសេវាវាយតម្លៃអចលនទ្រព្យ ថ្លៃសេវាមេធាវី ថ្លៃសេវាធានារ៉ាប់រង និងថ្លៃសេវាផ្សេងទៀតប្រសិនបើមាន
  - ថ្លៃសេវាដែលបង់តាមកាលកំណត់ រួមទាំងថ្លៃសេវាត្រួតពិនិត្យប្រចាំឆ្នាំ ការបង់ថ្លៃសេវាធានារ៉ាប់រងប្រចាំឆ្នាំ
  - ថ្លៃសេវាកែប្រែ ឬថ្លៃសេវាប្រតិបត្តិការ ដូចជាការទូទាត់សងមុនកាលកំណត់ (Early Settlement) ការថ្លៃសេវាចំពោះការបង់យឺតជាដើម

- របៀប និងពេលណាដែលលក្ខខណ្ឌអាចត្រូវបានកែប្រែ
- ប្រសិនបើមានការកែប្រែ តើស្ថាប័នត្រូវជូនដំណឹងដល់អតិថិជនអំពីការកែប្រែកិច្ចព្រមព្រៀងនេះ នៅពេលណានិងដោយរបៀបណា
- អាចមានការពិន័យ និង ដំណោះស្រាយផ្លូវច្បាប់ផ្សេងទៀតក្នុងករណីមានការរំលោភលើកិច្ចព្រមព្រៀង
- ព័ត៌មានទំនាក់ទំនងសម្រាប់សេវាកម្មអតិថិជនរបស់អ្នកផ្តល់សេវា

---

[90] (World Bank, 2017)

- របៀបដោះស្រាយទំនាស់ និងព័ត៌មានទំនាក់ទំនងស្ដីពីយន្ដការដោះស្រាយបណ្ដឹងភាគីទីបីខាងក្នុង និងខាងក្រៅ និង
- ការទូទាត់បង់ប្រាក់មុនកាលកំណត់ និងការដកយកទ្រព្យធានាមកវិញ៖ ការត្អូញត្អែរមួយក្នុងចំណោមការត្អូញត្អែរសំខាន់ៗ ពីអ្នកខ្ចីគឺនៅពេលដែលពួកគាត់ចង់ទូទាត់ប្រាក់កម្ចីមុនពេលកំណត់ និងដកយកទ្រព្យធានាមកវិញ ជាទូទៅមានបញ្ហាពីការដកនេះដែលពួកគាត់មិនបានដឹងពីមុនមក។ ដើម្បីជៀសវាងបញ្ហាបែបនេះ វាជាការទទួលខុសត្រូវរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការជូនដំណឹងដល់អ្នកខ្ចីដោយផ្ទាល់មាត់ និងនៅក្នុងកិច្ចសន្យា អំពីនីតិវិធីក្នុងការដកយកទ្រព្យធានាមមកវិញក្នុងករណីមានការទូទាត់សងប្រាក់មុនកាលកំណត់។

**ឧទាហរណ៍ ៖** ចាន់ បានខ្ចីប្រាក់ពីគ្រឹះស្ថាន រុក្ខាហ្វាយណាន់។ ថ្មីៗនេះ កូនប្រុសរបស់គាត់បានទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង ហើយបានផ្ញើប្រាក់ក្នុងចំនួនសមរម្យមួយមកឱ្យចាន់។ ចាន់បានសម្រេចចិត្តទូទាត់សងប្រាក់កម្ចីមុនកាលកំណត់ ហើយដកយកទ្រព្យធានាមកវិញ។ នៅពេលដែលគាត់បានបង់ផ្ដាច់ប្រាក់កម្ចីនោះ មន្ត្រីឥណទានបានប្រាប់គាត់ថា វានឹងចំណាយពេលដល់ទៅពីរសប្ដាហ៍សម្រាប់ការដកយកទ្រព្យធានាហើយត្រូវពិន័យ ៣%។ ចាន់ មិនបានដឹងពីលក្ខខណ្ឌនេះពីមុនមកទេ។ គេមិនបានជូនដំណឹងដល់គាត់ទេ ហើយក៏មិនមានចែងនៅក្នុងកិច្ចសន្យាខ្ចីរបស់គាត់ដែរ។ នៅពេលដែលមានភាពខុសគ្នាតាមការរំពឹងទុករបស់អ្នកខ្ចី វាជាទំនួលខុសត្រូវរបស់មន្ត្រីឥណទានក្នុងការបង្ហាញព័ត៌មានបែបនេះជាមុន។

### សំណួរឆ្លុះបញ្ចាំង ឃ១. ២.១

ដើម្បីអនុលោមតាមពិដានអត្រាការប្រាក់ ១៨%ក្នុងមួយឆ្នាំ គ្រឹះស្ថានរុក្ខាហ្វាយណាន់ បានអនុវត្តការគិតថ្លៃត្រួតពិនិត្យប្រចាំឆ្នាំ សូម្បីតែលើកម្ចីរយៈពេលវែង ទោះបីជាថ្លៃសេវាបែបនេះមិនចាំបាច់ក៏ដោយ។ មានករណីដែលអតិថិជនត្រូវបានគិតប្រាក់សម្រាប់ថ្លៃសេវាភាគីទីបី ដូចជាថ្លៃសេវាផ្ទេរកម្មសិទ្ធិ ឬថ្លៃសេវាវាយតម្លៃអចលនទ្រព្យទោះបីជាគ្មានការផ្ដល់សេវាកម្មវិជ្ជាជីវៈបែបនោះជាក់ស្ដែងក៏ដោយ។ តាមការបង្ហាញពីប្រាក់កម្ចី $២0K សម្រាប់ EMI-៣៦ខែ ក្នុងតារាងខាងក្រោម។ តើថ្លៃសេវាអ្វីខ្លះដែលត្រូវបង្ហាញប្រាប់ និងពន្យល់ដល់អតិថិជន?

| កាលវិភាគប្រាក់កម្ចី | | | |
|---|---|---|---|
| ចំនួនប្រាក់កម្ចី | ២០,០០០ ដុល្លារ | សោហ៊ុយទម្រង់ការ | ១% |
| អត្រាការប្រាក់ | ១៨.00% | ថ្លៃត្រួតពិនិត្យប្រចាំឆ្នាំ | ២% |

| | | | |
|---|---|---|---|
| រយៈពេល | ៣៦ ខែ | ថ្លៃសេវាផ្សេងៗ | ៣០ដុល្លារ |
| របៀបបង់ | EMI | | |

| Pmt No. | Payment Date | Principal | Interest | Processing Fee/Review Fee | Other Fees | Total Payment | Beginning Balance | Ending Balance |
|---|---|---|---|---|---|---|---|---|
| 0 | 01/Nov/21 | - | - | 400 | 200 | 600 | - | 20,000 |
| 1 | 01/Dec/21 | 423 | 300 | - | - | 723 | 20,000 | 19,577 |
| 12 | 01/Nov/22 | 490 | 233 | 210 | 300 | 1,233 | 15,018 | 14,528 |
| 23 | 01/Oct/23 | 586 | 137 | - | - | 723 | 9,146 | 8,560 |
| 24 | 01/Nov/23 | 590 | 133 | 110 | 300 | 1,134 | 8,560 | 7,969 |
| 36 | 01/Nov/24 | 822 | 13 | - | - | 835 | 822 | |

### ឃ១.២.២. ការបង្ហាញព័ត៌មានអំពីអ្នកអនុវត្តកាតព្វកិច្ចចំពោះឥណទាន

ដោយសារតែលក្ខខណ្ឌឥណទានមានសារៈសំខាន់ ភាគីទាំងអស់ខាងផ្នែកអតិថិជនត្រូវឈ្វេងយល់ឱ្យបានច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន។ សម្រាប់ការរៀបចំឥណទានធម្មតា កាតព្វកិច្ចហិរញ្ញវត្ថុចំពោះឥណទានអាចពាក់ព័ន្ធនឹង៖

(i) **អ្នកខ្ចី** រាប់បញ្ចូលទាំងអ្នកខ្ចីចំបង និងអ្នករួមខ្ចី (primary or principal borrower)

- កាតព្វកិច្ចទូទាត់ប្រាក់៖ បង់ថ្លៃសេវាទាក់ទងនឹងប្រាក់កម្ចីទាំងអស់ រួមទាំង សេវារដ្ឋបាល ការរៀបចំ ការសន្យា ថ្លៃសេវាកម្ចី ប្រាក់ដើម និងការប្រាក់
- ការទទួលខុសត្រូវ៖ គ្មានដែនកំណត់រហូតទាល់តែប្រាក់កម្ចីបានសងផ្តាច់
- ត្រូវរាយការណ៍ជូន ការិយាល័យឥណទានកម្ពុជា

(ii) **អ្នកបង្កើតហ៊ីប៉ូតែក** (Hypothecators) សន្យាដាក់ទ្រព្យធានាជា **ហ៊ីប៉ូតែក** (Hypothec) (សិទ្ធិស្របច្បាប់ដែលច្បាប់ប្រគល់ឱ្យម្ចាស់បំណុលលើទ្រព្យសម្បត្តិរបស់កូនបំណុល) ដើម្បីធានាប្រាក់កម្ចីរបស់អ្នកខ្ចី។

- កាតព្វកិច្ចបង់ប្រាក់៖ មិនមានកាតព្វកិច្ចតទេ ប្រសិនបើមិនបានចែងនៅក្នុងកិច្ចសន្យាទេនោះ
- ការទទួលខុសត្រូវ៖ មានការទទួលខុសត្រូវតែក្នុងករណីបានប្រព្រឹត្តកំហុស ហើយត្រូវកំណត់ត្រឹមតែតម្លៃទ្រព្យធានាប៉ុណ្ណោះ។

- ត្រូវរាយការណ៍ជូន ការិយាល័យឥណទានកម្ពុជា

(iii) **អ្នកធានាលក្ខណៈបុគ្គល** ជាធម្មតាធានាលើ កាតព្វកិច្ចគ្មានដែនកំណត់ដោយផ្អែកលើបំណុលរួម និងបំណុលដាច់ដោយឡែក លើកលែងតែមានការបញ្ជាក់ច្បាស់លាស់

- កាតព្វកិច្ច៖ មិនមានកាតព្វកិច្ចបង់ប្រាក់ទេ លើកលែងតែក្នុងករណីបានប្រព្រឹត្តកំហុស
- ការទទួលខុសត្រូវ៖ ត្រូវបានកម្រិតដូចមានបញ្ជាក់ក្នុងកិច្ចសន្យា
- ត្រូវរាយការណ៍ជូន ការិយាល័យឥណទានកម្ពុជា

(iv) **អ្នកធានាលក្ខណៈស្ថាប័ន៖** ប្រសិនបើប្រាក់កម្ចីត្រូវបានដាក់ក្រោមគម្រោងធានាណាមួយជាមួយភាគីទីបីដែលបានព្រមព្រៀងគ្នា ដូចជា CGCC ឬអ្នកឧបត្ថម្ភហិរញ្ញវត្ថុខ្សែសង្វាក់ផ្គត់ផ្គង់ អតិថិជនគួរតែបានដឹងអំពីការរៀបចំបែបនេះ។ ប្រសិនបើមានការចំណាយបន្ថែមសម្រាប់អតិថិជន ត្រូវជូនដំណឹងអំពីករណីនេះមុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀង។

(v) **សាក្សី៖** ធ្វើជាសាក្សីចំពោះកិច្ចព្រមព្រៀងប្រាក់កម្ចីរវាង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអ្នកខ្ចី។

- កាតព្វកិច្ច៖ មិនមានកាតព្វកិច្ចបង់ប្រាក់ទេ
- ការទទួលខុសត្រូវ៖ គ្មានការទទួលខុសត្រូវទេ
- មិនត្រូវរាយការណ៍ជូន ការិយាល័យឥណទានកម្ពុជាទេ

## ការបង្ហាញព័ត៌មានបន្ថែមសម្រាប់អ្នកធានា

សម្រាប់អ្នកធានាលក្ខណៈបុគ្គល មន្ត្រីឥណទានត្រូវប្រាកដថាពួកគាត់យល់ពីការជាប់ពាក់ព័ន្ធនៃការធ្វើជាអ្នកធានាតាមរយៈការបង្ហាញដូចខាងក្រោម ៖ [91]

### សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកធានាលក្ខណៈបុគ្គល

- សិទ្ធិបដិសេធមិនធ្វើជាអ្នកធានា
- សិទ្ធិស្នើសុំព័ត៌មានអំពីប្រតិបត្តិការ ឬឥណទានដែលបានធានា
- សិទ្ធិបញ្ចប់ការទទួលខុសត្រូវរបស់អ្នកធានាដោយការសងផ្តាច់បំណុលដែលនៅសេសសល់ ឬចំនួនទឹកប្រាក់ផ្សេងទៀត (ដូចមានចែងនៅក្នុងកិច្ចសន្យា)
- សិទ្ធិដកខ្លួនចេញពីការធានា
  - ➢ **មុនពេលផ្តល់ឥណទានដំបូង** ក្រោមកិច្ចសន្យាឥណទានដែលពាក់ព័ន្ធ

[91] (The Association of Banks in Cambodia, Cambodian Microfinance Association, Cambodian Association of Finance & Technology, 2022)

- **បន្ទាប់ពីបានផ្តល់ឥណទានដំបូង** ប្រសិនបើកិច្ចសន្យាឥណទានខុសពីកិច្ចសន្យាឥណទានដែលបានស្នើសុំ ដោយគ្មានការយល់ព្រមជាមុនពីអ្នកធានានៅមុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងធានា

- កាតព្វកិច្ចក្នុងការដឹងពីទំនួលខុសត្រូវទាំងអស់ពាក់ព័ន្ធនឹងហានិភ័យហិរញ្ញវត្ថុក្នុងនាមជាអ្នកធានា

## កាតព្វកិច្ចរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- ផ្តល់ច្បាប់ចម្លង និងការពន្យល់ដោយផ្ទាល់មាត់អំពីកិច្ចសន្យាឥណទានដែលពាក់ព័ន្ធ
- ផ្តល់ច្បាប់ចម្លង និងការពន្យល់ដោយផ្ទាល់មាត់អំពីលិខិតផ្តល់ជូនឥណទានចុងក្រោយដល់អ្នកខ្ចី
- ផ្តល់ច្បាប់ចម្លង និងការពន្យល់ដោយផ្ទាល់មាត់អំពីរបាយការណ៍ឥណទានដែលពាក់ព័ន្ធពីការិយាល័យឥណទានកម្ពុជា

**ឧទាហរណ៍៖** ចាន់បានខ្ចីប្រាក់ចំនួន ២០០០០ដុល្លារ ពីធនាគារថ្ងម៉ាក្វ។ ឪពុករបស់គាត់បានធានាប្រាក់កម្ចីនេះតាមរយៈការបង្កើតហ៊ីប៉ូតែក ដោយដាក់ដីទំនេរមួយកន្លែងជាទ្រព្យធានា។ ចាន់ ទូទាត់សងប្រាក់ប្រចាំខែរបស់គាត់យឺតបីថ្ងៃ។ មន្ត្រីឥណទានបានទូរសព្ទទៅឪពុករបស់គាត់ ហើយទាមទារឱ្យបង់ប្រាក់។ ការអនុវត្តបែបនេះគឺមិនសមស្របនោះទេ ពីព្រោះអ្នកធានាមិនទទួលខុសត្រូវលើការទូទាត់បង់ប្រាក់ប្រចាំខែទេ។ លុះត្រាតែធនាគារបានចាត់ថ្នាក់ប្រាក់កម្ចីនេះថាជាឥណទានមិនដំណើរការ (non-performing loan) នោះទើបត្រូវទាក់ទងទៅកាន់ឪពុករបស់គាត់ឱ្យស្វែងរកដំណោះស្រាយ។

## ឃ១.២.៣. ការបង្ហាញអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អតិថិជន

ក្រៅពីកាតព្វកិច្ចហិរញ្ញវត្ថុខាងលើ អតិថិជនត្រូវដឹងអំពីសិទ្ធិ និងកាតព្វកិច្ចស្នូលដូចខាងក្រោម៖

(i) តាមរយៈការទទួលយកកាតព្វកិច្ចហិរញ្ញវត្ថុ អតិថិជនបានផ្តល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពិនិត្យមើល ធ្វើរបាយការណ៍ និងចែករំលែកព័ត៌មានឥណទានរបស់ខ្លួនជាមួយ ការិយាល័យឥណទានកម្ពុជា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ធនាគារជាតិនៃកម្ពុជា ដែរ។

(ii) បើទោះជាអតិថិជន និងអ្នកបង្កើតហ៊ីប៉ូតែករក្សាសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិ ឬទ្រព្យសកម្មនៃហ៊ីប៉ូតែកដែលធានាប្រាក់កម្ចីក៏ដោយ ក៏គាត់មានកាតព្វកិច្ចសុំការយល់ព្រមជាមុនពី

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងនាមជាម្ចាស់បំណុលនៃហ៊ីប៉ូតែកដែរ មុនពេលធ្វើការកែប្រែទ្រង់ទ្រាយនៃទ្រព្យសម្បត្តិនោះ។

(iii) អតិថិជនមានកាតព្វកិច្ចប្រើប្រាស់ប្រាក់កម្ចីស្របតាមគោលបំណងកម្ចី ដែលបានព្រមព្រៀងគ្នាដូចមានចែងនៅក្នុងសំណើឥណទាន ឬពាក្យស្នើសុំកម្ចី។

(iv) អាចមានការកំណត់ខសន្យាហិរញ្ញវត្ថុពិសេសសម្រាប់គោលបំណងជាក់លាក់។ អតិថិជនប្រហែលជាមិនអាចសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ ឬធ្វើការវិនិយោគ ដែលលើសពីកម្រិតជាក់លាក់ដែលបានកំណត់ជាមុនដើម្បីជៀសវាងបញ្ហានៃការសងប្រាក់ ឧទាហរណ៍៖

- ការដាក់កម្រិតលើបំណុលហិរញ្ញវត្ថុបន្ថែម
- ការដាក់កម្រិតលើការវិនិយោគអាជីវកម្មថ្មី
- ការដាក់កម្រិតលើការទូទាត់បំណុល ឬការបង់ភាគលាភ

**ឧទាហរណ៍៖** អតិថិជនម្នាក់ត្រូវបានបោកបញ្ឆោតឱ្យចូលរួមធ្វើជាសាក្សី ចំពោះកិច្ចព្រមព្រៀងប្រាក់កម្ចី ដែលតាមពិតមិនគួរជាប់កាតព្វកិច្ចហិរញ្ញវត្ថុណាមួយឡើយ ប៉ុន្តែ សាក្សីបានប្រែក្លាយជាអ្នកត្រូវទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងជាកម្មវត្ថុនៃរបាយការណ៍ដាក់ជូនទៅ ការិយាល័យឥណទានកម្ពុជា ទៅវិញ។ បុគ្គលដែលយល់ព្រមធ្វើជា "សាក្សី" នៃប្រាក់កម្ចីច្រើនតែចុងក្រោយក្លាយជាអ្នករួមខ្ចី ឬអ្នកធានាទៅវិញ ដោយសារតែខ្លឹមសារបែបបំភាន់នៅក្នុងឯកសារច្បាប់ ឬចេតនាបំភាន់របស់មន្ត្រីឥណទានដែលទទួលខុសត្រូវ។

**សំណួរឆ្លុះបញ្ចាំង ឃ១.២.៣**

អ្នកសន្យាដាក់វត្ថុបញ្ចាំជាភាគីទីបី យល់ព្រមដាក់បញ្ចាំទ្រព្យសម្បត្តិរបស់គាត់ដែលមានតម្លៃ ១០០ ពាន់ដុល្លារដើម្បីរួមចំណែក ធានាឥណទានចំនួន ១ លានដុល្លារ។ ប្រសិនបើមានករណីបំពានលក្ខខណ្ឌលើឥណទាន ១ លានដុល្លារនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានសិទ្ធិអនុវត្តសិទ្ធិស្របច្បាប់របស់ខ្លួនទៅលើអចលនទ្រព្យដែលបានដាក់បញ្ចាំនោះ។ ទោះជាយ៉ាងនេះក្ដី អ្នកសន្យាដាក់វត្ថុបញ្ចាំភាគីទីបី ទទួលខុសត្រូវរួមគ្នាដោយមិនបានរំពឹងទុកលើបំណុលទាំងមូលដែលមានចំនួន ១ លានដុល្លារតាមឯកសារកិច្ចសន្យា។ និយ័តករបានប្ដឹង និងពិន័យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ តើការប្រព្រឹត្តិកំហុសបែបនេះត្រូវជៀសវាងដោយរបៀបណា?

## ការណែនាំអំពីផលិតផលកម្ចីត្រឹមត្រូវ

ទំនួលខុសត្រូវសំខាន់មួយទៀតរបស់បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលធ្វើការដោយផ្ទាល់ជាមួយនឹងប្រាក់កម្ចីរបស់អតិថិជន គឺត្រូវផ្តល់ការពិគ្រោះយោបល់ដល់អតិថិជនឱ្យជ្រើសរើសផលិតផលកម្ចីនីមួយៗ ដែលសមស្របបំផុត។ លក្ខណៈពិសេសរបស់ផលិតផលកម្ចីត្រូវពន្យល់ឱ្យច្បាស់លាស់ និងញែកឱ្យដាច់ពីគ្នាទៅកាន់អ្នកខ្ចីសក្តានុពល។ ដូចគ្នានេះដែរ បុគ្គលិកត្រូវចេះធ្វើការប្រៀបធៀប និងបង្ហាញឱ្យឃើញពីភាពខុសគ្នារវាងផលិតផលប្រាក់កម្ចីដោយលើកឡើងពីគុណសម្បត្តិ និងគុណវិបត្តិសម្រាប់ជម្រើសនីមួយៗ។ ដូច្នេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវផ្តល់ការណែនាំ និងការបណ្តុះបណ្តាលអំពីផលិតផល ឱ្យបានគ្រប់គ្រាន់ដល់បុគ្គលិកដើម្បីឱ្យបុគ្គលិកមានចំណេះដឹងច្បាស់អំពីផលិតផលកម្ចី និងលក្ខណៈពិសេសរបស់កម្ចីនៅពេលដែលពួកគេអនុវត្តនីតិវិធីលក់។

## ការណែនាំអំពីវិធីសាស្ត្របង់ប្រាក់ត្រឹមត្រូវ

បុគ្គលិកត្រូវស្តាប់ដោយយកចិត្តទុកដាក់ដើម្បីឈ្វេងយល់ពីលំនាំលំហូរសាច់ប្រាក់របស់អតិថិជន និងណែនាំអំពីផលិតផលដែលបំពេញតាមតម្រូវការរបស់គាត់ ជាជាងការណែនាំផលិតផលកម្ចីមិនចំគោលដៅ។ ដើម្បីណែនាំអំពីវិធីសាស្ត្របង់ប្រាក់ត្រឹមត្រូវ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវកំណត់ប្រាក់ចំណូលតាមរដូវកាល ឬលំនាំលំហូរសាច់ប្រាក់តាមរយៈការពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុ ធ្វើការវិភាគហិរញ្ញវត្ថុ និងការឈ្វេងយល់អំពីវិស័យនេះឱ្យបានល្អិតល្អន់។

**ឧទាហរណ៍៖** សាន បានស្នើសុំប្រាក់កម្ចីចំនួន ១០,០០០ ដុល្លារអាមេរិកពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានរយៈពេល ២៤ ខែ និងអត្រាការប្រាក់ប្រចាំខែចំនួន ១.២%។ ផែនការអាជីវកម្ម និងការវិភាគលំហូរសាច់ប្រាក់បង្ហាញថា គាត់មានលំហូរសាច់ប្រាក់សុទ្ធប្រចាំខែ ៩០០ ដុល្លារអាមេរិក។ គ្រឹះស្ថាន មានការកំណត់ចំនួនទឹកប្រាក់ត្រូវបង់រំលស់ ដែលត្រូវតែតិចជាង ៦០% នៃប្រាក់ចំណូលសុទ្ធប្រចាំខែ។ បុគ្គលិក គ្រឹះស្ថាន ត្រូវណែនាំអំពីវិធីសាស្ត្របង់ប្រាក់ដើមថេរ(Linear repayment) (តារាងទី 1) ជំនួសឱ្យវិធីសាស្ត្របង់រំលស់ថេរប្រចាំខែ (Annuity repayment) (តារាងទី ២) ពីព្រោះវាផ្តល់អត្ថប្រយោជន៍កាន់តែច្រើនដល់អតិថិជន ពីព្រោះអត្រាការប្រាក់សរុបគឺទាបជាង (១,៥០០ ដុល្លារអាមេរិក ធៀបនឹង ១,៥៦៨ ដុល្លារអាមេរិក)។

**តារាងទី ១៖** វិធីសាស្រ្តបង់ប្រាក់ដើមថេរ

| តម្លៃប្រាក់កម្ចី | | សង្ខេបប្រាក់កម្ចី | |
|---|---|---|---|
| ចំនួនប្រាក់កម្ចី | $10,000.00 | ការបង់ប្រចាំខែ | $536.67 |
| អត្រាការប្រាក់ប្រចាំខែ | 1.20% | ចំនួនដងនៃការបង់ប្រាក់ | 24 |
| រយៈពេលកម្ចីគិតជាខែ | 24 | ការប្រាក់សរុប | $1,500.00 |
| | | ការចំណាយសរុបនៃប្រាក់កម្ចី | $11,500.00 |

| លេខរៀង | ប្រាក់ដើម | ការប្រាក់ | ការបង់ប្រាក់ | សមតុល្យ |
|---|---|---|---|---|
| - | | 1.20% | | 10,000.00 |
| 1 | 416.67 | 120 | 536.67 | 9,583.33 |
| 2 | 416.67 | 115 | 531.67 | 9,166.67 |
| 3 | 416.67 | 110 | 526.67 | 8,750.00 |
| 4 | 416.67 | 105 | 521.67 | 8,333.33 |
| 5 | 416.67 | 100 | 516.67 | 7,916.67 |
| 6 | 416.67 | 95 | 511.67 | 7,500.00 |
| 7 | 416.67 | 90 | 506.67 | 7,083.33 |
| 8 | 416.67 | 85 | 501.67 | 6,666.67 |
| 9 | 416.67 | 80 | 496.67 | 6,250.00 |
| 10 | 416.67 | 75 | 491.67 | 5,833.33 |
| 11 | 416.67 | 70 | 486.67 | 5,416.67 |
| 12 | 416.67 | 65 | 481.67 | 5,000.00 |
| 13 | 416.67 | 60 | 476.67 | 4,583.33 |
| 14 | 416.67 | 55 | 471.67 | 4,166.67 |
| 15 | 416.67 | 50 | 466.67 | 3,750.00 |
| 16 | 416.67 | 45 | 461.67 | 3,333.33 |
| 17 | 416.67 | 40 | 456.67 | 2,916.67 |
| 18 | 416.67 | 35 | 451.67 | 2,500.00 |
| 19 | 416.67 | 30 | 446.67 | 2,083.33 |
| 20 | 416.67 | 25 | 441.67 | 1,666.67 |
| 21 | 416.67 | 20 | 436.67 | 1,250.00 |
| 22 | 416.67 | 15 | 431.67 | 833.33 |
| 23 | 416.67 | 10 | 426.67 | 416.67 |

| | | | | |
|---|---|---|---|---|
| 24 | 416.67 | 5 | 421.67 | - |
| | **10,000.00** | **1,500.00** | **11,500.00** | |

**តារាងទី ២៖** វិធីសាស្ត្របង់រំលស់ថេរប្រចាំខែ

| តម្លៃប្រាក់កម្ចី | | សង្ខេបប្រាក់កម្ចី | |
|---|---|---|---|
| ចំនួនប្រាក់កម្ចី | $10,000.00 | ការទូទាត់ប្រចាំខែ | $482.02 |
| អត្រាការប្រាក់ប្រចាំខែ | 1.20% | ចំនួនដងនៃការបង់ប្រាក់ | 24 |
| រយៈពេលកម្ចីគិតជាខែ | 24 | ការប្រាក់សរុប | $1,568.50 |
| | | ការចំណាយសរុបនៃប្រាក់កម្ចី | $11,568.50 |

| លេខរៀង | ប្រាក់ដើម | ការប្រាក់ | ការបង់ប្រាក់ | សមតុល្យ |
|---|---|---|---|---|
| - | | | | |
| 1 | $362.02 | $120.00 | $482.02 | $9,637.98 |
| 2 | $366.36 | $115.66 | $482.02 | $9,271.61 |
| 3 | $370.76 | $111.26 | $482.02 | $8,900.85 |
| 4 | $375.21 | $106.81 | $482.02 | $8,525.64 |
| 5 | $379.71 | $102.31 | $482.02 | $8,145.93 |
| 6 | $384.27 | $97.75 | $482.02 | $7,761.66 |
| 7 | $388.88 | $93.14 | $482.02 | $7,372.78 |
| 8 | $393.55 | $88.47 | $482.02 | $6,979.23 |
| 9 | $398.27 | $83.75 | $482.02 | $6,580.96 |
| 10 | $403.05 | $78.97 | $482.02 | $6,177.91 |
| 11 | $407.89 | $74.13 | $482.02 | $5,770.03 |
| 12 | $412.78 | $69.24 | $482.02 | $5,357.25 |
| 13 | $417.73 | $64.29 | $482.02 | $4,939.51 |
| 14 | $422.75 | $59.27 | $482.02 | $4,516.77 |
| 15 | $427.82 | $54.20 | $482.02 | $4,088.95 |
| 16 | $432.95 | $49.07 | $482.02 | $3,655.99 |
| 17 | $438.15 | $43.87 | $482.02 | $3,217.85 |
| 18 | $443.41 | $38.61 | $482.02 | $2,774.44 |

| | | | | |
|---|---|---|---|---|
| 19 | $448.73 | $33.29 | $482.02 | $2,325.71 |
| 20 | $454.11 | $27.91 | $482.02 | $1,871.60 |
| 21 | $459.56 | $22.46 | $482.02 | $1,412.04 |
| 22 | $465.08 | $16.94 | $482.02 | $946.96 |
| 23 | $470.66 | $11.36 | $482.02 | $476.30 |
| 24 | $476.30 | $5.72 | $482.02 | $0.00 |
| | **10,000.00** | **1,568.50** | **11,568.50** | |

## ឃ១.៣. វាយតម្លៃសំណើប្រាក់កម្ចី

បន្ទាប់ពីមន្ត្រីឥណទានបានណែនាំអំពីផលិតផលឥណទានដល់អតិថិជន ហើយពួកគាត់សម្រេចចិត្តជ្រើសរើសផលិតផលជាក់លាក់មួយ ជំហានបន្ទាប់គឺត្រូវរៀបចំសរសេរសំណើសុំកម្ចី និងធ្វើការវាយតម្លៃឥណទាន។ ការងារនេះគឺជាទំនួលខុសត្រូវរបស់មន្ត្រីឥណទាន និងអ្នកអនុម័តឥណទាន។

សំណើកម្ចីជាធម្មតាត្រូវរួមបញ្ចូល៖

- សារតាអ្នកដាក់ពាក្យស្នើសុំ (ព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានវិជ្ជាជីវៈ និងការស្គាល់អតិថិជនរបស់អ្នក (KYC))
- គោលបំណងនៃប្រាក់កម្ចី
- សមត្ថភាពសងប្រាក់ និងស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី
- ព័ត៌មានឥណទាន
- ព័ត៌មានទ្រព្យធានា

### ឃ១.៣.១. ព័ត៌មានមូលដ្ឋានរបស់អ្នកខ្ចីប្រាក់

ការដឹងអំពីព័ត៌មានមូលដ្ឋានរបស់អ្នកខ្ចីប្រាក់ គឺជារឿងដំបូងដែលត្រូវធ្វើក្នុងការវាយតម្លៃឥណទាន ឬហៅម្យ៉ាងទៀតថា ការស្គាល់អតិថិជនរបស់អ្នក (KYC)។ ដើម្បីអនុវត្ត KYC ប្រកបដោយក្រមសីលធម៌ មន្ត្រីឥណទានត្រូវបង្ហាញព័ត៌មានអំពីអតិថិជនឱ្យបានត្រឹមត្រូវ ហើយមិនត្រូវកែប្រែ ឬកែតម្រូវព័ត៌មាននោះដើម្បីបំពេញតាមលក្ខខណ្ឌត្រួតពិនិត្យ និងអនុម័តឥណទានរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នោះទេ។ អាស្រ័យហេតុនេះ ត្រូវជៀសវាងទង្វើដូចខាងក្រោម៖

- **ការរៀបចំឱ្យអ្នកខ្ចី/អ្នកធានាដែលមិនមានការស្នើសុំ៖** ស្នើឱ្យអ្នកមិនពាក់ព័ន្ធដែលមិនមានចំណាប់អារម្មណ៍ខ្ចីប្រាក់ឱ្យធ្វើជាអ្នករួមខ្ចី ឬអ្នកធានា ជូនកាលដោយមិនស្ម័គ្រចិត្ត។
- **ការលាក់បាំងព័ត៌មានអំពីរចនាសម្ព័ន្ធកម្មសិទ្ធិរបស់អ្នកខ្ចី៖** ពេលខ្លះ អាជីវកម្មមានរចនាសម្ព័ន្ធភាពជាដៃគូ ប៉ុន្តែ ត្រូវបានបង្ហាញថាជាសហគ្រាសឯកបុគ្គលដើម្បីប្រើប្រាស់ប្រាក់ចំណូលពេញលេញយកទៅគណនាសមត្ថភាពសងប្រាក់។
- **លាក់បាំងប្រវត្តិអាជីវកម្ម ឬលំនៅឋានរបស់អ្នកខ្ចី៖** ព័ត៌មានអវិជ្ជមានមួយចំនួនអំពីកំណត់ត្រាអាជីវកម្ម ឬការផ្លាស់ប្តូរទីលំនៅញឹកញាប់ អាចប៉ះពាល់ដល់សារតា ហានិភ័យឥណទានរបស់អតិថិជន។ ដូច្នេះ មន្ត្រីឥណទានអាចមានទំនោរលាក់បាំងព័ត៌មានទាំងនេះដើម្បីកែលម្អឥណទានរបស់អ្នកខ្ចី ខណៈពេលធ្វើការវាយតម្លៃហានិភ័យឥណទានដើម្បីតែបង្គ្រប់កិច្ច។
- **ក្លែងស្ថានភាពគ្រួសាររបស់អ្នកខ្ចី៖** អ្នកដាក់ពាក្យដែលបានរៀបអាពាហ៍ពិពាហ៍រួចហើយខ្លះត្រូវបានបង្ហាញព័ត៌មាន ថានៅលីវដោយសារតែមានព័ត៌មានអវិជ្ជមានទាក់ទងប្តី ឬប្រពន្ធពោលគឺប្រវត្តិឥណទានមិនល្អ ប្រភពចំណូលស្មុគស្មាញមានវិវាទមិនទាន់ដោះស្រាយរួច ជាដើម។ ពេលខ្លះ មន្ត្រីឥណទានធ្វើដូច្នេះដើម្បីជៀសវាងដំណើរការបង្កើតឥណទានវែងឆ្ងាយដោយសារតែតម្រូវការក្នុងការស្គាល់អតិថិជនរបស់អ្នក (KYC) ឱ្យបានត្រឹមត្រូវលើអ្នកខ្ចីពីរនាក់ជាជាងមួយនាក់។
- **លាក់បាំងចរិតលក្ខណៈនិងទម្លាប់អាក្រក់ របស់អ្នកខ្ចី៖** អ្នកខ្ចីខ្លះមានចរិតលក្ខណៈ និងទម្លាប់ដែលគួរជៀសវាង ដូចជា ឆេវឆាវបែបហិង្សា ខ្ជិលច្រអូស មិនទទួលខុសត្រូវ ញៀនល្បែង ញៀនស្រា មិនរួសរាយរាក់ទាក់ ។ល។ ប៉ុន្តែដោយសារតែកត្តានេះអាចប៉ះពាល់ដល់ការសម្រេចចិត្តផ្តល់ឥណទាន មន្ត្រីឥណទានជ្រើសរើសលាក់ព័ត៌មានលម្អិតទាំងនេះ ដោយបន្តផ្តល់ប្រាក់កម្ចីដើម្បីបំពេញគោលដៅកំណើនប្រាក់កម្ចីរបស់ខ្លួន។
- **លាក់បាំងបញ្ហានៃ គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច៖** អាជីវកម្មខ្លះអាចបង្កផលប៉ះពាល់មិនល្អនៅក្នុងសហគមន៍របស់ពួកគេ។ ប៉ុន្តែ មន្ត្រីឥណទានធ្វើជាមិនដឹងមិនឮអំពីអង្គហេតុទាំងនេះដើម្បីជៀសវាងការយកចិត្តទុកដាក់ស្គាល់អតិថិជន (due diligence) បន្ថែមទៀតលើអ្នកខ្ចី ហើយទីបំផុតអាចប៉ះពាល់ដល់ការសម្រេចចិត្តផ្តល់ឥណទានរបស់អ្នកអនុម័តប្រាក់កម្ចី។ ដូច្នេះហើយ មន្ត្រីឥណទានអាចជ្រើសរើសលុបព័ត៌មាននេះចេញពីការស្នើសុំកម្ចី ដោយមិនបានដឹងថា ការធ្វើបែបនេះនឹងធ្វើឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បំពានលើលក្ខខណ្ឌតម្រូវ នៃគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ដោយប្រយោលនោះឡើយ។

**សំណួរឆ្លុះបញ្ចាំង ឃ១.៣.១.**

អាជីវកម្មបូមខ្សាច់មួយកន្លែងកំពុងដំណើរការដោយមានអាជ្ញាបណ្ណបូមខ្សាច់លើផ្ទៃដីទំហំ ១ ហិកតា និងជម្រៅ ៥ ម៉ែត្រ ដែលចេញដោយក្រសួងរ៉ែ និងថាមពល។ ក្នុងពេលចុះពិនិត្យទីតាំងក្រុមហ៊ុននេះជាក់ស្តែង មន្ត្រីឥណទានបានសង្កេតឃើញថាអាជីវកម្មនេះកំពុងដំណើរការលើផ្ទៃដីទំហំប្រហែល ៣ហិកតា និងជម្រៅ ១៥ ម៉ែត្រ។ ម្ចាស់អាជីវកម្មបានពន្យល់ថានេះជារឿងធម្មតាទេ ពីព្រោះអាជីវកម្មជាច្រើនផ្សេងទៀតក៏ធ្វើដូចគ្នានេះដែរឱ្យតែម្ចាស់អាជីវកម្មមានដី។ ទោះជាយ៉ាងនេះក្តី ការធ្វើដូច្នេះមិនអនុលោមតាមអាជ្ញាបណ្ណឡើយ ហើយក៏អាចប្រឈមនឹងការផ្អាកអាជីវកម្ម និងទទួលរងនូវការពិន័យជាដើម។ នៅទីបំផុត មន្ត្រីឥណទានមិនបានបញ្ចូលព័ត៌មាននេះចូលទៅក្នុងសំណើប្រាក់កម្ចីទេដើម្បីកុំឱ្យមានភាពធ្ងន់ធ្ងរពាក់ព័ន្ធនឹងភាពអាចទុកចិត្តបាននៃឥណទានរបស់អ្នកខ្ចី។ តើការអនុវត្តនេះត្រឹមត្រូវស្របតាមក្រមសីលធម៌ដែរឬទេ? បើត្រឹមត្រូវ ហេតុអ្វី ឬបើមិនត្រឹមត្រូវ ហេតុអ្វី?

### ឃ១.៣.២. គោលបំណងកម្ចី និងមូលហេតុនៃការខ្ចីប្រាក់

គោលបំណងកម្ចី គឺជាកត្តាវាយតម្លៃឥណទានដ៏សំខាន់មួយដើម្បីកំណត់ថាតើប្រាក់កម្ចីនេះទីបំផុតនឹង៖

- សំខាន់ ឬមិនសំខាន់/តាមឆន្ទានុសិទ្ធិ (discretionary)
- បង្កើនប្រាក់ចំណូល និងបង្កើន/បន្ថយការចំណាយ
- បង្កើនទ្រព្យសកម្ម

គោលបំណងកម្ចីគឺការប្រើប្រាស់ប្រាក់កម្ចីក្នុងគោលបំណងផលិតភាព ឬការប្រើប្រាស់ផ្ទាល់ខ្លួន។ មានការណែនាំថាបើគ្មានសមត្ថភាពសងគ្រប់គ្រាន់ទេនោះ បុគ្គលនោះមិនត្រូវយកបំណុលហិរញ្ញវត្ថុក្នុងគោលបំណងមិនមានផលិតភាពនោះទេ (non-productive purpose) ដូចជាការទិញផលិតផលប្រណីត ដូចជា រថយន្តរ៉ូល រ៉យស៍ ជាដើម។ ដូចគ្នានេះដែរ មិនគួរផ្តល់បំណុលហិរញ្ញវត្ថុដល់អតិថិជនសម្រាប់គោលបំណងប្រថុយប្រថាន ដោយគ្មានមូលដ្ឋានគ្រឹះសេដ្ឋកិច្ចនោះឡើយ ដូចជាការទិញដីកសិកម្មដែលនៅទំនេរ ដោយសារពួកគេរំពឹងថានឹងមានការកើនឡើងគួរឱ្យកត់

សម្គាល់នៃតម្លៃទីផ្សារនាពេលអនាគតជាដើម។ ក្រៅពីអ្វីដែលបានលើកឡើងខាងលើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបុគ្គលិករបស់ខ្លួនត្រូវជៀសវាងសកម្មភាពដូចខាងក្រោម៖

- បំភាន់គោលបំណងកម្ចីដែលត្រូវបានហាមឃាត់ដោយច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ដោយមានចេតនាផ្តល់ព័ត៌មានមិនពិតអំពីគោលបំណងកម្ចី)
- ធ្វើបុនហិរញ្ញប្បទានយ៉ាងគំហុកដើម្បីរក្សាអតិថិជន ឬការផ្តល់ហិរញ្ញប្បទានលើសលប់ (ជាពិសេស ការផ្តល់ហិរញ្ញប្បទានលើទុនបង្វិល ជាដើម)
- ធ្វើឱ្យកម្ចីក្លាយទៅជាហ្វាស៊ីលីធីល្អជានិច្ច (Evergreening loan facilities) និងអាចបណ្តាល ឱ្យមានបំណុលវណ្ឌក (តាមរយៈ រយៈពេលកម្ចីការផ្លាស់ប្តូររបៀបបង់ប្រាក់ ការផ្តល់ប្រាក់កម្ចីបន្ថែម ការផ្តធ្វើបុនហិរញ្ញប្បទានការផ្លាស់ប្តូរ អ្នកខ្ចីជាដើម –។ល។)
- ការពន្យាររយៈពេលកម្ចីដើម្បីផ្តល់ប្រាក់កម្ចីធំជាងមុន ទោះបីជារយៈពេលនោះវែងជាងអាយុកាលទ្រព្យសកម្មដែលត្រូវបានផ្តល់ហិរញ្ញប្បទានក៏ដោយ។
- មានចេតនាផ្តល់ប្រាក់កម្ចីដល់អ្នកខ្ចីដោយដឹងថា ពួកគេមិនមែនជាអ្នកប្រើប្រាស់ប្រាក់កម្ចីនេះក៏ដោយ។

**ឧទាហរណ៍៖** អតិថិជនម្នាក់ផ្តល់សេវាកម្មរថយន្តតាក់ស៊ីដោយមានរថយន្តទេសចរណ៍ចំនួនប្រាំគ្រឿង ប៉ុន្តែ នៅពេលដែលគាត់ចង់ឡើងស៊េរីរថយន្តគ្រួសាររបស់គាត់ មន្ត្រីឥណទានបានកំណត់លក្ខណៈដោយមិនត្រឹមត្រូវនៃពាក្យស្នើសុំនេះថាជាប្រាក់កម្ចីអាជីវកម្មទៅវិញដោយរំពឹងថានឹងមានប្រាក់ចំណូលកាន់តែច្រើន ឬសន្សំសំចៃការចំណាយ ខណៈដែលអង្គហេតុគឺថា វាជាប្រាក់កម្ចីសម្រាប់យានយន្តផ្ទាល់ខ្លួន ដែលជាធម្មតាជាកម្មវត្ថុសម្រាប់ការពិចារណាទៅលើហានិភ័យឥណទានដែលមានការប្រុងប្រយ័ត្នខ្ពស់។

**សំណួរឆ្លុះបញ្ចាំង ឃ១.៣.២**

ម៉ាប់ជាអ្នករត់តាក់ស៊ី គាត់ចង់ខ្ចីប្រាក់យកមកសាងសង់ផ្ទះថ្មី ប៉ុន្តែ ផ្ទះបច្ចុប្បន្នរបស់គាត់ស្ថិតក្នុងស្ថានភាពល្អនៅឡើយ ហើយវាក៏ធំល្មមសម្រាប់គ្រួសារគាត់ទៅហើយ។ រថយន្តតាក់ស៊ីរបស់គាត់ចាស់ទ្រុឌទ្រោមខ្លាំង។ រថយន្តនេះត្រូវជួសជុលជាញឹកញាប់ ដែលរំខានដល់អាជីវកម្មរបស់គាត់។ អាយុកាលប្រើប្រាស់របស់រថយន្តនេះអាចបញ្ចប់នៅឆ្នាំក្រោយ។ តើគោលបំណងកម្ចីរបស់គាត់ត្រូវនឹងតម្រូវការរបស់គាត់ទេ? ហេតុអ្វី?

### ឃ១.៣.៣. សមត្ថភាពសងប្រាក់

សមត្ថភាពនៃការបង់ប្រាក់ និងស្ថានភាពហិរញ្ញវត្ថុ ជាធម្មតាជាលក្ខខណ្ឌទូទៅបំផុតសម្រាប់ធ្វើការសម្រេចចិត្តផ្តល់ឥណទាន។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើឱ្យសមហេតុផល និងប្រកបដោយវិជ្ជាជីវៈក្នុងការវាយតម្លៃឱ្យបានគ្រប់គ្រាន់នូវសមត្ថភាពហិរញ្ញវត្ថុ និងលក្ខខណ្ឌរបស់អ្នកខ្ចី។ ជាញឹកញាប់ណាស់ដែលអ្នកខ្ចីតែងតែព្យាយាមបន្ទាបការចំណាយ និងបំណុលរបស់ខ្លួន ឬបំប៉ោងប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីទទួលបានប្រាក់កម្ចីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ វាក៏មានបញ្ហាជាមួយនឹងកង្វះការវាយតម្លៃជាមូលដ្ឋានឬដំណើរការស្តីពីការយកចិត្តទុកដាក់ស្គាល់អតិថិជន (due diligence) ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានហិរញ្ញវត្ថុដែលអ្នកស្នើសុំបានបង្ហាញ។ ក្នុងករណីដ៏អាក្រក់បំផុត បុគ្គលិកនឹងក្លែងបន្លំឯកសារដើម្បីជួយឱ្យអតិថិជនទទួលបានប្រាក់កម្ចីដើម្បីសម្រេចគោលដៅឬទទួលបានកម្រៃជើងសារពីអតិថិជន ឬដើម្បីទទួលបានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ។

ប្រភពនៃការសងប្រាក់គឺជាលំហូរសាច់ប្រាក់សម្រាប់ទូទាត់ប្រាក់កម្ចី។ មន្ត្រីឥណទាន ត្រូវចាត់វិធានការសំខាន់ៗដូចខាងក្រោម៖

- មន្ត្រីឥណទានអាចរៀបចំកាលវិភាគសងប្រាក់កម្ចីសម្រាប់អ្នកខ្ចីនៅពេលដែលប្រភពនៃការទូទាត់សងអាចរកបាន
- មន្ត្រីឥណទានត្រូវទទួលបានព័ត៌មានអំពីភាគីពាក់ព័ន្ធ (ពាក់ព័ន្ធនឹងប្រភពនៃការទូទាត់សង) និងលើកឡើងពីមនុស្សទាំងនោះ (អ្នកខ្ចីរួមគ្នា ឬអ្នកធានា) នៅក្នុងកិច្ចសន្យាកម្ចី ឬកិច្ចសន្យាដែលមានការធានា។
- មន្ត្រីឥណទានត្រូវកំណត់ពីនិរន្តរភាពនៃប្រភពចំណូលសម្រាប់សងកម្ចីនាពេលអនាគតដើម្បីធានាថា អ្នកខ្ចីអាចមានលទ្ធភាពទូទាត់សងក្នុងរយៈពេលខ្លី និងរយៈពេលវែងបាន។

### ការផ្ទៀងផ្ទាត់សមត្ថភាពហិរញ្ញវត្ថុ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវដាក់ចេញនូវវិធាន និងយន្តការមួយចំនួនដើម្បីផ្ទៀងផ្ទាត់សមត្ថភាពហិរញ្ញវត្ថុ និងលក្ខខណ្ឌដែលបង្ហាញដោយអតិថិជន ដូចជា៖

(i) ភស្តុតាងជាឯកសារ ដូចជា របាយការណ៍ហិរញ្ញវត្ថុ វិក្កយបត្រលក់ ឬទិញ វិក្កយបត្រប្រើប្រាស់ទឹកភ្លើងជាដើម

(ii) ការយកចិត្តទុកដាក់ស្គាល់អតិថិជនដល់ទីកន្លែង

(iii) ពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានហិរញ្ញវត្ថុធៀបនឹងសូចនាករសំខាន់ៗ ដូចជា ចំនួនសមាជិកគ្រួសារ ចំនួនបុគ្គលិក ចំនួនទ្រព្យសកម្មរយៈពេលវែង ព័ត៌មាននិយោជក ចំណែកទីផ្សារ ទស្សនវិស័យនាពេលអនាគត កំណត់ត្រា និងផែនការអាជីវកម្ម/មុខរបរ ភាពងាយរងគ្រោះ។ល។

(iv) ពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានហិរញ្ញវត្ថុដោយចោះៗធៀបនឹងអនុបាតសំខាន់ៗ ដូចជា ប្រាក់ចំណេញធៀបនឹងមូលធន កម្រិតប្រាក់ចំណេញ និន្នាការប្រាក់ចំណេញ ការចំណាយធៀបនឹងចំណូល (Cost to Income) អនុបាតបំណុលធៀបនឹងបន្ទុក (Debt to Burden Ratio) ប្រាក់ចំណូលក្រោយកាត់ពន្ធ ( disposable income) ឬសមតុល្យ ជាដើម។

(v) ភស្តុតាងនៃការចុះបញ្ជីអាជីវកម្ម ឬអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជី

## ការរៀបចំ និងវិភាគរបាយការណ៍ហិរញ្ញវត្ថុ

### របាយការណ៍ប្រាក់ចំណូល (Income Statement)

SN Enterprise Co., Ltd

របាយការណ៍ប្រាក់ចំណូល

សម្រាប់រយៈពេលបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| | 2019 | 2020 | 2021 |
|---|---|---|---|
| ការលក់/ប្រាក់ចំណូល (Sales / Revenue) | 240,000 | 250,000 | 280,000 |
| ចំណាយថ្លៃដើម (Cost of Sales) | 196,800 | 207,500 | 238,000 |
| ប្រាក់ចំណេញដុល (Gross Profit) | 43,200 | 42,500 | 42,000 |
| ចំណាយប្រតិបត្តិការ (Operating Expenses) | 24,900 | 25,100 | 21,250 |
| ការចំណាយលើប្រាក់ខែ និងប្រាក់ឈ្នួល | 6,600 | 7,150 | 6,400 |
| ការចំណាយលើការជួល | 3,800 | 3,800 | 3,800 |
| ការចំណាយលើការដឹកជញ្ជូន | 4,500 | 5,000 | 3,500 |
| ការចំណាយលើទឹកភ្លើង | 3,000 | 3,200 | 3,300 |
| ការចំណាយរំលស់ | 1500 | 1500 | 1800 |
| ការចំណាយការប្រាក់ (ចំណូល) | 5,000 | 4,100 | 2,000 |
| ចំណាយប្រតិបត្តិការផ្សេងៗ | 500 | 350 | 450 |
| ប្រាក់ចំណេញសុទ្ធ (Net Profit) | 18,300 | 17,400 | 20,750 |

$$\text{DSCR*} = \frac{\text{ប្រាក់ចំណេញសុទ្ធ**}}{\text{ចំនួនសងប្រាក់ដើមត្រូវសង + ការចំណាយការប្រាក់}}$$

* DSCR៖ Debt Service Coverage Ratio

** ប្រាក់ចំណេញសុទ្ធ (Net Profit) ៖ ក៏សំដៅទៅលើ EBITDA = Earnings Before Interest, Taxes, Depreciation and Amortization (ប្រាក់ចំណូលមុនការប្រាក់ ពន្ធ និងរំលស់)

*** ចំនួនសងប្រាក់ដើមត្រូវសង (Principal Repayment)

**** ការចំណាយការប្រាក់ (Interest Expense)

**ចំណាំ៖**

- នេះជាការពន្យល់ដ៏សាមញ្ញអំពីរបាយការណ៍ប្រាក់ចំណូល ដែលមានគោលបំណងបង្ហាញអំពីរបៀបគណនាមូលដ្ឋានសម្រាប់ប្រាក់ចំណេញសុទ្ធ ឬប្រាក់ចំណូលសុទ្ធដែលត្រូវបានប្រើសម្រាប់ការគណនាពីសមត្ថភាពសងប្រាក់ (ដូចជា DSCR)។
- សម្រាប់កម្ចីអាជីវកម្មខ្នាតតូចខ្លះ ឬកម្ចីលក់រាយ ការលក់/ចំណូល ក៏អាចរួមបញ្ចូលចំណូលប្រាក់បៀវត្សរបស់អ្នករួមខ្ចី ដែលពិតជាធ្វើការនៅកន្លែងផ្សេង ហើយមិនពាក់ព័ន្ធនឹងអាជីវកម្មទេ។
- សម្រាប់រូបមន្ត DSCR ចំនួនប្រាក់ដើមត្រូវសង និងការចំណាយការប្រាក់ រួមបញ្ចូលទាំងប្រាក់កម្ចីដែលមានស្រាប់ និងប្រាក់កម្ចីថ្មីដែលកំពុងស្នើសុំ។

យោងតាមទស្សនៈនៃការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ សមត្ថភាពនៃការសងប្រាក់ (ដូចជា DSCR) របស់អ្នកខ្ចីគួរមានទ្រនាប់ (buffer) បន្ថែមពីលើកាតព្វកិច្ចហិរញ្ញវត្ថុ។ ទ្រនាប់នេះប្រែប្រួលពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មួយទៅមួយ។ ទោះជាយ៉ាងណាក្តី ជាទូទៅ វាមានកម្រិតអប្បបរមាចន្លោះចាប់ពី ១.២០x ដល់ ២.០០x។ ទ្រនាប់នេះត្រូវបម្រុងទុកដើម្បីរ៉ាប់រងលើការចំណាយចរន្ត (living cost) (ប្រសិនបើមិនបានរួមបញ្ចូលក្នុងការគណនាប្រាក់ចំណេញសុទ្ធ) និងការចំណាយលើការចាំបាច់ផ្សេងទៀតរបស់អ្នកខ្ចី។មិនមែនជាការអនុវត្តល្អទេ នៅពេលដែលគោលការណ៍ណែនាំស្តីពីការអនុម័តប្រាក់កម្ចីមិនតម្រូវឱ្យមានទ្រនាប់នោះ។ ការអនុវត្តបែបនេះ

អាចជួយឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បង្កើនផលបត្រប្រាក់កម្ចីកាន់តែខ្លាំងក្លា ឬឈានដល់គោលដៅនៃការទម្លាក់កម្ចី (disbursement target) ប៉ុន្តែ អ្នកខ្ចីនឹងមានហានិភ័យខ្ពស់ក្នុងការមិនមានលទ្ធភាពសងប្រាក់កម្ចីនៅពេលដែលពួកគាត់ស្រាប់តែមានការចំណាយស្មានមិនដឹងមុន។

**តារាងតុល្យការ** (Balance Sheet)

| ក្រុមហ៊ុន SN Enterprise Co., Ltd<br>**តារាងតុល្យការ**<br>**គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | | |
|---|---|---|---|
| (គិតជាដុល្លារអាមេរិក) | **2019** | **2020** | **2021** |
| ទ្រព្យសកម្ម | | | |
| ទ្រព្យសកម្មរយៈពេលខ្លី<br>**Assets Current Assets** | | | |
| សាច់ប្រាក់ (Cash) | 17,540 | 9,310 | 39,440 |
| គណនីសម្រាប់ទទួល (Account Receivables) | 21,000 | 24,000 | 15,000 |
| សន្និធិ (ស្តុក) (Inventory) | 65,000 | 70,000 | 35,000 |
| ការចំណាយដោយបង់ប្រាក់ជាមុន (Prepaid Expenses) | 4,000 | 5,000 | 6,000 |
| ទ្រព្យសកម្មរយៈពេលខ្លីសរុប | 107,540 | 108,310 | 95,440 |
| ទ្រព្យសកម្មអចរន្ត (មូលធននឹង)<br>**Non-Current Assets** | | | |
| ដី (Land) | 60,000 | 60,000 | 60,000 |
| អគារ (Buildings) | 30,000 | 30,000 | 36,000 |
| រំលស់បូកបន្ត - អគារ (Accumulated Depreciation - Buildings) | (15,000) | (16,500) | (18,300) |
| គ្រឿងចក្រ និងសម្ភារបរិក្ខារ (Machinery & Equipment) | 15,000 | 23,000 | 23,000 |
| រំលស់បូកបន្ត - គ្រឿងចក្រ និងសម្ភារបរិក្ខារ (Accumulated Depreciation) | (6,000) | (9,600) | (13,200) |
| ទ្រព្យសកម្មរយៈពេលវែងសរុប | 84,000 | 86,900 | 87,500 |
| ទ្រព្យសកម្មសរុប **(Total Assets)** | 191,540 | 195,210 | 182,940 |

| | | | |
|---|---|---|---|
| **បំណុល និង មូលធន (Liabilities & Equity)** | | | |
| **បំណុលរយៈពេលខ្លី (Current Liabilities)** | | | |
| គណនីសម្រាប់បង់ (Account Payables) | 4,500 | 5,850 | 6,500 |
| កម្ចីរយៈពេលខ្លី (Short-term Loan) | 30,000 | 25,000 | 8,000 |
| កម្រិតបច្ចុប្បន្ននៃបំណុលរយៈពេលវែង (Current Portion of Long-Term Debt) | 4,000 | 4,000 | 4,000 |
| **បំណុលរយៈពេលខ្លីសរុប Total Current Liabilities** | 38,500 | 34,850 | 18,500 |
| **បំណុលរយៈពេលវែង (Long Term Liabilities)** | | | |
| ប្រាក់កម្ចីរយៈពេលវែង | 16,000 | 12,000 | 8,000 |
| **បំណុលរយៈពេលវែងសរុប** | 16,000 | 12,000 | 8,000 |
| **បំណុលសរុប (Total Liabilities)** | 54,500 | 46,850 | 26,500 |
| | | | |
| **មូលធន (Equity)** | | | |
| ដើមទុន (Paid-In Capital) | 50,000 | 50,000 | 50,000 |
| ប្រាក់ចំណេញរក្សាទុក (Retained Earnings ) | 74,400 | 87,040 | 98,360 |
| ប្រាក់ចំណូលឆ្នាំចរន្ត (Current Year Earnings) | 12,640 | 11,320 | 8,080 |
| **មូលធនសរុប (Total Equity)** | 137,040 | 148,360 | 156,440 |
| **បំណុលនិងមូលធនសរុប (Total Liabilities & Equity)** | 191,540 | 195,210 | 182,940 |

សម្រាប់ឥណទានអាជីវកម្ម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវកំណត់លក្ខខណ្ឌតម្រូវដើម្បីធ្វើឱ្យមានសមតុល្យរវាងមូលធន និងបំណុលរបស់អ្នកខ្ចីពោលគឺរក្សាអានុភាពឱ្យបានល្អនៅក្នុងអាជីវកម្ម។ ជាធម្មតា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តម្រូវឱ្យអ្នកខ្ចីមានយ៉ាងច្រើនបំផុត៥០% នៃទ្រព្យសកម្មរបស់ពួកគេដែលបានផ្តល់ហិរញ្ញប្បទានតាមរយៈបំណុល។ ភាគរយខ្ពស់មានន័យថាអាជីវកម្មមានបំណុលច្រើនពេក ដែលអាចប៉ះពាល់ដល់សមត្ថភាព សងប្រាក់ និងសាធនភាព (solvency)។

សម្រាប់ឥណទានលក់រាយ (retail loans) (ដូចជា ឥណទានគេហដ្ឋាន ឥណទានរថយន្ត ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន ។ល។) គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនពិនិត្យមើលអនុបាតអានុភាពនេះដើម្បីវាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនោះទេ ប៉ុន្តែ ជាធម្មតា ពួកគេទាមទារការ

បង់ប្រាក់មួយផ្នែកមុន (down payment) របស់អតិថិជនក្នុងការទទួលបានទ្រព្យសកម្មរៀងៗខ្លួន ឧទាហរណ៍២០%-៣០% នៃការបង់ប្រាក់មួយផ្នែកមុនសម្រាប់ឥណទានលំនៅឋាន។ នេះគឺដើម្បីធានាថា អ្នកខ្ចីមានចំណែកសមរម្យក្នុងការទិញទ្រព្យសកម្មរបស់ខ្លួន ហើយទំនងជាមិនទទួលបានហិរញ្ញប្បទានលើសលប់ពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឡើយ។

**ចំណាប់អារម្មណ៍ ឃ១.៣.៣.**

ស៊ីថា ជាម្ចាស់អាជីវកម្មមួយដែលអាចរកចំណូលបាន១០០,០០០ ដុល្លារអាមេរិកក្នុងមួយខែ ដែលថ្លៃដើមទំនិញលក់បានចំនួន ៧០,០០០ ដុល្លារអាមេរិក និងចំណាយប្រតិបត្តិការ១៥,០០០ ដុល្លារអាមេរិក។ គាត់មានប្រាក់កម្ចីចំនួនពីរ ដែលត្រូវបង់ក្នុងទឹកប្រាក់៤,០០០ ដុល្លារអាមេរិក/ខែ ហើយគាត់កំពុងស្នើសុំប្រាក់កម្ចីមួយទៀតពីធនាគារថូម៉ាកូ ដែលគាត់ត្រូវបង់២,០០០ដុល្លារអាមេរិក/ខែ។ ដោយសន្មតថា លក្ខខណ្ឌផ្សេងទៀតទាំងអស់ត្រូវបានបំពេញ ហើយលក្ខខណ្ឌតម្រូវ DSCR យ៉ាងតិច ២.0x តើធនាគារអាចផ្តល់ប្រាក់កម្ចីថ្មីដល់គាត់ដែរឬទេ?

### ឃ១.៣.៤. ប្រវត្តិឥណទាន

ប្រវត្តិឥណទានសំដៅលើឥរិយាបថនៃការសងប្រាក់ និងការខ្ចីប្រាក់របស់អ្នកខ្ចី ដែលត្រូវវាយតម្លៃដើម្បីប្រាកដពីភាពអាចទុកចិត្តបាននៃឥណទានរបស់អ្នកខ្ចី។ ការវាយតម្លៃប្រវត្តិឥណទានពាក់ព័ន្ធនឹងការត្រួតពិនិត្យរបាយការណ៍របស់ ការិយាល័យឥណទានកម្ពុជា និងការសម្ភាសន៍អតិថិជនដើម្បីរកឱ្យឃើញថាតើពួកគាត់មានប្រាក់កម្ចី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬប្រាក់កម្ចីពីអ្នកចងការប្រាក់ឯកជនផ្សេងទៀតដែរឬទេ ដើម្បីអាចដាក់បញ្ចូលទៅក្នុង សំណើខ្ចីប្រាក់ និងដាក់ជូនសម្រាប់ការអនុម័ត ដើម្បីធានាថា ប្រវត្តិឥណទានរបស់អ្នកខ្ចីត្រូវបានវាយតម្លៃ និងផ្ទៀងផ្ទាត់បានត្រឹមត្រូវ មន្ត្រីឥណទានមិនត្រូវអនុវត្តសកម្មភាពដូចខាងក្រោមនេះ៖

- កុំបង្ហាញព័ត៌មានឥណទានរបស់អ្នកខ្ចី ដែលមិនបានបង្ហាញនៅក្នុងរបាយការណ៍ របស់ការិយាល័យឥណទានកម្ពុជា ទោះបីជាអ្នកខ្ចីមានប្រាក់កម្ចីជាមួយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបានប្រកាសត្រឹមត្រូវក៏ដោយ។ មន្ត្រីឥណទានអាចធ្វើបែបនេះដើម្បីបន្ថយការងារក្នុងការស្នើសុំកម្ចី ក៏ដូចជាកាត់បន្ថយកាតព្វកិច្ច ហិរញ្ញវត្ថុក្នុងការផ្តល់ប្រាក់កម្ចីក្នុងទំហំធំជាងនេះ។

- លាក់បាំងកម្ចីរបស់អ្នកខ្ចី ពីអ្នកចងការប្រាក់ឯកជន ដែលមិនបានបង្ហាញក្នុងរបាយការណ៍ ការិយាល័យឥណទានកម្ពុជា ទោះបីជាមន្រ្តីឥណទានបានដឹងអំពីរឿងនេះយ៉ាងច្បាស់ ក៏ដោយ។
- មានចេតនាប្រើប្រាស់ព័ត៌មានមិនពិត (ដូចជា លេខអត្តសញ្ញាណបណ្ណ ថ្ងៃខែឆ្នាំកំណើត) របស់អ្នកខ្ចីដើម្បីពិនិត្យផ្ទៀងផ្ទាត់ជាមួយ ការិយាល័យឥណទានកម្ពុជា ជាពិសេស សម្រាប់អ្នកខ្ចីដែលត្រូវប្រុងប្រយ័ត្នខ្ពស់ ឬមានកំណត់ត្រាឥណទានមិនល្អ។
- កែសម្រួលរបាយការណ៍នៃ ការិយាល័យឥណទានកម្ពុជា ដើម្បីក្លែងបន្លំកំណត់ត្រាឥណទានមិនល្អរបស់អ្នកខ្ចី។
- ពិនិត្យផ្ទៀងផ្ទាត់របាយការណ៍ ការិយាល័យឥណទានកម្ពុជា របស់អ្នកខ្ចី/អ្នកធានា និងបុគ្គលដែលពាក់ព័ន្ធដោយគ្មានការយល់ព្រមជាមុនពីអ្នកខ្ចី ហើយបង្ហាញកំណត់ត្រាឥណទានទាំងនេះទៅកាន់បុគ្គល/អង្គភាពដែលគ្មានការអនុញ្ញាត។
- មិនឱ្យអ្នកខ្ចីរួចផុតពីកិច្ចសន្យាប្រាក់កម្ចីនៅពេលដែលពួកគាត់មានសិទ្ធិទទួលបានស្របច្បាប់។ ឧទាហរណ៍ បុគ្គលដែលលែងលះគ្នានៅតែទទួលខុសត្រូវលើប្រាក់កម្ចី ទោះបីជាសាលក្រមរបស់តុលាការបានសម្រេចថា ប្រាក់កម្ចីនេះត្រូវបានប្រគល់ឱ្យប្តី ឬប្រពន្ធរបស់គាត់ក៏ដោយ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បដិសេធមិនធ្វើកិច្ចការនេះទេ ដោយសារតែពួកគេបារម្ភពីបញ្ហាសងបំណុល។ ប៉ុន្តែ ជាការខុសក្រមសីលធម៌ ឬអាចខុសច្បាប់ក្នុងការរារាំងបុគ្គលនោះក្នុងការអនុវត្តកាតព្វកិច្ចកិច្ចសន្យារបស់ខ្លួន។ ការធ្វើដូច្នេះ ធ្វើឱ្យប្រវត្តិឥណទានរបស់ពួកគេកាន់តែអាក្រក់ឡើង ជាពិសេស ប្រសិនបើប្រាក់កម្ចីរបស់អតីតប្តី ឬប្រពន្ធរបស់គាត់ប្រែទៅជា កម្ចីមិនដំណើរការ (NPL) ហើយនេះអាចកម្រិតលទ្ធភាពរបស់គាត់ក្នុងការខ្ចីប្រាក់កម្ចីផ្សេងទៀតនាពេលអនាគត។

**សំណួរឆ្លុះបញ្ចាំង ឃ១.៣.៤.**

វិបុលជាម្ចាស់សណ្ឋាគារមួយនៅក្នុងរាជធានីភ្នំពេញ បានស្នើសុំប្រាក់កម្ចីចំនួន១០០,០០០ ដុល្លារអាមេរិកនៅធនាគារថ្មមាក្វ ហើយបានបង្ហាញព័ត៌មានទាំងអស់ដែលត្រូវការសម្រាប់ការស្នើសុំឥណទានរបស់គាត់។ គាត់បានប្រាប់មន្ត្រីឥណទានថា គាត់មានប្រាក់កម្ចីនៅសម្បត្តិហ្វាយនែន ចំនួន៨០,០០០ ដុល្លារអាមេរិកសម្រាប់រយៈពេល ៣ ឆ្នាំរួចហើយ ហើយគាត់មានប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីសងត្រឡប់សម្រាប់កម្ចីទាំងពីរបាន។ នៅពេលដែលមន្ត្រីឥណទានពិនិត្យផ្ទៀងផ្ទាត់ជាមួយរបាយការណ៍ របស់ការិយាល័យឥណទានកម្ពុជា របស់វិបុល គេបានរកឃើញថា មានតែកំណត់ត្រាសាកសួរព័ត៌មានប៉ុណ្ណោះ ប៉ុន្តែមិនមានកំណត់ត្រាខ្ចីប្រាក់នៅ សម្បត្តិ

ហ្វាយនែន នៅឡើយនោះទេ។ ដោយមើលឃើញថា សមត្ថភាពសងបំណុលរបស់វិបុល មិនច្បាស់លាស់ ហើយបារម្ភថា អ្នកវិភាគឥណទាននឹងកាត់ប្រាក់ចំណូលដោយសារឧស្សាហកម្មដែលមានហានិភ័យខ្ពស់ (ក្នុងកំឡុងពេលមានជំងឺកូវីដ-១៩) ផងនោះ មន្ត្រីឥណទានរូបនេះបានសម្រេចចិត្តលុបចោលព័ត៌មានប្រាក់កម្ចីដែលមានស្រាប់ក្នុងសំណើឥណទានដើម្បីឱ្យប្រាកដថាវិបុល អាចទទួលបានការអនុម័តផ្តល់ប្រាក់កម្ចី។ តើទង្វើរបស់មន្ត្រីឥណទានរូបនេះចាត់ទុកថាមានក្រមសីលធម៌ដោយសារតែគាត់បានជួយអតិថិជនរបស់ខ្លួនដែរឬទេ?

**ឃ១.៣.៥. ប្រាតិភោគសម្រាប់ធានាប្រាក់កម្ចី** (Loan Security)

ប្រាតិភោគសម្រាប់ធានាប្រាក់កម្ចី គឺជាប្រភពទីពីរនៃការទូទាត់សង ដែលរួមបញ្ចូលនូវការធានា និងវត្ថុធានា។ ដោយសារតែវាជាកត្តាដ៏សំខាន់បំផុតក្នុងការវាយតម្លៃឥណទាន គួរយកចិត្តទុកដាក់ចំពោះ បញ្ជីសកម្មភាពដែលមិនអាចទទួលយកបានក្នុងការវាយតម្លៃប្រាតិភោគសម្រាប់ធានាប្រាក់កម្ចី។

- **ទាមទារវត្ថុធានាច្រើនពេក ទោះបីវត្ថុធានាមួយគ្រប់គ្រាន់ក៏ដោយ។** មន្ត្រីឥណទានធ្វើដូច្នេះដើម្បីកាត់បន្ថយហានិភ័យឥណទាននៅក្នុងករណីមានការខកខានបង់ប្រាក់កម្ចី និងដើម្បីដាក់សម្ពាធលើអតិថិជនឱ្យបង់ប្រាក់។ បើមិនដូច្នេះទេ ទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុធានាទាំងអស់នឹងត្រូវយកមកទូទាត់បំណុល។ ដូចគ្នានេះដែរ មន្ត្រីឥណទានស្នើសុំវត្ថុធានាឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដើម្បីទប់ស្កាត់អតិថិជនមិនឱ្យទទួលបានប្រាក់កម្ចីថ្មីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងទៀត។
- **វាយតម្លៃលើសពីតម្លៃវត្ថុធានា** ការធ្វើដូចនេះគឺដើម្បីបំពេញតាមលក្ខខណ្ឌត្រួតពិនិត្យ និងអនុម័តឥណទាន ហើយអាចអនុវត្តតាមរយៈវិធីសាស្ត្រទូទៅពីរយ៉ាងគឺៈ (១) មន្ត្រីឥណទានខ្លួនឯងបង្ហាញលើសពីតម្លៃនៃអចលនទ្រព្យ ដោយសារតែ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុញ្ញាតឱ្យពួកគេធ្វើការវាយតម្លៃវត្ថុធានាបាន និង (២) មន្ត្រីឥណទានមានចេតនាជ្រើសរើសអ្នកវាយតម្លៃអចលនទ្រព្យដែលផ្តល់តម្លៃវត្ថុធានាខ្ពស់ដោយមិនសមហេតុផល ឬជូនកាលថែមទាំងឃុបឃិតជាមួយអ្នកវាយតម្លៃទាំងនោះឱ្យវាយតម្លៃលើសពីតម្លៃវត្ថុធានា។
- **ស្នើសុំក្រុមជនងាយរងគ្រោះឱ្យធ្វើជាអ្នកធានា** ដូចជា ពលរដ្ឋវ័យចំណាស់ (អាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ) អនីតិជន ជនដែលមានប្រាក់ចំណូលទាបមិនសមាមាត្រ មនុស្សមានសតិគ្រប់ជាដើម ។ល។ ហើយករណីខ្លះ អ្នកធានាអ្នកខ្លះថែមទាំងត្រូវបានបង្ខំឱ្យធ្វើជា អ្នកធានាទៀតផង។ បើមិនដូច្នោះទេ ពួកគេមិនអាចទទួលបានប្រាក់កម្ចីនៅពេលអនាគតឡើយ។

➢ **កែប្រែរចនាសម្ព័ន្ធអ្នកខ្ចី/អ្នកធានា** ដោយដឹងថា អ្នកធានាគឺជាអ្នកខ្ចីប្រាក់ពិតប្រាកដ (de-facto borrowers) ចំណែកឯអ្នកខ្ចីគឺជាអ្នកធានាពិតប្រាកដ (de-facto guarantors) ដែរនោះករណីនេះកើតមានឡើង នៅពេលដែលអ្នកខ្ចីពិតប្រាកដមិនបំពេញលក្ខខណ្ឌត្រួតពិនិត្យ និងអនុម័តឥណទាន និងនៅពេលមានហានិភ័យឥណទានខ្ពស់។ រចនាសម្ព័ន្ធទំនាក់ទំនងត្រូវបានកែប្រែដើម្បីជំរុញឱ្យមានការអនុម័តនិងផ្ដល់ប្រាក់កម្ចី។

**សំណួរឆ្លុះបញ្ចាំង ឃ១.៣.៥.**

ជីវ៉ា គឺជាមន្ត្រីឥណទាននៅធនាគារ ថូម៉ាកូដែលបច្ចុប្បន្នកំពុងធ្វើពាក្យលើការស្នើសុំប្រាក់កម្ចីចំនួន ៥០០,០០០ដុល្លារអាមរិក។ លក្ខខណ្ឌវត្ថុធានារបស់ធនាគារតម្រូវឱ្យតម្លៃអចលនទ្រព្យមានយ៉ាងតិចមានចំនួន ១៥០% នៃកម្រិតអនុម័តប្រាក់កម្ចី។ ទន្ទឹមនឹងនេះ តម្លៃអចលនទ្រព្យដែលបង្ហាញដោយអ្នកវាយតម្លៃអចលនទ្រព្យមួយចំនួនបង្ហាញថា មានតម្លៃត្រឹមតែ៧០០,០០០ដុល្លារអាមេរិកប៉ុណ្ណោះ។ ពេលនោះជីវ៉ា បានទៅជួបមិត្តភក្តិរបស់គាត់ដែលធ្វើការនៅក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យផ្សេងទៀត ហើយបានបញ្ចុះបញ្ចូលមិត្តរបស់គាត់ឱ្យបញ្ជាក់ថា អចលនទ្រព្យនោះមានតម្លៃយ៉ាងហោចណាស់ ៧៥០,០០០ ដុល្លារអាមរិក។ គាត់បានសន្យាថានឹងប៉ាវអាហារពេលល្ងាចយ៉ាងពិសេសដល់មិត្តភក្តិរបស់គាត់ ប្រសិនបើការស្នើសុំកម្ចីនេះបានទទួលការអនុម័ត។ តើទង្វើរបស់ ជីវ៉ា ប្រកបដោយក្រមសីលធម៌ដែរឬទេ ព្រោះគាត់បានស្វែងរកតម្លៃដ៏ល្អបំផុតសម្រាប់អតិថិជនរបស់ខ្លួន?

## ឃ១.៤. ការអនុម័តឥណទាន

ការអនុម័តឥណទាន គឺជាគន្លឹះក្នុងការកាត់បន្ថយហានិភ័យឥណទានដែលអាចកើតមាន។ ដើម្បីធ្វើឱ្យដំណើរការកាន់តែរលូន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ភាគច្រើន កំណត់កម្រិតផ្សេងៗគ្នា សម្រាប់ការអនុម័តឥណទានស្របតាមលក្ខណៈវិនិច្ឆ័យជាក់លាក់របស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចជា ចំនួនទឹកប្រាក់ឥណទាន ប្រភេទអតិថិជន ប្រភេទផលិតផល និងចំណែកទីផ្សារជាដើម។ ប៉ុន្តែ ជាធម្មតាមន្ត្រីឥណទានមិនមានសិទ្ធិក្នុងការអនុម័តឥណទាននោះទេ។ ជាទូទៅដំណើរការអនុម័តឥណទាននេះអាចចាប់ផ្តើមពីអ្នកគ្រប់គ្រងឥណទានប្រចាំសាខា គណៈកម្មាធិការទទួលបន្ទុកអនុម័តឥណទាននៅសាខា អ្នកគ្រប់គ្រងប្រចាំតំបន់ ប្រធានផ្នែកប្រតិបត្តិការ ប្រធានផ្នែក/នាយកដ្ឋានឥណទាន គណៈកម្មាធិការទទួលបន្ទុកអនុម័តឥណទាន។ ជាការអនុវត្តល្អ សិទ្ធិអំណាចក្នុងការអនុម័តឥណទានមិនត្រូវប្រគល់ជូនផ្នែកលក់ផ្តាច់មុខនោះទេ។ យកល្អ គួរមាន

គណៈកម្មាធិការអនុម័តឥណទានប្រចាំសាខា ឬចាត់តាំងមុខងារឯករាជ្យ ដូចជា ប្រធានផ្នែកត្រួតពិនិត្យ និងអនុម័តឥណទានប្រចាំសាខា ដែលមានថ្នាក់លើខុសពីប្រធាន សាខាដើម្បីធ្វើការអនុម័តឥណទាន។

ការបញ្ជូនពាក្យស្នើសុំឥណទានទាំងអស់ទៅគណៈកម្មាធិការអនុម័តឥណទាន គឺនៅមិនគ្រប់គ្រាន់នោះទេ។ មន្ត្រីឥណទាន ប្រធានផ្នែកឥណទាន ឬប្រធានសាខាសាមី គួរមានសិទ្ធិសម្រេចបដិសេធទៅលើពាក្យស្នើសុំឥណទាន ប្រសិនបើពាក្យស្នើសុំកម្ចីនោះមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានចែង ដូចជា ប្រវត្តិឥណទានមិនល្អ ចំណូលសុទ្ធមិនគ្រប់គ្រាន់ ទ្រព្យធានាមិនគ្រប់គ្រាន់ ឬខ្វះ ឬអាជីវកម្មស្ថិតនៅក្នុងវិស័យមានហានិភ័យខ្ពស់ ជាដើម។ ដូច្នេះហើយ មន្ត្រីឥណទានមានតួនាទីផ្តល់អនុសាសន៍សម្រាប់ជម្រើសបដិសេធ ឬអនុម័តទៅលើពាក្យស្នើសុំឥណទាន។

ដើម្បីចៀសវាងកុំឱ្យបាត់បង់អតិថិជនមានសក្តានុពល ឬកាត់បន្ថយអត្រាបាត់បង់អតិថិជន ឬដើម្បីផ្តល់ភាពបត់បែនសម្រាប់ប្រតិបត្តិការនៅកម្រិតសាខា និងសម្រេចគោលដៅផ្តល់ឥណទានបុគ្គលិកប្រចាំសាខា អាចប្រព្រឹត្តសកម្មភាពដែលគ្មានក្រមសីលធម៌ហើយដាច់ខាតត្រូវចៀសវាងគ្រប់ពេលវេលា ដូចខាងក្រោម៖

- បន្ថយចំនួនទឹកប្រាក់ឥណទានឱ្យនៅក្រោមចំនួនទឹកប្រាក់ដែលខ្លួនមានសិទ្ធិអនុម័ត។
- បំបែកឥណទានទៅជាពាក្យស្នើសុំឥណទានច្រើនដើម្បីមិនចាំបាច់ដាក់ជូនថ្នាក់លើអនុម័ត។ ចំពោះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មួយចំនួន ការអនុម័តឥណទានគឺផ្អែកទៅលើកម្រិតកំណត់គួបបញ្ចូលគ្នា ពោលគឺ មិនមែនផ្អែកទៅលើគណនីឥណទានដាច់ដោយឡែកពីគ្នានោះទេ។

## ឃ១.៥. គ្រប់គ្រងឯកសារឥណទាន

ការគ្រប់គ្រងឯកសារឥណទាន គឺផ្តោតជាចម្បងលើការធ្វើឱ្យទៅជាផ្លូវការនូវសិទ្ធិ និងកាតព្វកិច្ចក្រោមកិច្ចសន្យារវាងអតិថិជនក្នុងនាមជាអ្នកខ្ចី និង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងនាមជាអ្នកផ្តល់កម្ចី។

ខ្លឹមសារ ឬរចនាសម្ព័ន្ធនៃឯកសារឥណទានមានភាពខុសគ្នាពីគ្រឹះស្ថានមួយទៅស្ថាប័នមួយ។ ទោះជាយ៉ាងនេះក្តី ឯកសារឥណទាន ភាគច្រើនមានលក្ខខណ្ឌឥណទានសំខាន់ៗ ដូចជា អ្នក

ជាប់កាតព្វកិច្ច កម្រិតកំណត់/ទំហំ អត្រាការប្រាក់ រយៈពេល វិធីសាស្រ្តទូទាត់ កម្រៃ/ថ្លៃសេវា ប្រាតិភោគ/ទ្រព្យធានា ជាដើម។

ជាទូទៅ លក្ខខណ្ឌឥណទានរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗ មានចំណុចខុសគ្នាខ្លះពីលក្ខខណ្ឌដែលស្នើសុំដោយអតិថិជន។ ជារឿយៗ អតិថិជនមានការភាន់ច្រឡំរវាងរយៈពេលកិច្ចសន្យាដែលអនុវត្តនៅក្នុងឯកសារឥណទាន និងការសន្យាការលក់ ដែលមិនមានពាក់ព័ន្ធនឹងកិច្ចសន្យានោះឡើយ។ ដូច្នេះ អតិថិជនគួរទទួលបានព័ត៌មានត្រឹមត្រូវអំពីភាពខុសគ្នានេះដើម្បីយល់ដឹងច្បាស់លាស់តាមរយៈការបង្ហាញព័ត៌មាន។[92]

- **ផ្តល់សេចក្តីថ្លែងអង្គហេតុសំខាន់ៗ៖** សេចក្តីថ្លែងនេះ គឺជាសេចក្តីសង្ខេបអំពីព័ត៌មានសំខាន់ៗ ដែលអានងាយយល់ ដែលយកល្អ មិនត្រូវលើសពីពីរទំព័រឡើយ។
- **ទុកពេលឱ្យអតិថិជនមើលខចែង និងលក្ខខណ្ឌ៖** មិនត្រូវស្នើសុំឱ្យអតិថិជនចុះហត្ថលេខាលើឯកសារណាមួយដោយមិនបានអានឯកសារទាំងលម្អិតនោះទេ។ ដូច្នេះ ត្រូវទុកពេលគ្រប់គ្រាន់ឱ្យអតិថិជនអានខចែង និងលក្ខខណ្ឌនានា។
- **គូសបង្ហាញអំពីខចែង និងលក្ខខណ្ឌសំខាន់ៗ៖** ដោយសារតែឯកសារមានច្រើនទំព័រ អតិថិជនងាយនឹងរំលង ឬមិនបានមើលខចែង និងលក្ខខណ្ឌសំខាន់ៗបានល្អិតល្អន់។ បុគ្គលិករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែបង្ហាញពីខចែង និងលក្ខខណ្ឌសំខាន់ៗទាំងនេះដោយផ្ទាល់មាត់ និងការគូសចំណាំនៅលើឯកសារជាក់ស្តែង។
- **លើកឡើងអំពីក្តីបារម្ភទូទៅ៖** មន្ត្រីឥណទាន គួរដឹងអំពីក្តីបារម្ភទូទៅក្នុងចំណោមអ្នកខ្ចីយោងតាមបទពិសោធកន្លងមក រួមទាំងកម្រៃសម្រាប់ការសងផ្តាច់មុនកាលកំណត់ និងដំណើរការដកយកទ្រព្យធានាបន្ទាប់ពីការទូទាត់ផ្តាច់។ ក្តីបារម្ភទាំងនេះ គួរបញ្ជាក់ប្រាប់អតិថិជនដើម្បីឱ្យគូភាគីមានការរំពឹងទុកដូចគ្នា។
- **បំពេញពាក្យស្នើសុំមុនពេលស្នើអតិថិជនចុះហត្ថលេខា៖** តាមស្មារតីផ្លូវច្បាប់ មិនត្រូវស្នើឱ្យអតិថិជនចុះហត្ថលេខាលើពាក្យស្នើសុំដែលមិនទាន់បានបំពេញ ដែលអាចបំពេញព័ត៌មាននៅពេលក្រោយនោះទេ ដែលអាចខុសគ្នាពីព័ត៌មានដែលបានព្រមព្រៀងគ្នាជាមួយអតិថិជន។
- **ផ្តល់បណ្តាញព័ត៌មានដែលអាចចូលប្រើប្រាស់បាន៖** ព័ត៌មានទាំងឡាយដែលចាំបាច់ឱ្យអតិថិជនយល់ ត្រូវមានអក្សរធំល្មមដែលអតិថិជនងាយស្រួលអាន។ ព័ត៌មានទាំងនេះមិនត្រូវមានទំហំតូចពេកនៅពេលអានតាមអេក្រង់ទូរសព្ទនោះទេ។

[92] (World Bank, 2017)

- **ផ្តល់សំណៅឯកសារសម្រាប់អតិថិជន៖** ជានិច្ចកាល ឯកសារដែលបានចុះហត្ថលេខានានាត្រូវប្រគល់ជូនអតិថិជនទុកជាឯកសារយោងនាពេលអនាគត។ ប្រសិនបើមិនអាចឱ្យឯកសារច្បាប់ដើមបានទេ គួរតែផ្តល់ឯកសារថតចម្លង។

**ឧទាហរណ៍៖** ជារឿយៗ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធ្វើឱ្យអតិថិជនមានការលំបាកក្នុងការធ្វើបុនហិរញ្ញប្បទាន (refinance) បំណុលរបស់ពួកគាត់ដើម្បីទទួលបានលក្ខខណ្ឌល្អប្រសើរជាងមុន ជាពិសេសតាមរយៈការពន្យារពេលប្រគល់ប្លង់រឹងទ្រព្យធានា ដែលបានដាក់តម្កល់ ទោះបីជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពុំមានសិទ្ធិអនុវត្តដូច្នេះនៅក្នុងឯកសារឥណទានក៏ដោយ ក៏គួរមាននីតិវិធីច្បាស់លាស់ដែលមានចែងនៅក្នុងកិច្ចសន្យា និងបញ្ជាក់ប្រាប់ឱ្យអតិថិជនបានដឹង។ ប្រសិនបើការដកទ្រព្យធានាតម្រូវឱ្យមានការជូនដំណឹងរយៈពេលបីសប្តាហ៍មុនពេលសងផ្តាច់មុនកាលកំណត់ នោះព័ត៌មាននេះត្រូវប្រាប់ទៅកាន់អ្នកខ្ចី ឬចែងនៅក្នុងកិច្ចសន្យា។

**សំណួរឆ្លុះបញ្ចាំង ឃ១.៥**

សុខចង់ធ្វើបុនហិរញ្ញប្បទាន (refinance) ឥណទានរបស់គាត់ពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយទៀតសម្រាប់ទឹកប្រាក់ចំនួន១០០,០០០ដុល្លារ។ មន្ត្រីឥណទានរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះដឹងថាសុខនឹងមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ទឹកប្រាក់១០០,០០០ដុល្លារ នោះទេ ដោយផ្អែកលើការវាយតម្លៃឥណទានបឋម។ ប៉ុន្តែ មន្ត្រីឥណទាននោះសន្យាចំពោះ សុខ ថាគាត់នឹងទទួលបានទឹកប្រាក់បន្ថែមចំនួន៤០,០០០ដុល្លារ ទៀតនៅពេលក្រោយបន្ទាប់ពីប្រើប្រាស់កម្រិតឥណទានដំបូង ៦០,០០០ដុល្លារ។ *តើចំណុចនេះសមស្របឬទេ?*

### ឯកជនភាពទិន្នន័យរបស់អតិថិជន

នៅក្នុងអំឡុងពេលទទួលយកអ្នកខ្ចី បុគ្គលិកគួរប្រាកដថាទិន្នន័យសម្ងាត់របស់អតិថិជនត្រូវបានការពារតាមរយៈចំណុចខាងក្រោម៖[93]

- រក្សាព័ត៌មានទាំងអស់អំពីអ្នកខ្ចីជាការសម្ងាត់។

[93] (The Assocation of Banks in Cambodia; Cambodian Microfinance Association; & Cambodian Association Finance & Technology, 2022)

- ជូនដំណឹងដល់អ្នកខ្ចីអំពីមូលហេតុប្រមូលទិន្នន័យរបស់ពួកគាត់ គោលបំណងនៃការប្រមូល និងរបៀបដែលព័ត៌មានរបស់គាត់នឹងត្រូវប្រើប្រាស់ និងចែករំលែកជាមួយភាគីខាងក្រៅ។
- ជម្រាបដល់អ្នកខ្ចីថាព័ត៌មាននៅក្នុងពាក្យស្នើសុំឥណទាន នឹងត្រូវបានប្រើប្រាស់ស្របតាមច្បាប់ រួមមានការដាក់បញ្ចូលក្នុងរបាយការណ៍នៃ ការិយាល័យឥណទានកម្ពុជា និងនៅក្នុងសេចក្ដីសម្រេចរបស់តុលាការ ព្រមទាំងនៅក្នុងការចែករំលែកជាមួយនឹងអង្គភាព/ទីភ្នាក់ងារធានាក្នុងករណីដែលឥណទាននោះ គឺស្ថិតក្រោមការធានា។ ការជម្រាបជូននេះត្រូវធ្វើឡើងដោយផ្ទាល់មាត់នៅក្នុងអំឡុងពេលបំពេញពាក្យស្នើសុំ ហើយអ្នកខ្ចីត្រូវផ្ដល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរ។
- ប្រកាសអំពី "ឯកជនភាព និងព័ត៌មានសម្ងាត់" ត្រូវមានចែងនៅក្នុងពាក្យស្នើសុំឥណទានទាំងអស់។
- ជូនដំណឹង និងផ្ដល់ការណែនាំដល់អ្នកខ្ចីអំពីសិទ្ធិទទួលបានឯកជនភាពទិន្នន័យរបស់ពួកគាត់។

## ឃ១.៦. ការរាយការណ៍ជូនការិយាល័យឥណទានកម្ពុជា (CBC)

ការរាយការណ៍ជូនការិយាល័យឥណទានកម្ពុជា គឺជាលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ ដែលបានចេញដោយ ធនាគារជាតិនៃកម្ពុជា ។ ដូច្នេះហើយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវផ្ដល់ទិន្នន័យត្រឹមត្រូវ និងទាន់ពេលវេលា ប៉ុន្តែ ត្រូវស្នើសុំការអនុញ្ញាតជាមុនពីអតិថិជនមុនពេលរាយការណ៍។

### ឃ១.៦.១. ការរាយការណ៍ព័ត៌មានឥណទានអវិជ្ជមាន

ការរាយការណ៍ ទៅកាន់ ការិយាល័យឥណទានកម្ពុជា ជាពិសេស អំពីព័ត៌មានឥណទានអវិជ្ជមាន មានឥទ្ធិពលជាខ្លាំងទៅលើសមត្ថភាពទូទាត់សងរបស់អតិថិជនដែលបានរាយការណ៍ ដែលអាចប៉ះពាល់សមត្ថភាពរបស់ពួកគាត់ក្នុងការទទួលបានឥណទាននៅអត្រាទីផ្សារធម្មតា។

ព័ត៌មានឥណទានមិនល្អ ឬអវិជ្ជមានសំខាន់ៗរួមមាន៖

(i) ឥណទានមិនដំណើរការ (NPL)

(ii) ការលុបចោលឥណទាន

(iii) ឥណទានរៀបចំឡើងវិញ

(iv) ការទូទាត់សងប្រចាំខែយឺត

ព័ត៌មានឥណទានអវិជ្ជមានខាងលើនេះ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់ពិន្ទុសរុបនៃនៃអ្នកខ្ចីក្នុងរបាយការណ៍របស់ការិយាល័យឥណទានកម្ពុជា។ ជាទូទៅ បុគ្គលដែលមានពិន្ទុទាប ឬពាក់ព័ន្ធជាមួយព័ត៌មានឥណទានអវិជ្ជមាន អាចមានការលំបាកនៅក្នុងការទទួលបានឥណទានពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ដូច្នេះ គ្រឹះស្ថានទាំងអស់ គួរយកចិត្តទុកដាក់ឱ្យខ្លាំងទៅលើរបាយការណ៍នេះដូចខាងក្រោម។

- បុគ្គលដែលមិនមានកាតព្វកិច្ចឥណទាន ឧទាហរណ៍ ជាសាក្សីនៃកិច្ចសន្យាឥណទាន មិនចាំបាច់ត្រូវរាយការណ៍ជូនការិយាល័យឥណទានកម្ពុជាឡើយ។
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានយន្តការធានាថាខ្លឹមសារនៃរបាយការណ៍របស់ការិយាល័យឥណទានកម្ពុជា មានភាពសុក្រឹត។ មានតែអ្នកជាប់កាតព្វកិច្ចហិរញ្ញវត្ថុចំពោះកិច្ចសន្យាឥណទានដែលផ្តល់ការអនុញ្ញាតជាមុនប៉ុណ្ណោះ ដែលត្រូវរាយការណ៍។

**ឧទាហរណ៍៖** ចាន់ យល់ថាគាត់ត្រូវធ្វើជាសាក្សីនៃកិច្ចសន្យាឥណទានឱ្យបងប្រុសរបស់គាត់សុខ ដែលជាអ្នកខ្ចីកម្ចីចំនួន ១០,០០០ ដុល្លារអាមេរិក ប៉ុន្តែនៅក្នុងឯកសារជាក់ស្តែង គាត់បានភាន់ច្រឡំថាគាត់គឺជាអ្នកធានាទៅវិញ។ ការធ្វើបែបនេះគឺគ្មានក្រមសីលធម៌ និងមានផលប៉ះពាល់ផ្លូវច្បាប់សម្រាប់មន្ត្រីឥណទានផងដែរ។ ដូច្នេះ ចាន់ ក៏ត្រូវដាក់ក្នុងរបាយរាយការណ៍ជូនការិយាល័យឥណទានកម្ពុជា ដែរ។

## ឃ១.៦.២.សិទ្ធិក្នុងការកែតម្រូវ

បុគ្គលដែលព័ត៌មានឥណទានរបស់ខ្លួនត្រូវបានរាយការណ៍ជូន ការិយាល័យឥណទានកម្ពុជា មិនសុក្រឹត មានសិទ្ធិស្នើសុំធ្វើការកែតម្រូវ។ ជាទូទៅ បុគ្គលដែលរាយការណ៍ ដឹងអំពីការរាយការណ៍នេះតាមរយៈ៖

(i) ទំនាក់ទំនងឥណទានថ្មីជាមួយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មួយទៀតដែលទាមទាររបាយការណ៍ពី ការិយាល័យឥណទានកម្ពុជា ឬ

(ii) ការដាក់ពាក្យសុំដោយខ្លួនឯងផ្ទាល់នៅការិយាល័យឥណទានកម្ពុជា៖ បច្ចុប្បន្ននេះ ការិយាល័យឥណទានកម្ពុជាផ្តល់របាយការណ៍ឥតគិតថ្លៃដែលមានចំណងជើងថា "របាយការណ៍សុខភាពផ្ទាល់ខ្លួន" ក្នុងមួយឆ្នាំតាមរយៈកម្មវិធីទូរសព្ទដៃ និងគ្រឹះស្ថានដៃគូផ្សេងទៀត។

មន្ត្រីឥណទាន ត្រូវជម្រាបអ្នកខ្ចីអំពីដំណើរការទទួលរបាយការណ៍ពី ការិយាល័យឥណទានកម្ពុជា និងសិទ្ធិរបស់ពួកគាត់ក្នុងការកែតម្រូវ។

> **សំណួរឆ្លុះបញ្ចាំង ឃ១. ៦**
>
> ម្ចាស់អាជីវកម្មបានធានាឥណទានរបស់បុគ្គលិករបស់គាត់ជាមួយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយស្ថានភាពរបស់គាត់ក្នុងនាមជាអ្នកធានា គឺត្រូវបានរាយការណ៍ជូនការិយាល័យឥណទានកម្ពុជា។ ក្រោយមក បុគ្គលិករបស់គាត់មិនបានសងឥណទាន ដោយមានស្ថានភាពឥណទានបច្ចុប្បន្ននៅក្នុង ការិយាល័យឥណទានកម្ពុជា "WOFF" ស្មើនឹងការលុបចោលឥណទាន។ បន្ទាប់ពីដឹងអំពីរឿងនេះ ម្ចាស់អាជីវកម្មបានស្ម័គ្រចិត្តទូទាត់សងឥណទានជំនួសឱ្យបុគ្គលិករបស់គាត់។
>
> **ក)** តើករណីនេះសមស្របសម្រាប់ម្ចាស់អាជីវកម្មក្នុងការប្រគល់អាណត្តិដល់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ការណែនាំឱ្យការិយាល័យឥណទានកម្ពុជាលុបស្ថានភាព "WOFF" ពីឥណទានបានដែរឬទេ?
>
> **ខ)** តើម្ចាស់អាជីវកម្មដែលពាក់ព័ន្ធជាមួយនឹងស្ថានភាព "WOFF" នៅក្នុងការិយាល័យឥណទានកម្ពុជាដូចដែលបានរៀបរាប់ខាងលើត្រូវទទួលបានឥណទាននៅពេលអនាគតឬទេ?

## ឃ២. តាមដានផលបត្រឥណទាន (Credit Portfolio) ដោយក្រមសីលធម៌

ទោះបីជាការផ្តល់ឥណទានដើម្បីផ្តល់ឥទ្ធិពលវិជ្ជមានដល់គ្រួសារ និងអាជីវកម្មរបស់អតិថិជនក៏ដោយ វាក៏អាចក្លាយជាឥទ្ធិពលអវិជ្ជមានវិញផងដែរ ប្រសិនបើការផ្តល់ឥណទានមិនបានធ្វើឡើងដោយប្រុងប្រយ័ត្ន និងមិនមានការតាមដានត្រួតពិនិត្យផលបត្រឥណទានត្រឹមត្រូវទេនោះ។

ការតាមដានផលបត្រឥណទាន គឺជាផ្នែកមួយនៃការគ្រប់គ្រងហានិភ័យឥណទានដើម្បីធានាបាននូវគុណភាពផលបត្រឥណទានល្អ។ ក្របខណ្ឌនេះរួមមានសកម្មភាពតាមដានត្រួតពិនិត្យក្នុងគោលបំណង ធ្វើសុពលកម្ម និងលើកកម្ពស់ការអនុវត្តន៍កាតព្វកិច្ចឥណទានរបស់អតិថិជន ដោយរួមបញ្ចូលទាំងការប្រើប្រាស់ឥណទាន ការអនុវត្តន៍តាមលក្ខខណ្ឌឥណទាន និងការទូទាត់ឥណទាន។ ការមានការតាមដានផលបត្រឥណទានប្រកបដោយប្រសិទ្ធភាព អាចឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កំណត់បានទាន់ពេលវេលានូវហានិភ័យដែលអាចកើតឡើង អាចកំណត់បាននូវទំហំហា

និភ័យ និងចាត់វិធានការដោះស្រាយចាំបាច់ដើម្បីគ្រប់គ្រងហានិភ័យទាំងនោះបានទាន់ពេលវេលា ដើម្បីកាត់បន្ថយការខាតបង់ឥណទាន។ កិច្ចការនេះ មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប៉ុណ្ណោះទេ តែថែមទាំងផ្តល់អត្ថប្រយោជន៍ដល់ភាគីពាក់ព័ន្ធផ្សេងទៀត និងរួមចំណែករក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុទាំងមូលទៀតផង។

- **ចំពោះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងភាគទុនិក៖** តាមរយៈការរកឃើញបញ្ហាទាន់ពេលវេលា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចមានដំណោះស្រាយជាច្រើន ដែលអាចដំណើរការដោយការសហការជាមួយអតិថិជនដើម្បីទប់ស្កាត់ការខាតបង់។ ក្នុងករណី ឥណទាន បានខូចផុតទៅហើយ នោះស្ថាប័ននឹងមិនមានជម្រើសច្រើនឡើងហើយដំណោះស្រាយក្នុងការប្រមូលស្តារការខាតបង់ ភាគច្រើនគឺជាការលក់ឡាយឡុងទ្រព្យធានាទៅវិញ។ ចំណុចនេះអាចជាដំណើរការ ដ៏ពិបាក និងត្រូវចំណាយពេលវេលាច្រើនសម្រាប់ទាំង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអ្នកខ្ចី ហើយវាអាចមានឥទ្ធិពលអវិជ្ជមានដល់កេរ្តិ៍ឈ្មោះទៀតផង ប្រសិនបើធ្វើឡើងមិនបានត្រឹមត្រូវទេនោះ។ ប្រសិនបើមានការតាមដានត្រឹមត្រូវ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចកំណត់ទំហំហានិភ័យលើផលបត្រឥណទានរបស់ខ្លួន និងបម្រុងទុកនូវប្រាក់បម្រុងមូលធនដើម្បីគ្របដណ្តប់លើហានិភ័យដោយផ្អែកលើ លក្ខខណ្ឌតម្រូវតាមបទប្បញ្ញត្តិដែលធ្វើយ៉ាងណាធានាថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនធ្លាក់ចូលទៅក្នុងសម្ពាធហិរញ្ញវត្ថុនៅពេលដែលខាត។
- **ចំពោះអ្នកខ្ចី៖** តាមរយៈការតាមដានឥណទានត្រឹមត្រូវ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចទប់ស្កាត់ឥណទានពីការខកខានសងបាន ដែលការខកខានមិនបានសងនេះនឹងបង្កការខូចខាតដល់សាវតាឥណទានរបស់អ្នកខ្ចី។ ការខូចខាតនេះនឹងបន្ទាបលទ្ធភាពរបស់អ្នកខ្ចីក្នុងការទទួលបានឥណទានពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលជាប្រភពទុនមានតម្លៃទាបនាពេលអនាគត។

**ការតាមដានផលបត្រឥណទាន មានពីរកម្រិត ដូចជា កម្រិតបុគ្គល និងកម្រិតស្ថាប័ន៖**

- **កម្រិតអ្នកខ្ចីជាបុគ្គល៖** ការតាមដានចាប់ផ្តើមពីការបញ្ចេញឥណទានរហូតដល់ឥណទានត្រូវបានទូទាត់សងគ្រប់ចំនួន។ នៅក្នុងអំឡុងពេលនេះ មន្ត្រីឥណទានមានការទទួលខុសត្រូវតាមដានសាវតាហានិភ័យឥណទានរបស់អ្នកខ្ចីម្នាក់ៗ ដោយមានគោលបំណងស្វែងរកឱ្យឃើញជាមុននូវសញ្ញាព្រមានណាមួយនៃភាពមិនប្រក្រតីនៃស្ថានភាពឥណទាន និងដាក់ចេញនូវវិធានការដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតឡើង។ សកម្មភាពនឹងរួមបញ្ចូល

ការតាមដានស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី និងសមត្ថភាពរបស់ពួកគាត់ក្នុងការបំពេញតាមកាតព្វកិច្ចបង់សងឥណទានមកវិញ។ ដើម្បីអនុវត្តបែបនេះបាន មន្ត្រីឥណទាន ត្រូវមានព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើការវិភាគ និងរាយការណ៍ផលប៉ះពាល់ដែលអាចកើតមានណាមួយទៅលើអាជីវកម្ម ដែលអាចកើតចេញពីកត្តាជាច្រើនដូចជា ការផ្លាស់ប្តូរគណៈគ្រប់គ្រង លទ្ធផលអាជីវកម្ម លទ្ធផលហិរញ្ញវត្ថុ ស្ថានភាពសេដ្ឋកិច្ច បរិយាកាសនយោបាយ និងការប្រកួតប្រជែងនៅក្នុងវិស័យ។

- **កម្រិតស្ថាប័ន៖** ការតាមដាននេះជួយឱ្យគណៈគ្រប់គ្រងបានដឹងពីទិដ្ឋភាពរួមអំពីគុណភាពទាំងមូលនៃបញ្ជីឥណទាន រួមទាំងហានិភ័យប័ត្រឥណទានប្រមូលផ្តុំ និងហានិភ័យនៃការខកខានទូទាត់សង។ ផ្នែកទទួលបន្ទុក ចំពោះការចាត់ក្រុមផលបត្រឥណទាន។ ការចាត់ក្រុមផលបត្រឥណទាននេះត្រូវផ្អែកលើលក្ខណៈស្រដៀងគ្នា ដូចជា ផលបត្រឥណទានតាមផលិតផលឥណទាន វិធីសាស្ត្រ/ រយៈពេល/ ចំនួនទឹកប្រាក់/ វិស័យ/ តំបន់ភូមិសាស្ត្រ/ ឬតាមចំនួនថ្ងៃហួសកាលកំណត់សង។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមដានផលបត្រឥណទានជាទៀងទាត់ដើម្បីធ្វើបច្ចុប្បន្នភាពបម្រែបម្រួលរបស់ផលបត្រឥណទានទាំងនោះពីពេលមួយទៅពេលមួយ និងអនុវត្តវិធីសាស្ត្រសមស្របដើម្បីធានាថា ហានិភ័យផលបត្រឥណទានស្ថិតនៅក្នុងកម្រិតដែលអនុញ្ញាតទទួលយកបាន។

ទោះបីជាមានក្របខណ្ឌតាមដានក៏ដោយ ក៏ការតាមដានផលបត្រឥណទានមិនបានត្រឹមត្រូវអាចជះឥទ្ធិពលលើការសម្រេចចិត្តរបស់គណៈគ្រប់គ្រងជាន់ខ្ពស់ ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុន ដោយសារតែមិនមានព័ត៌មានគ្រប់គ្រាន់ និងអាចទុកចិត្តបានដើម្បីសម្រេចចិត្តឱ្យបានត្រឹមត្រូវ។ ជាចុងក្រោយ វានឹងជះឥទ្ធិពលដល់ការជឿទុកចិត្តរបស់អតិថិជន និងវិនិយោគិនទៅលើប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។ ឧទាហរណ៍សំខាន់ៗខ្លះអំពីការអនុវត្តមិនបានត្រឹមត្រូវ រួមមាន៖

- **ការបង្ហាញព័ត៌មានអំពីហានិភ័យ៖** គណៈគ្រប់គ្រងមិនអើពើចំពោះហានិភ័យដែលអាចកើតឡើងចំពោះកំណើនរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬនៅពេលដែល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានចុះបញ្ជីការបោះផ្សាយមូលបត្រជាសាធារណៈ លើកដំបូង (IPO)។ គណៈគ្រប់គ្រងជាន់ខ្ពស់មានការព្រួយបារម្ភថា ព័ត៌មានអំពីហានិភ័យនេះ នឹងអាចជះឥទ្ធិពលដល់តម្លៃភាគហ៊ុន។
- **ការសិក្សាវាយតម្លៃ៖** មន្ត្រីឥណទានមានការមមាញឹកច្រើន និងមិនបានចុះទៅទីតាំងផ្ទាល់ដើម្បីពិនិត្យមើលតថភាពជាក់ស្តែងនោះទេ ផ្ទុយមកវិញ បានសម្រេច ចិត្តអនុវត្តការតាមដានតាមរយៈការហៅទូរសព្ទ ឬមិនអនុវត្តការតាមដានទាល់តែសោះ។ បញ្ហានេះក៏អាច

កើតឡើងដែរ នៅពេលមន្ត្រីឥណទានមិនអនុវត្តតាមគោលនយោបាយតាមដានឥណទាន ដោយសារតែការអនុវត្តន៍គោលនយោបាយនេះត្រូវចំណាយពេលវេលាច្រើន ហើយបង្អាក់ទឹកចិត្ត អ្នកខ្ចីសំខាន់ៗ និងអ្នកខ្ចីធំៗ។

- **ការលើកទឹកចិត្ត៖** មន្ត្រីឥណទាន មិនចង់ធ្វើឱ្យដំណើរការតាមដានស្មុគស្មាញនោះទេ ដោយសារតែការអនុវត្តរបស់សហការីរួមវិស័យមកពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងទៀត ដែលបង្កើនឱកាសធ្វើបុនហិរញ្ញប្បទាន (refinancing) ទៅកាន់ គ្រឹះស្ថាន ផ្សេងទៀត។ មន្ត្រីឥណទានបន្ថែម ឬបន្ថយព័ត៌មាននៅក្នុងទម្រង់តាមដានផលបត្រឥណទាន ក្នុងគោលបំណងធ្វើឲ្យមានបាយការណ៍ល្អសម្រាប់ទទួលបាន ប្រាក់រង្វាន់លើកទឹកចិត្ត។

ដើម្បីចៀសវាងការប្រព្រឹត្តិគ្មានក្រមសីលធម៌ មន្ត្រីឥណទាន គួរតែ ១) អនុវត្តការសិក្សាវាយតម្លៃអតិថិជន និង ២) ចៀសវាងទំនាស់ផលប្រយោជន៍ ដែលធនាគារិកយកផលប្រយោជន៍ផ្ទាល់ខ្លួនជាធំ។ ដូច្នេះ ដើម្បីឱ្យមានដំណើរការតាមដានឥណទានមានប្រសិទ្ធភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមក្របខណ្ឌឱ្យបានត្រឹមត្រូវ និងដាក់បញ្ចូលបទដ្ឋានសីលធម៌នៅក្នុងដំណើរការតាមដាននេះ។

### ឃ២.១. ការតាមដានឥណទាន

ដើម្បីកាត់បន្ថយហានិភ័យឥណទានមិនដំណើរការ មន្ត្រីឥណទានត្រូវធានាឱ្យបានថា សារតាហានិភ័យរបស់អតិថិជន ត្រូវបានតាមដាន និងមានទំនាក់ទំនងជាទៀងទាត់ជាមួយភាគីពាក់ព័ន្ធ។ កិច្ចការនេះហៅថា "**ការត្រួតពិនិត្យតាមកាលកំណត់**" ដែលជាទូទៅធ្វើឡើងនៅពេល ឬបន្ទាប់ពីពេលបានបញ្ចេញឥណទានស្របតាមលក្ខខណ្ឌឥណទានដែលបានព្រមព្រៀង ឬដោយផ្អែកទៅលើគោលនយោបាយទូទៅរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗ។ ប្រសិនបើមានព័ត៌មានមិនល្អអំពីអ្នកខ្ចី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានឆន្ទានុសិទ្ធិ (discretion) ដាក់ចេញនូវវិធានការដោះស្រាយ អនុវត្តការប្រមូលត្រឡប់មកវិញ ឬទាមទារឱ្យបង់សងឥណទានទាំងស្រុងមកវិញ។

ខាងក្រោមនេះគឺជាឧទាហរណ៍អំពី ការប្រព្រឹត្តិគ្មានក្រមសីលធម៌នៅក្នុងការតាមដានឥណទាន ដែលអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយក៏មិនបានជួយអ្វីដល់អតិថិជននោះទេ។

- **ការក្លែងបន្លំឯកសារ៖** មន្ត្រីឥណទាន ក្លែង ឬបន្លំឯកសារត្រួតពិនិត្យការប្រើប្រាស់ឥណទានតាមរយៈសកម្មភាពខាងក្រោម។

- ការបង្ហាញថាឥណទានត្រូវបានប្រើប្រាស់ក្នុងគោលបំណងជាក់លាក់នៅក្នុងពាក្យស្នើសុំ ខណៈដែលជាក់ស្តែងឥណទានមិនត្រូវបានប្រើប្រាស់ដូចអ្វីដែលបានស្នើនោះទេ
- ការបង្ហាញថាស្ថានភាពអាជីវកម្មដំណើរការល្អប្រសើរ ឬរីកចម្រើន ខណៈពេលជាក់ស្តែងអាជីវកម្មកាត់បន្ថយសកម្មភាពជាច្រើន និងមានចំណូលធ្លាក់ចុះ
- ការបង្ហាញថាទ្រព្យធានានៅតែដូចមុន ខណៈពេលដែលទ្រព្យធានានោះបច្ចុប្បន្នកំពុងមានវិវាទកម្មសិទ្ធិ
- ផ្តិតមេដៃជំនួសឱ្យអ្នកខ្ចីនៅលើឯកសារត្រួតពិនិត្យការប្រើប្រាស់ឥណទាន

- **ការមិនបានចុះត្រួតពិនិត្យនៅទីតាំងផ្ទាល់៖** មន្ត្រីឥណទានទទួលខុសត្រូវបំពេញឯកសារតាមដានផលបត្រឥណទានដោយមិនបានចុះទៅពិនិត្យមើលនៅទីតាំងផ្ទាល់ និងមិនបានពិភាក្សាជាមួយអតិថិជនដើម្បីព័ត៌មាន ឬការអង្កេតជាក់ស្តែង។
- **ការធ្វេសប្រហែសលើការផ្ទៀងផ្ទាត់គោលបំណងឥណទាន៖** មន្ត្រីឥណទាន ផ្តោតតែទៅលើការបំពេញឯកសារ ប៉ុន្តែមានការយកចិត្តទុកដាក់តិចតួចចំពោះការប្រើប្រាស់ឥណទានជាក់ស្តែង។ ឥណទានអាចនឹងត្រូវបានប្រើប្រាស់មិនត្រឹមត្រូវ និងមិនមានការចាត់វិធានការទាន់ពេលវេលាដើម្បីកែតម្រូវបញ្ហានោះ។
- **ការធ្វេសប្រហែសក្នុងការផ្ទៀងផ្ទាត់លទ្ធផលអាជីវកម្ម៖** មន្ត្រីឥណទានមិនបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលអាជីវកម្មរបស់អតិថិជន ហេតុដូច្នេះមិនអាចកំណត់រកឃើញបញ្ហាដែលអាចកើតមាន ហើយក៏មិនអាចចាត់វិធានការដោះស្រាយដើម្បីផ្តល់ជំនួយដល់អ្នកខ្ចីនៅក្នុងអំឡុងពេលមានការលំបាកនោះទេ។
- **ការធ្វេសប្រហែសលើស្ថានភាព/លក្ខខណ្ឌទ្រព្យធានា៖** មន្ត្រីឥណទានមិនបានត្រួតពិនិត្យមើលលក្ខខណ្ឌនៃអចលនទ្រព្យធានាដើម្បីធានាថាអចលនទ្រព្យនោះនៅតែមានស្ថានភាពដដែល។ ការផ្លាស់ប្តូរធំដុំ ការកែរចនាសម្ព័ន្ធ ឬកត្តាណាមួយដែលនាំឱ្យមានការការធ្លាក់តម្លៃទ្រព្យធានាទាបជាងមុននោះ ត្រូវចងក្រងជាឯកសារ និងជូនដំណឹងដល់ភាគីដែលពាក់ព័ន្ធ (ជាពិសេស ដល់អ្នកអនុម័តឥណទាន)។
- **ការធ្វេសប្រហែសលើកំណត់ត្រាឥណទានរបស់អ្នកខ្ចី៖** មន្ត្រីឥណទានមិនបានធ្វើការតាមដានថាតើអ្នកខ្ចីបានយកឥណទានបន្ថែម ឬក៏មានព័ត៌មានមិនល្អណាមួយអំពីការទូទាត់សងឥណទាន និងស្ថានភាពឥណទានរបស់អ្នកខ្ចី។ ព័ត៌មានទាំងនេះអាចស្វែងរកបានពីរបាយការណ៍នៃការិយាល័យឥណទានកម្ពុជា ដូចជា ការទាញយករបាយការណ៍ឥណទានស្វ័យត្រួតពិនិត្យ ឬសេវាតាមដានផលបត្រឥណទាន ជាដើម។
- **ការធ្វេសប្រហែសលើសញ្ញាព្រមានរបស់អ្នកខ្ចី៖** មន្ត្រីឥណទាន មិនបានតាមដានភាពប្រែប្រួលទៅលើព័ត៌មានមូលដ្ឋានមួយចំនួនរបស់អ្នកខ្ចី ដូចជាការផ្លាស់ប្តូរទីលំនៅ ស្ថានភាព

គ្រួសារ ស្ថានភាពសុខភាព ជីវភាពរស់នៅជាដើម។ ទោះបីជាការផ្លាស់ប្តូរមួយចំនួនមានលក្ខណៈអំណោយផលក៏ដោយ ក៏ការផ្លាស់ប្តូរមួយចំនួនទៀតអាចនឹងធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពទូទាត់សងទៅកាន់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

- **ទំនាស់ផលប្រយោជន៍៖** ទំនាស់ផលប្រយោជន៍អាចកើតមាន ប្រសិនបើមន្ត្រីឥណទាន ៖
  - ទទួលបានកម្រៃជើងសារពីអ្នកខ្ចីឥណទាន
  - ចែករំលែកឥណទានជាមួយអ្នកខ្ចី
  - ទទួលសំណូកក្នុងទម្រង់ជាអំណោយ ឬអាហារឥតគិតថ្លៃ និង
  - មានទំនាក់ទំនងជិតស្និទ្ធខ្លាំងពេកជាមួយអ្នកខ្ចី ដូចជា សាច់ញាតិ ឬសាច់ញាតិអនាគត។

- **កត្តាជំរុញប្រាក់លើកទឹកចិត្ត៖** មន្ត្រីឥណទានផ្តល់ព័ត៌មានមិនពិតអំពីស្ថានភាពហានិភ័យរបស់អ្នកដាក់ពាក្យសុំកម្ចីដើម្បីទទួលបានប្រាក់រង្វាន់លើកទឹកចិត្តដោយផ្អែកលើលទ្ធផលការងារ។

## តើត្រូវផ្ទៀងផ្ទាត់គោលបំណងឥណទានដោយរបៀបណា?

គោលបំណងឥណទានគឺជាកត្តាសំខាន់មួយក្នុងការកំណត់ផលិតផលសមស្របបំផុតសម្រាប់អតិថិជន។ ខាងក្រោមនេះគឺជាការអនុវត្តទូទៅសម្រាប់ការផ្ទៀងផ្ទាត់គោលបំណងឥណទាន។

### (i) សម្រាប់ហិរញ្ញប្បទានបុគ្គល៖

- **ឥណទានសម្រាប់ទិញរថយន្ត/ម៉ូតូ៖** ឥណទាននេះអាចធ្វើការផ្ទៀងផ្ទាត់បានដោយផ្ទៀបជាមួយបង្កាន់ដៃ ឬលិខិតកក់ប្រាក់ កិច្ចព្រមព្រៀងទិញលក់ ឬបណ្ណចុះបញ្ជីយានយន្ត។ ជាទូទៅ ឥណទានប្រភេទនេះត្រូវបានធានាដោយយានយន្តផ្ទាល់តែម្តង។ ដូច្នេះ ការប្រើប្រាស់ឥណទានបានត្រឹមត្រូវ គឺត្រូវបានបង្ហាញយ៉ាងច្បាស់ណាស់ ហើយដំណើរការផ្ទៀងផ្ទាត់គឺមានភាពងាយស្រួល។
- **ឥណទានទិញផ្ទះ/ឥណទានសង់គេហដ្ឋាន៖** បុគ្គលិករបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចស្នើរកកិច្ចព្រមព្រៀងទិញច្បាប់ដើមភស្តុតាងបញ្ជាក់ពីការកក់ប្រាក់/ការទូទាត់ប្រាក់ ឯកសារផ្ទេរកម្មសិទ្ធិ និងឯកសារបញ្ជាក់ម្ចាស់កម្មសិទ្ធិ/ប្លង់រឹង។ ចំពោះការសាងសង់ផ្ទះវិញ បុគ្គលិករបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចស្នើរកកិច្ចព្រមព្រៀងសាងសង់ជាមួយអ្នកម៉ៅការព្រមទាំងបញ្ជីសកម្មភាព និងថ្លៃចំណាយផ្សេងៗ។

### (ii) សម្រាប់ហិរញ្ញប្បទានអាជីវកម្ម៖

- **ឥណទានទុនបង្វិល៖** សម្រាប់ឥណទានខ្នាតតូច បុគ្គលិករបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចចុះទៅទីតាំងផ្ទាល់ និងអង្កេតមើលសកម្មភាពអាជីវកម្មពាក់ព័ន្ធថាតើសមស្របទៅនឹងគោលបំណងដែលបានលើកឡើងនៅក្នុងពាក្យស្នើសុំដែរឬទេ។ បុគ្គលិក អាចសួរបញ្ជាក់ដោយពាក្យសម្ដីពីអ្នកខ្ចី អតិថិជន/អ្នកផ្គត់ផ្គង់ អ្នកជិតខាង ឬអាជ្ញាធរមូលដ្ឋានរបស់អ្នកខ្ចី។ ប៉ុន្តែ ចំពោះឥណទានខ្នាតធំវិញ បុគ្គលិករបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចតាមដានប្រតិបត្តិការធនាគាររបស់អ្នកខ្ចី និងពិនិត្យមើលនិន្នាការលក់របស់អ្នកខ្ចីនៅក្នុងអំឡុងពេលត្រួតពិនិត្យតាមកាលកំណត់ (ឧទាហរណ៍ ប្រចាំត្រីមាស ឬប្រចាំឆ្នាំ ជាដើម)។ ស្ថាប័នមានឥណទានទុនបង្វិលជាក់លាក់ដែលផ្អែកលើប្រតិបត្តិការ ដូចជា ឥណទានហិរញ្ញវត្ថុពាណិជ្ជកម្ម ឬបង្កាន់ដៃកិច្ចព្រមព្រៀង ហើយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្តល់ឥណទានតែនៅពេលដែលអ្នកខ្ចីអាចបង្ហាញឯកសារស្របតាមលក្ខខណ្ឌ ដូចជា បណ្ណបញ្ជាទិញ កិច្ចព្រមព្រៀងទិញលក់ វិក្កយបត្រ និងវិក្កយបត្រមធ្យោបាយដឹកជញ្ជូន។ ការអនុវត្តន៍បែបនេះគឺអាចកំណត់ថាការប្រើប្រាស់ឥណទានត្រឹមត្រូវតាមគោលបំណងស្នើសុំខ្ចីមានកម្រិតខ្ពស់។
- **ឥណទានចំណាយមូលធន៖** បុគ្គលិករបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចស្នើសុំមើលកិច្ចព្រមព្រៀងទិញលក់ទ្រព្យសកម្មច្បាប់ដើម ភស្តុតាងបញ្ជាក់ពីការកក់ប្រាក់ ឬការទូទាត់ប្រាក់ជូនអ្នកលក់ និង/ឬ ឯកសារម្ចាស់កម្មសិទ្ធិ/ប្លង់រឹង។ ក្នុងករណីអ្នកខ្ចីមិនបានទិញទ្រព្យសកម្មរយៈពេលវែង ប៉ុន្តែបានដំឡើង ឬសាងសង់ដោយខ្លួនឯង ឬដោយភាគីទីបីនោះបុគ្គលិករបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចសួររកកិច្ចព្រមព្រៀងជាមួយអ្នកម៉ៅការអមជាមួយនឹងបញ្ជីរាយនាមសកម្មភាព និងបញ្ជីចំណាយ ហើយការផ្តល់ ឥណទានអាចធ្វើតាមដំណាក់កាល។

**ឧទាហរណ៍៖** ក្រុមហ៊ុន ក បានចុះកិច្ចសន្យាកសិកម្មជាមួយសមាគមកសិកម្មចំនួន ៥ ដើម្បីទិញស្រូវពីសមាគមក្នុងបរិមាណ ១,០០០ តោនក្នុងមួយសមាគម ក្នុងតម្លៃ ៧៥០ រៀលក្នុងមួយគីឡូក្រាមនៅរដូវប្រមូលផល។ សមាគមកសិកម្មទាំង ៥ បានប្រមូលស្រូវពីសមាជិករបស់ខ្លួនដើម្បីលក់ឱ្យក្រុមហ៊ុន ក។ ប៉ុន្តែមិនអាចប្រមូលបាន ១,០០០ តោនក្នុងពេលតែមួយនោះទេ។ ពួកគេអាចប្រមូលបានតែ២០០ តោនប៉ុណ្ណោះនៅក្នុងសប្តាហ៍ទី ១។ បន្ទាប់មក ក្រុមហ៊ុន ក បានដាក់ជូនវិក្កយបត្រស្រូវ ១,០០០ តោន (២០០ តោន * ៥ សមាគមកសិកម្ម) ជាមួយនឹងកិច្ចសន្យាជា លាយ

លក្ខណ៍អក្សរដែលបានចុះជាមួយសមាគមកសិកម្មទាំងនោះជូនដល់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីស្នើសុំបញ្ចេញឥណទាន។ ការធ្វើបែបនេះ ក្រុមហ៊ុន ក មិនចាំបាច់ត្រូវបង់ការប្រាក់សម្រាប់សាច់ប្រាក់ដែលមិនបានប្រើប្រាស់នោះទេ ហើយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏អាចធានាថាឥណទានបានប្រើប្រាស់ត្រឹមត្រូវដែរ។

**សំណួរវគ្គៈបញ្ជាំង ឃ២.១**

រិទ្ធ មន្ត្រីឥណទានរបស់គ្រឹះស្ថាន រុក្ខាហ្វាយណាន់ បានធ្វើការត្រួតពិនិត្យការប្រើប្រាស់ឥណទានរបស់សាន ដែលបានទទួលឥណទានចំនួន២០,០០០ដុល្លារ កាលពីខែមុនសម្រាប់រយៈពេល ៤ ឆ្នាំដើម្បីធ្វើអាជីវកម្មលក់ដី។សាន និងរិទ្ធ បានបែងចែកឥណទាននេះក្នុងចំនួនស្មើគ្នា ប៉ុន្តែឥណទាននេះបែរជាត្រូវបានប្រើប្រាស់ដើម្បីទិញដីសម្រាប់ទុកចំណេញទៅវិញ។ នៅក្នុងអំឡុងពេលចុះពិនិត្យមើលទីតាំងផ្ទាល់ សាន បានសួរថាតើដីដែលពួកគេបានទិញជាមួយគ្នានោះឥឡូវនេះឡើងថ្លៃដែរឬទេ។រិទ្ធ បាននិយាយថាទាល់តែចាំមើលពីរបីខែទៀតទើបអាចលក់ចំណេញប្រាក់បានច្រើនពីដីនោះ។សានបានប្រាប់ថាការទូទាត់ប្រាក់បង់រំលោះបន្ទាប់គឺនៅថ្ងៃទី១៦ ខែសីហា ហើយបានរំឭក រិទ្ធ ឱ្យផ្ញើប្រាក់មកបង់។ រិទ្ធ បានសន្យាថានឹងផ្ញើប្រាក់ឱ្យនៅថ្ងៃទី១៥។ នៅពេលត្រឡប់មកកាន់ការិយាល័យវិញរិទ្ធ បានដាក់ជូនឯកសារត្រួតពិនិត្យការប្រើប្រាស់ឥណទានដល់អ្នកគ្រប់គ្រងផ្ទាល់របស់គាត់ពិនិត្យ និងមិនបានរាយការណ៍អំពីចំណុចខុសប្រក្រតីណាមួយឡើយ។

តើការតាមដានឥណទាននេះមានក្រមសីលធម៌ដែរឬទេ? សូមបញ្ជាក់ចម្លើយរបស់អ្នក។

## ឃ២.២. តាមដានឥណទានហួសកាលកំណត់សង[94]

### ឃ២.២.១ នីតិវិធីសម្រាប់ការតាមដានឥណទាន

ឥណទានហួសកាលកំណត់សងកើតឡើងនៅពេលអ្នកខ្ចីមិនបានបង់សងឥណទានតាមកាលវិភាគត្រូវទូទាត់សង។ មន្ត្រីឥណទាន និង/ឬបុគ្គលិកផ្សេងទៀតដែលទទួលខុសត្រូវ នឹងកត់

[94] (International Finance Corporation, 2015)

ចំណាំគណនីឥណទានហួសកាលកំណត់សង និងត្រូវធ្វើការតាមដានដោយក្រមសីលធម៌ដូចខាងក្រោម៖

- **ការជួបជាមួយអតិថិជន៖** មន្ត្រីឥណទានជួបជាមួយអតិថិជនដែលហួសកាលកំណត់សង ដើម្បីធ្វើការពិភាក្សាស្វែងយល់អំពី ដើមចមនៃការទូទាត់សងយឺតជាងកាលកំណត់ក្នុងគោលបំណងកំណត់ថាតើករណីបែបនេះកើតឡើងតែម្តងនេះ ជាបណ្តោះអាសន្ន ឬជាសញ្ញាបង្ហាញពីភាពមិនប្រក្រតីរបស់ឥណទាន។ មន្ត្រីឥណទានគួរព្យាយាមស្វែងយល់អំពីរបៀប និងពេលវេលាដែលអាចដោះស្រាយបញ្ហាឥណទានហួសកាលកំណត់សងនេះ ដោយផ្អែកលើលំហូរសាច់ប្រាក់បច្ចុប្បន្នរបស់អតិថិជន។ ចំណុចខ្វះខាតដែលតែងតែកើតឡើងគឺមន្ត្រីឥណទានមិនបានកំណត់រកបុព្វហេតុនាំឱ្យមានការហួសកាលកំណត់សងនោះ ប៉ុន្តែបែរជាសន្មតថាអ្នកខ្ចីមិនមានឆន្ទៈទូទាត់សងទៅវិញ។
- **រៀបចំការជួបប្រជុំលក្ខណៈវិជ្ជាជីវៈ៖** ការពិភាក្សាគួរតែធ្វើឡើងតាមរបៀបមួយដែលអតិថិជនមានអារម្មណ៍ថាមិនរងការគំរាមកំហែង ឬភ័យខ្លាចឡើយ។ មន្ត្រីឥណទានអាចប្រព្រឹត្តដោយគ្មានក្រមសីលធម៌ក្នុងអំឡុងពេលជួបប្រជុំតាមសេណារីយ៉ូដូចខាងក្រោម។
  - អញ្ជើញក្រុមស្តារឥណទាន ឬមិត្តរួមការងារផ្សេងទៀតឱ្យជួបជាមួយអ្នកខ្ចី ដែលមានឥណទានហួសកាលកំណត់សងដើម្បីមានប្រៀបលើអ្នកខ្ចី។
  - គំរាមកំហែងអ្នកខ្ចីឱ្យសងប្រាក់ហួសកាលកំណត់បង់នោះ បើមិនដូច្នោះទេ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នឹងដាក់ពាក្យបណ្តឹងភ្លាមៗ ឬរឹបអូស/ដាក់ដេញថ្លៃទ្រព្យធានាដោយផ្អែកលើកិច្ចព្រមព្រៀងឥណទាន។ ការធ្វើបែបនេះនឹងបន្ថែមសម្ពាធដែលមិនចាំបាច់ទៅលើអ្នកខ្ចីទៅវិញ។ ទោះជាយ៉ាងនេះក្តី ការធ្វើបែបនេះអាចមានភាពចាំបាច់ជាពិសេស សម្រាប់អ្នកខ្ចីណាដែលក្លែងបន្លំ ឬដែលគ្មានឆន្ទៈសងក្នុងចេតនាមិនល្អ។
  - ការដាក់សម្ពាធលើអ្នកខ្ចីឱ្យទូទាត់សងភ្លាមៗតាមរយៈអ្នកធានាឥណទាន ឬសាច់ញាតិដោយមិនបានពន្យល់អំពីជម្រើសផ្សេងៗដែលមាន ឬផលវិបាកនានា ។
  - មិនជម្រាបអ្នកខ្ចីអំពីជំហានខាងក្រោមនៅក្នុងការដោះស្រាយការទូទាត់សងយឺតយ៉ាវ
    - ការជួបប្រជុំដើម្បីឈ្វេងយល់អំពីស្ថានភាព និងស្វែងរកការប្តេជ្ញាចិត្តក្នុងការទូទាត់សងឥណទាន
    - ឱ្យអ្នកធានាឥណទានចូលរួមដើម្បីពង្រឹងកាតព្វកិច្ចធានាឥណទាន
    - ផ្តល់ការជូនដំណឹងអំពីការទាមទារឱ្យពង្រឹងកាតព្វកិច្ចទូទាត់សងឥណទាន
    - ចាប់ផ្តើមនីតិវិធីបណ្តឹងដើម្បីអនុវត្តកិច្ចព្រមព្រៀងឥណទាន

- **ពន្យល់អំពីផលវិបាក៖** ជំនួសឱ្យការគ្រាន់តែប្រាប់អ្នកខ្ចីថាការទូទាត់សងយឺតលើកនេះនឹងកត់ត្រាចូលទៅក្នុងរបាយការណ៍ឥណទានរបស់ពួកគាត់ មន្ត្រីឥណទានគួរតែឆ្លៀតឱកាសនេះបង្កើតវិន័យឥណទានតាមរយៈការពន្យល់ក្នុងន័យបញ្ចុះបញ្ចូលអំពីរបៀបដែលការទូទាត់សងយឺតនឹងប៉ះពាល់ដល់របាយការណ៍ឥណទានរបស់ពួកគាត់។

    - ការិយាល័យឥណទានកម្ពុជាគឺជាការិយាល័យឥណទានដែលកត់ត្រារាល់ប្រតិបត្តិការកម្ចីដែលរួមមាន ការស្នើសុំឥណទាន ការខ្ចីឥណទាន និងការទូទាត់សងឥណទានរវាងអ្នកខ្ចី និង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។
    - ចំនួនប្រតិបត្តិការស្នើសុំឥណទាន ចំនួនទឹកប្រាក់បំណុលសរុបដែលនៅជំពាក់ និងប្រវត្តិនៃប្រតិបត្តិការទូទាត់សង នឹងត្រូវបានបូកបញ្ចូលគ្នាដើម្បីបង្កើតបានជាពិន្ទុឥណទានដើម្បីគាំទ្រសេចក្តីសម្រេចចិត្តរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ថាតើគួរផ្តល់ឥណទានដល់អ្នកខ្ចីឬទេ។
    - គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បញ្ចូលទិន្នន័យប្រតិបត្តិការទូទាត់សងឥណទានរបស់អតិថិជនចូលទៅក្នុងការិយាល័យឥណទានកម្ពុជាជារៀងរាល់ខែ ហើយប្រតិបត្តិការខកខានមិនបានសង ឬប្រតិបត្តិការទូទាត់សងយឺតយ៉ាវនឹងបង្ហាញនៅលើរបាយការណ៍ឥណទានដែលឆ្លុះបញ្ចាំងអំពីឥរិយាបថទូទាត់សងរបស់អតិថិជន ហើយព័ត៌មាននេះនឹងនាំឱ្យអតិថិជនមានការលំបាកក្នុងការទទួលបានសេវាហិរញ្ញវត្ថុនាពេលអនាគត។

- **ស្វែងរកវិធានការតាមដាន៖** ត្រូវរៀបចំការពិភាក្សាពាក់ព័ន្ធនឹងការប្តេជ្ញាចិត្តពីអតិថិជនសម្រាប់ការទូទាត់សងឥណទាន។ ជារឿយៗ មន្ត្រីឥណទានមិនបានផ្តល់ការពិគ្រោះយោបល់ឱ្យអ្នកខ្ចីស្វែងរកដំណោះស្រាយសមស្របនោះទេ។ ក្នុងកាលៈទេសៈបែបនេះ មន្ត្រីឥណទានមានភារកិច្ចគាំទ្រអតិថិជនតាមរយៈការលើកឡើងអំពីជម្រើសទាំងអស់ រួមទាំងការរៀបចំឥណទានឡើងវិញនៅមុនពេលអនុវត្តលក្ខខណ្ឌកិច្ចសន្យា។

### ឃ២.២.២. ឥរិយាបថប្រមូលបំណុលប្រកបដោយទំនួលខុសត្រូវ

ការប្រមូលបំណុល គួត្រូវបានអនុវត្តប្រកបដោយទំនួលខុសត្រូវ ដែលរួមមានឥរិយាបថដូចខាងក្រោម[95]៖

[95] (The Assocation of Banks in Cambodia; Cambodian Microfinance Association; & Cambodian Association Finance & Technology, 2022)

- ចៀសវាងការបង្កគ្រោះថ្នាក់ បៀតបៀន ឬគំរាមកំហែងដល់អ្នកខ្ចី សាច់ញាតិ ឬទ្រព្យសម្បត្តិរបស់អ្នកខ្ចី។
- ចៀសវាងប្រើប្រាស់ភាសាគំរោះគំរើយ បង្ខូចកេរ្តិ៍ឈ្មោះ ឬភាសាគំរាមកំហែងនៅគ្រប់ពេលធ្វើការដោះស្រាយទាំងអស់។
- ចៀសវាងទូរសព្ទទៅលេខការងារ ឬលេខទូរសព្ទផ្ទាល់ខ្លួននៅថ្ងៃឈប់សម្រាក ពិធីបុណ្យសាសនា ពិធីបុណ្យនានា កម្មវិធីធំក្នុងគ្រួសារ (ដូចជា ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យសព -ល-) ឬនៅចន្លោះពីម៉ោង ៩ យប់ ដល់ម៉ោង ៦ព្រឹក លើកលែងតែមានការអនុញ្ញាតពីអ្នកខ្ចី។
- ចៀសវាងបញ្ចេញព័ត៌មាន ឬគំរាមបង្ហាញព័ត៌មានដែលអាចនឹងមានឥទ្ធិពលមិនល្អដល់កេរ្តិ៍ឈ្មោះរបស់អ្នកខ្ចី ដែលនឹងប៉ះពាល់ដល់លទ្ធភាពខ្ចីឥណទានពេលក្រោយទៀតបើទោះជាដឹង ឬសង្ស័យថាព័ត៌មាននោះគឺក្លែងក្លាយក៏ដោយ។
- ចៀសវាងណែនាំ ជំរុញ ឬបង្ខំឱ្យអ្នកខ្ចីស្វែងរកឥណទានក្រៅផ្លូវការ (ដូចជាអ្នកចងការប្រាក់ឯកជន កម្ចីខុសក្រៅផ្លូវការ (loan shark) -ល-) ដើម្បីប្រើប្រាស់ផលពីឥណទានយកទៅទូទាត់ការបង់រំលស់ឥណទានហួសកាលកំណត់ ឬសមតុល្យឥណទានដែលនៅសល់ទាំងមូល។
- ចៀសវាងណែនាំ ជំរុញ ឬបង្ខំអ្នកខ្ចីឱ្យយកឥណទានបន្ថែម ឬធ្វើបុនហិរញ្ញប្បទានទៅលើឥណទានមានស្រាប់ក្នុងទឹកប្រាក់ចំនួនច្រើនជាងមុន និងប្រើប្រាស់ផលពីឥណទានដើម្បីទូទាត់ការបង់ការរំលស់ឥណទានដែលហួសកាលកំណត់បង់។
- ចៀសវាងសហការជាមួយអាជ្ញាធរមូលដ្ឋាន កងកម្លាំងសន្តិសុខ នគរបាល ទាហាន និង/ឬកងកម្លាំងប្រដាប់អាវុធផ្សេងៗនៅក្នុងដំណើរការប្រមូល និងស្តារឥណទានឡើងវិញ។
- ចៀសវាងរឹបអូស ឬឃាត់ទុកចលនទ្រព្យនានារបស់អ្នកខ្ចីដោយមិនមានការឆ្លងកាត់នីតិវិធីផ្លូវច្បាប់។
- ចៀសវាងបញ្ចុះបញ្ចូល ឬបង្ខំឱ្យអ្នកខ្ចីលក់ទ្រព្យសម្បត្តិផលិតកម្មសំខាន់របស់ពួកគាត់ដែលមិនបានដាក់ធានាជាមួយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេសទ្រព្យសម្បត្តិដែលពួកគាត់ត្រូវការដើម្បីបំពេញការងារប្រចាំថ្ងៃ ឬជាមធ្យោបាយតែមួយគត់ដែលពួកគាត់អាចរកចំណូលបាន។
- ចៀសវាងបំភាន់ ឬក្លែងបន្លំភស្តុតាង ឬសកម្មភាពផ្សេងទៀតដើម្បីលក់ទ្រព្យធានារបស់អ្នកខ្ចីក្នុងតម្លៃទាបជាងតម្លៃទីផ្សារខ្លាំងពេក។

**សំណួរឆ្លុះបញ្ចាំង ឃ២.២**

សារិន បានខ្ចីប្រាក់ចំនួន២,០០០ដុល្លា ពីគ្រឹះស្ថាន រុក្ខាហ្វាយណាន់ សម្រាប់រយៈពេលមួយឆ្នាំ ដែលមានអត្រាការប្រាក់ប្រចាំខែ១.៥%។ ឥណទានបានផ្តល់ជូននៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ហើយគាត់ត្រូវទូទាត់សងឥណទាននៅថ្ងៃទី០៥ ជារៀងរាល់ខែរហូតដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០២០។ ដោយសារតែភោជនីយដ្ឋានរបស់គាត់ដំណើរការល្អ ហើយកូនប្រុសពីរនាក់របស់គាត់ បានផ្ញើប្រាក់មួយចំនួនដល់គាត់ជារៀងរាល់ខែពីប្រទេសកូរ៉េ គាត់បានសងឥណទានទាន់ពេល វេលារហូតដល់ខែមិថុនា ឆ្នាំ២០២០។ ជាអកុសល ដោយសារផ្ទុះជំងឺកូវីដ-១៩ តំបន់នៅទីតាំង ភោជនីយដ្ឋានរបស់គាត់ត្រូវបានបិទខ្ទប់រយៈពេលពីរសប្តាហ៍ ហើយគាត់បានបាត់បង់ចំណូល ទាំងស្រុង ស្របពេលដែលកូនប្រុសទាំងពីររបស់គាត់រកចំណូលបានតិចជាងមុន។ ថ្ងៃនេះគឺជា ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០។

តើសេចក្តីថ្លែងមួយណាខាងក្រោមនេះ ដែលមន្ត្រីឥណទានអនុវត្តមិនសមស្របក្នុងការផ្តល់ ឥណទានដោយទំនួលខុសត្រូវ?

**ក.** ទៅសួរសុខទុក្ខគាត់ដើម្បីឈ្វេងយល់អំពីបញ្ហាប្រឈមសំខាន់ៗរបស់គាត់ដែលបានធ្វើ ឱ្យគាត់គ្មានលទ្ធភាពសងឥណទាន។

**ខ.** ទៅជាមួយមន្ត្រីឥណទានបីនាក់ផ្សេងទៀតដោយដើរតួជាប៉ូលិសល្អ ប៉ូលិសអាក្រក់ ដើម្បីធ្វើឱ្យគាត់សងឥណទាន។ មន្ត្រីឥណទានពីរនាក់ធ្វើជាអ្នកគំរាមកំហែងរឹបអូសចលនទ្រព្យរបស់គាត់ ហើយមន្ត្រីឥណទានម្នាក់ទៀតធ្វើជាអ្នកមកនិយាយជាមួយអ្នកខ្ចី ដោយការអត់ធ្មត់ និងបញ្ចុះបញ្ចូលគាត់ឱ្យទៅខ្ចីប្រាក់ពីអ្នកចងការផ្សេងទៀតដើម្បី ទូទាត់សងឥណទាន។

**គ.** សុំឱ្យគាត់សហការដើម្បីស្វែងរកដំណោះស្រាយសមស្របដូចជាកាលបរិច្ឆេទសន្យា ទូទាត់សងឥណទានជាដើម។

**ឃ.** ឈ្វេងយល់អំពីកម្រិតប្រាក់ចំណូល និងប្រភពចំណូលបច្ចុប្បន្នរបស់គាត់ដើម្បីអាចរក ដំណោះស្រាយសមស្របសម្រាប់គាត់បាន ដោយផ្តល់ជម្រើសរៀបចំឥណទានឡើង វិញដល់គាត់សម្រាប់គ្រាលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ននេះតាមរយៈការស្នើសុំឱ្យ គាត់ទូទាត់តែការប្រាក់សម្រាប់រយៈពេល ៤ ខែ ដោយធ្វើឱ្យស្របទៅនឹងប្រកាសរបស់ ធនាគារជាតិនៃកម្ពុជា នៅក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩។

## ឃ២.៣. កំណត់រកសញ្ញាព្រមានដំបូងនិងឆ្លើយតបចំពោះភាពមិនប្រក្រតីនៃឥណទាន

### ឃ២.៣.១. តើសញ្ញាព្រមានដំបូងជាអ្វី?

សញ្ញាព្រមានដំបូងគឺជាសញ្ញាដំបូងដែលបង្ហាញថាឥណទានអាចនឹងខុសប្រក្រតី។ សញ្ញាព្រមានដំបូងអាចចាត់ក្រុមទៅជា សូចនាករ សន្ទនីយភាព ហិរញ្ញវត្ថុ ឥរិយាបថ និងភូមិសាស្ត្រ៖[96]

- **សូចនាករសន្ទនីយភាព**[97]

  សូចនាករសន្ទនីយភាព គឺជាសូចនាករសំខាន់ដោយសារតែសូចនាករនេះផ្តល់នូវសញ្ញាខ្លាំងបំផុត និងមុនគេបំផុតអំពីភាពមិនប្រក្រតីនៃឥណទាន។ សញ្ញាទាំងនេះអាចមានដូចខាងក្រោម

  - ការផ្តល់សញ្ញាពី ការិយាល័យឥណទានកម្ពុជា ដែលបង្ហាញថា អតិថិជនកំពុងដាក់ពាក្យស្នើសុំឥណទានមួយទៀតពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងទៀត
  - ការផ្តល់សញ្ញាពី ការិយាល័យឥណទានកម្ពុជា ដែលបង្ហាញថា អតិថិជនមានការលុបចោលឥណទានដោយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងទៀត
  - អតិថិជនស្នើសុំឥណទានពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មួយទៀតក្នុងចំនួនទឹកប្រាក់ជាក់លាក់ណាមួយដែលនឹងនាំឱ្យជះផលអវិជ្ជមានដល់លំហូរសាច់ប្រាក់
  - អតិថិជនស្នើសុំបង់ផ្តាច់ឥណទាន និងស្នើសុំឥណទានមួយទៀតភ្លាមៗពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដដែលដោយមានរយៈពេលយូរជាងមុន និងចំនួនទឹកប្រាក់ច្រើនជាងមុន (បុនហិរញ្ញប្បទានផ្ទៃក្នុង refinancing)
  - អតិថិជនលក់ទ្រព្យធានាដោយមិនបានស្នើសុំការអនុញ្ញាតជាមុនពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពាក់ព័ន្ធ

- **សូចនាករហិរញ្ញវត្ថុ**[98]

  សូចនាករហិរញ្ញវត្ថុជាសូចនាករសំខាន់ដើម្បីផ្តល់សញ្ញាពីភាពមិនប្រក្រតីនៃឥណទាន។ ភាពមិនប្រក្រតីនេះអាចកើតឡើងដោយសារតែអតិថិជនមានបញ្ហាហិរញ្ញវត្ថុ ឬការវាយតម្លៃរបស់មន្ត្រីឥណទានមិនបានល្អិតល្អន់ទៅលើសមត្ថភាពសងឥណទាន។ សញ្ញាទាំងនេះអាចមានដូចខាងក្រោម

---

96 (PWC, 2019)
97 (Institute of Banking and Finance, 2021)
98 Ibid

- ➢ អាជីវកម្មរបស់អតិថិជនមិនសូវសកម្មធៀបទៅនឹងស្ថានភាពនាពេលវាយតម្លៃឥណទាន។
- ➢ អាជីវកម្មរបស់អតិថិជនបិទលែងដំណើរការដោយមិនមានមូលហេតុសមរម្យ។
- ➢ អតិថិជនមានបញ្ហាជាមួយដៃគូអាជីវកម្ម។
- ➢ អាជីវកម្មរបស់អតិថិជនរងការបំផ្លាញដោយសារតែអគ្គិភ័យ ឬមហន្តរាយធម្មជាតិផ្សេងៗ។
- ➢ អតិថិជនបាត់បង់ការងារ។
- ➢ អតិថិជន ឬអ្នករកចំណូលចម្បងមានជំងឺធ្ងន់ធ្ងរ ទទួលមរណភាព ឬមានពិការភាពអចិន្ត្រៃយ៍។

- **សូចនាករឥរិយាបថ**[99]

  សូចនាករឥរិយាបថ អាចផ្តល់សញ្ញាពាក់ព័ន្ធនឹងសុចរិតភាព និងការប្តេជ្ញាចិត្តរបស់អតិថិជនក្នុងការទូទាត់សង ដែលរួមមាន៖
  - ➢ អតិថិជនមានចេតនាគេចពីមន្ត្រីឥណទានក្នុងអំឡុងពេលត្រួតពិនិត្យប្រចាំឆ្នាំ ឬប្រចាំឆមាស។
  - ➢ អតិថិជនមិនចង់ប្រាស្រ័យទាក់ទងជាមួយមន្ត្រីឥណទាន។
  - ➢ អតិថិជនមិនមានបំណងទូទាត់សងឥណទាន។
  - ➢ អតិថិជនប្រើប្រាស់ឥណទានសម្រាប់គោលបំណងខុសពីគោលបំណងដើមតាមការអនុម័តឥណទាន។
  - ➢ អតិថិជនពាក់ព័ន្ធនៅក្នុងអំពើល្បែងស៊ីសង ថ្នាំញៀន ឬសកម្មភាពខុសច្បាប់ផ្សេងៗ។

- **សូចនាករអាជីវកម្ម និងវិស័យ**[100]

  សូចនាករអាជីវកម្ម ជាការសន្មតដោយផ្អែកលើការវិភាគទៅលើការឈរជើងនៅក្នុងទីផ្សារ/យុទ្ធសាស្ត្ររបស់អាជីវកម្ម។ សញ្ញាព្រមានដំបូង កើតឡើងនៅពេលដែលទីផ្សារសម្រាប់អាជីវកម្មរបស់អតិថិជននឹងបាត់បង់ក្នុងពេលខាងមុខឆាប់ៗ ឬកំពុងតែមានការធ្លាក់ចុះ។ ឧទាហរណ៍ ភោជនីយដ្ឋានចិនមួយធ្វើប្រតិបត្តិការជាមួយគូប្រជែងចំនួន១០ នៅតាមបណ្តោយផ្លូវតែមួយ ប៉ុន្តែភោជនីយដ្ឋាននេះមានបុគ្គលិកលាឈប់ច្រើនពេក រួមទាំង មេចុងភៅផងដែរ ដែលធ្វើឱ្យប៉ះពាល់ដល់ការពេញចិត្តរបស់អតិថិជន ដូច្នេះធ្វើឱ្យចំនួនអតិថិជនធ្លាក់ចុះ។

  សូចនាករវិស័យ គឺជាសូចនាករសំខាន់នៅពេលដែលស្ថានភាពដំណើរការរបស់វិស័យមួយមិនល្អ ឬមាននិន្នាការអវិជ្ជមាន ដែលប៉ះពាល់ដល់ផលបត្រឥណទាននៅក្នុងវិស័យនោះ។ ឧទាហរណ៍ ហាងកុំព្យូទ័រឯកជនធ្លាប់តែមានប្រជាប្រិយភាព ប៉ុន្តែទីផ្សារប្រែទៅជាតូចចង្អៀត

[99] (Institute of Banking and Finance, 2021)
[100] (PWC, 2019)

ជាងមុននៅពេលដែលអ៊ីនធឺណិត និងទូរសព្ទស្មាតហ្វូនមានឱ្យប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា។

- **សូចនាករភូមិសាស្ត្រ**[101]

  សូចនាករនេះគឺសំខាន់ខ្លាំងណាស់ ពីព្រោះវាអាចមានផលប៉ះពាល់ទ្រង់ទ្រាយធំ។ វាកើតឡើងនៅពេលណា ដែលមានកត្តាហានិភ័យខ្ពស់កំពុងកើតឡើងនៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ដែលតំបន់នោះជាកន្លែង ដែលផលបត្រឥណទាន អ្នកខ្ចី ឬសកម្មភាពស្វែងរកប្រាក់ចំណូលរបស់អ្នកខ្ចី រងផលប៉ះពាល់។ ឧទាហរណ៍ ដោយសារតែផ្លូវខូច និងមានផ្លូវតែមួយខ្សែទៅកាន់ខេត្តកោះកុង ទិន្នផលកសិកម្មទាំងអស់មិនអាចដឹកជញ្ជូនចេញពីខេត្តបានរយៈពេលមួយខែរហូតទាល់តែផ្លូវបានជួសជុលរួច។ ដូច្នេះ ឥណទានកសិកម្មទាំងអស់នៅក្នុងខេត្តបានទទួលរងផលប៉ះពាល់។

មន្ត្រីឥណទាន ដើរតួនាទីជារបាំងការពារជួរមុខសម្រាប់ការគ្រប់គ្រងហានិភ័យឥណទាន ដូច្នេះមន្ត្រីឥណទានមានការទទួលតាមដានស្ថានភាពគណនី ស្ថានភាពហិរញ្ញវត្ថុ និងបរិយាកាសអាជីវកម្មរបស់អ្នកខ្ចីដើម្បីកំណត់រកសញ្ញាព្រមានដំបូង។ នៅពេលដែលរកឃើញសញ្ញាព្រមានដំបូង នោះវាអាចជំរុញឱ្យមានការផ្លាស់ប្តូរសារតាហានិភ័យឥណទានរបស់អ្នកខ្ចីដែលទាមទារឱ្យមានការតាមដានកាន់តែលម្អិតបន្ថែមទៀត។ មន្ត្រីឥណទានត្រូវជជែកជាមួយអ្នកខ្ចីអំពីផលប៉ះពាល់ដែលអាចកើតមានទៅលើអាជីវកម្ម និងធ្វើការវាយតម្លៃហានិភ័យទៅលើផលប៉ះពាល់នោះ។ សញ្ញាឥណទានមិនប្រក្រតីច្បាស់លាស់ គួរត្រូវបានរាយការណ៍ទៅកាន់គណៈគ្រប់គ្រងជាន់ខ្ពស់ និងស្វែងរកដំណោះស្រាយឱ្យបានត្រឹមត្រូវ។ ការព្រងើយកន្តើយចំពោះសញ្ញាព្រមាននេះ អាចនឹងចាត់ទុកថាជាឥរិយាបថមិនមានក្រមសីលធម៌ដែលអាចកើតឡើងមកពី៖

- មន្ត្រីឥណទានមិនបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព និងមិនបានយកចិត្តទុកដាក់បំពេញកិច្ចការរបស់ខ្លួន។
- មានទំនាស់ផលប្រយោជន៍ ដូចជា ការទទួលសំណូកពីអ្នកខ្ចី ឬការមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយអ្នកខ្ចី ឬទម្រង់ផ្សេងៗនៃផលប្រយោជន៍ផ្ទាល់ខ្លួន (ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ) នៅក្នុងប្រតិបត្តិការ ឬជាមួយអ្នកខ្ចី។
- មន្ត្រីឥណទានមានចេតនារក្សាឥណទានឱ្យនៅល្អជានិច្ច (evergreening) តាមរយៈការផ្តល់នូវឥណទានបន្ថែមជាបន្តបន្ទាប់ ឬបុនហិរញ្ញប្បទានផ្ទៃក្នុង (internal refinancing)។

[101] Ibid

**សំណួរឆ្លុះបញ្ចាំង ឃ២.៣.១**

នៅខែមករា ឆ្នាំ២០១៥ សារ៉ាបានទទួលឥណទានចំនួន៥០.០០០ ដុល្លារអាមេរិកពីធនាគារថ្ងម៉ាកូ សម្រាប់រយៈពេលឥណទាន៥ ឆ្នាំ ដើម្បីបើកឃ្លាំងស្តុកដំឡូងមីនាំចេញទៅកាន់ប្រទេសថៃដែលជាកន្លែងកែច្នៃមុននាំចេញបន្តទៅប្រទេសចិនដែលជាទីផ្សារធំចុងក្រោយ។ គាត់ទទួលបានប្រាក់ចំណេញច្រើន ដោយសារតែដំឡូងមីឆៅឡើងថ្លៃនៅឆ្នាំ២០១៥។ តែនឹកស្មានមិនដល់ នៅខែកុម្ភៈ ឆ្នាំ២០១៦ តម្លៃដំឡូងមីឆៅបានធ្លាក់ចុះដោយសារតែតម្រូវការទាបនៅប្រទេសចិន និងការប្រកួតប្រជែងខ្ពស់ពីឈ្មួញនៅប្រទេសថៃ។ អាជីវកម្មរបស់សារ៉ា បានចាប់ផ្តើមមានបញ្ហាប្រឈមយ៉ាងធំនៅក្នុងការស្តុកទុកដំឡូងមីឆៅ។ ផ្អែកលើស្ថានភាពរបស់ សារ៉ា តើនេះគឺជាសញ្ញាព្រមានដំបូងសម្រាប់ឥណទានខុសប្រក្រតីមែនឬទេ? សូមឆ្លើយដោយធ្វើការពន្យល់បកស្រាយ។

### ឃ២.៣.២. ការឆ្លើយតបដែលអាចគ្មានក្រមសីលធម៌ចំពោះឥណទានមិនប្រក្រតី

ភាពមិនប្រក្រតីនៃឥណទានកើតឡើងនៅពេលដែល សមត្ថភាពសងកាន់តែមានលក្ខណៈយ៉ាប់យ៉ឺន ដែលអាចនាំឱ្យមានហានិភ័យមិនអាចទូទាត់សងបាន។ កត្តានេះបង្កើនសំវិធានធនឥណទាន ដែលប៉ះពាល់ដល់លទ្ធផលហិរញ្ញវត្ថុទាំងមូលរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ដើម្បីធ្វើការឆ្លើយតបត្រឹមត្រូវ វាទាមទារឱ្យមន្ត្រីឥណទានត្រូវមានការយល់ដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់អ្នកខ្ចីតាមរយៈការពិភាក្សា និងការវាយតម្លៃ។ មន្ត្រីឥណទានគួរសហការជាមួយអ្នកខ្ចីដើម្បីស្វែងរកផែនការសកម្មភាព/ដំណោះស្រាយដែលបានព្រមព្រៀងគ្នាដើម្បីដោះស្រាយបញ្ហា។ម្យ៉ាងទៀតដោយសារតែមាននូវដំណោះស្រាយនេះ មន្ត្រីឥណទានមានសម្ពាធតិចជាងមុនពីអ្នកគ្រប់គ្រងផ្ទាល់ និងទទួលបានការសន្យាប្តេជ្ញាក្នុងការបង់សងត្រឡប់ពីអ្នកខ្ចី។ ប៉ុន្តែ បញ្ហាសីលធម៌មួយចំនួនអាចនឹងកើតឡើងនៅក្នុងអំឡុងពេលប្រតិបត្តិការនេះ។

- **ការប្រជុំមិនមានលក្ខណៈវិជ្ជាជីវៈ** យោងតាមការពិភាក្សានៅក្នុងចំណុច ឃ២.២។
- **ដាក់សម្ពាធលើអ្នកខ្ចីឱ្យបង់ផ្តាច់ឥណទានទាំងអស់៖** ជំនួសឱ្យការស្វែងរកដំណោះស្រាយឱ្យបានត្រឹមត្រូវ មន្ត្រីឥណទានអាចមិនអើពើទៅលើសុខុមាលភាពរបស់អ្នកខ្ចី តែបែរជា

ស្វែងរកមធ្យោបាយរហ័សជាងនេះដើម្បីឱ្យអ្នកខ្ចីសងឥណទានផ្ដាច់និងចៀសវាងផលប៉ះពាល់អវិជ្ជមានមកលើប្រសិទ្ធភាពការងាររបស់ខ្លួន។

- **ការលក់ទ្រព្យសម្បត្តិ៖** មន្ត្រីឥណទានបង្ខំអ្នកខ្ចីឱ្យលក់ទ្រព្យសម្បត្តិដែលជាឧបករណ៍ចាំបាច់សម្រាប់រកចំណូលដើម្បីសងឥណទាន។
- **ឥណទានស្អាតជានិច្ច** (Evergreening)៖ មន្ត្រីឥណទានជំរុញឱ្យអ្នកខ្ចីស្វែងរកបុនហិរញ្ញប្បទានពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងទៀត ឬយកកម្ចីពីអ្នកចងការប្រាក់ក្នុងមូលដ្ឋានដែលអាចនឹងគិតការប្រាក់ខ្ពស់។ ជួនកាល មន្ត្រីឥណទានណែនាំអតិថិជនឱ្យទៅរកអ្នកចងការប្រាក់ក្នុងមូលដ្ឋានដើម្បីយកកម្ចីរយៈពេលខ្លីហើយចៀសវាងការរាយការណ៍អំពីភាពមិនប្រក្រតីមុននឹងឥណទានថ្មីរួចរាល់សម្រាប់អតិថិជន។

- **ការគៃបន្លំ និងអំពើពុករលួយ៖**
  - **កម្រៃជើងសារ ឬផលប្រយោជន៍ហិរញ្ញវត្ថុ៖** មន្ត្រីឥណទានបំភាន់អតិថិជនឱ្យលក់ ឬបញ្ចាំទ្រព្យសម្បត្តិ ទៅឱ្យហាងបញ្ចាំ ឬកម្ចីដែលមានការប្រាក់ថ្លៃដើម្បីបានសាច់ប្រាក់ហើយខ្លួនទទួលបានកម្រៃជើងសារ។
  - **អំពើសូកប៉ាន់៖** មន្ត្រីឥណទានបំភាន់អ្នកខ្ចីដើម្បីទទួលបានប្រាក់ជាថ្នូរនឹងការសម្រួលសំណើ សុំរៀបចំឥណទានឡើងវិញ ក៏ដូចជាលើកលែងការពិន័យ/កម្រៃពីការទូទាត់សងយឺតយ៉ាវ។

**សំណួរឆ្លុះបញ្ចាំង ឃ២.៣.២**

នៅឆ្នាំ២០១៥ ចូណាបានទទួលឥណទានចំនួន ៨០,០០០ ដុល្លារអាមេរិកពីធនាគារថូម៉ាក្ស សម្រាប់រយៈពេល ៥ ឆ្នាំដើម្បីបើកដេប៉ូលក់ជី។ គាត់បានដាក់ផ្ទះល្វែងពីរខ្នងរបស់គាត់ជាទ្រព្យធានា ដែលគាត់ជួលឱ្យគេក្នុងតម្លៃ១២០០ដុល្លារមេរិកក្នុងមួយខែ។ គាត់មានចំណូល៧០០ដុល្លារអាមេរិកក្នុងមួយខែក្នុងនាមជាបុគ្គលិកគណនេយ្យករ។ តាមរយៈប្រភពចំណូលទាំងបីនេះ គាត់អាចទូទាត់សងឥណទានចំនួន ២,០០០ ដុល្លារអាមេរិកក្នុងមួយខែ។ នៅខែមីនា ឆ្នាំ២០១៦ បងស្រីរបស់គាត់ធ្លាក់ខ្លួនឈឺ និងបានបញ្ជូនទៅព្យាបាលនៅទីក្រុងបាងកក។ អស់រយៈពេលពីរខែ ដេប៉ូលក់ជីរបស់គាត់ត្រូវបានបិទទ្វារ។ ជាលទ្ធផល ចូណាមិនអាចសងឥណទានសម្រាប់រយៈពេលពីរខែនេះបានទេ។ នៅខែឧសភា ប្រធានសាខារបស់ធនាគារ ថូម៉ាក្ស បានទូរសព្ទទៅគាត់ និងបានណែនាំឱ្យគាត់លក់ផ្ទះល្វែងពីរខ្នងរបស់គាត់។ គាត់បានណែនាំស្ត្រីម្នាក់ដែលគាត់ស្គាល់ និងចង់ទិញផ្ទះ ធ្វើដូច្នេះទើបគាត់អាចទទួលបានកម្រៃជើងសារមួយចំនួន។ តើការឆ្លើយតបរបស់ប្រធានសាខាមានក្រមសីលធម៌ឬទេ? ហេតុអ្វី?

## ឃ២.៤. គាំទ្រអតិថិជនដោះស្រាយឥណទានហួសកាលកំណត់សង

### ឃ២.៤.១. កំណត់ និងវិភាគបុព្វហេតុនៃឥណទានហួសកាលកំណត់សង

ឥណទានហួសកាលកំណត់សង កើតឡើងនៅពេលដែលឥណទានមិនត្រូវបានទូទាត់សងទាន់ពេលវេលាស្របតាមកាលវិភាគបង់ប្រាក់។ ខាងក្រោមនេះ គឺជាបុព្វហេតុមួយចំនួនដែលអាចនឹងនាំឱ្យមានឥណទានហួសកាលកំណត់សង។[102]

| ល.រ | ប្រភេទ | បុព្វហេតុ |
|---|---|---|
| ១ | គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | • **ការជ្រើសរើសអតិថិជនដែលមិនមែនជាអតិថិជនគោលដៅ៖** បុគ្គលិកគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនបានអនុវត្តតាម ដំណើរការជ្រើសរើស អតិថិជនឱ្យបានត្រឹមត្រូវ ដើម្បីសម្រេចផែនការគោលដៅរបស់ខ្លួន ដែលអាចនាំឱ្យមានឥណទានមិនបង្កើនចំណូល ហើយ ជាលទ្ធផល អតិថិជនគ្មានលទ្ធភាពទូទាត់សង។<br>• **ការបង្កើតផលិតផលឥណទានមិនសមស្រប៖** ផលិតផលឥណទានមានលក្ខណៈមួយដែលធ្វើឱ្យអតិថិជនប្រើប្រាស់ឥណទានមិនបានត្រឹមត្រូវ ដោយសារតែ៖<br>➢ គោលបំណងឥណទានមិនមានភាពបត់បែនគ្រប់គ្រាន់ ហើយអតិថិជនកុហកដើម្បីទទួលបានឥណទាន ដែលបានបំភាន់ដល់បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅពេលធ្វើការវិភាគសមត្ថភាពទូទាត់សង។<br>➢ ថ្លៃដើមនៃកម្ចីមិនអនុញ្ញាតឱ្យអតិថិជនទទួលបានប្រាក់ចំណេញសមស្រប ហេតុដូច្នេះប៉ះពាល់ដល់សមត្ថភាពទូទាត់សងរបស់អតិថិជន។<br>➢ ភាពញឹកញាប់នៃការទូទាត់សងមិនត្រូវគ្នាជាមួយនឹងលំហូរសាច់ប្រាក់របស់អតិថិជន។<br>• **រយៈពេលឥណទានមិនសមស្រប៖** រយៈពេលឥណទានមិនត្រូវគ្នាជាមួយនឹងវដ្តអាជីវកម្ម ឬវដ្តផលិតកម្មដែលធ្វើឱ្យអតិថិជនមិនអាចបង្កើនប្រាក់ចំណូល និងបង្កើតលំហូរសាច់ប្រាក់ឱ្យបានគ្រប់គ្រាន់ដើម្បីអាចទូទាត់សងតាមកាលវិភាគបង់ប្រាក់។ |

[102] (CGAP, 2009)

| | | |
|---|---|---|
| | | • **កង្វះទ្រព្យធានាសមស្រប៖** ទ្រព្យធានាដែលតម្រូវសម្រាប់ឥណទាន មិនងាយលក់ចេញ ពិបាកតាមដាន និងពិបាកគ្រប់គ្រង (ឧទាហរណ៍ ប្លង់ទន់ ឬប្លង់រឹង) ឬកម្មសិទ្ធិ (ឧទាហរណ៍ អាចផ្ទេរបានដោយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនបានដឹង)។ ឧទាហរណ៍ តម្លៃជាក់ស្តែងនៃទ្រព្យធានា គឺមានតម្លៃត្រឹមពាក់កណ្តាលនៃឥណទានប៉ុណ្ណោះ ដូច្នេះ អតិថិជនអាចមិនយកចិត្តទុកដាក់ទៅលើការទូទាត់សងឡើយ។<br><br>• **កង្វះការពន្យល់បកស្រាយត្រឹមត្រូវអំពីព័ត៌មានឥណទាន៖** បុគ្គលិកគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនបានផ្តល់ការពន្យល់បកស្រាយអំពីព័ត៌មានឥណទានបានច្បាស់លាស់ និងត្រឹមត្រូវដល់អ្នកខ្ចី អំពីចំណុចដូចខាងក្រោម<br>➢ ប្រភេទនៃការទូទាត់សង (ការសងប្រាក់ដើម ឬការសងសរុប ឧទាហរណ៍ កម្រៃតាមដានប្រចាំខែបូកនឹងប្រាក់ដើម និងការប្រាក់) និង<br>➢ លក្ខខណ្ឌឥណទាន (ការពិន័យលើការបង់ប្រាក់យឺតយ៉ាវ ការមិនទទួលការទូទាត់សងមុន លក្ខខណ្ឌឥណទាន)<br>• **ឆ្លើយតបយឺតយ៉ាវទៅនឹងសំណើឥណទានរបស់អ្នកខ្ចី៖** ចំណុចរួមមានដូចជា ការបង្កើនកម្រិតកំណត់ ឬការកែប្រែបណ្តោះអាសន្នទៅលើលក្ខខណ្ឌទូទាត់ដើម្បីដោះស្រាយបញ្ហាលំហូរសាច់ប្រាក់ បណ្តោះអាសន្ន ដែលអាចបណ្តាលមកពីការវិនិយោគរបស់អាជីវកម្ម ឬករណីលំហូរសាច់ប្រាក់ចេញផ្សេងៗ។ |
| ២ | អតិថិជន | • **គ្មានឆន្ទៈសង៖** អ្នកខ្ចីមិនចង់សងឥណទានដោយសារមូលហេតុមួយចំនួន។<br>• **បំភ្លៃការប្រើប្រាស់ឥណទាន៖** ឥណទានមិនត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ឬមិនត្រឹមត្រូវដែលប៉ះពាល់ដល់សមត្ថភាពទូទាត់សង។ ឧទាហរណ៍ ឥណទានត្រូវបានអនុម័តសម្រាប់ការដាំបន្លែ ប៉ុន្តែបែរជាយកទៅចែករំលែកជាមួយសាច់ញាតិទៅវិញ។ |

| | | |
|---|---|---|
| | | • **បញ្ហាលំហូរសាច់ប្រាក់៖** អ្នកខ្ចីជួបប្រទះនឹងការខាតក្នុងអាជីវកម្ម ឬប្រភពចំណូលធ្លាក់ចុះ ដែលអាចបណ្តាលមកពីកត្តាខាងក្នុង និងខាងក្រៅ៖<br>➢ **បរិយាកាសផ្ទៃក្នុងអាជីវកម្ម៖** រួមមាន ការផ្លាស់ប្តូរគណៈគ្រប់គ្រង បុគ្គលសំខាន់នៅក្នុងអាជីវកម្មទទួលមរណភាព បញ្ហាគ្រួសាររបស់ភាគីពាក់ព័ន្ធ/គណៈគ្រប់គ្រងសំខាន់ៗ ហានិភ័យ កេរ្តិ៍ឈ្មោះ ការវិនិយោគថ្មីៗ បញ្ហាគ្រប់គ្រងលំហូរសាច់ប្រាក់ជាដើម។ ចំពោះអ្នកខ្ចីជាបុគ្គលវិញ បញ្ហានេះ រួមមាន ការចាយវាយខ្ជះខ្ជាយ ដូចជា ការគ្រប់គ្រងចំណូលមិនបានល្អ ឬគ្មានចំណូល រួមទាំងការលេងល្បែងស៊ីសង និងការចំណាយលើរបស់របរប្រណីតៗ ការប្រែប្រួលមិនអំណោយផលនៃស្ថានភាពគ្រួសារ ដូចជា ការលែងលះ ឬអំពើហិង្សាក្នុង<br>គ្រួសារ។<br>➢ **បរិយាកាសខាងក្រៅអាជីវកម្ម៖** រួមមានស្ថានភាពទីផ្សារ ការប្រកួតប្រជែងជាដើម។ |
| ៣ | កត្តាខាងក្រៅ | • បទប្បញ្ញត្តិថ្មី ឬកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល។ ឧទាហរណ៍ រដ្ឋាភិបាលចេញគោលនយោបាយ និងបទប្បញ្ញត្តិ ដើម្បីពន្យារការទូទាត់សង ដោយសារតែកុបកម្ម ឬចលាចល និងព្រឹត្តិការណ៍ផ្សេងៗ។<br>• អស្ថិរភាព/ ភាពមិនច្បាស់លាស់នៃនយោបាយ (ឧទាហរណ៍ដូចជាសង្គ្រាម)<br>• ព្រឹត្តិការណ៍ផ្សេងៗទៀតដូចជា គ្រោះមហន្តរាយ វិបត្តិសេដ្ឋកិច្ច វិបត្តិជំងឺរាតត្បាតជាដើម។ |

**សំណួរឆ្លុះបញ្ចាំង ឃ២.៤.១**

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ក្រុមហ៊ុនអាហ្គ្រី ក្រប (Agri-Crop) បានទទួលឥណទានចំនួន ១០០,០០០ ដុល្លារអាមេរិកពីធនាគារថ្ងម៉ាក្ញ សម្រាប់រយៈពេល៦ ខែក្នុងគោលបំណងប្រើជាទុនបង្វិល។ ការទូទាត់ការប្រាក់ត្រូវធ្វើឡើងជារៀងរាល់ខែ ហើយការទូទាត់ប្រាក់ដើមនៅចុងបញ្ចប់នៃរយៈពេលឥណទាន។ ក្រុមហ៊ុនបានទិញស្រូវពីកសិករ និងសមាគម ហើយនាំចេញស្រូវទៅក្រៅប្រទេស។ ដោយសារតែបញ្ហារីករាលដាលជំងឺរាតត្បាតសកល កូវីដ-១៩ ប្រទេសនៅទិសដៅនាំចេញទទួលរងនូវការធ្លាក់ចុះចំណូល និងបានកាត់បន្ថយការនាំចូល។ ការនាំចេញរបស់ក្រុមហ៊ុនក៏មានការធ្លាក់ចុះផងដែរ ដូច្នេះហើយទើបមិនអាចមានលទ្ធភាពសងប្រាក់ដើមដល់ធនាគារ។ ចូរកំណត់អំពីមូលហេតុដែលក្រុមហ៊ុនមិនមានលទ្ធភាពសងឥណទាន។ សូមផ្តល់នូវចម្លើយបកស្រាយសមហេតុផល។

### ឃ២.៤.២. ផ្តល់ការគាំទ្រដល់អតិថិជនដែលហួសកាលកំណត់សង

ទោះបីជាការទូទាត់សងឥណទានទាន់ពេលវេលាគឺជាគន្លឹះឆ្ពោះទៅរកចីរភាពហិរញ្ញវត្ថុ និងលទ្ធភាពចំណេញសម្រាប់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដោយ ក៏មានស្ថានភាពជាច្រើនដែលអាចនាំឱ្យមានការសងឥណទានហួសកាលកំណត់។ បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានការយល់ដឹង និងចាត់វិធានការឱ្យបានសមស្រប។

### I. ការគាំទ្រអតិថិជន

គោលនយោបាយរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការប្រព្រឹត្តិរបស់បុគ្គលិកគឺជាកត្តាចម្បងក្នុងការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់អតិថិជន។

#### i. គោលនយោបាយដើម្បីធានាឱ្យបាននូវការផ្តល់ការគាំទ្រដល់អតិថិជនដែលហួសកាលកំណត់សង

- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរអនុវត្តស្តង់ដារការពារអតិថិជនដោយការយកចិត្តទុកដាក់។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានគោលនយោបាយស្តីពីការបង្កើត និងការផ្តល់ផលិតផលសមស្រប ដែលត្រូវមានការតាមដានលើ ចីរភាពរបស់ផលិតផល សេវា និងបណ្តាញផ្តល់ផលិតផល និងសេវានោះ។

- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរពង្រឹងការអនុវត្តក្រមប្រតិបត្តិ និងគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទានរួម[103] បន្ថែមពីលើវិធានការការពារអ្នកប្រើប្រាស់ដែលកំណត់ដោយសមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងធនាគារជាតិនៃកម្ពុជា ។
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែផ្តល់ការគាំទ្រឱ្យបានគ្រប់គ្រាន់ (ការណែនាំនិងការបណ្តុះបណ្តាល) សម្រាប់បុគ្គលិក និងអ្នកតំណាងដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការអនុលោមតាមក្រមប្រតិបត្តិ និងចូលរួមដោយទំនួលខុសត្រូវជាមួយអតិថិជនប្រកបដោយតម្លាភាព ភាពសមហេតុផល និងមានក្រមសីលធម៌។
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែមានគោលនយោបាយសម្រាប់កែប្រែកាលវិភាគសងឥណទានឡើងវិញធ្វើបុនហិរញ្ញប្បទាន និងលុបចោលឥណទាន ក្នុងករណីពិសេស។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរៀបរាប់ឱ្យបានច្បាស់អំពីករណីលំបាកជាក់លាក់ ដែលនៅក្រោមករណីទាំងនេះ អតិថិជនអាចនឹងទទួលបានការរៀបចំកាលវិភាគបង់ប្រាក់ឡើងវិញ ឬធ្វើបុនហិរញ្ញប្បទាន (refinancing) (ឧទាហរណ៍ គ្រោះមហន្តរាយធម្មជាតិ ឬបង្កឡើងដោយមនុស្ស ការសម្រាកព្យាបាលធ្ងន់ធ្ងរជាដើម។)
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវថែងឱ្យបានច្បាស់អំពីគុណតម្លៃ ស្តង់ដារនៃការប្រព្រឹត្តិប្រកបដោយលក្ខណៈវិជ្ជាជីវៈ និងការប្រព្រឹត្តចំពោះអតិថិជនដែលរំពឹងឱ្យបុគ្គលិកប្រព្រឹត្តតាម។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានថែងអំពីការដាក់ទណ្ឌកម្ម ដែលត្រូវអនុវត្តក្នុងករណីមានការរំលោភបំពានលើក្រមប្រតិបត្តិពាក់ព័ន្ធនឹងឥរិយាបថហាមឃាត់ដូចជា៖
  - ➢ ការប្រើប្រាស់ភាសាមិនសមរម្យ
  - ➢ ការប្រើប្រាស់កម្លាំងបាយដើម្បីបង្ខំឱ្យទូទាត់ឥណទាន
  - ➢ ការដាក់កម្រិតទៅលើសេរីភាពរូបរាងកាយរបស់អ្នកខ្ចី
  - ➢ ការស្រែកគំហកដាក់អ្នកខ្ចី
  - ➢ ការចូលក្នុងផ្ទះរបស់អ្នកខ្ចីដោយមិនមានការអញ្ជើញ
  - ➢ ជេរប្រមាថអ្នកខ្ចីជាសាធារណៈ
  - ➢ បំពានលើសិទ្ធិ ឬឯកជនភាពរបស់អ្នកខ្ចី

[103] (The Assocation of Banks in Cambodia; Cambodian Microfinance Association; & Cambodian Association Finance & Technology, 2022)

- ប្រព្រឹត្តមិនត្រឹមត្រូវចំពោះអ្នកខ្ចីដោយផ្អែកលើកត្តាដែលត្រូវបានការពារនានា (ឧទាហរណ៍ ជាតិសាសន៍ យេនឌ័រ អាយុ ពិការភាព ទំនាក់ទំនងនយោបាយ និន្នាការផ្លូវភេទ ឬសាសនា) ឬ
- ការប្រើពាក្យសម្តីបៀតបៀនផ្លូវភេទ ឬខ្វះសីលធម៌។

- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែរួមបញ្ចូល និងលើកកម្ពស់គោលនយោបាយស្តីពីការការពារអតិថិជន ហើយខិតខំប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីធានាថានឹងគ្មានករណីដែលអតិថិជនមានប្រាក់ចំណូលទាបត្រូវបង្ខំចិត្តលក់ទ្រព្យសម្បត្តិ ជាពិសេសដីធ្លី ដើម្បីសងឥណទាន។ ប្រសិនបើករណីនេះកើតឡើង គួរតែកើតឡើងតែនៅក្នុងកាលៈទេសៈកម្របំផុតប៉ុណ្ណោះ ហើយករណីនេះត្រូវចងក្រង និងរាយការណ៍ឱ្យបានត្រឹមត្រូវជូនអ្នកគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាននីមួយៗ។[104]

## ii. សមត្ថភាពរបស់បុគ្គលិកជួរមុខក្នុងការគាំទ្រអតិថិជនដែលហួសកាលកំណត់សង

- **ការយកចិត្តទុកដាក់ស្គាល់អតិថិជន៖** បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែសិក្សាឱ្យបានល្អិតល្អន់អំពីមូលហេតុជាក់លាក់ដែលនាំឱ្យមានឥណទានហួសកាលកំណត់សង ជាជាងការសន្មតថាអ្នកខ្ចីមិនចង់សងឥណទាន។
- **ការពិគ្រោះយោបល់៖** ផ្តល់ការពិគ្រោះយោបល់ផ្នែកអាជីវកម្មដល់អ្នកខ្ចី គឺជាសេវាគាំទ្រសហគមន៍ ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនផ្តល់ជូន។ ក្នុងករណីដែលការពិគ្រោះយោបល់អំពីប្រតិបត្តិការអាជីវកម្ម គឺហួសពីសមត្ថភាពរបស់ខ្លួន មន្ត្រីឥណទានគួរតែកម្រិតត្រឹមការពិគ្រោះយោបល់អំពីដំណោះស្រាយដែលពាក់ព័ន្ធនឹងឥណទាន និងផលិតផលរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។
- **ការគាំទ្ររឹងមាំ៖** បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែពិភាក្សាជាមួយអ្នកគ្រប់គ្រងផ្ទាល់ថាតើការពន្យារការទូទាត់សងឥណទានក្នុងរយៈពេលណាមួយអាចទៅរួចដែរឬទេ? ផ្ទុយទៅវិញ បុគ្គលិកបានធ្វើការគំរាមកំហែង ឬរំលោភបំពានលើអ្នកខ្ចីឱ្យសងឥណទានភ្លាមៗ ដូចជា ការបង្ខំអតិថិជនឱ្យស្វែងរកកម្ចីមិនស្របច្បាប់ដែលមានការប្រាក់ថ្លៃ។
- **ការជំរុញដោយការលើកទឹកចិត្តធៀបជាមួយនឹងការជំរុញដោយការគាំទ្រ៖** នៅពេលដែលអ្នកខ្ចីស្នើសុំទូទាត់សងឥណទានមួយផ្នែក ចំណុចនេះគួរតែចាត់ទុកថាជាការមិនពាក់ព័ន្ធទៅនឹងលទ្ធផល និងគម្រោងលើកទឹកចិត្តរបស់មន្ត្រីឥណទាន។ បុគ្គលិក

[104] (The Assocation of Banks in Cambodia; Cambodian Microfinance Association; & Cambodian Association Finance & Technology, 2022)

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំណាប់អារម្មណ៍តែទៅលើការជំរុញអ្នកខ្ចីឱ្យទូទាត់សងឥណទានដោយមិនគិតអំពីស្ថានភាពរបស់អតិថិជនឡើយ។

**ប្រភេទឥណទានហួសកាលកំណត់សង៖** ការចាត់ថ្នាក់គឺផ្អែកលើកត្តាអថេរពីរ៖ ឆន្ទៈបង់ និងសមត្ថភាពបង់ ដែលបែងចែកជាបួនប្រភេទដូចខាងក្រោម៖

- មានឆន្ទៈ និងសមត្ថភាពសង
- មានឆន្ទៈ តែមិនមានសមត្ថភាពសង
- មិនមានឆន្ទៈ តែមានសមត្ថភាពសង ឬ
- មិនមានឆន្ទៈ និងមិនមានសមត្ថភាពសង។

បន្ទាប់មក សកម្មភាពស្តារឥណទានទៅវិញទៅមកមួយចំនួនត្រូវបានបង្កើតឡើង និងអនុវត្តដោយផ្អែកលើប្រភេទនីមួយៗ។ នៅពេលឥណទានហួសកាលកំណត់សង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែសិក្សាឱ្យបានល្អិតល្អន់ទៅលើប្រភពចំណូលដែលមាន និងឆន្ទៈរបស់អ្នកខ្ចីឥណទាន ដើម្បីធានាឱ្យបាននូវការចាត់ថ្នាក់ឥណទានឱ្យបានត្រឹមត្រូវ។ ដូច្នេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចអនុវត្តវិធានការស្តារឥណទានសមស្រប និងផ្តល់ការគាំទ្រត្រឹមត្រូវដល់អ្នកខ្ចី។

## II. ការផ្តល់ការគាំទ្រដល់អតិថិជនងាយរងគ្រោះ

វិធានការល្អដែលត្រូវអនុវត្ត គួរតែកំណត់លើការកាត់បន្ថយផលប៉ះពាល់ដែលអាចកើតឡើងសម្រាប់អតិថិជនកម្ចី និង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ យកល្អបំផុត អតិថិជនងាយរងគ្រោះគួរតែទទួលបានការគាំទ្របន្ថែម រួមទាំង គ្រួសារដែលមានចំណូលទាប មនុស្សចាស់ គ្រួសារមានតែឪពុក/ម្តាយ អ្នកមានពិការភាព ឬអ្នកខ្ចីដែលមានចំណេះដឹងហិរញ្ញវត្ថុកម្រិតទាប ដែលជារឿយៗពួកគេរងគ្រោះពីការអនុវត្តការប្រមូលឥណទានដែលគ្មានក្រមសីលធម៌[105]ដោយមិនគិតអំពីប្រភេទអ្នកខ្ចី ដូចដែលបានអនុវត្តដោយវិស័យទាំងនៅក្នុងប្រទេស និងក្រៅប្រទេស គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចផ្តល់ការគាំទ្រលើការរៀបចំហ្វាស៊ីលីធី (facility) ឡើងវិញដែលរួមមានដូចខាងក្រោម៖

- **ការកាត់បន្ថយការទូទាត់សង ដែលជម្រើសនេះអាចអនុវត្តតាមវិធីពីរយ៉ាង៖** (១) ការពន្យាររយៈពេលឥណទាន ឬ (២) ការបែងចែកចំណែកនៃប្រាក់ដើមដែលត្រូវបង់នៅពេលវេលា ឬកាលកំណត់ជាក់លាក់។ ការអនុវត្តនេះតម្រូវអតិថិជនធ្វើការទូទាត់ទាំងប្រាក់ដើម និងការ

[105] (World Bank, 2017)

ប្រាក់ ប៉ុន្តែទូទាត់ប្រាក់ដើមក្នុងបរិមាណទាបជាងមុន។ ជាទូទៅ ជម្រើសនេះ អនុវត្តនៅពេលដែលអតិថិជនជួបបញ្ហាចំណូលថយចុះទាំងរយៈពេលខ្លី និងរយៈពេលវែង។ គុណសម្បត្តិរបស់វាគឺ ការអនុវត្តជម្រើសនេះជួយអតិថិជនទូទាត់ទាំងប្រាក់ដើម និងការប្រាក់តាមរយៈពេលឥណទានថ្មីដែលសមស្របតាមកម្រិតប្រាក់ចំណូលបច្ចុប្បន្នរបស់ពួកគាត់។ គុណវិបត្តិគឺ ការអនុវត្តជម្រើសនេះអូសបន្លាយរយៈពេលឥណទាន ដូច្នេះអតិថិជនត្រូវសងការប្រាក់កាន់តែច្រើន ហើយប្រាក់ដើមគឺត្រូវរំលស់ក្នុងរយៈពេលយូរជាងមុន។

- **ការពន្យារពេលសងប្រាក់ដើម និង/ឬការប្រាក់៖** ជម្រើសនេះអាចអនុវត្តដោយផ្តល់រយៈពេលអនុគ្រោះ ដល់អ្នកខ្ចី ដោយតម្រូវឱ្យសងតែការប្រាក់ ឬមិនមានការទូទាត់សងទាល់តែសោះ។ ជាទូទៅ ជម្រើសនេះអនុវត្តនៅពេលដែលអតិថិជនជួបបញ្ហាធ្លាក់ចុះប្រាក់ចំណូលខ្លាំងជាបណ្តោះអាសន្ន ឧទាហរណ៍ ការផ្ទុះជំងឺកូវីដ-១៩ និងគ្រោះមហន្តរាយធម្មជាតិជាដើម។ គុណសម្បត្តិគឺ អ្នកខ្ចីត្រូវបង់ចំនួនទឹកប្រាក់ទាបជាងមុន ឬមិនបង់ទាល់តែសោះដែលសមស្របបំផុតតាមការលំបាកផ្នែកហិរញ្ញវត្ថុធ្ងន់ធ្ងរនាពេលបច្ចុប្បន្ន ប៉ុន្តែប្រាក់ដើមឥណទានមិនថយចុះនោះទេក្នុងអំឡុងពេលអនុគ្រោះនេះហើយក្នុងករណីមួយចំនួន ការសងការប្រាក់ដែលបានពន្យារ នឹងត្រូវបានធ្វើមូលធនកម្ម (capitalized) ជា ប្រាក់ដើមដូច្នេះបង្កើនចំនួនទឹកប្រាក់ឥណទានដែលនៅសល់។

- **ការកាត់បន្ថយអត្រាការប្រាក់៖** ជម្រើសនេះអាចអនុវត្តបានដោយការបន្ទាបអត្រាការប្រាក់ ឬការលើកលែងសោហ៊ុយការប្រាក់មួយចំនួន។ ជាទូទៅ ជម្រើសនេះអនុវត្តតែនៅពេលដែលអតិថិជនជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្នប៉ុណ្ណោះ ដូចជា ប្រាក់ចំណូលធ្លាក់ចុះជាដើម។ គុណសម្បត្តិគឺ ដំណោះស្រាយនេះអាចប្រើប្រាស់បានដើម្បីជំរុញអ្នកខ្ចីឱ្យសង
ឥណទាន ជាជាងការផ្តល់រយៈពេលអនុគ្រោះឬការពន្យារពេលការសងប្រាក់ដើមទៅឥណប្រតិទាន។ ប៉ុន្តែ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវខាតការប្រាក់។ បច្ចុប្បន្ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កម្រអនុវត្តជម្រើសនេះខ្លាំងណាស់។

- **ការពន្យារឥណប្រតិទាន ឬកាលបរិច្ឆេទបង់ប្រាក់៖** ជម្រើសនេះអាចអនុវត្តបានតាមរយៈការពន្យាឥណប្រតិទាន ឬកាលបរិច្ឆេទបង់ប្រាក់ទៅកាលបរិច្ឆេទណាមួយផ្សេងទៀតនាពេលអនាគត។ ជាទូទៅ ជម្រើសនេះអាចអនុវត្តបានចំពោះឥណទានដែលទូទាត់សងតាមរដូវកាល(ឧទាហរណ៍ ប្រចាំត្រីមាស ប្រចាំឆមាស ជាដើម) ហើយអ្នកខ្ចីជួបនឹងការលំបាក

ផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្នដោយសារតែមានព្រឹត្តិការណ៍មិនបានគ្រោងទុក ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ឬការមិនអាចប្រមូលបំណុល/ប្រាក់ត្រូវទទួលណាមួយ។ គុណសម្បត្តិគឺ ការអនុវត្តជម្រើសបែបនេះផ្តល់ឱកាសជាលើកទីពីរដល់អ្នកខ្ចីទូទាត់សងដោយផ្អែកលើស្ថានភាពលំបាកបច្ចុប្បន្នរបស់ពួកគាត់ ប៉ុន្តែ គឺមានភាពមិនច្បាស់លាស់ដែលថាអ្នកខ្ចីអាចធ្វើការទូទាត់សងនៅកាលកំណត់ថ្មីដោយសារតែចំណូលរបស់ពួកគាត់គឺតាមរដូវកាលដែរសម្រាប់ការរៀបចំបែបនេះ។

- **ការបន្ថែមអ្នករួមខ្ចី និង/ឬអ្នកធានា៖** ជម្រើសនេះអាចអនុវត្តទៅបានដោយបន្ថែមអ្នករួមខ្ចី ឬអ្នកធានាដើម្បីធានានូវលទ្ធភាពទូទាត់សង ឬគាំទ្រដល់ការទូទាត់សងនៅពេលដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានមន្ទិលសង្ស័យពាក់ព័ន្ធនឹងសមត្ថភាពទូទាត់សងរបស់អ្នកខ្ចីបច្ចុប្បន្ន។ គុណសម្បត្តិគឺ ឱកាសទូទាត់សងគឺមានកម្រិតខ្ពស់ជាងមុន និងមានបុគ្គលបង្គោលច្រើនជាងមុនដើម្បីសម្រួលដល់ការទូទាត់សង។ ក៏ប៉ុន្តែ តាមបច្ចេកទេសគឺមានការពិបាកក្នុងការស្វែងរកអ្នកដែលមានបំណងធ្វើជាអ្នករួមខ្ចី ឬអ្នកធានាចំពោះឥណទានមានបញ្ហាណាស់។

- **ការផ្លាស់ប្តូរវិធីសាស្ត្រទូទាត់សង៖** ជម្រើសនេះអាចអនុវត្តបានដោយការកែប្រែវិធីសាស្ត្រទូទាត់សងឱ្យទៅជាការទូទាត់សងមិនសូវញឹកញាប់វិញ ឧទាហរណ៍ ប្តូរពីប្រចាំខែទៅជាប្រចាំត្រីមាស ឬពីប្រចាំត្រីមាសទៅជាប្រចាំឆមាសវិញ។ ជាទូទៅជម្រើសនេះអាចអនុវត្តបានចំពោះអ្នកខ្ចីដែលជួបប្រទះការប្រែប្រួលប្រាក់ចំណូល និង/ឬលំនាំលំហូរសាច់ប្រាក់។ គុណសម្បត្តិគឺថា វិធីសាស្ត្រទូទាត់ថ្មីនឹងសម្រួលដល់ការផ្លាស់ប្តូរទាំងនោះ និងដោះស្រាយបញ្ហាទូទាត់សងផងដែរ។ ក៏ប៉ុន្តែ នៅមានភាពមិនច្បាស់លាស់ថាតើវិធីសាស្ត្រទូទាត់សងថ្មីនេះនឹងអាចសមស្របទៅនឹងការប្រែប្រួលប្រាក់ចំណូល និង/ឬលំនាំលំហូរសាច់ប្រាក់របស់អតិថិជនដែរឬទេ ជាពិសេស ប្រសិនបើការប្រែប្រួលនេះពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៃដំណើរការអាជីវកម្ម។

- **ការលើកលែងទ្រព្យធានា៖** ជម្រើសនេះអាចអនុវត្តបានតាមរយៈការបញ្ចេញទ្រព្យធានាមួយ ឬច្រើនដល់អតិថិជនដើម្បីប្រើប្រាស់សម្រាប់បង្កើតចំណូល ឬលក់ចេញ។ ចំណុចនេះអាចអនុវត្តបានចំពោះអតិថិជននានា ប៉ុន្តែជាទូទៅគឺចំពោះអតិថិជនដែលមានទ្រព្យធានាលើសពីមួយ។ គុណសម្បត្តិគឺថាការអនុវត្តបែបនេះអនុញ្ញាតឱ្យអតិថិជនបង្កើតចំណូលបានកាន់តែច្រើន ឬលក់អចលនទ្រព្យចេញដែលជាលទ្ធផល បង្កើនលទ្ធភាពនៃការទូទាត់

សង។ នៅក្នុងករណីមួយចំនួន អ្នកខ្ចីប្រើប្រាស់ផលនៃការលក់ទ្រព្យធានា ដើម្បីសងឥណទានដែលនៅសល់មួយចំនួនឬទាំងអស់។ ប៉ុន្តែ ការអនុវត្តបែបនេះនាំឱ្យមានអនុបាតឥណទានធៀបនឹងតម្លៃ (LTV) កាន់តែខ្ពស់ ប្រសិនបើអតិថិជនមិនគោរពតាមការសន្យាទូទាត់សង។

- **ការលើកលែងការសន្យាឥណទាន៖** ការសន្យាឥណទាន រួមបញ្ចូលនៅក្នុងកិច្ចសន្យាឥណទាន ដើម្បីកាត់បន្ថយហានិភ័យឥណទានដែលអាចកើតឡើងក្នុងគោលបំណងទប់ស្កាត់ការខកខានសងឥណទាន។ ការសន្យាមួយចំនួន ក៏អាចបន្ធូរបន្ថយសម្ពាធហិរញ្ញវត្ថុបណ្ដោះអាសន្នបានដែរ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ខ្លះ កំណត់លក្ខខណ្ឌបំពាន នៅក្នុងកិច្ចសន្យាឥណទាន និងតម្រូវឱ្យអតិថិជនអនុលោមតាមការសន្យាទាំងនេះ។ ប្រសិនបើអ្នកខ្ចីមិនបំពេញតាមការសន្យានេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចប្រមូលឥណទានមកវិញ។ ឧទាហរណ៍ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ខ្លះនឹងប្រមូលយកឥណទានមកវិញប្រសិនបើអាជីវកម្មរបស់អ្នកខ្ចីខាតក្នុងរយៈពេលបីខែជាប់ៗគ្នា ប៉ុន្តែ គ្រឹះស្ថាន អាចលើកលែង លក្ខខណ្ឌនេះបានដោយសារតែផលវិបាកសេដ្ឋកិច្ចរយៈពេលវែងដែលមិនអាចព្យាករដឹងមុន។

**សំណួរឆ្លុះបញ្ចាំង ឃ ២.៤.២**

នៅខែមករា ឆ្នាំ២០២០ សុខា បានទទួលឥណទានចំនួន១០,០០០ដុល្លារអាមេរិកពីធនាគារថូម៉ាក្ង ដោយមានអត្រាការប្រាក់ប្រចាំខែ១.៣% សម្រាប់រយៈពេលឥណទាន៣ឆ្នាំ។ គាត់ត្រូវបង់ប្រាក់ដើម និងការប្រាក់ចំនួន៤១០ដុល្លារអាមេរិកក្នុងមួយខែ។ គាត់មានលទ្ធភាពទូទាត់សងឥណទានទាន់ពេលវេលាពេញមួយឆ្នាំ២០២០។ គួរឱ្យសោកស្ដាយ ដោយសារតែការបិទច្រកព្រំដែនបណ្ដាលមកពីជម្លោះយោធា អាជីវកម្មរបស់សុខាដំណើរការមិនល្អឡើយ។ ប្រាក់ចំណូលបានធ្លាក់ចុះ៥០% បើធៀបទៅនឹងប្រាក់ចំណូលនៅមុនខែកុម្ភៈ ឆ្នាំ២០២១។ គាត់ខំប្រឹងប្រែងសន្សំប្រាក់ខ្លាំងមែនទែន និងបង្ហាញឆន្ទៈរបស់គាត់ក្នុងការអនុវត្តកាតព្វកិច្ចទូទាត់សងឥណទាន។ គាត់បានរាយការណ៍អំពីស្ថានភាពបច្ចុប្បន្ននៃអាជីវកម្មរបស់គាត់ដល់បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជានិច្ច ហើយបានស្នើសុំការគាំទ្រពីធនាគារតាមមធ្យោបាយណាក៏ដោយ។ តើអ្វីទៅជាដំណោះស្រាយសមស្របបំផុតដែលអ្នកណែនាំដល់ សុខា ប្រសិនបើអ្នកជាបុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលខុសត្រូវចំពោះការគ្រប់គ្រងឥណទាននេះ? សូមឆ្លើយដោយពន្យល់បកស្រាយ។

## ឃ២.៥. ទប់ស្កាត់បំណុលវណ្ឌក

ការទប់ស្កាត់បំណុលវណ្ឌក គឺជាចំណុចអាទិភាពសំខាន់មួយក្នុងចំណោមចំណុចអាទិភាពនានារបស់ ធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដូចដែលបានឆ្លុះបញ្ចាំងតាមរយៈគំនិតផ្តួចផ្តើមជាច្រើនរួចមកហើយ ដូចជា កម្មវិធីយុទ្ធនាការ ចំណេះដឹងហិរញ្ញវត្ថុ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមគោលការណ៍ដែលមានចែងនៅក្នុងគោលការណ៍ណែនាំរបស់វិស័យដើម្បីទប់ស្កាត់បំណុលវណ្ឌក ជាពិសេស ចំពោះការគ្រប់គ្រងឥណទានច្រើន និងការដាក់ឱ្យប្រើប្រាស់នូវយន្តការវាយតម្លៃឥណទានឱ្យបានត្រឹមត្រូវ។

### ការវាយតម្លៃហិរញ្ញវត្ថុល្អិតល្អន់

ការវាយតម្លៃហិរញ្ញវត្ថុធូររលុងគួបផ្សំជាមួយនឹងបច្ចេកទេសលក់បង្ខំរបស់មន្ត្រីឥណទាន និង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ភាគច្រើនជាបុព្វហេតុទូទៅធ្វើឱ្យអតិថិជនជាប់បំណុលវណ្ឌក។ ជារឿយៗ ការវាយតម្លៃហិរញ្ញវត្ថុធូររលុងនាំឱ្យ៖

- ការបំប៉ោងប្រាក់ចំណូល
- ការបន្ទាបការចំណាយ
- ការបំប៉ោងតម្លៃនៃទ្រព្យសម្បត្តិ ឬ
- ការបន្ទាបបំណុល

ដោយហេតុថាវិស័យធនាគារមានការរីកចម្រើនខ្លាំង តម្រូវការជ្រើសរើសបុគ្គលិក ជាពិសេសបុគ្គលិកជួរមុខ មានការប្រកួតប្រជែងគ្នាជាខ្លាំង និងអាចនាំឱ្យមានការបន្ថយស្តង់ដារលក្ខណៈវិនិច្ឆ័យ ជ្រើសរើសបុគ្គលិក ឬអាចមានការអូសទាញបុគ្គលិកមិនសមស្របនៅពេលដាក់គោលដៅលើអ្នកដែលមានបទពិសោធការងារ។ ទោះជាតាមមធ្យោបាយណាក៏ដោយ ប្រសិនបើមិនមានកម្មវិធីកសាងសមត្ថភាពបុគ្គលិកត្រឹមត្រូវទេនោះ និង/ឬជាមួយនឹងការកំណត់គោលដៅលក់ដោយបង្ខំនោះ បំណុលវណ្ឌកអាចនឹងកើតមានឡើង ឬនៅទីបំផុត អ្នកខ្ចីនឹងក្លាយជាអ្នកដែលទទួលរងផលប៉ះពាល់អវិជ្ជមានជាក់ជាមិនខាន។

## ការអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន

ឧបករណ៍សំខាន់មួយទៀតដែលប្រើប្រាស់ដើម្បីទប់ស្កាត់បំណុលវណ្តក គឺការអនុវត្តគោលការណ៍រួមស្តីពីការផ្តល់ឥណទាន។ គោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន មានសមាសធាតុសំខាន់ៗបីដូចខាងក្រោម៖

- **ការបញ្ចូលទិន្នន័យ** – គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបញ្ចូលទិន្នន័យទៅក្នុងផ្លែតហ្វមរបស់ការិយាល័យឥណទានកម្ពុជាឱ្យបានទាន់ពេលវេលាក្នុងរយៈពេល៥ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទផ្តល់ឥណទានដល់អតិថិជន។
- **វិធានពហុកម្ចី**- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនអាចធ្វើជាអ្នកផ្តល់សេវាឥណទានទីបួននោះទេ ប្រសិនបើអតិថិជនមានទំនាក់ទំនងឥណទានជាមួយនឹង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួនបីផ្សេងទៀតរួចហើយនោះ ហើយចំនួនទឹកប្រាក់ដែលបានផ្តល់ដំបូងគឺតូចជាង ឬស្មើនឹង ២០,០០០ ដុល្លារអាមេរិក ដូចមានបង្ហាញនៅក្នុងឧទាហរណ៍ខាងក្រោម។

| | BFI ទី១ | BFI ទី២ | BFI ទី៣ | លទ្ធភាពនៃការក្លាយជា BFI ទី៤? |
|---|---|---|---|---|
| ចំនួនទឹកប្រាក់ដែលបានផ្តល់ | 2,000 ដុល្លារអាមេរិក | 5,000 ដុល្លារអាមេរិក | 10,000 ដុល្លារអាមេរិក | ទេ |
| ចំនួនទឹកប្រាក់ដែលបានផ្តល់ | 2,000 ដុល្លារអាមេរិក | 5,000 ដុល្លារអាមេរិក | 20,000 ដុល្លារអាមេរិក | ទេ |
| ចំនួនទឹកប្រាក់ដែលបានផ្តល់ | 2,000 ដុល្លារអាមេរិក | 5,000 ដុល្លារអាមេរិក | 25,000 ដុល្លារអាមេរិក | បាទ/ចាស |
| ចំនួនទឹកប្រាក់ដែលបានផ្តល់ | 22,000 ដុល្លារអាមេរិក | 23,000 ដុល្លារអាមេរិក | 30,000 ដុល្លារអាមេរិក | បាទ/ចាស |

## វិធានបុនហិរញ្ញប្បទានឥណទាន

- មិនថាឥណទានថ្មីត្រូវបានផ្តល់ឱ្យដោយម្ចាស់ឥណទានដដែល ឬម្ចាស់ឥណទានផ្សេងនោះទេ ឥណទាននេះត្រូវបានចាត់ទុកដូចជាឥណទានដែលបានធ្វើបុនហិរញ្ញប្បទាន ដែរ ប្រសិនបើឥណទាននេះត្រូវបានផ្តល់ជូនក្នុងរយៈពេល ១៥ ថ្ងៃនៅមុន ឬបន្ទាប់ពីការបង់ផ្តាច់មុននៃឥណទានដែលមានស្រាប់។

- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលធ្វើបុនហិរញ្ញប្បទានឥណទានយ៉ាងសកម្មពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងទៀត អាចបង្កហានិភ័យបំណុលវណ្ឌកដល់អតិថិជន និងធ្វើឱ្យខូចដល់ទីផ្សារ។
- រយៈពេល និងទំហំឥណទាន គឺត្រូវបានប្រើប្រាស់ជារង្វាស់ហានិភ័យដើម្បីបង្ហាញអំពីកម្រិតហានិភ័យនៃការធ្វើបុនហិរញ្ញប្បទានឥណទាន។ តារាងខាងក្រោម គឺជាឧទាហរណ៍អំពីម៉ាទ្រីសហានិភ័យឥណទាន។

| ប្រតិបត្តិការបុនហិរញ្ញប្បទាន (refinancing) | ទំហំឥណទានកើតឡើង | | |
|---|---|---|---|
| | ហានិភ័យទាប | ហានិភ័យមធ្យម | ហានិភ័យខ្ពស់ |
| ត្រីមាសទី1 (1/3) | < 110% | ≥ 110% - < 140% | ≥ 140% |
| ត្រីមាសទី2 (2/3) | < 120% | ≥ 120% - < 180% | ≥ 180% |
| ត្រីមាសទី3 (3/3) | <160% | ≥ 160% ឡើងទៅ | មិនពាក់ព័ន្ធ |

**កំណត់សម្គាល់៖**

- ត្រីមាសគឺជារយៈពេលដែលរយៈពេលឥណទានពីមុនត្រូវបានធ្វើបុនហិរញ្ញប្បទាន និងស្មើនឹង ១/៣ នៃរយៈពេលឥណទានដែលបានអនុម័ត។ ឧទាហរណ៍ ប្រសិនបើរយៈពេលឥណទានគឺ ៦០ ខែ ត្រីមាសនៃរយៈពេលឥណទាននោះគឺស្មើនឹង ២០ ខែ។
- ទំហំឥណទានកើនឡើង សំដៅទៅលើការប្រៀបធៀបភាគរយនៃឥណទានថ្មី ធៀបនឹងឥណទានចាស់ ដែលឥណទានទាំងពីរនេះសុទ្ធតែផ្អែកលើចំនួនទឹកប្រាក់ដែលបានអនុម័ត។
- មិនមានពិតានកំណត់សម្រាប់បុនហិរញ្ញប្បទានហានិភ័យទាបទេ ។
- បុនហិរញ្ញប្បទានហានិភ័យមធ្យមមិនត្រូវលើសពី ១៥% នៃចំនួនសរុបនៃឥណទានដែលបានផ្តល់ជូននៅក្នុងខែនោះឡើយ។
- បុនហិរញ្ញប្បទានហានិភ័យខ្ពស់ មិនត្រូវលើសពី ៥% នៃចំនួនសរុបនៃឥណទានដែលបានផ្តល់ជូននៅក្នុងខែនោះឡើយ។

**សំណួរឆ្លុះបញ្ចាំង ឃ២.៥.**

ចាន់ថា កំពុងជាប់ឥណទានចំនួន ៥,០០០ ដុល្លារអាមេរិករយៈពេលពីរឆ្នាំនៅគ្រឹះស្ថានរុក្ខា ហ្វាយណាន់។ ឥណទាននេះបានបើកជូនគាត់កាលពីពេលបីខែមុន។ ដោយបុណ្យចូលឆ្នាំខ្មែរខិតជិត

មកដល់ គាត់រំពឹងថាអាជីវកម្មហាងលក់គ្រឿងទេសរបស់គាត់នឹងដំណើរការល្អ។ គាត់បានទៅរកបុគ្គលិករបស់គ្រឹះស្ថានរុក្ខាហ្វាយណាន់ ដើម្បីខ្ចីឥណទានបន្ថែម។ ប៉ុន្តែ ពាក្យស្នើសុំឥណទានថ្មីរបស់គាត់ត្រូវបានបដិសេធដោយសារតែគាត់នៅជាប់ឥណទានចំនួន៥០០០ ដុល្លារអាមេរិកនៅឡើយ។ គាត់បានទៅរកបុគ្គលិកមកពីធនាគារថូម៉ាក្វ។ បុគ្គលិកនោះបានណែនាំពាក្យស្នើសុំឥណទានចំនួន១០,០០០ ដុល្លារសម្រាប់គាត់ ក្រោមលក្ខខណ្ឌឱ្យគាត់បង់ផ្តាច់ឥណទានពីគ្រឹះស្ថានរុក្ខាហ្វាយណាន់។ គាត់បានយល់ព្រមចំពោះលក្ខខណ្ឌនេះ។ ពាក្យស្នើសុំឥណទានថ្មីបានដំណើរការក្នុងរយៈពេល ២ ថ្ងៃ ហើយធនាគារ ថូម៉ាក្វ បានផ្តល់ទឹកប្រាក់ឥណទានចំនួន ១០,០០០ ដុល្លារអាមេរិកជូនដល់ ចាន់ថា។ គាត់បានប្រើប្រាស់ឥណទាននោះដើម្បីបង់ផ្តាច់ឥណទានពី គ្រឹះស្ថានរុក្ខាហ្វាយណាន់ នៅពេលបង់រំលោះលើកទីបួន។ សូមពន្យល់បកស្រាយថាតើការធ្វើបែបនេះគឺជាការធ្វើបុនហិរញ្ញប្បទានឥណទានមែនទេ? ប្រសិនបើមែន តើការអនុវត្តបែបនេះស្ថិតក្រោមបុនហិរញ្ញប្បទានហានិភ័យទាប ហានិភ័យមធ្យម ឬហានិភ័យខ្ពស់? ហេតុអ្វី?

## ឃ២.៦. គោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន (LG)

### ឃ២.៦.១. ការអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន

- គោលការណ៍ណែនាំស្តីពីការផ្តល់ឥណទានត្រូវបានអនុវត្តចំពោះអ្នកផ្តល់សេវាហិរញ្ញវត្ថុផ្លូវការដែលមានអាជ្ញាបណ្ណចេញដោយ ធនាគារជាតិនៃកម្ពុជា រួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានឥណទានជនបទ និងក្រុមហ៊ុនភតិសន្យា។
- គោលការណ៍ណែនាំស្តីពីការផ្តល់ឥណទានអនុវត្តចំពោះពាក្យស្នើសុំឥណទានរហូតដល់ ២០,០០០ ដុល្លារអាមេរិក ឬរូបិយបណ្ណសមមូល។

### ឃ២.៦.២. ការលើកលែងចំពោះការអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន

- គណនីខាងក្រោមនេះ គឺត្រូវបានលើកលែងពីការអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន៖
  - ឥណទានដែលមានទំហំជាង២០,០០០ ដុល្លារអាមេរិក ឬរូបិយបណ្ណសមមូល
  - បណ្ណឥណទាន
  - ឥណទានវិបារូបន៍
  - ឥណទានសម្រាប់ទុនបង្វិល (Revolving loans) និង
  - ឥណទានហិរញ្ញប្បទានពាណិជ្ជកម្ម។

### ឃ២.៦.៣. លក្ខខណ្ឌអំពីការរំលោភបំពានលើគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន

- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នឹងត្រូវចាត់ទុកថាបានរំលោភបំពានទៅលើគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន ប្រសិនបើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នោះអនុម័តលើពាក្យស្នើសុំឥណទានដែលមានទឹកប្រាក់តិចជាង ឬស្មើនឹង ២០,០០០ ដុល្លារអាមេរិកខណៈ ពេលដែលអ្នកដាក់ពាក្យសុំកំពុងស្ថិតក្រោមលក្ខខណ្ឌដូចខាងក្រោម។
  - អ្នកដាក់ពាក្យសុំបច្ចុប្បន្នកំពុងមានទំនាក់ទំនងឥណទានជាមួយស្ថាប័នហិរញ្ញវត្ថុយ៉ាងតិចចំនួន ៣ និង
  - ចំនួនទឹកប្រាក់ឥណទានដែលបានអនុម័តទាំងបីនោះមានចំនួនតិចជាង ឬស្មើនឹង ២០០,០០ ដុល្លារអាមេរិក ឬរូបិយបណ្ណសមមូល។

### ឃ២.៦.៤. ផលប៉ះពាល់ដែលអាចមានសម្រាប់ការរំលោភបំពានលើគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន

- របាយការណ៍ព្រឹត្តិបត្រ (Dashboard) គោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន ត្រូវបានបញ្ជូនទៅកាន់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗដើម្បីធ្វើការតាមដាន ត្រួតពិនិត្យដោយខ្លួនឯង និងចាត់វិធានការកែតម្រូវ។
- សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា តាមដានត្រួតពិនិត្យការអនុវត្តនិងវិភាគភាពធ្ងន់ធ្ងរ និងផលប៉ះពាល់នៃការរំលោភបំពានដែលអាចកើតឡើង។
- សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជានឹងបញ្ជូនលិខិតព្រមានដល់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពាក់ព័ន្ធដើម្បីជម្រាបដល់ គ្រឹះស្ថាន ទាំងនោះអំពីការរំលោភបំពាន និងណែនាំនូវវិធានការកែតម្រូវ។
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពាក់ព័ន្ធអាចនឹងមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានការបញ្ជាក់ទទួលស្គាល់គោលការណ៍ស្តីពីការការពារអ្នកប្រើប្រាស់ (CPP) ឡើយដោយសារតែកម្រិតបំពានខ្ពស់លើគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាននេះ។
- ដូចគ្នានេះដែរ ចំពោះ គ្រឹះស្ថាន ពាក់ព័ន្ធ វិនិយោគិនសង្គម អាចនឹងមិនចង់វិនិយោគលើ គ្រឹះស្ថាន ណាដែលមានកម្រិតបំពានខ្ពស់លើគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាននេះ។
- ការរំលោភបំពាននេះក៏ប៉ះពាល់ទៅលើកេរ្តិ៍ឈ្មោះរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយអាចប្រឈមនឹងការដាក់ទណ្ឌកម្មពីនិយ័តករទៀតផង។

### ឃ២.៦.៥. អនុសាសន៍សម្រាប់ការអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន

បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវយល់ច្បាស់អំពីគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទានចំពោះ ការរំលោភបំពានលើវិធានពហុកម្ចី និងវិធានបុនហិរញ្ញប្បទាន (refinancing) ហានិភ័យខ្ពស់ ដោយសារតែការរំលោភបំពានទាំងនេះនឹងជះឥទ្ធិពលដល់ ដំណើរការពាក្យស្នើសុំឥណទានសម្រាប់អតិថិជន។ នៅពេលបដិសេធពាក្យស្នើសុំឥណទាន បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវជម្រាបប្រាប់អ្នកដាក់ពាក្យសុំឱ្យបានត្រឹមត្រូវអំពីមូលហេតុនៃការបដិសេធនោះ។ បុគ្គលិកក៏ត្រូវជម្រាបដល់អ្នកដាក់ពាក្យសុំថាការសម្រេចរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺដើម្បីការពារដល់វិស័យទាំងមូល និងដើម្បីពង្រឹងវិន័យឥណទានក្នុងចំណោមអ្នកខ្ចីសំដៅរួមចំណែកដល់ចីរភាពហិរញ្ញវត្ថុ។ (សម្រាប់របៀបដោះស្រាយបំណុលវណ្ឌកសូមមើលផ្នែក ឃ២.៥)

**ការបដិសេធមិនទទួលខុសត្រូវ៖** ផ្នែកខាងលើដែលរៀបរាប់អំពីគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន គឺស្ថិតនៅក្នុងរយៈពេលអនុវត្តបណ្តោះអាសន្នដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ ការអនុវត្តនេះអាចមានការផ្លាស់ប្តូរនាពេលអនាគត។

**សំណួរឆ្លុះបញ្ចាំង ឃ២.៦**

ចាន់ទ្រា កំពុងមានទំនាក់ទំនងឥណទានជាមួយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួន ៣ ក្នុងទំហំទឹកប្រាក់កម្ចីដើមចំនួន ២៣,០០០ ដុល្លារអាមេរិក ៩,០០០ ដុល្លារអាមេរិក និង ៧,០០០ ដុល្លារអាមេរិកសម្រាប់កម្ចីនីមួយៗ។ គាត់ទៅរកបុគ្គលិករបស់គ្រឹះស្ថានរុក្ខាហ្វាយណាន់ដើម្បីស្នើសុំឥណទានចំនួន ៦,០០០ ដុល្លារអាមេរិកទៀត។ ចំពោះករណីនេះ តើគ្រឹះស្ថានរុក្ខាហ្វាយណាន់ បំពានទៅលើគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទានដែរឬទេ ប្រសិនបើគ្រឹះស្ថានរុក្ខាហ្វាយណាន់ អនុម័តផ្តល់ឥណទានបន្ទាប់ពីបានធ្វើការវាយតម្លៃឥណទានបានត្រឹមត្រូវ? ហេតុអ្វី?

## ឃ២.៧. របាយការណ៍របស់ការិយាល័យឥណទានកម្ពុជាអំពីសកម្មភាពអនុលោមតាមគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន

### ឃ២.៧.១. នីតិវិធីក្នុងការរាយការណ៍អំពីសកម្មភាពនៃគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន

ដើម្បីធានាបាននូវការតាមដានត្រួតពិនិត្យដោយប្រសិទ្ធភាព ទៅលើការអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន ការិយាល័យឥណទានកម្ពុជា នឹងចេញរបាយការណ៍

ព្រឹត្តិបត្រ (Dashboard) ដាច់ដោយឡែកស្តីពីអនុលោមភាពតាមគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទានជារៀងរាល់ខែ។

ការរំលោភបំពានលើគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទានដែលពាក់ព័ន្ធទៅនឹង ក) ការបញ្ចូលទិន្នន័យ ខ) វិធានពហុកម្ចី និង គ) ការធ្វើបុនហិរញ្ញប្បទាន (refinancing) ឥណទាន អាចមានឥទ្ធិពលអវិជ្ជមានមកលើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលអាចកម្រិតសមត្ថភាព ក្នុងការទទួលបានកម្ចីពីអ្នកផ្តល់កម្ចីបច្ចុប្បន្ន និងអនាគត ការព្រមាន និងទណ្ឌកម្មរបស់សមាគម និងនិយ័តករ។

ពាក់ព័ន្ធនឹងការរាយការណ៍ទិន្នន័យជូន ការិយាល័យឥណទានកម្ពុជា គោលការណ៍ណែនាំស្តីពីការផ្តល់ឥណទានមានដូចខាងក្រោម៖[106]

- រាល់ឥណទានដែលបញ្ចេញនាពេលថ្មីៗ និងឥណទានដែលបានបិទទាំងអស់ ត្រូវរាយការណ៍ជូនការិយាល័យឥណទានកម្ពុជាជារៀងរាល់សប្តាហ៍នៅក្នុងរយៈពេល ៥ ថ្ងៃធ្វើការ និង
- ពង្រឹងការត្រួតពិនិត្យ រួមទាំងគ្រប់គ្រងការបញ្ចូលទិន្នន័យទៅក្នុង ការិយាល័យឥណទានកម្ពុជា ពាក់ព័ន្ធនឹងទិន្នន័យហិរញ្ញវត្ថុ (រួមទាំងព័ត៌មានលម្អិតអំពីអត្តសញ្ញាណផ្ទាល់ខ្លួន)។

### ឃ២.៧.២. គំរូរបាយការណ៍ព្រឹត្តិបត្រនៃគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន[107]

របាយការណ៍ព្រឹត្តិបត្រ (Dashboard) នៃគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន គ្របដណ្តប់លើ

- ផ្នែកទី ១៖ ការរំលោភបំពានលើវិធានពហុកម្ចី
- ផ្នែកទី ២៖ ការរំលោភបំពានលើវិធានបញ្ចូលទិន្នន័យ
- ផ្នែកទី ៣៖ អនុបាតឥណទានធៀបនឹងចំណូល
- ផ្នែកទី ៤៖ ឥណទានហានិភ័យខ្ពស់ដែលមានការផ្លាស់ប្តូរអ្នកផ្តល់កម្ចី
- ផ្នែកទី ៥៖ ម៉ាទ្រីសហានិភ័យឥណទាន

[106] (The Association of Banks in Cambodia, Cambodian Microfinance Association, Cambodian Association of Finance & Technology, 2022)
[107] (The Association of Banks in Cambodia & Cambodian Microfinance Assoication, 2022)

**គំរូរបាយការណ៍ព្រឹត្តិបត្រ (Dashboard) នៃគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន។**

ខាងក្រោមនេះគឺជាគំរូរបាយការណ៍ពី ការិយាល័យឥណទានកម្ពុជា ដែលបង្ហាញអំពីការប្រៀបធៀប គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗទៅនឹងវិស័យធនាគារ ឬវិស័យមីក្រូហិរញ្ញវត្ថុ



### ឃ២.៧.៣ ការបកស្រាយរបាយការណ៍ព្រឹត្តិបត្រ (Dashboard) នៃគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទានស្តីពីសកម្មភាពអនុលោមភាព

#### ផ្នែកទី១៖ ការរំលោភបំពានលើវិធានពហុកម្ចី

**Section 1: Multiple loan rule violation**

| Member | | Microfinance Sector | | Industry | |
|---|---|---|---|---|---|
| Borrowers | Percent | Borrowers | Percent | Borrowers | Percent |
| 15 | 1.11% | 1,884 | 0.99% | 2,202 | 0.84% |

- **សេចក្តីពណ៌នា៖** ក្រាហ្វនេះបង្ហាញអំពីការរំលោភបំពានលើវិធានពហុកម្ចីដោយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រៀបធៀបជាមួយនឹងវិស័យ និងឧស្សាហកម្ម។
- **ពាក្យគន្លឹះ៖**
  - **វិធានពហុកម្ចី៖** ប្រសិនបើអ្នកខ្ចីមានឥណទានចំនួនបីរួចទៅហើយដែលមានទំហំទឹកប្រាក់ទាបជាង ២០,០០០ ដុល្លារអាមេរិកពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួនបី នោះមិនត្រូវផ្តល់ឥណទានទីបួនទៀតឡើយ។
  - **អ្នកខ្ចី៖** ចំនួនអ្នកខ្ចីដែលមានឥណទានទីបួនជាមួយនឹង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងៗគ្នាលើសពី ៣
  - **ភាគរយ៖** ភាគរយនៃអ្នកខ្ចីដែលមានឥណទានទីបួនជាមួយនឹង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងៗគ្នាលើសពី ៣
- **ការបកស្រាយ៖** កម្រិតកំណត់អតិបរមានៃការរំលោភបំពានលើវិធានពហុកម្ចីគឺ ២%។ ភាគរយនៃការរំលោភបំពានខ្ពស់ជាងនេះ បង្ហាញអំពីការបង្ខំរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលអាចនាំឱ្យមានបំណុលវណ្ឌកដល់អ្នកខ្ចី។ ដូច្នេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗគួរធ្វើយ៉ាងណាឱ្យមានភាគរយទាបជាង ២%។
- **ការអាន៖**
  - នៅក្នុងចំណោមឥណទានដែលបានផ្តល់ជូនទាំងអស់ក្នុងអំឡុងខែរាយការណ៍ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានផ្តល់ឥណទានដល់អ្នកខ្ចីចំនួន ១៥ នាក់ដែលបានបំពានលើ

វិធានផ្តល់ពហុកម្ម។ ការរំលោភបំពាននេះគឺស្មើនឹង ១.១១% ធៀបទៅនឹង ០០.៩៩% ចំពោះការរំលោភបំពានរបស់វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ០.៨៤% សម្រាប់ការរំលោភបំពានរបស់ឧស្សាហកម្មទាំងមូល។

- នៅក្នុងឧទាហរណ៍នេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដំណើរការយ៉ាប់យ៉ឺនខ្លាំងជាង វិស័យមីក្រូហិរញ្ញវត្ថុ និងឧស្សាហកម្មទាំងមូលទៅទៀត។ ទោះជាយ៉ាងនេះក្តី ការរំលោភបំពានរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមកម្រិតកំណត់ ២%។

### ផ្នែកទី ២៖ ការរំលោភបំពានលើវិធានបញ្ចូលទិន្នន័យ

| Section 2: Data Upload Violation (later than 5 bussiness days) | | | | | |
|---|---|---|---|---|---|
| Member | | Microfinance Sector | | Industry | |
| New Acc | Close Acc | New Acc | Close Acc | New Acc | Close Acc |
| 0% | 0% | 7% | 18% | 26% | 34% |

- **សេចក្តីពណ៌នា៖** ក្រាហ្វនេះបង្ហាញអំពីការរំលោភបំពានលើការបញ្ចូលទិន្នន័យអំពីគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន ដែលហួសរយៈពេល៥ថ្ងៃធ្វើការ។
- **ពាក្យគន្លឹះ៖**
  - **ការរំលោភបំពានទិន្នន័យ៖** ទិន្នន័យអំពីគណនីថ្មី និងគណនីបិទទាំងអស់ ត្រូវដាក់ជូនការិយាល័យឥណទានកម្ពុជាមិនឱ្យហួសរយៈពេល៥ថ្ងៃធ្វើការឡើយ។
  - **គណនីថ្មី៖** ភាគរយនៃការរាយការណ៍យឺតយ៉ាវអំពីគណនីថ្មី
  - **គណនីបិទ៖** ភាគរយនៃការរាយការណ៍យឺតយ៉ាវអំពីគណនីបិទ
- **ការបកស្រាយ៖** គោលដៅសម្រាប់ការរំលោភបំពានគឺមិនត្រូវលើសពី ៥% សម្រាប់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗ វិស័យ និងឧស្សាហកម្មទាំងមូល។ ដូច្នេះ ប្រសិនបើភាគរយសម្រាប់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗទាបជាង ៥% នោះភាគរយនេះបង្ហាញពីការអនុលោមបានល្អ ដែលអាចជួយឱ្យវិស័យចៀសផុតពីការជាប់បំណុលវណ្ណក។
  - នៅក្នុងឧទាហរណ៍នេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានបញ្ចូលទិន្នន័យអំពីគណនីថ្មី និងគណនីបិទចូលទៅក្នុងការិយាល័យឥណទានកម្ពុជាបានទាន់ពេលវេលា (នៅក្នុងរយៈពេល ៥ថ្ងៃធ្វើការ) ខណៈដែលវិស័យមីក្រូហិរញ្ញវត្ថុបានរំលោភបំពាន ៧% សម្រាប់ការ

បញ្ចូលទិន្នន័យអំពីគណនីថ្មី និង ១៨% សម្រាប់ការបិទគណនី។ ឧស្សាហកម្មទាំងមូលបានបំពាន ២៦% ចំពោះការបញ្ចូលទិន្នន័យថ្មី និង ៣៩% ចំពោះការបិទគណនី។

- ➢ នៅក្នុងឧទាហរណ៍នេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានដំណើរការល្អប្រសើរជាងវិស័យមីក្រូហិរញ្ញវត្ថុ និងឧស្សាហកម្មទាំងមូល។

## ផ្នែកទី ៣៖ អនុបាតឥណទានធៀបនឹងចំណូល




- **សេចក្តីពណ៌នា៖** ក្រាហ្វនេះបង្ហាញពីអនុបាតឥណទានធៀបនឹងចំណូលរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយប្រៀបធៀបជាមួយនឹងវិស័យ និងឧស្សាហកម្ម។
- **ពាក្យគន្លឹះ៖**
  - ➢ **ចំណូល ឬចំណូលដុល៖** រួមមានចំណូលរបស់អ្នកខ្ចី ចំណូលរបស់អ្នករួមខ្ចី និងចំណូលគាំទ្រផ្សេងៗ ដែលបានកត់ត្រានៅក្នុងពាក្យស្នើសុំឥណទាន។
  - ➢ **ចំនួនទឹកប្រាក់ឥណទាន៖** តំណាងឱ្យចំនួនទឹកប្រាក់ដើមដំបូងដែលផ្តល់ជូនដោយគ្រឹះស្ថានរាយការណ៍។ ចំនួនទឹកប្រាក់នេះមិនរួមបញ្ចូលសមតុល្យឥណទានបច្ចុប្បន្នដែលអ្នកខ្ចីកំពុងជំពាក់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងទៀតឡើយ។
  - ➢ **អនុបាតឥណទានធៀបនឹងចំណូល** (Loan to Income Ratio, LTI)៖ ចំនួនទឹកប្រាក់ឥណទាន / ចំណូល *១០០% (ឧទាហរណ៍អតិថិជនម្នាក់មានឥណទានចំនួន ១,០០០ ដុល្លា និងចំណូលចំនួន ៨០០ដុល្លា។ ដូច្នេះ LTI = ១,០០០/៨០០*១០០ = ១២៥%)
  - ➢ **ភាគរយ (អ័ក្ស X)** បង្ហាញពីភាគរយនៃអនុបាតឥណទានធៀបនឹងចំណូល។
  - ➢ **ភាគរយនៅខាងលើរបារ** បង្ហាញពីភាគរយនៃឥណទានសរុបដែលបានផ្តល់ជូននៅក្នុងអំឡុងខែដែលស្ថិតនៅក្រោមអនុបាតឥណទានធៀបនឹងចំណូលនីមួយៗ។
- **ការបកស្រាយ៖** អនុបាតនៃចំនួនទឹកប្រាក់ឥណទានធៀបនឹងចំណូលកាន់តែខ្ពស់ ហានិភ័យនៃការជាប់បំណុលវណ្ឌកក៏កាន់តែខ្ពស់ដែរ។

- **ការអាន៖** នៅក្នុងក្រាហ្វទីមួយនៃ "សមាជិក" មានអតិថិជនរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួន ៣១.៤០% ដែលមានអនុបាត LTI (ឥណទានធៀបនឹងចំណូល) ចន្លោះពី ១០០% ទៅ ២០០%។ ចំនួនអតិថិជនប្រភេទនេះមានតែ ១៣.៨៥% ប៉ុណ្ណោះសម្រាប់វិស័យ ធនាគារ ដូចនៅក្នុងក្រាហ្វទីពីរ "វិស័យធនាគារ" និង ៥.០៣% សម្រាប់ឧស្សាហកម្មទាំងមូលនៅក្នុងក្រាហ្វទីបី "ឧស្សាហកម្ម"។ តួលេខនេះឆ្លុះបញ្ចាំងឱ្យឃើញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានផ្តល់ឥណទានដែលមានហានិភ័យឥណទានក្នុងកម្រិតខ្ពស់ខ្លាំង ដែលអាចសន្មតបានថា នឹងនាំឱ្យមានការជាប់បំណុលវណ្ណក។ អនុបាតរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺយ៉ាប់យ៉ឺនជាងវិស័យ និងឧស្សាហកម្មទាំងមូល។

**សំណួរឆ្លុះបញ្ចាំង យ២.៧.៣ (ក)**

ចូរប្រៀបធៀបអនុបាតឥណទានធៀបនឹងចំណូល (LTI) ២០០-១,០០០% របស់សមាជិកទៅនឹងវិស័យ និងឧស្សាហកម្ម។

## ផ្នែកទី ៤៖ ឥណទានហានិភ័យខ្ពស់ដែលមានការផ្លាស់ប្តូរអ្នកផ្តល់កម្ចី




- **សេចក្តីពណ៌នា៖** ក្រាហ្វនេះបង្ហាញពីភាគរយនៃឥណទានហានិភ័យខ្ពស់ជាប្រចាំខែរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រៀបធៀបជាមួយនឹងវិស័យ និងឧស្សាហកម្ម។
- **ពាក្យគន្លឹះ៖**
  - **ឥណទានហានិភ័យខ្ពស់៖** ឥណទាននេះសំដៅលើការធ្វើបុនហិរញ្ញប្បទាន (refinancing) ឥណទាន ដែលកើតឡើងនៅពេលដែល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទៅរកអតិថិជនដែលកំពុងជំពាក់អ្នកផ្តល់កម្ចីចំនួនបីរួចទៅហើយ ហើយផ្តល់ឥណទានទីបួននៅក្រោមលក្ខខណ្ឌបុនហិរញ្ញប្បទានឥណទាន។
  - **ភាគរយ (អ័ក្ស Y)៖** ភាគរយនៃឥណទានហានិភ័យខ្ពស់

- ➢ **ចំនួន (អ័ក្ស X)៖** តំណាងឱ្យខែនៃឆ្នាំជាក់លាក់ ឧទាហរណ៍, ២០២១០៣ = ខែមីនា ឆ្នាំ២០២១, ២០២១០៤ = ខែមេសា ឆ្នាំ២០២១

- **ការបកស្រាយ៖** ភាគរយខ្ពស់តំណាងឱ្យឥណទានហានិភ័យខ្ពស់ ដែលអាចនាំឱ្យមានការជាប់បំណុលវណ្ឌកហេតុដូច្នេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗ គួរតែខំប្រឹងធ្វើយ៉ាងណារក្សាឱ្យភាគរយនេះទាបជាងភាគរយរបស់វិស័យ និងឧស្សាហកម្ម។
- **ការអាន៖** នៅក្នុងឧទាហរណ៍នេះ សម្រាប់ខែឧសភា ឆ្នាំ២០២១ ជាខែរាយការណ៍ (របារទីបី៖២០២១០៥) គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានឥណទាន បានធ្វើបុនហិរញ្ញប្បទានចំនួន ១៨.៥០% នៃឥណទានសរុប (បុនហិរញ្ញប្បទានផ្ទៃក្នុង និងខាងក្រៅ) ខណៈដែលតួលេខរបស់វិស័យធនាគារគឺមានតែ ៦.៩២% និង៧.០១% សម្រាប់ឧស្សាហកម្មទាំងមូលប៉ុណ្ណោះ។ តួលេខនេះឆ្លុះបញ្ចាំងឱ្យឃើញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានបង្ខំធ្វើបុនហិរញ្ញប្បទានឥណទាន បើធៀបជាមួយនឹងឧស្សាហកម្មទាំងមូល ដែលអាចនាំឱ្យមានការជាប់បំណុលវណ្ឌក និងការប្រកួតប្រជែងកាន់តែតានតឹងនៅក្នុងវិស័យ។

## ផ្នែកទី ៥៖ ម៉ាទ្រីសហានិភ័យឥណទាន




- **សេចក្ដីពណ៌នា៖** ក្រាហ្វនេះបង្ហាញពីព័ត៌មានលម្អិតអំពីឥណទានដែលមានហានិភ័យដោយសារតែសកម្មភាពបុនហិរញ្ញប្បទាន (refinancing)។ ភាពលម្អៀងរវាងក្រាហ្វនេះ និងក្រាហ្វពីមុន មានបង្ហាញនៅពេលក្រោយ ដែលបង្ហាញពីការប្រៀបធៀបជាមួយវិស័យ និងឧស្សាហកម្ម។
- **ពាក្យគន្លឹះ៖** (ដូចគ្នាទៅនឹងក្រាហ្វខាងលើ)
- **ការបកស្រាយ៖** (ដូចគ្នាទៅនឹងក្រាហ្វខាងលើ)
- **ការអាន៖** នៅក្នុងឧទាហរណ៍នេះ សម្រាប់ខែឧសភា ឆ្នាំ២០២១ ជាខែរាយការណ៍ (របារទីបីនៅក្នុងក្រាហ្វ៖២០២១០៥) គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានធ្វើបុនហិរញ្ញប្បទានឥណទានហានិភ័យខ្ពស់ចំនួន ៧.២៦% ខណៈដែលតួលេខរបស់វិស័យធនាគារគឺមានត្រឹមតែ២.៩៦% និង៤.០១% សម្រាប់ឧស្សាហកម្មទាំងមូលប៉ុណ្ណោះ។ តួលេខនេះឆ្លុះ

បញ្ជាំងឱ្យឃើញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានដំណើរការយ៉ាប់យ៉ឺនជាងវិស័យធនាគារ និងឧស្សាហកម្មទាំងមូលទៅទៀត។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ថែមទាំងបានបំពានលើកម្រិតកំណត់ចំនួន ២.២៦% ពីលើពិតានអតិបរិមា ៥%។

**សំណួរឆ្លុះបញ្ចាំង ឃ២.៧.៣ (ខ)**

ចូរប្រៀបធៀបហានិភ័យមធ្យមរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទៅនឹងវិស័យនិងឧស្សាហកម្ម។

## ឃ៣. ស្តារឡើងវិញនូវឥណទានមិនដំណើរការ (NPL) ប្រកបដោយសីលធម៌

### ឃ.៣.១. តើអ្វីទៅគឺជាឥណទានមិនដំណើរការ?

ឥណទានដែលចាត់ថ្នាក់ជា "ឥណទានដំណើរការ" និង "ឥណទានមិនដំណើរការ" គឺផ្អែកលើសមត្ថភាពទូទាត់សងរបស់អ្នកខ្ចី។ យោងតាមនិយមន័យរបស់ ធនាគារជាតិនៃកម្ពុជា ឥណទានមិនដំណើរការសំដៅទៅលើទ្រព្យសកម្មដែលលែងអាចបង្កើតចំណូល និងត្រូវផ្អែកលើចំណុចខាងក្រោម៖[108]

i. ឥណទានដែលត្រូវបានចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ ឥណទានសង្ស័យ ឬចំឥណទានបាត់បង់សម្រាប់ទាំងឥណទានរយៈពេលខ្លី និងរយៈពេលវែង ដោយផ្អែកលើចំនួនថ្ងៃហួសកាលកំណត់សងដូចមានក្នុងតារាងខាងក្រោម៖

| ការចាត់ថ្នាក់ឥណទាន | ថ្ងៃហួសកាលកំណត់សង | | ប្រភេទ |
|---|---|---|---|
| | ឥណទានមានរយៈពេលតិចជាង ១ ឆ្នាំ | ឥណទានមានរយៈពេលលើសពី ១ ឆ្នាំ | |
| ឥណទានធម្មតា | <=១៤ ថ្ងៃ | <=២៩ ថ្ងៃ | ឥណទានដំណើរការ |
| ឥណទានឃ្លាំមើល | ១៥-៣០ថ្ងៃ | ៣០-៨៩ថ្ងៃ | |
| ឥណទានក្រោមស្តង់ដារ | ៣១-៦០ ថ្ងៃ | ៩០-១៧៩ ថ្ងៃ | ឥណទានមិនដំណើរការ |

[108] (National Bank of Cambodia, 2017)

| | | | |
|---|---|---|---|
| ឥណទានសង្ស័យ | ៦១-៩០ ថ្ងៃ | ១៨០-៣៥៩ ថ្ងៃ | |
| ឥណទានបាត់បង់ | >=៩១ ថ្ងៃ | >=៣៦០ ថ្ងៃ | |

ii. ទោះបីឥណទានជាឥណទានកំពុងដំណើរការក៏ដោយ ប្រសិនបើមានហេតុការណ៍ណាមួយ ដែលអាចជះឥទ្ធិពលអវិជ្ជមានខ្លាំងទៅលើសមត្ថភាពទូទាត់សងដោយផ្អែកលើការវាយតម្លៃផ្ទៃក្នុង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរធ្វើការចាត់ថ្នាក់អវិជ្ជមានលើឥណទាន។ លក្ខណៈវិនិច្ឆ័យខាងក្រោម ត្រូវបានយកមកពិចារណាបន្ថែម ពីលើថ្ងៃហួសកាលកំណត់សង។ យោងតាមលក្ខខណ្ឌតម្រូវរបស់ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានប្រព័ន្ធចាត់ថ្នាក់ហានិភ័យឥណទានដើម្បីវាយតម្លៃសមត្ថភាពទូទាត់សងរបស់អ្នកខ្ចី ដែលលក្ខណៈវិនិច្ឆ័យទាំងនោះ យ៉ាងហោចណាស់គួរតែមានចំណុចដូចខាងក្រោម៖

- **បទពិសោធទូទាត់ពីមុន៖** តើមានបញ្ហាណាមួយលើកំណត់ត្រាតាមដានការទូទាត់សងពីមុនដែរឬទេ? ប្រសិនបើ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានទិញរបាយការណ៍ តាមដានពីការិយាល័យឥណទានកម្ពុជានោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនឹងទទួលបានព័ត៌មានបច្ចុប្បន្នភាពប្រចាំថ្ងៃអំពីស្ថានភាពរបស់អ្នកខ្ចី រួមទាំងពាក្យស្នើសុំឥណទានឥណទានថ្មី ឬការលុបចោលឥណទាន ពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងទៀត។ ហ្វាស៊ីលីធីហួសកាលកំណត់សង ត្រូវចាត់ទុកថាមានហានិភ័យខ្ពស់ក្នុងការទូទាត់សងជាងហ្វាស៊ីលីធីកំពុងដំណើរការស្របតាមលក្ខខណ្ឌកិច្ចសន្យា។
- **ស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន ឬព្យាករណ៍របស់អ្នកខ្ចី៖** សំដៅលើលទ្ធផលហិរញ្ញវត្ថុរបស់អ្នកខ្ចី ក្នុងន័យប្រាក់ចំណេញ ប្រសិទ្ធផល សន្ទនីយភាព និងជំហររីកចម្រើន។
- **ទិដ្ឋភាពអាជីវកម្ម និងការព្យាករណ៍លំហូរសាច់ប្រាក់ដោយផ្អែកលើការសន្មតជាក់ស្តែង និងយកចិត្តទុកដាក់៖** សំដៅទៅលើទិដ្ឋភាពឧស្សាហកម្ម កម្រិតនៃការប្រកួតប្រជែង តម្រូវការបច្ចុប្បន្ន និងអនាគតនៃផលិតផល/សេវាកម្ម និន្នាការលក់ (រីកចម្រើនមានស្ថិរភាព ឬធ្លាក់ចុះ) ស្ថានភាពលំហូរសាច់ប្រាក់រឹងមាំ (ជាពិសេស លំហូរសាច់ប្រាក់ពីប្រតិបត្តិការ)។
- **បរិយាកាសសេដ្ឋកិច្ច៖** បរិយាកាសនេះគឺស្ថិតនៅកម្រិតម៉ាក្រូសេដ្ឋកិច្ច។ នៅពេលដែលមានកំណើនសេដ្ឋកិច្ច កំណើននេះនឹងមានឥទ្ធិពលវិជ្ជមានមកលើអាជីវកម្ម។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវដាក់បញ្ចូលបរិយាកាសសេដ្ឋកិច្ចទៅក្នុងការវាយតម្លៃស្ថានភាពហិរញ្ញវត្ថុក៏ដូចជាទិដ្ឋភាពអាជីវកម្ម និងលំហូរសាច់ប្រាក់/លទ្ធផលអាជីវកម្មនាពេលអនាគតរបស់អ្នកខ្ចីផងដែរ។

**សំណួរឆ្លុះបញ្ចាំង ឃ.៣.១.**

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ចាន់ថា បានទទួលឥណទានចំនួន ៥,០០០ ដុល្លារអាមេរិកពីគ្រឹះស្ថានរុក្ខាហ្វាយណាន់ ដែលរយៈពេលឥណទានមួយឆ្នាំ ក្រោមអត្រាការប្រាក់ប្រចាំខែ ១.៥% ដោយគ្មានទ្រព្យធានា ប៉ុន្តែមានពូគាត់ធ្វើជាអ្នកធានា។ ប្រាក់ដើម និងការប្រាក់ត្រូវទូទាត់ជារៀងរាល់ខែ។ គាត់បានប្រើប្រាស់ឥណទាននោះដើម្បីទិញអីវ៉ាន់ដាក់ស្តុកបន្ថែមសម្រាប់លក់នៅក្នុងហាង បេប៊ី ឃៃររបស់គាត់។ នៅពេលធ្វើការវាយតម្លៃពាក្យស្នើសុំឥណទានគ្រឹះស្ថានរុក្ខាហ្វាយណាន់ បានរកឃើញថា ចាន់ថា ជាប់ឥណទានជាមួយនឹង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួនពីរផ្សេងទៀតរួចទៅហើយគឺធនាគារមោះ ប៊ែងឃ៍ (Moh Bank) និងធនាគារស៊ី ប៊ែងឃ៍ (C Bank) ដោយមានទឹកប្រាក់ចំនួន១០,០០០ ដុល្លារអាមេរិកសម្រាប់ឥណទាននីមួយៗ។

នៅពេលដែលបានទទួលការទូទាត់សងខែទីមួយពី ចាន់ថា គ្រឹះស្ថានរុក្ខាហ្វាយណាន់ ក៏បានទទួលការជូនដំណឹងពីការិយាល័យឥណទានកម្ពុជាថា គាត់មិនបានបង់ធនាគារមោះ ប៊ែងឃ៍ នៅក្នុងខែនោះទេ។ ករណីនេះក៏បានកើតឡើងចំពោះធនាគារស៊ី ប៊ែងឃ៍ ដែរនៅក្នុងខែបន្ទាប់។ នៅក្នុងអំឡុងពេលបង់លើកទីពីរ (ថ្ងៃទី១ ខែមីនា)ចាន់ថា បានទូទាត់សងឥណទានជូនគ្រឹះស្ថានរុក្ខាហ្វាយណាន់ យឺត១០ ថ្ងៃ។ បន្ទាប់ពីនោះមក បុគ្គលិករបស់គ្រឹះស្ថានរុក្ខាហ្វាយណាន់ បានចុះទៅហាង បេប៊ី ឃៃរ របស់គាត់ផ្ទាល់ ហើយបានដឹងថាហាងនោះគឺបានបិទទ្វារតាំងពីកាលបរិច្ឆេទផ្តល់ឥណទានមកម្ល៉េះ។ បន្ទាប់មកចាន់ថា ក៏បានខកខានទូទាត់សងលើកទីបួន។ មន្ត្រីឥណទានបានគំរាមឱ្យហៅពូ (អ្នកធានា) ទៅកាន់តុលាការ ប្រសិនបើមិនទូទាត់សង។ចាន់ថា បានធ្វើការទូទាត់សងលើកទីបីនៅចុងខែឧសភា។ ចូរបញ្ជាក់ថា តើឥណទានរបស់គាត់គឺជា "ឥណទានដំណើរការ" ឬ "ឥណទានមិនដំណើរការ"? ហើយតើឥណទាននេះស្ថិតក្នុងចំណាត់ថ្នាក់ឥណទានមួយណា? តើសកម្មភាពរបស់មន្ត្រីឥណទានមានក្រមសីលធម៌ឬទេ? ហេតុអ្វីមាន ឬហេតុអ្វីមិនមានក្រមសីលធម៌?

## ឃ.៣.២. រៀបចំឥណទានមិនដំណើរការឡើងវិញ (NPL)

### និយមន័យ

ឥណទានរៀបចំឡើងវិញ (restructured loan) គឺជាឥណទានដែលបានកែប្រែខចែង និងលក្ខខណ្ឌដើមនៃកិច្ចសន្យា។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្តល់ជម្រើសរៀបចំឥណទានឡើងវិញនេះដល់អ្នកខ្ចីដែលមានបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន និងអាចមានលទ្ធភាពទូទាត់

សងឥណទានបានដោយប្រើជម្រើសនេះ។ ការសម្រេចឱ្យរៀបចំឥណទានឡើងវិញនេះ គួរតែមានបញ្ជាក់នូវមូលហេតុត្រឹមត្រូវអមជាមួយនឹងសេចក្តីពន្យល់ និងឯកសារជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់។ ការអនុម័តឥណទានរៀបចំឡើងវិញ ត្រូវធ្វើឡើងដោយគណៈគ្រប់គ្រងជាន់ខ្ពស់ យកល្អក៏ត្រូវខុសគ្នាពីអ្នកដែលអនុម័តដំបូងលើឥណទាននេះដែរ។ ការរៀបចំឥណទានឡើងវិញ ត្រូវអនុវត្តដោយផ្នែកឯករាជ្យ ផ្សេងពីផ្នែកដែលបង្កើតឥណទានដំបូង។

**របៀបដំណើរការនៃឥណទានរៀបចំឡើងវិញ**

ទោះបីជាប្រហែលជាមិនអាចអនុវត្តបានគ្រប់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទាំងអស់យោងតាមបទពិសោធរបស់អ្នកនិពន្ធឯកសារនេះ ការរៀបចំឥណទានឡើងវិញអាចជាឧបករណ៍មួយដែលមានប្រសិទ្ធភាពដើម្បីគាំទ្រដល់អ្នកខ្ចីឥណទាន ដែលមានបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុ។ ដូច្នេះ ត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនឱ្យបានល្អិតល្អន់ និងដោយយកចិត្តទុកដាក់ព្រមទាំងត្រូវធ្វើការវាយតម្លៃហានិភ័យឱ្យបានតឹងរ៉ឹងជាងមុនដើម្បីធានាថាអ្នកខ្ចីមានលទ្ធភាពគោរពតាមលក្ខខណ្ឌទូទាត់ថ្មី។

### ឃ.៣.២.១. ការអនុវត្តជម្រើសរៀបចំឥណទានឡើងវិញ

ជាទូទៅ ការផ្តល់ជម្រើសរៀបចំឥណទានឡើងវិញដល់អ្នកខ្ចីដែលបានមានបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ជាឧបករណ៍ដ៏មានប្រយោជន៍មួយ ដែលអាចស្តារស្ថានភាពឥណទានឱ្យល្អប្រសើរឡើងវិញសម្រាប់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាស្ថានភាពអាជីវកម្មរបស់អ្នកខ្ចីផងដែរ។ គោលនយោបាយឥណទានល្អ គួរតែរួមមានផ្នែកស្តីពីឥណទានរៀបចំឡើងវិញ។ ស្ថានភាពខាងក្រោមនេះគួរតែយកមកពិចារណា នៅពេលអនុវត្តការរៀបចំឥណទានឡើងវិញ។

- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចមានជម្រើសរៀបចំឥណទានឡើងវិញនៅក្នុងគោលនយោបាយឥណទាន។ ប៉ុន្តែប្រសិនបើមិនបានទទួលការបណ្តុះបណ្តាល និងសេចក្តីណែនាំទេ មន្ត្រីឥណទានអាចខកខានមិនអនុវត្តជម្រើសនេះទេ ដោយសារតែខ្វះចំណេះដឹង ឬ ខ្លាចបាត់បង់គោលដៅប្រាក់រង្វាន់។
- ដំណើរការរៀបចំឥណទានឡើងវិញពាក់ព័ន្ធនឹងពាក្យស្នើសុំ ការវាយតម្លៃ និងការអនុម័តអាចនឹងមានលក្ខណៈស្មុគស្មាញពេកដែលអាចបង្អាក់ទឹកចិត្តអ្នកខ្ចីក្នុងការស្នើសុំការរៀបចំឥណទានឡើងវិញនេះ។ ដូច្នេះ ដំណើរការនេះគួរធ្វើឱ្យមានលក្ខណៈសាមញ្ញ និងងាយ

ស្រួលសម្រាប់ឱ្យអ្នកខ្ចីស្នើសុំរៀបចំឥណទានឡើងវិញ ប្រសិនបើអ្នកខ្ចីពិតជាមានបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុប្រាកដមែន។

- បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែជម្រាបដល់អ្នកខ្ចីឥណទានអំពីជម្រើសរៀបចំឥណទានឡើងវិញដែលមានផ្តល់ជូន ដោយមិនគិតអំពីស្ថានភាពរបស់អ្នកខ្ចីនោះទេ ជាពិសេសនៅក្នុងអំឡុងពេលខ្ចីជាលើកដំបូង។
- បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនត្រូវបង្អាក់ទឹកចិត្តរបស់អ្នកខ្ចីក្នុងជ្រើសរើសការរៀបចំឥណទានឡើងវិញឡើយ ប្រសិនបើមានអត្ថប្រយោជន៍ពិតប្រាកដចំពោះអ្នកខ្ចី។[109]

**សំណួរឆ្លុះបញ្ចាំង ឃ.៣.២**

នៅខែឧសភា ឆ្នាំ២០១៩ ចំប៉ី បានខ្ចីប្រាក់ចំនួន ៣០,០០០ ដុល្លារអាមេរិកពីធនាគារ ថូម៉ាក្វ ដោយមានរយៈពេលឥណទានបួនឆ្នាំ។ របៀបទូទាត់សងគឺសងប្រាក់ដើម និងការប្រាក់ជាប្រចាំខែ។ គាត់បានប្រើប្រាស់ឥណទាននោះដើម្បីបញ្ចាទិញសម្លៀកបំពាក់ពីប្រទេសជិតខាងសម្រាប់បោះដុំ។ គាត់តែងតែបង់ប្រាក់ពីរបីថ្ងៃមុនកាលបរិច្ឆេទត្រូវសងប្រាក់។ ធនាគារ ថូម៉ាក្វ ពេញចិត្តនឹងការអនុវត្តបែបនេះរបស់គាត់ខ្លាំងណាស់។ គួរឱ្យសោកស្តាយ មានបាតុកម្មប្រឆាំងនឹងរដ្ឋាភិបាលនៅក្នុងប្រទេស ដែលធ្វើឱ្យការផ្គត់ផ្គង់អាជីវកម្មរបស់គាត់ត្រូវបានកាត់ផ្តាច់ទាំងស្រុងនៅដើមឆ្នាំ២០២០។ ការធ្វើបាតុកម្មនេះបានធ្វើឱ្យប្រតិបត្តិការអាជីវកម្មរបស់គាត់បិទជាបណ្តោះអាសន្ន។ ចំណូលពីអាជីវកម្មរបស់គាត់បានធ្លាក់ចុះ ៦០% ដោយសារតែគាត់អាចរកចំណូលបានតែពីឥវ៉ាន់ដែលមានក្នុងស្តុកស្រាប់ប៉ុណ្ណោះ។ គាត់មិនរំពឹងថាកម្រិតចំណូលរបស់គាត់ត្រឡប់មកដូចធម្មតាវិញនោះទេ យ៉ាងតិចក៏៣ខែទៀតដែរ។ ប្រសិនបើអ្នកជាអ្នកគ្រប់គ្រងឥណទានរបស់ ចំប៉ី តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីគាំទ្រដល់គាត់?

[109] (Licadho Equitable Cambodia, 2021)

# ចម្លើយសំណួរផ្ទុះបញ្ចាំង

## ចម្លើយ ក១

ការធ្វើជាតួបនីយកម្មវិស័យធនាគារ អាចបង្កឱ្យមានភាពខ្វះខាតហិរញ្ញប្បទាន (financing) សម្រាប់វិស័យមួយចំនួននៅក្នុងប្រទេស (ឧទាហរណ៍ វិស័យកសិកម្ម) ក៏ដូចជាបញ្ហាវិសមភាពរវាងតំបន់ជនបទ និងទីក្រុងផងដែរ។ ការមិនអនុញ្ញាតឱ្យធនាគារឯកជនក្នុងស្រុក និងបរទេសធ្វើប្រតិបត្តិការ នោះ **ប្រទេស ក** បានបង្កការរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន ហើយធ្វើឱ្យលំហូរប្រូបិយប័ណ្ណពុំមានតុល្យភាព ពុំមានលំហូរសាច់ប្រាក់ពីខាងក្រៅមកទេពីព្រោះពុំមានការវិនិយោគដោយផ្ទាល់ពីបរទេសនៅក្នុងវិស័យធនាគារ។

## ចម្លើយ ក២

ក្នុងករណីនេះ ធនាគារត្រូវមានភាពបុរេសកម្មក្នុងការស្វែងរកវិធីដើម្បីប្រាស្រ័យទាក់ទងជាមួយ ធីតា។ ដំបូង ធនាគារត្រូវព្យាយាមស្វែងយល់អំពីបញ្ហាប្រឈមពិតប្រាកដដែលអតិថិជនជួបប្រទះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន។ ទីពីរ ពិនិត្យមើលគោលនយោបាយផ្ទៃក្នុងសម្រាប់ការផ្តល់ការគាំទ្រដល់អតិថិជនដែលងាយរងគ្រោះបែបនេះ។ ទីបី ពិភាក្សាជាមួយនឹងថ្នាក់គ្រប់គ្រង និងអតិថិជន ដើម្បីដាក់ចេញនូវដំណោះស្រាយ។

## ចម្លើយ ក៣

ចម្លើយដែលត្រឹមត្រូវគឺ **ខ**, **គ**, **ង**។

## ចម្លើយ ក៤

ធនាគារនេះ ផ្តល់អាទិភាពលើប្រាក់ចំណេញជាជាងអតិថិជន។ នៅក្នុងករណីទាំងនេះ ធនាគារហ្គោលមែន មិនមានគុណធម៌នៃភាពស្មោះត្រង់ទេ ព្រោះខ្លួនបានណែនាំអតិថិជនឱ្យចំណាយប្រាក់ច្រើនជាងលើសពីតម្លៃនៃក្រុមហ៊ុនទាំងពីរនោះ។ ធនាគារហ្គោលមែន បានជ្រើសរើសយកថ្លៃសេវាជាជាងហានិភ័យចំពោះកេរ្តិ៍ឈ្មោះរបស់ខ្លួន។

## ចម្លើយ ខ១

ឆដា អាចប្រឈមនឹងការពិបាក ឬមិនមានលទ្ធភាពបង់ប្រាក់នៅពេលអត្រាការប្រាក់ (១៥%) បន្ទាប់ពីប៉ុន្មានឆ្នាំដំបូងហើយចុងក្រោយក៏បរាជ័យក្នុងការទូទាត់កម្ចី។ សម្រាប់ការផ្តល់កម្ចីដល់អតិថិជនដែលមានប្រវត្តិឥណទានមិនល្អ អត្រាការប្រាក់អាចមានបម្រែបម្រួល ដោយដំបូងចាប់ផ្តើមក្នុងអត្រាទាប ហើយកើនឡើងទៅតាមពេលវេលា ដែលធ្វើឱ្យអ្នកខ្ចីដូចជាឆដា មានការពិបាក

ក្នុងការសងប្រាក់ដើមត្រឡប់មកវិញ។ ម្យ៉ាងវិញទៀត **ធនាគារ ថូម៉ាកូ** នឹងប្រឈមចំពោះហានិភ័យឥណទានកាន់តែខ្ពស់ ដោយសារតែតម្លៃអចលនទ្រព្យដែលធានាលើកម្ចី អាចនឹងធ្លាក់ចុះទាបជាងប្រាក់ដើម នៅពេលដែលតម្លៃលំនៅឋានធ្លាក់ចុះ។ ក្នុងករណីធ្ងន់ធ្ងរបំផុត នៅពេលដែលឆដាបាត់បង់លទ្ធភាពទូទាត់សងទាំងស្រុង គាត់អាចនឹងអនុញ្ញាតឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រឹបអូសយកទ្រព្យធានា ហើយកាលៈទេសៈនៃវិបត្តិ ទ្រព្យធានានោះ អាចនឹងមិនងាយស្រួលលក់ចេញឡើយដែលនាំឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នោះជួបប្រទះហានិភ័យសន្ទនីយភាព (Liquidity risks)។ ជាងនេះទៅទៀត ប្រសិនបើទីផ្សារកម្ចីអចលវត្ថុសម្រាប់អតិថិជនមានប្រវត្តិឥណទានមិនល្អ មិនត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹង នៅអំឡុងពេលដែលអចលនវត្ថុឡើងថ្លៃ នោះ គ្រឹះស្ថានកាន់តែច្រើន នឹងមានទំនោរក្នុងការបន្ធូរបន្ថយដំណើរការវាយតម្លៃឥណទាន ហើយប្រឹងពង្រីកកម្ចីដល់អ្នកខ្ចីដែលមានប្រវត្តិឥណទានមិនល្អ ពីព្រោះពួកគេជឿលើទីផ្សារលំនៅឋាន ហើយរំពឹងថាទ្រព្យធានាអាចលក់ចេញ និងរ៉ាប់រងលើប្រាក់ដើម និងការប្រាក់នៃកម្ចី។ ទោះជាយ៉ាងណា នៅពេលដែលទីផ្សារលំនៅឋានចាប់ផ្តើមធ្លាក់ចុះ អ្នកខ្ចីដែលមានប្រវត្តិឥណទានមិនល្អ នឹងលែងបង់សងត្រឡប់សម្រាប់កម្ចីរបស់ខ្លួន ដូច្នេះ ប្រព័ន្ធធនាគារនឹងជោរជន់ទៅដោយឥណទានមិនដំណើរការ ហើយទ្រព្យធានាអាចនឹងមិនងាយស្រួលលក់ចេញសម្រាប់ទូទាត់បំណុល។ ទីបញ្ចប់ អាចនឹងនាំទៅរកវិបត្តិហិរញ្ញវត្ថុ។

## ចម្លើយ ៩១.១

ប្រសិនបើអ្នកដាក់ប្រាក់បញ្ញើទាំងអស់ ទាមទារប្រាក់បញ្ញើរបស់ពួកគេក្នុងពេលតែមួយ នោះ **ធនាគារ ថូម៉ាកូ** នឹងមិនមានសន្ទនីយភាព និងទុនបម្រុងគ្រប់គ្រាន់ដើម្បីបំពេញកាតព្វកិច្ចទូទាត់ប្រាក់បញ្ញើនោះឡើយ។ ក្នុងករណីនេះ **ធនាគារថូម៉ាកូ** នឹងស្វែងរកជំនួយគាំទ្រសន្ទនីយភាពបន្ទាន់រយៈពេលខ្លីពីអាជ្ញាធរនានា ដើម្បីរក្សាស្ថានការណ៍ឱ្យមានស្ថិរភាព។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើពាក្យចចាមអារ៉ាមនៅតែបន្តឃ្លូវ នោះនឹងអាច នាំទៅរកការសម្រុកដកប្រាក់ចេញពីធនាគារ។នៅក្នុងសេណារីយ៉ូដ៏អាក្រក់បំផុត នៅពេលដែលការសម្រុកដកប្រាក់ចេញពីធនាគារកើតឡើង នោះ**ធនាគារ ថូម៉ាកូ** ប្រហែលជាមិនអាចបន្តប្រតិបត្តិការរបស់ខ្លួនបានឡើយ ហើយសម្រេចចិត្តប្រកាសក្ស័យធន ដូច្នេះអ្នកដាក់ប្រាក់បញ្ញើជាច្រើនប្រហែលជាមិនទទួលបានប្រាក់របស់ពួកគេវិញទេ។ ក្នុងករណីនេះ វាអាចនឹងមានឥទ្ធិពលដូមីណូ ដល់ប្រព័ន្ធធនាគារទាំងមូល ដែលនាំឱ្យមានការថយចុះនូវទំនុកចិត្តសាធារណៈលើប្រព័ន្ធធនាគារ ហើយអ្នកដាក់ប្រាក់បញ្ញើតាម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងទៀតអាចដកប្រាក់របស់ពួកគេភ្លាមៗ ពីព្រោះពួកគេក៏ភ័យខ្លាចថាពួកគេក៏អាចនឹងបាត់បង់ប្រាក់របស់ខ្លួនផងដែរ នៅពេលដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរបស់ខ្លួន

ក្ស័យធន។ ប្រសិនបើរឿងនេះកើតឡើងចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជាច្រើន ក្នុងពេលតែមួយនោះ វិបត្តិហិរញ្ញវត្ថុនៅក្នុងប្រព័ន្ធធនាគារអាចនឹងកើតមាន។

## ចម្លើយ ២១.២

ធនាគារ ថូម៉ាកូ ដាក់ចេញនូវសេវានវានុវត្តន៍នេះដើម្បីពង្រីកចំណែកទីផ្សាររបស់ខ្លួន ពង្រឹងការប្រកួតប្រជែង ដើម្បីសម្រួលដល់ដំណើរការបើកគណនីធនាគារ និងកាត់បន្ថយការចំណាយប្រតិបត្តិការ។ សេវាប្រភេទនេះ មានប្រសិទ្ធភាព និងផ្តល់ភាពងាយស្រួលដល់អតិថិជន។ សេវានេះក៏រួមចំណែកដល់ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅក្នុងប្រទេសផងដែរ។

ដើម្បីទប់ស្កាត់ហានិភ័យហិរញ្ញវត្ថុណាមួយដែលទាក់ទងនឹងនវានុវត្តន៍នេះ **ធនាគារថូម៉ាកូ** ត្រូវតែធានាថាប្រព័ន្ធធនាគារស្នូលរបស់ខ្លួនមានសមត្ថភាពក្នុងការការពារការក្លែងបន្លំ KYC ការគំរាមកំហែង AML សន្តិសុខទិន្នន័យ ប្រតិបត្តិការក្លែងបន្លំ ការគំរាមកំហែងតាមអ៊ីនធឺណិត និងត្រូវពង្រឹងសមត្ថភាពសន្តិសុខតាមអ៊ីនធឺណិតជាបន្តបន្ទាប់ ដើម្បីដើរឱ្យទាន់ការរីកចម្រើននៃបច្ចេកវិទ្យា។ ធនាគារក៏ត្រូវតែធានាឱ្យបាននូវអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលកំណត់ដោយអាជ្ញាធរ និងនិយ័តករ ព្រមទាំងធានាថាឯកជនភាពរបស់អ្នកប្រើប្រាស់ត្រូវបានការពារយ៉ាងពេញលេញ។ ទន្ទឹមនឹងនេះ អាជ្ញាធរ និងនិយ័តករក៏ត្រូវតាមដានយ៉ាងជិតដល់នូវនវានុវត្តន៍ផ្នែកហិរញ្ញវត្ថុទាំងនេះ ដើម្បីធានាបាននូវស្ថិរភាពប្រព័ន្ធធនាគារ និងកិច្ចការពារអ្នកប្រើប្រាស់។

## ចម្លើយ ២២

និយ័តករសេវាហិរញ្ញវត្ថុមិនមែនធនាគារមានចំនួន៦នៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងក្រុមហ៊ុនធានារ៉ាប់រង ទីផ្សារមូលបត្រ ទីភ្នាក់ងារសន្តិសុខសង្គម ក្រុមហ៊ុនបរធនបាលកិច្ច ក្រុមហ៊ុនគណនេយ្យ និងសវនកម្ម និងអាជីវកម្មអចលនវត្ថុ និងហាងបញ្ចាំ។ ម្យ៉ាងវិញទៀត ធនាគារជាតិនៃកម្ពុជា គឺជាអាជ្ញាធរត្រួតពិនិត្យរបស់ប្រទេស ដែលទទួលខុសត្រូវលើការគ្រប់គ្រង និងត្រួតពិនិត្យធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ (financial leasing companies) គ្រឹះស្ថានឥណទានជនបទ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកឥណទាន (ការិយាល័យឥណទានកម្ពុជា) អ្នកដំណើរការតតិយភាគី (third-party processors) និង អាជីវករប្តូរប្រាក់។

**ចម្លើយ ខ៣**

ជម្រើស **ឃ** ជាចម្លើយត្រឹមត្រូវ។

**ចម្លើយ ខ៤**

**ជម្រើស គ** ជាចម្លើយត្រឹមត្រូវ។

**ចម្លើយ គ១.១**

ការសម្រេចចិត្តរបស់ដារ៉ាដែលផ្តល់តួនាទីជូនកុសលគឺអាចមានភាពលម្អៀងដោយសារកត្តាពីរយ៉ាង ១) ដារ៉ាអាចសម្រេចចិត្តដោយផ្អែកលើការរើសអើងភេទ ដែលបុរសមានភាពស័ក្តិសមជាងសម្រាប់ការងារដែលទាមទារឱ្យមានការធ្វើដំណើរ ២) ការសម្រេចចិត្តរបស់ដារ៉ាអាចរងឥទ្ធិពល ពីរឿងដែលកុសលជាសាច់ញាតិរបស់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់។

- តាមទ្រឹស្តីក្រមសីលធម៌ផ្អែកលើកាតព្វកិច្ច៖ ការរើសអើង និងបក្ខានុគ្រោះ ជារឿងអសីលធម៌ ឬខុសឆ្គង បើទោះបីជាការជ្រើសរើសតួនាទីនោះ អាចនាំឱ្យក្រុមហ៊ុនទទួលបានលទ្ធផលល្អក្តី។ ដារ៉ាគួរតែផ្តល់ការងារដោយផ្អែកលើគុណសម្បត្តិ និងសមត្ថភាពរបស់បេក្ខជនដោយមិនមានការរើសអើង ឬបក្ខានិយមនោះឡើយ។ ដារ៉ាមានភារកិច្ចគោរពនូវគោលការណ៍ "ស្មើភាព" "គ្មានការរើសអើង" និងជ្រើសរើសមនុស្សត្រឹមត្រូវសម្រាប់តួនាទីនោះ។ ភាពលម្អៀង និងការរើសអើង អាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់ដារ៉ា។ ដូច្នេះ ការផ្តល់ការងារដល់កុសលគឺមិនមែនជារឿងត្រឹមត្រូវដែលគួរធ្វើនោះទេ។
- តាមទ្រឹស្តីប្រយោជន៍និយម៖ បើសិនជាគិតគូរពីអត្ថប្រយោជន៍របស់បុគ្គលភាគច្រើន ដែលពួកគេជាបុគ្គលិក ម្ចាស់ក្រុមហ៊ុន និងអតិថិជន ដូច្នោះការរើសអើងលើភេទ(gender) គឺមិនត្រឹមត្រូវ ព្រោះវាអាចបង្កផលមិនល្អដល់ដំណើរការអាជីវកម្ម ដូចខាងក្រោម៖
  - ប្រសិនបើសុធីជាបេក្ខជនដែលស័ក្តិសមសម្រាប់តួនាទីនេះ។ ការមិនផ្តល់ការងារដល់នាង មានន័យថាក្រុមហ៊ុនបានបោះបង់ចោលមនុស្សពូកែ មានសក្តានុពលម្នាក់ ដែលអាចជំរុញក្រុមហ៊ុនឱ្យទទួលបានប្រាក់ចំណូលកាន់តែច្រើន និងដំណើរការកាន់តែប្រសើរ។
  - ការធ្វើដូច្នេះ គឺជាការរើសអើងដែលអាចបង្កើតឱ្យមានវប្បធម៌មិនល្អបំពុល ហើយនាំឱ្យមានអារម្មណ៍អវិជ្ជមានសម្រាប់បុគ្គលិកក្នុងការបម្រើការឱ្យក្រុមហ៊ុន។

## ចម្លើយ គ១.២

ប្រសិនបើការបញ្ចុះតម្លៃសម្រាប់ការទិញនេះផ្តល់ជូនជាពិសេសសម្រាប់តែលោក រិទ្ធី នេះជាការផ្តល់ការអនុគ្រោះពិសេស ដូច្នេះហើយការទទួលយកការបញ្ចុះតម្លៃនេះនឹងបង្កើតជាទំនាស់ផលប្រយោជន៍។ ទង្វើនេះផងដែរអាច ធ្វើឱ្យរិទ្ធី ផ្តល់ការអនុគ្រោះត្រលប់ទៅវិញដោយចេតនា ឬអចេតនា ដល់អតិថិជនរបស់គាត់ ហើយវាមានឥទ្ធិពលលើការវិនិច្ឆ័យរបស់ រិទ្ធីក្នុងការគ្រប់គ្រងទំនាក់ទំនងរបស់អតិថិជនគាត់ ឬសំណើអាជីវកម្មនាពេលអនាគត។ ភាពធ្ងន់ធ្ងរនៃហានិភ័យនេះអាស្រ័យទៅលើការសម្រេចចិត្តរបស់រិទ្ធី ទៅកាន់សំណើរបស់អតិថិជនគាត់នាពេលអនាគត។ រិទ្ធីអាចបដិសេធមិនទទួលយកការបញ្ចុះតម្លៃនេះដើម្បីបញ្ចៀសកុំឱ្យមានទំនាស់ផលប្រយោជន៍។

ម៉្យាងទៀត គាត់អាចពិនិត្យមើលពីគោលនយោបាយផ្ទៃក្នុង ធ្វើរបាយការណ៍បង្ហាញពីប្រតិបត្តិការទៅនិយោជករបស់គាត់ ហើយសុំការយល់ព្រមលើសកម្មភាពនេះ។ ដំណោះស្រាយទាំងពីរនេះអាចធានាបាននូវទំនុកចិត្តរវាង រិទ្ធី និយោជករបស់គាត់ និងអតិថិជន ដូច្នេះហើយ វានឹងធានាបាននូវ កេរ្តិ៍ឈ្មោះល្អរបស់ធនាគារទាំងមូល និងកេរ្តិ៍ឈ្មោះរបស់រិទ្ធីផងដែរ។

## ចម្លើយ គ២.១

- រិទ្ធី ត្រូវពិនិត្យមើលបទបញ្ជាផ្ទៃក្នុង។ ប្រតិបត្តិការនេះត្រូវបានបដិសេធតាមលក្ខណៈវិជ្ជាជីវៈ ប្រសិនបើវាមិនអនុលោមតាមបទប្បញ្ញត្តិ ហើយរិទ្ធី ត្រូវផ្តល់ការពន្យល់ដល់អតិថិជនរូបនេះ។
- រិទ្ធី ត្រូវទទួលស្គាល់ពីសកម្មភាពរបស់ធារី ហើយធានាថា គាត់បានធ្វើរឿងដែលត្រឹមត្រូវដោយអនុវត្តតាមវិធានច្បាប់។ រិទ្ធី ត្រូវបើកចិត្តឱ្យទូលាយ ហើយស្តាប់ការពន្យល់បកស្រាយរបស់ធារី ចំពោះអាកប្បកិរិយារបស់អតិថិជនរូបនេះ។ ហេតុការណ៍នេះត្រូវរាយការណ៍ទៅអ្នកគ្រប់គ្រងជាន់ខ្ពស់ អនុលោមតាមនីតិវិធីរាយការណ៍របស់ធនាគារ។
- ដោយផ្អែកលើអាកប្បកិរិយារបស់អតិថិជន អតិថិជនរូបនេះមិនបានបង្ហាញពី "ការគោរព" ទេ។ បន្ទាប់ពីការស៊ើបអង្កេត ធនាគារអាចធ្វើការពិចារណាបញ្ចប់ទំនាក់ទំនងជាមួយអតិថិជនរូបនេះដោយសារតែបញ្ហាអាកប្បកិរិយារបស់គេនេះឯង។ ការសម្រេចចិត្តរបស់អ្នកគ្រប់គ្រងនេះបង្ហាញពីការប្រកាន់ខ្ជាប់នូវគុណតម្លៃស្តីពី "ការគោរព" ចំពោះបុគ្គលិក និងអ្នកពាក់ព័ន្ធទាំងអស់។ ការសម្រេចចិត្តនោះក៏ជាឧទាហរណ៍មួយបង្ហាញឱ្យឃើញថា ការប្រតិបត្តិតាមក្រមសីលធម៌មានអាទិភាពជាងផលប្រយោជន៍ផ្សេងទៀត។

## ចម្លើយ គ២.២

ទោះបីជាមានសម្ពាធ ក៏ដោយ ក៏ធារី ត្រូវរក្សាវិជ្ជាជីវៈ ធ្វើសកម្មភាពដោយសុចរិតភាព មិនលម្អៀង និងត្រឹមត្រូវ។

- ការទទួលកម្រៃជើងសារនឹងបង្កើតទំនាស់ផលប្រយោជន៍ដែលធារី គួរជៀសវាង ដើម្បីធានាបាននូវសុចរិតភាព និងភាពត្រឹមត្រូវក្នុងការវិនិច្ឆ័យលើកម្ចីដែលបានស្នើសុំ។
- ការមិនមានរបាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវប្រហែលជារឿងធម្មតាសម្រាប់អាជីវកម្មលក្ខណៈគ្រួសារ។ សម្រាប់ដំណោះស្រាយរយៈពេលខ្លី ធារីអាចជួយអតិថិជននោះបង្កើតកំណត់ត្រាហិរញ្ញវត្ថុ ប៉ុន្តែត្រូវធានានូវភាពត្រឹមត្រូវនៃទិន្នន័យដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពហិរញ្ញវត្ថុពិតប្រាកដនៃអាជីវកម្មរបស់អតិថិជន។ ក្នុងករណីនេះ ឯកសារ/ព័ត៌មានគាំទ្រត្រូវប្រមូលទុកជាភស្តុតាង។សម្រាប់ដំណោះស្រាយរយៈពេលវែង ធារី អាចពិចារណាលើការលើកកម្ពស់ការយល់ដឹងរបស់អតិថិជនលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសារៈសំខាន់របស់វា ក៏ដូចជាការលើកទឹកចិត្តអតិថិជនឱ្យរក្សាកំណត់ត្រាហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ។
  - ការបង្ហាញពីស្ថានភាពជាក់ស្តែង (អវត្តមានកំណត់ត្រាហិរញ្ញវត្ថុត្រឹមត្រូវ) នៅក្នុងឯកសារឥណទានដើម្បីធានាបាននូវសុចរិតភាព និងភាពត្រឹមត្រូវ នៃទំនាក់ទំនងនេះ។ តាមរយៈការបង្ហាញនេះ អ្នកអនុម័តឥណទានមានព័ត៌មានពេញលេញរបស់អតិថិជន/ស្ថានភាពសម្រាប់ការវិភាគហានិភ័យ ក៏ដូចជាការសម្រេចចិត្តរបស់ពួកគេ។

## ចម្លើយ ឃ១.១

ចម្លើយដែលត្រឹមត្រូវគឺ "**គ**"។ ការបង់ប្រាក់ប្រចាំខែទាំងការប្រាក់និងប្រាក់ដើម គឺជាចំនួនទឹកប្រាក់ដ៏ច្រើន ហើយអតិថិជនប្រហែលជាមិនមានប្រភពចំណូលផ្សេងទៀតសម្រាប់ការទូទាត់សងប្រចាំខែនោះទេ។ ជាទូទៅ ការបង់សងប្រាក់កម្ចីអាចធ្វើឡើងបន្ទាប់ពីអតិថិជនប្រមូលផលដំណាំរបស់ពួកគាត់រួចរាល់។

## ចម្លើយ ឃ១.១.២

ទីមួយ ការស្នើសុំឱ្យបុគ្គលម្នាក់ចុះហត្ថលេខាលើឯកសារដែលមិនទាន់បានបំពេញព័ត៌មានត្រឹមត្រូវពុំមានសុពលភាពតាមផ្លូវច្បាប់នោះទេ។ អ្នកខ្ចីគួរដឹងពី ព័ត៌មានដែលបានបំពេញ ហើយយល់ស្របចំពោះព័ត៌មាននោះសិន មុនពេលចុះហត្ថលេខា។ ទីពីរ អ្នកខ្ចីមានសិទ្ធិស្នើសុំព័ត៌មានចាំបាច់ទាំង

អស់ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ រួមទាំងសំណើសុំការពន្យល់អំពីលក្ខខណ្ឌសំខាន់ៗ ការគណនា និងគំរូនៃកិច្ចសន្យាជាដើម។

## ចម្លើយ ឃ១.២.១

អត្រាការប្រាក់ប្រចាំឆ្នាំ ១៨% សោហ៊ុយទម្រង់ការ២% ស្មើនឹង ៤០០ដុល្លារ មានតម្លាភាពគ្រប់គ្រាន់។ ប៉ុន្តែ ថ្លៃសេវាខាងក្រោមតម្រូវឱ្យមានការបង្ហាញព័ត៌មាន និងការពន្យល់ដល់អតិថិជន។

- ថ្លៃសេវាបង់ជាមុនចំនួន ៣០ ដុល្លារ (ថ្លៃសេវាផ្សេងទៀត) អាចត្រូវបានបំផ្លើស ប្រសិនបើមិនមានការផ្តល់សេវាកម្មផ្សេងទៀត ដូចជាថ្លៃសេវាផ្នែកច្បាប់ ឬថ្លៃសេវាវាយតម្លៃអចលនទ្រព្យដល់អ្នកខ្ចីទេនោះ។
- ថ្លៃសេវាត្រួតពិនិត្យប្រចាំឆ្នាំចំនួន ២% សម្រាប់រៀងរាល់១២ខែម្តង ជាធម្មតាមិនយុត្តិធម៌ចំពោះអតិថិជននោះទេ ហើយជារឿយៗ ជាវិធីដើម្បីបំប៉ោងអត្រាការប្រាក់ដ៏មានប្រសិទ្ធភាពទៅវិញទេ និងជៀសវាងការបំពានអត្រាពិតានតាមបទប្បញ្ញត្តិចំនួន ១៨%។

## ចម្លើយ ឃ១.២.៣

ដើម្បីជៀសវាងឧប្បត្តិហេតុបែបនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានគោលនយោបាយតឹងរ៉ឹងដើម្បីធ្វើយ៉ាងណាធានា ថា អ្នកបង្កើតហ៊ីប៉ូតែកបានយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ មន្ត្រីឥណទាមានភារកិច្ច និងទំនួលខុសត្រូវអនុវត្តកិច្ចការនេះ។ មន្ត្រីឥណទានត្រូវទទួលបានការបណ្តុះបណ្តាលអំពីប្រធានបទនេះ។

## ចម្លើយ ឃ១.៣.១

មិនត្រឹមត្រូវទេ ពីព្រោះវាមិនត្រឹមត្រូវតាមក្រមសីលធម៌សម្រាប់ការលាក់បាំង គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច អវិជ្ជមាន និងការរំលោភអាជ្ញាបណ្ណរបស់អ្នកខ្ចី ហើយនៅពេលដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្តល់ហិរញ្ញប្បទានដល់អាជីវកម្មនេះ គេអាចយល់ថា គ្រឹះស្ថាន ពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មនេះដោយប្រយោល ឬពង្រីកសកម្មភាពបូមខ្សាច់របស់អាជីវកម្មដែលរងការចោទប្រកាន់នេះ។

## ចម្លើយ ឃ១.៣.២

អត់ត្រូវទេ ព្រោះមូលហេតុនៃកម្ចីគឺគួរតែទិញរថយន្តថ្មី។ រថយន្តរបស់គាត់នឹងមិនអាចផ្គត់ផ្គង់អាជីវកម្មបានទេចាប់ពីឆ្នាំក្រោយតទៅ ដូច្នេះនឹងមានបញ្ហាក្នុងការសងត្រឡប់មិនខាន។

## ចម្លើយ ឃ១.៣.៣

មុននឹងធ្វើការសម្រេចអនុម័ត DSCR ត្រូវធ្វើការគណនាជាមុន ដែលក្នុងនោះ៖

- ប្រាក់ចំណេញសុទ្ធ = ចំណូល – ថ្លៃដើមនៃទំនិញដែលបានលក់ – ចំណាយប្រតិបត្តិការ

  = ១00,000 – ៧0,000 – ១៥,000

  = ១៥,000

- ការបង់ដើមសរុប និងការចំណាយការប្រាក់ = ៤,000 + ២,000

  = ៦,000

- DSCR = ១៥,000 / ៦,000

  = ២.៥0x

ដូច្នេះហើយ ទាក់ទងនឹងសមត្ថភាពសងប្រាក់របស់គាត់ ការស្នើសុំប្រាក់កម្ចីរបស់ស៊ីថា អាចផ្តល់ជូនបាន ដោយសារ DSCR របស់គាត់ខ្ពស់ជាងតម្រូវការអប្បបរមារបស់ធនាគារ គឺ ២.0x។

## ចម្លើយ ឃ១.៣.៤

ទេ ទង្វើរបស់មន្ត្រីឥណទាននេះគ្មានក្រមសីលធម៌ និងការទទួលខុសត្រូវនោះទេ។ គាត់មានបំណងបកស្រាយមិនពិតពីកាតព្វកិច្ចហិរញ្ញវត្ថុរបស់អ្នកខ្ចី ហើយទង្វើនេះអាចនាំឱ្យមានការគណនាមិនត្រឹមត្រូវចំពោះសមត្ថភាពបង់ប្រាក់របស់គាត់ ហើយបានជំរុញឱ្យអ្នកខ្ចីប្រាក់ទៅជាជំពាក់បំណុលច្រើនហួសទៅវិញទេ។ ជាងនេះទៅទៀត ដោយគ្មានព័ត៌មានពេញលេញអំពីប្រាក់កម្ចីដែលមានស្រាប់ គេមិនប្រាកដថាតើប្រាក់កម្ចីនេះនៅតែមានលទ្ធភាពសងឬក៏អត់នោះទេ។ ដូច្នេះហើយ នៅពេលដែលមន្ត្រីឥណទានជួបប្រទះភាពមិនស្របគ្នាណាមួយនៅក្នុងកំណត់ត្រាឥណទាន គាត់ត្រូវបញ្ជូនបញ្ហានេះទៅអ្នកគ្រប់គ្រងរបស់ខ្លួន ហើយផ្ទៀងផ្ទាត់ជាមួយ ការិយាល័យឥណទានកម្ពុជា ដើម្បីធានាថា មានព័ត៌មានត្រឹមត្រូវសម្រាប់វាយតម្លៃ និងអនុម័តប្រាក់កម្ចីនោះ។

## ចម្លើយ ឃ១.៣.៥

ទង្វើរបស់ ជីវ៉ាគឺមិនត្រូវតាមក្រមសីលធម៌នោះទេ ដោយសារតែគាត់បានព្យាយាមបញ្ចុះបញ្ចូលអ្នកវាយតម្លៃអចលនទ្រព្យឱ្យដាក់តម្លៃតាមដែលគាត់ចង់បានដើម្បីឱ្យគាត់អាចបន្តការស្នើសុំប្រាក់កម្ចី។ការវាយតម្លៃអចលនទ្រព្យគួរមានឯករាជ្យភាព និងឆ្លុះបញ្ចាំងពីតម្លៃទីផ្សារបច្ចុប្បន្នរបស់អចលនទ្រព្យ ដែលមិនត្រូវកែតម្រូវដើម្បីបំពេញតាមចំនួនប្រាក់កម្ចីដែលបានស្នើសុំនោះឡើយ។ ទង្វើនេះក៏អាចធ្វើឱ្យធនាគារប្រឈមនឹងហានិភ័យដែរ នៅពេលធ្វើការប្រមូលប្រាក់ដោយសារតម្លៃវត្ថុធានាមានការបំប៉ោង។

## ចម្លើយ ឃ១.៥

មិនសមស្របទេ ដោយសារតែទំនាក់ទំនងផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរមិនត្រូវគ្នា។

## ចម្លើយ ឃ១.៦

**ក)** ទេ ស្ថានភាព "WOFF" នឹងត្រូវរក្សាទុកនៅក្នុងការិយាល័យឥណទានកម្ពុជាក្នុងគោលបំណងរាយការណ៍ ទោះបីជានៅក្រោយពេលឥណទានត្រូវបានទូទាត់សងគ្រប់ចំនួនដោយស្ម័គ្រចិត្តហើយក៏ដោយ។

**ខ)** ទទួលបាន ប្រសិនបើប្រវត្តិឥណទានមិនល្អនៅពេលអតីតកាលមិនឆ្លុះបញ្ចាំងអំពីសមត្ថភាពនិងលក្ខខណ្ឌហិរញ្ញវត្ថុបច្ចុប្បន្នទេនោះ។

## ចម្លើយ ឃ២.១

ករណីនេះពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍។ វិទ្ធ បានចែកឥណទានជាមួយកញ្ញាសាន ដែលអំពើបែបនេះមិនគួរកើតមាននោះទេ ដោយហេតុថាវាធ្វើឱ្យមានទំនាស់ផលប្រយោជន៍ ដែលផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ នៅពេលមានទំនាស់ផលប្រយោជន៍ បញ្ហានេះជះឥទ្ធិពលដល់ដំណើរការការងារដែលពាក់ព័ន្ធ នឹងការសម្រេចចិត្តទាំងឡាយ។ នៅក្នុងករណីនេះ វិទ្ធ មិនបានធ្វើការតាមដានជាក់ស្តែងនោះទេ ដែលមានន័យថាគាត់បានបំពានទៅលើគោលការណ៍ "សុចរិតភាព"។ ទោះបីជាគាត់បានតាមដានក៏ដោយ ក៏គាត់មិនបានរាយការណ៍អំពីបញ្ហាណាមួយឡើយដោយសារតែខ្លាចបញ្ហានេះជាប់ពាក់ព័ន្ធជាមួយនឹងគាត់ដែរ។

### ចម្លើយ ឃ២.២

**ជម្រើស ខ** ជាចម្លើយត្រឹមត្រូវ។

### ចម្លើយ ឃ២.៣.១

មែនហើយ នេះគឺជាសញ្ញាព្រមានដំបូង។ សញ្ញានេះស្ថិតនៅក្រោមផ្នែក "សូចនាករអាជីវកម្ម និងវិស័យ" ដោយសារតែតម្រូវការដំឡូងមីកាន់តែទាបជាងមុន។ ការយកប្រៀបលើការប្រកួតប្រជែងគឺមានការធ្លាក់ចុះចំពោះអាជីវកម្មស្តុកដំឡូងមី។ ថៃអាចផ្គត់ផ្គង់ និងបំពេញតម្រូវការរបស់ប្រទេសចិនបាន។ សញ្ញានេះស្ថិតនៅក្រោមផ្នែក "សូចនាករហិរញ្ញវត្ថុ" ដោយសារតែនិន្នាការចំណូល និងចំណេញមានលក្ខណៈអវិជ្ជមាន។

### ចម្លើយ ឃ២.៣.២

ការឆ្លើយតបនេះមិនមានក្រមសីលធម៌នោះទេ ដោយសារតែប្រធានសាខានឹងទទួលបានកម្រៃជើងសារពីស្ត្រីដែលចង់ទិញផ្ទះនោះ។ គាត់មិនបានពិភាក្សាជាមួយនឹងថូណាដើម្បីឱ្យយល់អំពីស្ថានភាព និងស្នើឡើងនូវដំណោះស្រាយសមស្របនោះទេ ប៉ុន្តែផ្ទុយមកវិញ គាត់បែរជាដាក់សម្ពាធលើថូណាឱ្យលក់ផ្ទះដែលជាទ្រព្យសម្បត្តិមានចំណូលរបស់គាត់ទៅវិញ។ អំពើមិនមានក្រមសីលធម៌នេះ គឺពាក់ព័ន្ធទៅនឹងការមានទំនាស់ផលប្រយោជន៍ ឬការដាក់សម្ពាធលើការលក់ទ្រព្យសម្បត្តិ។

### ចម្លើយ ឃ២.៤.១

ស្ថានភាពរបស់អតិថិជនអាចចាត់ទុកថាជាការបរាជ័យអាជីវកម្ម ប៉ុន្តែកត្តាចម្បងបំផុតដែលធ្វើឱ្យគ្មានលទ្ធភាពសងគឺ "កត្តាខាងក្រៅ"។ ការផ្ទុះជំងឺកូវីដ-១៩ បានប៉ះពាល់ដល់កម្រិតប្រភពចំណូលដែលទីបំផុត បានប៉ះពាល់ដល់តម្រូវការ និងបរិមាណបញ្ជាទិញរបស់អតិថិជន។

### ចម្លើយ ឃ ២.៤.២

ប្រសិនបើការបិទច្រកព្រំដែនមានរយៈពេលខ្លី ធនាគារគួរផ្តល់រយៈពេលអនុគ្រោះដោយតម្រូវឱ្យសុខា ទូទាត់សងតែការប្រាក់សិន។ ប្រសិនបើការបិទច្រកព្រំដែនមានរយៈពេលវែង ធនាគារគួរពិចារណារៀបចំកាលវិភាគបង់ឥណទាន សុខា ឡើងវិញ។ ឧទាហរណ៍ សុខា គួរតែទទួលបានការអនុញ្ញាតឱ្យទូទាត់សងក្នុងចំនួនទឹកប្រាក់តិចជាងមុនជាប្រចាំខែក្នុងរយៈពេលវែងជាងមុន ដោយផ្អែកលើកម្រិតចំណូលបច្ចុប្បន្នរបស់គាត់។ ជម្រើសនេះ កាត់បន្ថយបន្ទុកហិរញ្ញវត្ថុទៅលើ

ការទូទាត់សងឥណទានរបស់គាត់ ហើយគាត់អាចផ្ដោតលើអាជីវកម្មរបស់គាត់បានច្រើនដូចមុន។ ជម្រើសនេះ ក៏បង្ហាញថាបុគ្គលិកផ្ដល់ការគាំទ្រដ៏ល្អជូនដល់អតិថិជនដែរ។

## ចម្លើយចំពោះចំណុច ឃ២.៥.

មែន នេះគឺជាបុនហិរញ្ញប្បទានឥណទានពិតមែន ពីព្រោះឥណទានថ្មីពីធនាគារ ថូម៉ាកូ បានផ្ដល់ជូន ចាន់ថាក្នុងរយៈពេលពីរថ្ងៃនៅមុនពេលគាត់បង់ផ្ដាច់ឥណទានពី គ្រឹះស្ថានរុក្ខាហ្វាយណាន់ ។ ឥណទានដែលបានធ្វើបុនហិរញ្ញប្បទាននោះស្ថិតក្រោមប្រភេទបុនហិរញ្ញប្បទានហានិភ័យខ្ពស់ ដោយសារតែ៖

- រយៈពេលឥណទាន៖ ស្ថិតនៅក្នុងរយៈពេលត្រីមាសទីមួយនៃឥណទានជាមួយគ្រឹះស្ថានរុក្ខាហ្វាយណាន់ (រយៈពេលឥណទាន ២៤ ខែ / ៣ = ៨ ខែ។ ដូច្នេះ ការធ្វើបុនហិរញ្ញប្បទាននៅការបង់រំលស់លើកទីបួន (ខែទី៤) ស្ថិតនៅក្នុងត្រីមាសទីមួយ។
- ទំហំឥណទាន៖ ១០,០០០ ដុល្លារអាមេរិក (ឥណទានថ្មី) / ៥,០០០ដុល្លារអាមេរិក (ឥណទានចាស់) * ១០០ = ២០០% ដែល > ១៥០%

## ចម្លើយ ឃ២.៦

ទេ គ្រឹះស្ថានរុក្ខាហ្វាយណាន់ មិនបានបំពានលើគោលការណ៍ណែនាំស្ដីពីការផ្ដល់ឥណទាននោះទេ ដោយសារតែក្នុងចំណោមឥណទានមានស្រាប់ទាំង ៣ មានឥណទានដែលមានទំហំច្រើនជាង ២០,០០០ ដុល្លារអាមេរិក។

## ចម្លើយ ឃ២.៧.៣ (ក)

មានអតិថិជនរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួន ១៥.០៦% ដែលមានអនុបាតឥណទានធៀបនឹងចំណូល (LTI) ចន្លោះចាប់ពី ២០១% ទៅ ១០០០% ដោយប្រៀបធៀបជាមួយចំណូលដុលរបស់អតិថិជន។ អតិថិជនប្រភេទនេះមានតែ ៤.៧៥% ប៉ុណ្ណោះសម្រាប់វិស័យធនាគារ និង ១.៦០% សម្រាប់ឧស្សាហកម្មទាំងមូល។ តួលេខនេះឆ្លុះបញ្ចាំងឱ្យឃើញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានផ្ដល់ឥណទានដែលមានហានិភ័យឥណទានកម្រិតកាន់តែខ្ពស់ ដែលអាចសន្មតបាន

ថានឹងនាំឱ្យមានការជាប់បំណុលហួសកម្រិត។ អនុបាតនេះគឺយ៉ាប់យ៉ឺនជាងវិស័យ និងឧស្សាហកម្មទាំងមូលទៅទៀត។

## ចម្លើយ ឃ២.៧.៣ (ខ)

សម្រាប់ខែឧសភា ឆ្នាំ២០២១ ដែលជាខែរាយការណ៍ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានធ្វើបុនហិរញ្ញប្បទានឥណទានហានិភ័យមធ្យមចំនួន ៨.៧៥% ខណៈដែលតួលេខរបស់វិស័យធនាគារគឺ ១០.៣៨% និង១២.៨១% សម្រាប់ឧស្សាហកម្មទាំងមូល។ តួលេខនេះឆ្លុះបញ្ចាំងឱ្យឃើញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានដំណើរការល្អប្រសើរជាងវិស័យ និងឧស្សាហកម្មទាំងមូលទៅទៀត។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មិនបានបំពានលើកម្រិតកំណត់នោះទេ ដោយពិតានអប្បបរិមា គឺ ១៥%។

## ចម្លើយ ឃ.៣.១

- ឥណទានរបស់គាត់បានក្លាយទៅជា "ឥណទានមិនដំណើរការ" ដោយសារតែគាត់លែងមានចំណូលតទៅទៀត ហេតុដូច្នេះគាត់មិនមានសមត្ថភាពទូទាត់សងឡើយ។
- សកម្មភាពរបស់មន្ត្រីឥណទានមិនមានក្រមសីលធម៌នោះទេ ដោយសារតែមន្ត្រីឥណទានមិនបានពិភាក្សាឱ្យបានត្រឹមត្រូវជាមួយ ចាន់ថា អំពីមូលហេតុនៃការបិទទ្វារអាជីវកម្ម និងការខកខានទូទាត់សង និងមិនបានព្យាយាមស្វែងរកដំណោះស្រាយនោះទេ។ អ្នកធានារបស់គាត់គួរតែជាជម្រើសចុងក្រោយបំផុត នៅពេលដែលមន្ត្រីឥណទានបានដឹងហើយថាចន្ថាមិនមានលទ្ធភាពសងឥណទានទាល់តែសោះ ហេតុដូច្នេះធ្វើឱ្យគាត់ខកខានសង ឥណទាន។

## ចម្លើយ ឃ.៣.២

បុគ្គលិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួរតែពិចារណាទៅលើការរៀបចំឥណទានឡើងវិញសម្រាប់ចំប៉ី ដោយសារតែគាត់បានបង្ហាញអំពីវិន័យឥណទានល្អ និងឆន្ទៈក្នុងការទូទាត់សង ឥណទានរបស់គាត់។ ជម្រើសដ៏សមស្របបំផុតគឺ (១) ការកាត់បន្ថយប្រាក់ដើមដែលត្រូវបង់ ឬ (២) ការពន្យារការទូទាត់សងប្រាក់ដើម។

# References (ឯកសារយោង)

Adamson, I., & Handford, D. (2003). Relationshiop marketing: customer commitment and trust as a strategy for the smaller Hong Kong corporate banking sector. *International journal of bank marketing* .

Ahmed, I. (2016). Aspirations of an Islamic bank: an exploration from stakeholders' perspectives. *International Journal of Islamic and Middle Easten Finance and Management* .

Anginer, D., & Demirguc-Kunt, A. (2018). *Bank Runs and Moral Hazard: A Review of Deposit Insurance.* World Bank Group.

Bank for Internation Settlements. (2018, June 5). *Basel Committee Charter*. Retrieved from Bank for Internation Settlements: https://www.bis.org/bcbs/charter.htm

Bank of America Corporation. (n.d.). *Bank of America*. Retrieved from Bank of America: www.bankofamerica.com

Bazerman, M. H. (2020). *A New Model for Ethical Leadership* . Retrieved from Harvard Business Review: https://hbr.org/amp/2020/09/a-new-model-for-ethical-leadership

Bell, D. (2019, Aug 13). *Volvo's Gift To The World, Modern Seat Belts Have Saved Millions Of Lives*. Retrieved from Forbes: https://www.forbes.com/sites/douglasbell/2019/08/13/60-years-of-seatbelts-volvos-great-gift-to-the-world/

Bessong, P. K. (2012). Social responsibility cost and its influence on the profitability of Nigerian banks. *International Journal of Financial Research* , 33.

Bessong, P. K. (2012). Social responsibility cost and its influence on the profitability of Nigerian banks. . *International Journal of Financial Research*, 33.

Bessong, P. K., & Tapang, A. T. (2012). Social responsibility cost and its influence on the profitability of Nigerian banks. *International Journal of Financial Research* , 33.

Boatright, J. R. (2014). *Ethics in Finances.* Wiley-Blackwell.

Bun, Y. (2019). Cambodia: Banking Regulation Review. In J. Putnis, *The Banking Regulation Review* (pp. 98-115). Law Business Research Ltd.

Cerise. (2021). *Client Protection Resources*. Retrieved from Cerise: https://cerise-spm.org/en/spi4/client-protection-resources/

Cerise. (n.d.). *Social performance management.* Retrieved from Cerise: https://cerise-spm.org/en/social-performance/

CGAP. (2009). *Delinquency Management and Interest Rate Setting for Microfinance Institutions.* Retrieved from http://www.cgap.org/

Chun, B. J., Zhang, X., Sharma, A., & Hsu, A. (2001). *Financial Sector Blueprint For 2001-2010.* Royal Government of Cambodia.

Daniel Knoll, A. D. (2020, November 30). *Restoring Trust in Banking*. Retrieved from KPMG: https://home.kpmg/au/en/home/insights/2020/11/major-banks-restoring-trust-in-banking.html

Díaz, R. C. (2000). Do financial markets need regulation? *Invenio*.

Dodd, V. (2021, November 4). *Tax Avoidnace Vs Tax Evasion*. Retrieved from Skillcast: https://www.skillcast.com/blog/tax-avoidance-tax-evasion-difference

Driver, J. (2007). *Ethics: The Fundamentals.* Blackwell Publishing.

Duma, N. (2011). *Dollarization in Cambodia: Causes and Policy.* International Monetary Fund.

Eple, N., & Kumar, A. (2019). *How to Design an Ethical Organization.* Retrieved from Harvard Business Review: https://hbr.org/amp/2019/05/how-to-design-an-ethical-organization

European Systematic Risk Board. (2015). *Report on misconduct risk in the banking sector.* Frankfurt, Germany: European Systematic Risk Board.

Federal Reserve Bank of San Francisco. (2001, July). *What is the economic function of a bank?* Retrieved from Federal Reserve Bank of San Francisco: https://www.frbsf.org/education/publications/doctor-econ/2001/july/bank-economic-function/

Franck, T. (2020, January 23). *Former Wells Fargo CEO John Stumpf barred from industry, to pay $17.5 million for sales scandal*. Retrieved from CNBC: https://www.cnbc.com/2020/01/23/former-wells-fargo-ceo-stumpf-barred-from-industry-to-pay-17point5-million-over-sales-scandal.html

Gertler, M. (1988). Financial Structure and Aggregate Economic Activity: An Overview. *Journal of Money, Credit and Banking*.

Gurpur. (2013, September 10). *Lessons from UK about mis-selling of insurance*. Retrieved from Moneylife: https://www.moneylife.in/article/lessons-from-uk-about-mis-selling-of-insurance/34405.html

Heng, D., Chea, S., & Heng, B. (2021, April). *Impact of Interest Rate Cap on Financial Inclusion in Cambodia.* Retrieved August 2021, from Interantional Monetory Fund: https://www.imf.org/-/media/Files/Publications/WP/2021/English/wpiea2021107-print-pdf.ashx

Hofstrand, D. (2013, May). *Types of Term Loan Payment Schedules* . Retrieved from Iowa State University: https://www.extension.iastate.edu/agdm/wholefarm/html/c5-93.html

IFC. (2021). *IFC ESG Guidebook* . Washington: International Finance Corporation .

Indian Institute of Banking & Finance. (2018). *Ethics in Banking.* Mumbai: Taxmann Publications (P.) Ltd.

Institute of Banking and Finance. (n.d.). *Competency Framework for Compliance*. Retrieved from http://ibfkh.org/competency-framework/

Institute of Banking and Finance. (2021). *SME Lending Certification Level 2.* Phnom Penh, Cambodia. Retrieved from http://ibfkh.org/

International Finance Corporation. (2015). *Promoting Financial Consumer Protection in Cambodia.* World Bank. Retrieved from https://www.ifc.org/wps/wcm/connect/corp_ext_content/ifc_external_corporate_site/home

International Finance Corporation. (2015). *Promoting Financial Consumer Protection in Cambodia.* International Finance Corporation. Retrieved from https://www.ifc.org/wps/wcm/connect/corp_ext_content/ifc_external_corporate_site/home

Jeucken, M., & Bouma, J. (1999). The changing environment of banks. *Greener Management International*, 21-35.

Jeuken, M. H. (1998). Milieu als comparatieve factor in international handel. *Maandschrift Economie*.

Joint WHO-China Study. (2021). *WHO-convened Global Study of Origins of SARS-CoV-2: China Part.* Joint Report. Retrieved from https://www.who.int/health-topics/coronavirus/origins-of-the-virus

KnowYourCountry. (2021, October 21). *Anti-money laundering*. Retrieved from KnowYourCountry Limited: https://www.knowyourcountry.com/cambodia1111#:~:text=Cambodia's%20money%20laundering%20vulnerabilities%20include,growing%20financial%20and%20banking%20industries.

Knufken, D. (2009, May 7). *25 Biggest Bank Failures in History*. Retrieved from Business Pundit: https://www.businesspundit.com/25-biggest-bank-failures-in-history/

KPMG. (2020a, May ). Purpose or Profit? Why Not Both. *Frontiers in Finance* , pp. 12-59.

KPMG. (2020b, November 30). *Restoring trust in banking*. Retrieved from https://home.kpmg/au/en/home/insights/2020/11/major-banks-restoring-trust-in-banking.html

Kumar, R. (2014). Regulatory Environment of Financial Institutions. In R. Kumar, *Strategies of Banks and Other Financial Institutions* (pp. 31-60).

Kunthear, M. (2021, April 27). *Gov't bans travel from India* . Retrieved from The Phnom Penh Post: https://www.phnompenhpost.com/national/govt-bans-travel-india

Licadho Equitable Cambodia. (2021). *Right to relief_Indebted land communities speak out.* Retrieved from http://www.mficambodia.com/

National Bank of Cambodia. (1996, January 26). Law of the organization and conduct of the national bank of Cambodia.

National Bank of Cambodia. (2000, January 11). *Prakas on the Licensing of Microfinance Institutions.* Retrieved September 2021, from National Bank of Cambodia: https://www.nbc.org.kh/download_files/legislation/prakas_eng/7175B7-00-06.pdf

National Bank of Cambodia. (2011, December 27). *Prakas on Transparency in Granting Credit Facilities of Banking and Fiancial Institutions.* Retrieved August 2021, from National Bank of Cambodia: https://www.nbc.org.kh/download_files/legislation/prakas_eng/6683B7-011-243.pdf

National Bank of Cambodia. (2015, December 23). *Prakas on Liquidity Coverage Ratio.* Retrieved September 2021, from National Bank of Cambodia: https://www.nbc.org.kh/download_files/legislation/prakas_eng/5759prakas-liquidity-coverage-ratio-english.pdfhttps://www.nbc.org.kh/download_files/legislation/prakas_eng/5759prakas-liquidity-coverage-ratio-english.pdf

National Bank of Cambodia. (2016, March 22). *Prakas on Minimum Registered Captial of Banking and Financial Institutions.* Retrieved September 2021, from National Bank of Cambodia: https://www.nbc.org.kh/download_files/legislation/prakas_eng/7848B7-016-117-Pro.Kor_ENG.pdf

National Bank of Cambodia. (2017, December 01). *Prakas on Credit Risk Grading and Impairment Provisioning.* Retrieved September 2021, from National Bank of Cambodia: https://www.nbc.org.kh/download_files/legislation/prakas_eng/1.Prakas_on_Credit_Risk_Grading_and_Impairment_Provisioning_ENG.pdf

National Bank of Cambodia. (2017). *Prakas on Credit Risks Grading* . Retrieved from https://www.nbc.org.kh/english/

National Bank of Cambodia. (2017, March 13). *Prakas on Interest Rate Ceiling on Loans.* Retrieved August 2021, from National Bank of Cambodia: https://www.nbc.org.kh/download_files/legislation/prakas_eng/Prakas-on-Interest-Rate-Cap-Eng.pdf

National Bank of Cambodia. (2017, September 27). *Prakas on Resolution of Consumer Complaints.* Retrieved August 2021, from National Bank of Cambodia: https://www.nbc.org.kh/download_files/legislation/prakas_eng/Prakas_on_Resolution_of_Consumer_Complaints_ENG.pdf

National Bank of Cambodia. (2020, March 17). *Announcement.* Retrieved September 2021, from National Bank of Cambodia: https://www.nbc.org.kh/download_files/news_and_events/press_kh/3610Press_Release_Measures_to_Increase_Banking_and_FI_Reducing_Impact_Covid19.pdf

National Bank of Cambodia. (2020, March 27). *Circular on Loan Restructuring During Convid-19 Pandamic*. Retrieved September 2021, from Fresh News: http://m.freshnewsasia.com/index.php/en/localnews/152915-2020-03-28-01-20-32.html

National Bank of Cambodia. (2020, March 27). *Circular on restructured facility during the impact of Covid-19*. Retrieved from https://www.nbc.org.kh/english/news_and_events/announcements.php

National Bank of Cambodia. (2021). *Annual Supervision Report 2020.* Phnom Penh: National Bank of Cambodia.

Olander, S. (2007). Stakeholder impact analysis in construction project management . *Construction management and economics* , 277-287.

Onich, T. M. (2010). *Problem Loans: Early Detection.* Retrieved from http://www.turnaroundinternational.com/ProblemLoans.pdf

Oxford Answers. (2019, December 3). *Making LIBOR manipulation-proof: overcoming the flaws in the London Interbank Offered Rate*. Retrieved from Said Business School: https://www.sbs.ox.ac.uk/oxford-answers/making-libor-manipulation-proof-overcoming-flaws-london-interbank-offered-rate

Phnom Penh Post. (2021, July 27). *The Phnom Penh Post*. Retrieved from Phnom Penh Post: https://www.phnompenhpost.com/business/nbc-financial-institutions-h1-restructure-55-billion-loans

PWC. (2019, January). *Early warning signals in a digital era: A proposed PwC framework to manage credit risk better.* Retrieved from https://www.pwc.in/assets/pdfs/consulting/financial-risk-and-regulations/early-warning-signals-in-a-digital-era.pdf

Reserve Bank of Australia. (2018, Ocotober 04). *The Global Financial Crisis.* Retrieved from Reserve Bank of Australia: https://www.rba.gov.au/education/resources/explainers/the-global-financial-crisis.html

Royal Government of Cambodia. (2019, November 02). *Law on Consumer Protection*. Retrieved August 2021, from The National Assembly of The Kingdom of Cambodia: http://national-assembly.org.kh/ViewLawFile.aspx?LawDID=571

Schmukler, S. L. (2004). Benefits and Risks of Financial Globalization: Challenges for Developing Countries.

Scholtens, B. (2009). Corporate social responsibility in the internal banking industry. *Journal of Buisness Ethics*, 159-175.

Schwartz, M. S. (2017). *Business Ethics, An Ethical Decision-Making Approach.* John Wiley & Sons.

Singer, P. (n.d). *Ethics*. Retrieved from Britannica: https://www.britannica.com/topic/ethics-philosophy

Stampe, J. (2014). *Environmental, Social, and Governance Integration for Banks: A Guide to Starting Implementation.* Gland: World Wide Fund for Nature (Formerly World Wildlife Fund).

Stellinga, B., Hoog, J. d., Riel, A. V., & Vries, C. d. (2021). How Is Money Created? In B. Stellinga, J. d. Hoog, A. v. Riel, & C. d. Vries, *Money and Debt: The Public Role of Banks* (pp. 17-46).

Tal, N. I., & Dabadie, M. (2007). *Dollarization in Cambodia.* Phnom Penh: National Bank of Cambodia.

The Asian Institute of Chartered Bankers. (2015). *Professionalism, Ethics and Regulation.* London: BPP Learning Media.

The Assocation of Banks in Cambodia; Cambodian Microfinance Association; & Cambodian Association Finance & Technology. (2022). *Guide for Implementation of the Lending Guidelines.* Retrieved from The Association of Banks in Cambodia: https://www.cma-network.org/

The Association of Banks in Cambodia & Cambodian Microfinance Association. (2021). *Banking and Financial Code of Conduct.* Retrieved from https://www.abc.org.kh/

The Association of Banks in Cambodia & Cambodian Microfinance Assoication. (2022). *Banking and Finance Institutions' Code of Conduct.* Retrieved from The Association of Banks in Cambodia: https://www.abc.org.kh/publication

The Association of Banks in Cambodia. (2021, November 04). *Code of Conduct.* Retrieved from https://www.abc.org.kh/news/code-conduct

The Association of Banks in Cambodia. (2022, Match 4). Banking and Financial Institutions Code of Conduct. 297-323. Phnom Penh, Cambodia: John Wiley & Sons.

The Association of Banks in Cambodia. (2022). Cambodian Sustainable Finance Principles. *The Association of Banks in Cambodia*, pp. https://www.abc.org.kh/CSFI/sustainable-finance-initiative.

The Association of Banks in Cambodia. (2022). *Cambodian Sustainable Finance Principles.* Retrieved from https://www.abc.org.kh/CSFI/sustainable-finance-initiative

The Association of Banks in Cambodia, Cambodian Microfinance Association, Cambodian Association of Finance & Technology. (2022). *Guide for Implementation of the Lending Guidelines.* Retrieved from The Association of Banks in Cambodia: https://www.abc.org.kh/publication

The Council of Ministers. (2019, July 12). *National Financial Includion Strategy.* Retrieved from file:///C:/Users/Admin/Downloads/Telegram%20Desktop/Final_NFIS_in_English.pdf

ViZolution. (2020, July 23). *Consumer Trust in Banking: Why it Matters Now, More than Ever*. Retrieved from ViZolution: https://www.vizolution.com/blog/consumer-trust-in-banking/

Warren, S. E. (2016, September 21). *Senator Elizabeth Warren questions Wells Fargo CEO John Stumpf at Banking Committee Hearing*. Retrieved from Youtube: https://www.youtube.com/watch?v=xJhkX74D10M

Wattles, J., Geier, B., Egan, M., & Wiener-Bronner, D. (2018, April 24). *Wells Fargo's 20-month nightmare*. Retrieved from CNN Business: https://money.cnn.com/2018/04/24/news/companies/wells-fargo-timeline-shareholders/index.html

World Bank. (2017). *Financial Consumer Protection.* Retrieved from https://www.worldbank.org/en/home

World Bank. (2017). *Good Practices for Financial Consumer Protection.* Washington DC: World Bank Group.

Xavier, V. (2011). The Financial Industry and the Crisis: The Role of Innovation. In *Innovation. Perspectives for the 21st.* BBVA.

Yeung, S. (2011). The role of banks in corporate social responsibilities. *Journal of Applied Economics and Business Research*, 103-115.

Yi, Y., & Wang, S. (2021). Banks' maturity mismatch, financial stability, and macroeconomic dynamics. *Economic Research-Ekonomska Istraživanja*.

Zhang, A. (2016, January 28). *The Case of Goldman Sachs*. Retrieved from Seven Pillars Institute: www.sevenpillarsinstitute.org/the-case-of-goldman-sachs-and1mdb/

INSTITUTE OF BANKING AND FINANCE

Contact us:

- Phone: (+855) 23 224 313 / 61 626 902
- Email: cm@ibfkh.org
- Facebook: The Institute of Banking & Finance Cambodia
- Website: www.ibfkh.org
- Address: #10, Street 242, Chaktomuk, Daun Penh, Phnom Penh

9 789924 926993